ISSN 1560 9812

# ការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្ម

## ទស្សនៈស្តីពីការបង្កើតការងារនៅកម្ពុជា

ឯកសារពិភាក្សាលេខ ២៦

Sarthi Acharya គឹម សេដារា,
ចាប សុធារិទ្ធ និង មាច យ៉ាឌី

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រួមសហការជាមួយ វិទ្យាស្ថានខ្មែរសំរាប់ប្រតិបត្តិការ និងសន្តិភាព

ឯកសារ
ពិភាក្សា
លេខ ២៦

# ការងារក្រៅកសិដ្ឋាន
# និងការងារមិនមែនកសិកម្មៈ

## ទស្សនៈស្តីពីការបង្កើតការងារនៅកម្ពុជា

**ឯកសារពិភាក្សាលេខ ២៦**

**Sarthi Acharya,** គីម សេតារា, ចាប សុថារិទ្ធ និង មាច យ៉ាឌី

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
**សហការជាមួយ វិទ្យាស្ថានខ្មែរសំរាប់ប្រតិបត្តិការ និងសន្តិភាព**
**ខែកញ្ញា ឆ្នាំ២០០៣**

© រក្សាសិទ្ធិឆ្នាំ២០០៣ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីវិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

**ISSN 1560 9812**

**ការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្ម: ទស្សនៈស្ដីពីការបង្កើតការងារនៅកម្ពុជា**

**ឯកសារពិភាក្សាលេខ ២៦**

ខែកញ្ញា ឆ្នាំ២០០៣

Sarthi Acharya, គីម សេតារា, ចាប សុថារិទ្ធ និង មាច យ៉ាឌី

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ ។ ទស្សនៈទាំងនោះ មិនមែនជាទស្សនៈរបស់វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាទេ ។*

វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ ខណ្ឌទួលគោក ភ្នំពេញ កម្ពុជា (ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា)
ទូរស័ព្ទ: (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣) ៨៨០-៧៣៤
**អ៊ីមែល:** cdri@camnet.com.kh **website:** http://www.cdri.org.kh

វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព
វិមានរដ្ឋាភិបាល តិរវិថី សីសុវត្ថិ ភ្នំពេញ (ប្រអប់សំបុត្រលេខ ១០០៧ ភ្នំពេញ កម្ពុជា)
ទូរស័ព្ទ: (៨៥៥-២៣) ៧២២ ៧៥៩ ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣) ៣៦២ ៥២០
**អ៊ីមែល:** cicp@camnet.com.kh

បកប្រែដោយ: អ៊ុំ ចាន់ថា
កែសម្រួល និងរចនាដោយ: យូ សិទ្ធីរិទ្ធ និងអែម សូវ៉ានី
បោះពុម្ពនៅប្រទេសកម្ពុជា ដោយរោងពុម្ព JSRC ស្ថិតនៅក្នុងបរិវេណវិទ្យាល័យបឹងត្របែក រាជធានីភ្នំពេញ

# មាតិកា


សេចក្តីសង្ខេប ..... i

បញ្ជីអក្សរកាត់ ..... iii

សេចក្តីថ្លែងអំណរគុណ ..... v

**ជំពូកទី ១. សេចក្តីផ្តើម** ..... ១

**ជំពូកទី ២. ប្រវត្តិនៃសកម្មភាពក្រៅកសិដ្ឋាន និងមិនមែនកសិកម្ម** ..... ៣

២.១ សម័យដើមប្រវត្តិសាស្ត្រ ..... ៣

២.២ សម័យក្រោយអង្គរ ..... ៣

២.៣ សម័យអាណានិគមនិយមបារាំង (ពាក់កណ្តាលសតវត្សរ៍ទី១៩ ដល់ពាក់កណ្តាលសតវត្សរ៍ទី២០) ..... ៤

២.៤ ពីឆ្នាំ១៩៥៣ ដល់ទសវត្សរ៍១៩៨០ ..... ៥

២.៥ សង្ខេប ..... ៦

**ជំពូកទី ៣. ចំរុះកម្មមុខរបរនៅទសវត្សរ៍១៩៩០** ..... ៧

៣.១ ការវិភាគរបាយកំលាំងពលកម្ម ឆ្នាំ១៩៩៧-២000 ..... ៧

៣.២ ការប្រៀបធៀបអង្កេត SES ១៩៩៧ និង SES ១៩៩៩ ..... ១១

៣.៣ របាយសកម្មភាព ផ្អែកតាមជំរឿនឆ្នាំ១៩៩៨ ..... ១៣

៣.៤ របាយតាមតំបន់នៃការងារមិនមែនកសិកម្ម ..... ១៥

៣.៥ សង្ខេប ..... ១៧

**ជំពូកទី ៤. ការពិពណ៌នាពីមុខសកម្មភាពការងារនៅជនបទកម្ពុជា** ..... ១៩

៤.១ ម៉ាស៊ីនកិនស្រូវ ..... ១៩

៤.២ ការផ្គត់ផ្គង់អគ្គិសនីនៅជនបទ ..... ២០

៤.៣ នេសាទ និងការកែច្នៃត្រី ..... ២១

៤.៤ ការផលិតក្អមឆ្នាំង ..... ២៣

៤.៥ ផលិតកម្មឥដ្ឋ ..... ២៤

៤.៦ តម្បាញសូត្រ ..... ២៤

៤.៧ ក្រណាត់អំបោះត្បាញដោយកីសិប្បកម្ម ..... ២៥

៤.៨ វត្ថុសិល្បៈសិប្បកម្ម ........ ២៦

៤.៩ សង្ខេប ........ ២៧

**ជំពូកទី ៥. លក្ខណៈសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃ សហគមន៍ភាពជនបទជ្រើសរើសមួយចំនួននៅកម្ពុជា** ........ ២៩

៥.១ គំរូតាង ........ ២៩

៥.៣ ចំណាយជាមូលធន ........ ៣៤

៥.៤ ផលិតកម្ម និងផលិតភាព ........ ៣៨

៥.៥ ប្រាក់ចំណេញ និង ភាពមានចំណេញ ........ ៤១

៥.៦ ភាពមានចំណេញ និងទំហំ ........ ៤២

៥.៧ សង្ខេប ........ ៤៣

**ជំពូកទី ៦. ម៉ាឃីទិង និងខ្សែរយៈទីផ្សារ** ........ ៤៥

៦.១ ទីផ្សារ និង ការកំណត់ថ្លៃ ........ ៤៥

៦.២ ទំនាក់ទំនងដើមខ្សែ និងចុងខ្សែ ........ ៤៨

៦.៣ សង្ខេប ........ ៥៤

**ជំពូកទី ៧. គំនិតផ្តួចផ្តើមខាងគោលនយោបាយ និងទីផ្សារ** ........ ៥៧

៧.១ ការរៀបរាប់ពីគំនិតផ្តួចផ្តើមជ្រើសរើសមួយចំនួន ........ ៥៧

៧.២ សង្ខេប ........ ៦១

**ជំពូកទី ៨. សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ........ ៦៣

៨.១ ការអភិវឌ្ឍន៍តាមវិស័យ ........ ៦៤

៨.២ ម៉ាឃីទិង ........ ៦៤

៨.៣ បច្ចេកវិទ្យា និងទុនមនុស្ស ........ ៦៥

៨.៤ សេវាអភិវឌ្ឍន៍អាជីវកម្ម និងការពង្រឹងផ្នែកផ្គត់ផ្គង់ ........ ៦៦

៨.៥ ហិរញ្ញវត្ថុ ........ ៦៧

**ឯកសារយោង** ........ ៦៩

**បញ្ជីឯកសារពិភាក្សារបស់ វបសអ** ........ ៧៣

# បញ្ជីតារាង និងក្រាហ្វិក

## បញ្ជីក្រាហ្វិក


ក្រាហ្វិក៣.១ សមាមាត្រពលករបុរស ក្នុងវិស័យមិនមែនបឋម នៅក៏រិតស្រុក នៅឆ្នាំ១៩៩៨........................................ ១៦

ក្រាហ្វិក៣.២ សមាមាត្រពលករស្ត្រី ក្នុងវិស័យមិនមែនបឋម នៅក៏រិតស្រុក នៅឆ្នាំ១៩៩៨........................................ ១៦

ក្រាហ្វិក៦.១ ទំនាក់ទំនងដើមខ្សែ និងចុងខ្សែ នៅក្នុងប្រតិបត្តិការនេសាទ ........................................ ៤៩

ក្រាហ្វិក៦.២ ទំនាក់ទំនងដើមខ្សែ និងចុងខ្សែនៅក្នុងផលិតកម្មសូត្រ........................................ ៥០

ក្រាហ្វិក៦.៣ ទំនាក់ទំនងដើមខ្សែ និងចុងខ្សែ ក្នុងផលិតកម្មតំបាញអំបោះ ........................................ ៥១

ក្រាហ្វិក៦.៤ ទំនាក់ទំនងដើមខ្សែ និងចុងខ្សែ ក្នុងផលិតកម្មក្ដួមឆ្នាំង........................................ ៥២

ក្រាហ្វិក៦.៥ ទំនាក់ទំនងដើមខ្សែ និងចុងខ្សែ ក្នុងសិប្បកម្មថ្មម៉ាប........................................ ៥៣

ក្រាហ្វិក៦.៦ ទំនាក់ទំនងដើមខ្សែ និងចុងខ្សែ នៅក្នុងផលិតកម្មឥដ្ឋក្បឿង........................................ ៥៤


## បញ្ជីតារាង


តារាង៣.១ ភាគរយរបាយកម្មករ, ចំណាត់ថ្នាក់មានលេខពីរខ្ទង់នៃមុខសកម្មភាពសំរាប់ ........................................ ៩

តារាង៣.២ ការងារ និងបំរែបំរួលការងារ តាមក្រុមសកម្មភាពនៅតំបន់ជនបទឆ្នាំ១៩៩៧-៩៩........................................ ១១

តារាង៣.៣ ការងារនៅក្នុងក្រុមសកម្មភាពជាក់លាក់មួយចំនួននៅឆ្នាំ១៩៩៨........................................ ១៣

តារាង៣.៤ មធ្យមភាគការងារជាភាគរយ នៅក្នុងវិស័យទាំង ១៧ : មធ្យមភាគ និងមេគុណបំរែបំរួល........................................ ១៧

តារាង៣.៥ សមាមាត្រការងារ គិតតាម ១៥វិស័យសកម្មភាពចំបងៗ និងគិតតាមខេត្តនិមួយៗ........................................ ១៨

តារាង៥.១ ពត៌មានលំអិតលើគំរូតាង........................................ ៣០

តារាង៥.២ របាយគ្រួសារតាមការកាន់កាប់ដី ........................................ ៣០

តារាង៥.៣ ទំហំចំណូលទទួលបានពីសកម្មភាពមិនមែនកសិកម្ម (របាយសហគ្រាសតាមមុខសកម្មភាព)........................................ ៣១

តារាង៥.៤ ចំនួនឆ្នាំ តាំងពីសហគ្រាសចាប់ផ្ដើមប្រតិបត្តិការ (របាយសហគ្រាសតាមមុខសកម្មភាព) ........................................ ៣១

តារាង៥.៥ ចំនួនកម្មករសរុប (របាយសហគ្រាសតាមមុខសកម្មភាព)........................................ ៣២

តារាង៥.៦ ចំនួនភាគរយជាមធ្យមនៃកម្មករស៊ីឈ្នួល និង ប្រាក់កំរៃជាមធ្យម (តាមមុខសកម្មភាព) ........................................ ៣៣

តារាង៥.៧ ប្រភពនៃការទទួលបានជំនាញសំរាប់កម្មករ (របាយសហគ្រាសតាមមុខសកម្មភាព)........................................ ៣៤

តារាង៥.៨ ទំហំទ្រព្យសកម្មជាប់លាប់ (របាយសហគ្រាសតាមមុខសកម្មភាព) ........................................ ៣៥

តារាង៥.៩ របៀបធ្វើលទ្ធកម្មទ្រព្យសកម្មជាប់លាប់ (របាយសហគ្រាសតាមមុខសកម្មភាព)........................................ ៣៦

តារង៥.១០ អនុបាតមូលធន-ពលកម្ម (តាមមុខសកម្មភាព)........................................ ៣៧

តារាង៥.១១ របាយសហគ្រាសតាមទំហំផលិតកម្ម, មធ្យមភាគផលិតកម្ម, និង មធ្យមភាគតំលៃបន្ថែម........................៣៩
តារាង៥.១២ អនុបាត ធាតុចេញ-ពលកម្ម, តំលៃបន្ថែម-ពលកម្ម, និង មូលធន-ធាតុចេញ........................................៤០
តារាង៥.១៣ អនុបាតភាពមានចំណេញ (គិតជារៀល)........................................................................................ ៤១
តារាង៦.១ វិធីលក់ផលិតផលទៅទីផ្សារ.........................................................................................................៤៥
តារាង៦.២ ចំណាប់អារម្មណ៍អំពី អ្នកណាត្រួតត្រាលើថ្លៃធាតុចេញ........................................................................ ៤៦
តារាង៦.៣ តើអ្នកផ្គត់ផ្គង់ធាតុចូល ជាអ្នកទិញធាតុចេញដែរឬយ៉ាងណា................................................................ ៤៦
តារាង៦.៤ ពេលវេលានៃការទូទាត់ គិតតាមរបាយគ្រួសារ ................................................................................. ៤៧

# សេចក្តីសង្ខេប

នៅជនបទកម្ពុជា ជម្រើសនានាដើម្បីរក្សាជីវភាពរស់នៅឱ្យមានចីរភាព គឺមានតែការធ្វើកសិកម្មជីវព្រឹត្តិប៉ុណ្ណោះ ដោយហេតុផលខាងប្រវត្តិសាស្ត្រជាសំខាន់ ។ កិច្ចប្រឹងប្រែងធ្វើទំនើបកម្មសេដ្ឋកិច្ចក្នុងអំឡុងទសវត្សរ៍១៩៥០ និង ១៩៦០ បានផ្តល់លទ្ធផលជាផ្លែផ្កាមួយចំនួន ប៉ុន្តែផលប៉ះពាល់ពិតៗ មានតែនៅតាមតំបន់ទីក្រុងមួយចំនួនតូចប៉ុណ្ណោះ ។ ក្នុងទសវត្សរ៍១៩៨០ និង ១៩៩០ សកម្មភាពខ្លះបានរីកដុះដាលទៅដល់តំបន់ជនបទ និងសកម្មភាពដែលមានស្រាប់ខ្លះ ដូចជា ការនេសាទ ជាដើម ត្រូវបានរៀបចំឱ្យកាន់តែរៀបរយឡើង ។ ទោះយ៉ាងនេះក្តី រហូតមកដល់សព្វថ្ងៃ សេដ្ឋកិច្ចមិនមែនកសិកម្មនៅជនបទ មិនទាន់រីកចំរើនដល់ទំហំមួយដែលអាចមានផលប៉ះពាល់ទៅលើរចនាសម្ព័ន្ធនៃការងារនៅជនបទទេ ។ ការសិក្សានេះកើតឡើងពីភាពចាំបាច់នៃការបង្កើតការងារផ្សេងៗឱ្យបានច្រើន និងចំរុះមុខ នៅក្នុងសេដ្ឋកិច្ចអន្តរកាលរបស់កម្ពុជា ដើម្បីកាត់បន្ថយភាពក្រីក្រ ភាពគ្មានការងារធ្វើ និងភាពមានការងារមិនពេញលទ្ធភាព ។

នៅខែមីនា ២០០៣ បណ្តាញវិភាគអភិវឌ្ឍន៍បានបោះពុម្ពឯកសារមួយស្តីពីការសិក្សាតាមប្រទេស ដែលមានចំណងជើងថា "ការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្មក្នុងសេដ្ឋកិច្ចអន្តរកាលនានានៅអាស៊ីអគ្នេយ៍ និងនៅប្រទេសថៃ" និងដែលមាន ជំពូកមួយស្តីពីកម្ពុជា ហើយជំពូកនេះបានដកស្រង់យកមកចងក្រងជាឯកសារពិភាក្សានេះ ។ ក្នុងជំពូកទី២ ឯកសារនេះអធិប្បាយពីមូលដ្ឋានប្រវត្តិសាស្ត្រ និងស្ថានភាពពិតនៃសកម្មភាពក្រៅកសិដ្ឋាននិងមិនមែនកសិកម្មផ្សេងៗដែលមាននៅកម្ពុជា ។ ជំពូកទី៣ ពិនិត្យទៅលើ ទិន្នន័យដែលមានស្រាប់ និងដែលទទួលបានពីប្រភពទី២ ដើម្បីបង្ហាញរូបភាពនៃសកម្មភាពមិនមែនកសិកម្មក្នុងពេលសព្វថ្ងៃ ។ ជំពូកទី៤ មានបកស្រាយលំអិតពីស្ថានភាពនៃឧស្សាហកម្មជនបទនៅកម្ពុជា ដោយផ្អែកលើការសិក្សាដល់ទីកន្លែង និងបំពេញបន្ថែមដោយ ឯកសារដែលមានស្រាប់នានាស្តីពីឧស្សាហកម្មជាក់លាក់មួយចំនួន ។ ជំពូកទី៥ ធ្វើការពិភាក្សាពីកត្តាខាងហិរញ្ញវត្ថុនិងសេដ្ឋកិច្ចនានាដោយផ្អែកលើអង្កេតលើ ២៧៦សហគ្រាស ស្ថិតក្នុង ៧ក្រុមឧស្សាហកម្ម ។ ជំពូកទី៦ ពិភាក្សាទៅលើទំនាក់ទំនងទីផ្សារនៃសហគ្រាសទាំងនេះ ។ ជំពូកទី៧ បង្ហាញដោយសង្ខេបពីគោលនយោបាយនានាដែលមានស្រាប់ រួមទាំងគោលនយោបាយលើការបណ្តុះបណ្តាលផង ។ សេចក្តីសន្និដ្ឋានរួមមានចុះនៅក្នុងជំពូកទី៨ ។

ឯកសារនេះផ្តល់ការសង្ឃឹមថា នឹងអាចក្លាយជាឯកសារយោងដ៏សំខាន់សំរាប់អ្នកវិភាគគោលនយោបាយ និងអ្នកធ្វើសេចក្តីសំរេចនានា ទាំងនៅក្នុង និងនៅក្រៅរដ្ឋាភិបាល ហើយអាចមានប្រយោជន៍ជាពិសេសសំរាប់ អ្នកជួយផ្តល់យោបល់ពិគ្រោះ ឬអ្នកធ្វើការជាមួយនឹងសកម្មភាពក្រៅកសិដ្ឋាន និងសកម្មភាពមិនមែនកសិកម្មផ្សេងៗនៅកម្ពុជា ។

*ភ្នំពេញ, ខែកុម្ភៈ ២០០២*

*Eva Mysliwiec*

*នាយិកា វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

# បញ្ជីអក្សរកាត់

| | |
|---|---|
| ACLEDA | សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ហៅកាត់ថា *អេស៊ីលីដា* (Association of Cambodian Local Economic Development Agencies) |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank) |
| ASEAN | សមាគមប្រជាជាតិអាស៊ីអគ្នេយ៍ (Association of Southeast Asian Nations) |
| BDS | សេវាអភិវឌ្ឍន៍ពាណិជ្ជកម្ម (Business Development Services) |
| CARERE | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ/គំរោងស្តារ និងបង្កើតតំបន់ឡើងវិញ (Cambodia Area Rehabilitation and Regeneration) |
| EDC | ការអភិវឌ្ឍន៍សហគ្រិនភាពនៃកម្ពុជា (Enterpreneurship Development of Cambodia) |
| GDP | ផលិតផលក្នុងស្រុកសរុប (Gross Domestic Product) |
| ILO | អង្គការពលកម្មអន្តរជាតិ (International Labour Organisation) |
| KOC | ព្រះរាជាណាចក្រកម្ពុជា (Kingdom of Cambodia) |
| LFS | អង្កេតកំលាំងពលកម្ម (Labour Force Survey) |
| MPDF | កម្មវិធីអភិវឌ្ឍន៍គំរោងតំបន់ទន្លេមេគង្គ (The Mekong Project Development Facility) |
| REE | សហគ្រាសអគ្គិសនីជនបទ (Rural Electrical Enterprises) |
| NGO | អង្គការក្រៅរដ្ឋាភិបាល (Non-Government Organisation) |
| PRASAC | កម្មវិធីទ្រទ្រង់វិស័យកសិកម្មនៅកម្ពុជា (Support Programme for the Agriculture Sector in Cambodia) |
| PRSP | ឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (Poverty Reduction Strategy Paper) |
| SEATE | សេដ្ឋកិច្ចអន្តរកាលនៅអាស៊ីអគ្នេយ៍ (South East Asian Transitional Economy) |
| SEDP | ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច (Socio-economic Development Plan) |
| SES | អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច (Socio-economic Survey) |
| SME | សហគ្រាសធុនតូច និងមធ្យម (Small and Medium Size Enterprise) |
| UNTAC | អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជា (United Nations Transitional Authority in Cambodia) |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក (World Trade Organisation) |

# សេចក្តីថ្លែងអំណរគុណ

ក្រុមអ្នកនិពន្ធ សូមសម្តែងនូវការដឹងគុណដល់អ្នកឆ្លើយសំភាន៏ទាំងអស់ ដែលបានចំណាយពេលវេលាផ្តល់ចម្លើយចំពោះសំនួរទាំងអស់របស់យើងខ្ញុំ ។ ក្រុមអ្នកនិពន្ធក៏សូមថ្លែងអំណរគុណដល់ មន្ត្រីអង្គការក្រៅរដ្ឋាភិបាល និង មន្ត្រីរដ្ឋាភិបាល ដែលបានផ្តល់ការសំភាសន៏ និងពតិមានទាំងឡាយដល់ក្រុមអ្នកស្រាវជ្រាវ ។ ក្រុមអ្នកនិពន្ធសូមថ្លែងអំណរគុណជាពិសេសដល់លោក សូ សុវណ្ណារិទ្ធ លោកស្រី ប៉ុន ដូរីណា និង កញ្ញា ទុយ ចរិយា បានជួយដឹកនាំការងារក្នុងពេលចុះស្រាវជ្រាវដល់ទីកន្លែង ។ ក្រុមអ្នកនិពន្ធសូមសូមសំដែងកតញ្ញូតាធមិដល់លោកស្រី អេវ៉ា មីស្លីវិក និងលោក គិម-យ៉ាត ដារារិទ្ធ ចំពោះការជួយទ្រទ្រង់ខាងភស្តុភារ និងផ្តល់លទ្ធភាពទូលាយអាចបត់បែនបាន ដល់ដំណើរការសិក្សានេះ ។

ជាទីបញ្ចប់ ក្រុមអ្នកនិពន្ធ និង វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា សូមថ្លែងការដឹងគុណដល់មជ្ឈមណ្ឌលស្រាវជ្រាវអន្តរជាតិ-កាណាដា និងមូលនិធិ Rockefeller ដែលបានផ្តល់នូវជំនួយគាំទ្រដ៏សប្បុរសដល់គំរោងស្រាវជ្រាវនេះ ។

*ភ្នំពេញ, ខែកុម្ភៈ ២០០៣*

*Sarthi Acharya, គីម សេតារា, ចាប សុថារិទ្ធ និង មាច យ៉ាឌី*

# ជំពូកទី ១

# សេចក្តីផ្តើម

នៅពេលដែលសេដ្ឋកិច្ចកម្ពុជា ចាប់បើកចំហនៅដើមទសវត្សរ៍១៩៩០ ប្រជាជនកម្ពុជាប្រកបការងារជាសំខាន់ក្នុងកសិកម្មជីវព្រឹត្ត (សំរាប់មួយរស់) និងសកម្មភាពជាប់ទាក់ទិនផ្សេងៗដែលរួមមានខាងរុក្ខាប្រមាញ់ និងនេសាទ ។ ភាគច្រើននៃកំលាំងពលកម្ម នៅតែធ្វើការក្នុងវាលស្រែនៅរដូវវស្សារាដដែល ហើយពួកគេនេសាទ និងកាប់យកឈើពីព្រៃនៅរដូវប្រាំង ។ ដោយសារប្រជាជនដ៏ច្រើនលើសលុបប្រមូលផ្តុំនៅតាមតំបន់ជុំវិញបឹងទន្លេសាបនិងតំបន់អាងទន្លេមេគង្គ ដូច្នេះភាគច្រើនអាចរកធនធានត្រីបាន ។ តាំងពីដើមរៀងមក ប្រជាជននៅតំបន់ខ្ពង់រាបតែងពឹងផ្អែកលើធនធានព្រៃឈើ ជាបន្ថែមទៅលើការងារដាំដុះនៅរដូវវស្សា ។ ប៉ុន្តែធនធានព្រៃឈើក៏មានសារៈសំខាន់សំរាប់សហគមន៍នៅតាមកន្លែងផ្សេងទៀតនៃប្រទេសកម្ពុជាដែរ ។

បន្ទាប់ពីកសាងសន្តិភាពបានឡើងវិញនៅឆ្នាំ១៩៩២-៩៣, សេដ្ឋកិច្ចបានកើនឡើងយ៉ាងរហ័ស (អត្រាកំណើន ២លេខ) ពីឆ្នាំ១៩៩២-១៩៩៧ និងកើនឡើងល្អបង្គួរពីឆ្នាំ១៩៩៨-២០០១ (អត្រាកំណើនមធ្យមលើសពី ៥-៦%/ឆ្នាំ ក្នុងរយៈ ១០ឆ្នាំមកទល់ចុងឆ្នាំ២០០១) ។ ម្យ៉ាងទៀតមានការធ្វើចំរុះកម្មគួរកត់សំគាល់នៅក្នុងមូលដ្ឋានផលិតកម្ម ក្នុងនេះមានជាង ២០០ រោងចក្រកាត់ដេរត្រូវបានកកើតឡើងនៅក្នុងទសវត្សរ៍១៩៩០ និងមានវិនិយោគគួរចាប់អារម្មណ៍មួយចំនួនខាងផ្នែកសណ្ឋាគារ សកម្មភាពសំណង់ និងវិស័យទូរគមនាគមន៍ផងដែរ ។ ប្រទេសកម្ពុជា បានចូលជាសមាជិកពេញសិទ្ធិអាស៊ាន និងបានឈានទៅមុខច្រើនហើយក្នុងការសុំចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក នៅឆ្នាំ២០០៥ ។ ទេសចរមកទស្សនាកម្ពុជា បានកើនចំនួនជារៀងរាល់ឆ្នាំ ទោះជាមានការធ្លាក់ចុះក្នុងពេលថ្មីៗនៃសេដ្ឋកិច្ចអន្តរជាតិក៏ដោយ ។ ទីក្រុងសំខាន់ៗ បានរីកធំថែមទៀត ហើយហេដ្ឋារចនាសម្ព័ន្ធនៃទីក្រុងទាំងនេះ ក៏មានការអភិវឌ្ឍន៍ដែរ ។ មជ្ឈមណ្ឌលបីដែលរីកលូតលាស់ខ្លាំងជាងគេគឺ ក្រុងភ្នំពេញ ក្រុងព្រះសីហនុ និងខេត្តសៀមរាប ។

បញ្ហាចំបងមួយដែលបន្តរាំងស្ទះដល់សេដ្ឋកិច្ច គឺមូលដ្ឋានការងារហាក់ដូចជាចង្អៀតបន្តិច ។ ទោះបីមានកំណើនយ៉ាងលឿនដូចបានលើកខាងលើក្តី ក៏ការបង្កើតការងារក្រៅពីកសិកម្មជីវព្រឹត្ត មានតិចតួចនៅឡើយ ។ នៅឆ្នាំ២០០១ តាមការប៉ាន់ស្មាន កំលាំងពលកម្មសរុបនៅកម្ពុជា មានប្រមាណ ៥,៦៣លាននាក់ ។ ក្នុងនេះ មាន ៤,៣៥លាននាក់ (៧៧,២៦%) ប្រកបការងារក្នុងកសិកម្ម ។ ទំហំកំលាំងពលកម្មក្នុងវិស័យផ្លូវការ (ការងារមានប្រាក់ឈ្នួលទៀងទាត់) មាន ៥% នៃកំលាំងពលកម្មសរុប ឬ ០,២៨លាននាក់ ។ រូបភាពនេះគ្មានប្រែប្រួលទេក្នុងអំឡុងទសវត្សរ៍១៩៩០ ។ ក្នុងចំនោមពលករ ២០០.០០០នាក់ ដែលចូលទៅក្នុងកំលាំងពលកម្មក្នុងមួយឆ្នាំៗ មានតែ ១៥.០០០នាក់ប៉ុណ្ណោះ ដែលទទួលបានការងារនៅក្នុងវិស័យផ្លូវការ ហើយសល់ពីនេះត្រូវចូលធ្វើការក្នុងវិស័យមិនផ្លូវការ ជាពិសេសកសិកម្មជីវព្រឹត្ត ។ គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេដែលអត្រាកំណើនចំណូលជាតិលើសពី ៦%/ឆ្នាំ (មធ្យមភាគ ១៩៩៣-៩៩) អាចកាត់បន្ថយភាពក្រីក្របានតែ ៣% ប៉ុណ្ណោះក្នុងរយៈពេលនោះ[១] ។ ការពង្រីកលក្ខខណ្ឌធ្វើការងារឱ្យសមរម្យ សំរាប់កំលាំងពលកម្មមានស្រាប់ និងទើបចូលថ្មី គឺជាបញ្ហាប្រឈមមួយគួរកត់សំគាល់ ។

---

[១] សំរាប់រាល់កំណើន ១០% ក្នុងចំណូលជាតិ, ភាពក្រីក្រត្រូវបានកាត់បន្ថយត្រឹមតែ ១,៤% (Acharya) ។

ក្នុងពេលបច្ចុប្បន្ន ប្រទេសកម្ពុជាជួបបញ្ហាជាច្រើនដែលរាំងស្ទះដល់ការដោះស្រាយភាពក្រីក្រ និងភាពគ្មានការងារធ្វើនៅជនបទ ។ ទី១ សកម្មភាពសេដ្ឋកិច្ចថ្មី មិនទាន់មានការរីកចំរើនតាមបែបបទ ឬទៅតាមល្បឿនមួយដែលអាចមានឥទ្ធិពលទៅលើរចនាសម្ព័ន្ធការងារនោះទេ[២] ។ កាលណាអាចបង្កើតការងារបាន ស្ទើរតែទាំងអស់គឺជាការងារនៅតាមតំបន់ទីក្រុង[៣] ។ ទី២ សញ្ជ័យក្នុងស្រុក ពុំមានទំហំ ឬស្ថិរភាពគ្រប់គ្រាន់ទេ សំរាប់ផ្ដល់ទុន និងទ្រទ្រង់សកម្មភាពក្រៅកសិកម្មនានា ។ ជំរើសមួយទៀតគឺ ទុនពីបរទេស ប៉ុន្តែទុននេះតែឯង មិនអាចក្លាយជាក្បាលម៉ាស៊ីននៃកំណើនបានទេ ។ ទី៣ វិនិយោគនានា (ទោះជាវិនិយោគក្នុងស្រុក ឬ បរទេស ក្ដី) តំរូវឱ្យមានហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្សក្នុងស្រុកមានការបណ្ដុះបណ្ដាលឱ្យបានច្រើនគ្រប់គ្រាន់ និងមានថ្លៃសមរម្យ ។ ទី៤ គឺបញ្ហាអភិបាលកិច្ចខ្សោយ ដែលត្រូវមានការអភិវឌ្ឍន៍ច្រើនណាស់ ។ បញ្ហាទាំងអស់នេះបង្ហាញពីតំរូវការបង្កើនល្បឿនកំណែទំរង់ និងផ្ដួចផ្ដើម ឬជួយទ្រទ្រង់ដល់សកម្មភាពនានាដែលអាចផ្ដល់ការងារបានច្រើន ដែលត្រូវបានដាក់ពង្រាយនៅគ្រប់តំបន់ និងដែលត្រូវការដើមទុនតូចគួរសមដើម្បីរីកលូតលាស់ ។

សំណើមួយដែលកំពុងពេញនិយមក្នុងសន្និសីទអន្តរជាតិ គឺការលើកកំពស់សកម្មភាពនៅក្នុងវិស័យក្រៅផ្លូវការនៅតាមជនបទ ក៏ដូចនៅតាមតំបន់ទីក្រុងនានា[៤] ។ ការធ្វើចំរុះកម្មមុខរបរនៅតាមជនបទមានអត្ថប្រយោជន៏ជាច្រើន ហើយមានឯកសារច្រើនណាស់ដែលបានសិក្សាលំអិតពីផលចំណេញទាំងនេះ (Saith 1992; Islam 1983) ។ ប៉ុន្តែការលើកកំពស់សកម្មភាពក្រៅផ្លូវការនៅជនបទតាមវិស័យ (សកម្មភាពក្រៅកសិដ្ឋាន និងមិនមែនកសិកម្ម) ទាមទារការស្វែងរកមើលសកម្មភាពទាំងនេះការពង្រឹងមូលដ្ឋានសេដ្ឋកិច្ចបច្ចេកទេសរបស់វា និងការបង្កើតច្រកទីផ្សារ ។

ឯកសារនេះត្រូវបានតាក់តែងឡើងក្នុងស្មារតីបំផុសឱ្យឃើញបញ្ហា គឺបានន័យថា ឯកសារនឹងព្យាយាមបញ្ជាក់ពី ទំហំ និងទ្រង់ទ្រាយនៃសកម្មភាពក្រៅកសិដ្ឋាន និងមិនមែនកសិកម្ម ជាជាងផ្ដល់មតិតែមួយមុខអំពីមធ្យោបាយដើម្បីលើកកំពស់សកម្មភាពទាំងនេះ ។ រឿងនេះគឺដោយសារគ្មានការធ្វើអង្កេត ឬជំរឿនថ្មីៗ លើគ្រឹះស្ថានអាជីវកម្មក្នុងប្រទេសកម្ពុជា[៥] ។ របាយការណ៏គ្រប់ជ្រុងជ្រោយតាមវិស័យសកម្មភាពផ្សេងៗ ក្រៅពីសហគ្រាសផលិតកម្ម ឬខាងទេសចរណ៏ធំៗ មិនទាន់មានធ្វើនៅឡើយទេ ។ ដូច្នេះ គឺមានតំរូវការដ៏ធំធេងនៃការធ្វើជំរឿនគ្រឹះស្ថានយ៉ាងលំអិតមួយ ហើយឯកសារនេះគឺជាជំហានដំបូងក្នុងគោលដៅនេះហើយ ។ នៅជំពូកទី ២ ឯកសារនេះព្យាយាមតាមដានមូលដ្ឋានប្រវត្តិសាស្ត្រ និងមូលដ្ឋានពិតជាក់ស្ដែងនៃសកម្មភាពក្រៅកសិដ្ឋាន និងមិនមែនកសិកម្មផ្សេងៗ ដែលធ្លាប់មាននៅកម្ពុជា ។ ជំពូកទី៣ ពិនិត្យទៅលើទិន្នន័យដែលមានស្រាប់ និងដែលទទួលបានពីប្រភពទី២ ដើម្បីបង្ហាញរូបភាពនៃសកម្មភាពមិនមែនកសិកម្មក្នុងពេលបច្ចុប្បន្ន ។ ជំពូកទី៤ មានបកស្រាយលំអិតពីស្ថានភាពនៃឧស្សាហកម្មជនបទនៅកម្ពុជា ដោយផ្អែកលើការសិក្សាដល់ទីកន្លែង និងបំពេញបន្ថែមដោយឯកសារដែលមានស្រាប់នានាស្ដីពីឧស្សាហកម្មជាក់លាក់មួយចំនួន ។ ជំពូកទី៥ ធ្វើការពិភាក្សាពីកត្តាខាងហិរញ្ញវត្ថុនិងសេដ្ឋកិច្ចនានា ដោយផ្អែកលើអង្កេតលើ ២៧៦សហគ្រាស ស្ថិតក្នុង ៧ក្រុមឧស្សាហកម្ម ។ ជំពូកទី៦ ពិភាក្សាទៅលើទំនាក់ទំនងទីផ្សារនៃសហគ្រាសទាំងនេះ ។ ជំពូកទី៧ បង្ហាញដោយសង្ខេបពីគោលនយោបាយនានាដែលមានស្រាប់ រួមទាំងគោលនយោបាយលើការបណ្ដុះបណ្ដាលផង ។ សេចក្ដីសន្និដ្ឋានរួមមានចុះនៅក្នុងជំពូកទី៨ ។

---

[២] ឧស្សាហកម្មកាត់ដេរ បានបង្កើតការងារផ្លូវការច្រើនជាងគេ ។ ពីឆ្នាំ១៩៩៣-២001 មានប្រហែល ២00.000ការងារត្រូវបានបង្កើតឡើង ប៉ុន្តែតួលេខនេះស្មើនឹងជាង ៣% បន្តិចនៃអ្នកមានការងារធ្វើប៉ុណ្ណោះ ។ ក៏រិតប្រាក់កំរៃមិនទាន់ខ្ពស់គ្រប់គ្រាន់ អាចមានឥទ្ធិពលទៅលើរចនាសម្ព័ន្ធចំណាយនៅតាមជនបទទេ ។

[៣] ផ្ទុយទៅវិញ ប្រជាជនជាង ៨0% មានលំនៅដ្ឋាននៅជនបទ (RGC 1999) ។ ដូច្នេះការងារមិនបានកើតមានតាមកន្លែងមានតំរូវការទេ ។

[៤] អង្គការពលកម្មអន្តរជាតិបានដឹកនាំការពិភាក្សានេះ ។ សូមអាន ILO (1999); ILO (2000); ILO (2001) ។

[៥] ជំរឿនគ្រឹះស្ថានទូទាំងប្រទេសចុងក្រោយ បានធ្វើឆ្នាំ១៩៩៥ ហើយបានស្រង់ពត៌មានតែលើគ្រឹះស្ថានធំៗប៉ុណ្ណោះ ។ គេគ្មានពត៌មានអ្វីច្រើនទេពីអង្កេតថ្មីៗដោយក្រសួងផែនការ ជំនួយពី ABD ក្រៅពីពត៌មានថា អង្កេតនោះបានផ្ដោតដូចមុនដែរលើគ្រឹះស្ថានធំៗក្នុងតំបន់ក្រុង ។

# ជំពូកទី ២

# ប្រវត្តិនៃសកម្មភាពក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្ម

## ២.១ សម័យដើមប្រវត្តិសាស្ត្រ

តាំងពីដើមរៀងមក សង្គមកម្ពុជាមានជំនាញច្រើនណាស់ខាងផ្នែកវិស្វកម្មស៊ីវិល ការជីកលើកដី ប្រព័ន្ធទុបទឹក និងបង្ហូរទឹកតាំងពីជាង ១.000ឆ្នាំ ដូចមានភស្តុតាងបញ្ជាក់នៅលើប្រាសាទអង្គរ (Rooney 2000) ។ មានភស្តុតាងគ្រប់គ្រាន់ដែរសំរាប់បញ្ជាក់ថា សង្គមខ្មែរក្តាប់បានច្បាស់លាស់នូវបច្ចេកវិទ្យារំលាយដែក ការចាក់ពុម្ពធ្វើប្រាក់កាស គ្រឿងស្និតជារាងមនុស្ស និងឧបករណ៍ប្រើប្រាស់ធម្មតា តាំងពីក្នុងសហសវត្សរ៍ទី១ នៃគ្រិស្តសករាជ ។ មធ្យោបាយដឹកជញ្ជូន ដែលអាចដឹករបស់របរបានច្រើនៗ ជាពិសេសទឹក និងថ្មធំៗ ត្រូវបានអភិវឌ្ឍន៍ ហើយវាជួយសំរួលដល់ការកសាងប្រាសាទអង្គរ និងបណ្តារចនាសម្ព័ន្ធដ៏ធំសំបើមផ្សេងៗរបស់ប្រាសាទ ។ លើសពីនេះ ស្ថាបត្យកម្មអង្គរបានបញ្ជាក់ថា ខ្មែរសម័យដើមមានចំណេះដឹងផ្នែកតារាសាស្ត្រ ភូមិវិទ្យា និងមែកធាងផ្សេងទៀតនៃគណិតសាស្ត្រ ។ គេដឹងមិនច្បាស់ទេថា តើខ្មែរសម័យដើមបានប្រើជំនាញទាំងនេះ ដើម្បីអភិវឌ្ឍន៍សកម្មភាពមិនមែនកសិកម្ម ប៉ុន្តែភស្តុតាងដ៏តិចតួចដែលរកឃើញ បានបង្ហាញថា ក្រៅពីការកសាងសំណង់វិស្វកម្មស៊ីវិលធំៗសំរាប់ដឹកជញ្ជូនទឹក, ជំនាញទាំងនោះគេបានប្រើប្រាស់សឹងតែសុទ្ធសាធសំរាប់កសាងប្រាង្គប្រាសាទ និងកំពែងការពារប្រាសាទ ។ ម្យ៉ាងទៀត ដោយសារចក្រភពខ្មែរនៅយុគកណ្តាល មានវិសាលភាពធំធេងជាងព្រំដែនបច្ចុប្បន្ន ជំនាញទាំងនេះប្រហែលជាប្រើប្រាស់ ដើម្បីធ្វើគ្រឿងអាវុធ បរិក្ខារដឹកជញ្ជូនទ្រង់ទ្រាយធំ ការកែច្នៃម្ហូបអាហារ និងបង្ហឹកសត្វអូសទាញ ។

## ២.២ សម័យក្រោយអង្គរ

គេគ្មានពត៌មានច្រើនទេលើប្រវត្តិសាស្ត្រខ្មែរ ក្នុងចន្លោះពេលរវាងការដួលរលំក្រុងអង្គរនៅសតវត្សរ៍ទី១៤ និងសតវត្សរ៍ទី១៩ ។ Chandler (1993) និង Tarling (1999) បានអះអាងថា នៅពាក់កណ្តាលខាងដើមនៃសតវត្សរ៍ទី១៩ កម្ពុជាត្រូវបំផ្លិចបំផ្លាញដោយគ្រោះទុរ្ភិក្ស និងកងទ័ពឈ្លានពាន ។ ជាលទ្ធផល ប្រជាជនកម្ពុជាបានថយចុះ[៦] ហើយរស់នៅជាសំខាន់តាមតំបន់ជនបទ និងប្រកបរបរធ្វើស្រែ ។ ជនជាតិភាគតិច ដូចជា ចិន ខ្មែរកាត់ចិន និងចាម ជាអ្នកគ្រប់គ្រងទីផ្សារ ធ្វើច្បារដំណាំមិនមែនស្រូវ តម្បាញ និងនេសាទជាលក្ខណៈពាណិជ្ជកម្ម (Willmott 1977) ។ កំណត់ត្រាពីការធ្វើពាណិជ្ជកម្មនៅសតវត្សរ៍ទី១៩ បង្ហាញថា ពាណិជ្ជកម្មអន្តរជាតិអនុវត្តតែលើទំនិញជាផលិតផលកសិកម្ម និងផលិតផលយកពីសត្វ ដូចជា ភ្លុក ម្រេច ក្រវាញ ស្បែក និងឈើ ហើយវាមានចំនួនតូចៗទេ[៧] ។ សង្គ្រាមមិនចេះចប់ គ្រោះធម្មជាតិ ចលនាប្រជាជន បានជះឥទ្ធិពលមិនល្អ ក្នុងរូបភាពជា

---

[៦] ប្រភពទាំងនេះអះអាងថា ប្រជាជនកម្ពុជានៅទសវត្សរ៍១៨៤0 មានមិនលើសពីមួយលាននាក់ទេ ។

[៧] ភូគព្ភនយោបាយ (geopolitics) នៅពេលនោះមិនបើកដៃឱ្យពាណិជ្ជកម្មរីកលូតលាស់ទេ បើពុំនោះទេវានឹងអាចនាំមកនូវជំរើសអភិវឌ្ឍន៍ថ្មីៗចូលមកក្នុងប្រទេស ។ ជាក់ស្តែងប្រទេសកម្ពុជាត្រូវបានកាត់ផ្តាច់ពីពិភពលោក ។

ការបាត់បង់ជំនាញនៅក្នុងសង្គម ធ្វើឱ្យប្រជាជនធ្លាក់ខ្លួនជាកសិករជីវព្រឹត្ត ។ ទាក់ទិននឹងរឿងរ៉ាវនៅពាក់ កណ្តាលខាងដើមនៃសតវត្សរ៍ទី១៩ លោក Chandler បានសរសេរថា :

*" មិនដូចប្រទេសភូមា និងឡាវទេ, ដីកម្ពុជាមានតិចតួចជាងនូវ ត្បូង និងលោហធាតុមានតម្លៃ ។ មិនដូចប្រទេសសៀមទេ, កម្ពុជាមានពាណិជ្ជកម្ម កម្មន្តសាល មុខរបរផ្សេងទៀត មិនសូវអភិវឌ្ឍន៍ ហើយផលិតផលសំរេចដូចជា គ្រឿងស្មូនព័រសីឡែន កាំភ្លើង គឺសុទ្ធតែមកពីបរទេស ។ មិនដូចប្រទេសវៀតណាមទេ វិស័យសារគមនាគមន៍របស់កម្ពុជានៅខ្សោយ ហើយទីផ្សារផ្ទៃក្នុងនៅអន់ថយ... កម្ពុជាវិញមានសេដ្ឋកិច្ចជីវព្រឹត្ត, ប្រជាជនភាគច្រើនចំណាយពេលមួយភាគធំលើការដាំដុះស្រូវ" ។ (ទំព័រទី ១០០-១០១)*

នៅសតវត្សរ៍ទី១៩ អំណាចគ្រប់គ្រងមានទីតាំងនៅឯរាជធានីឧត្តុង្គ (៣០គ.ម ខាងជើងក្រុងភ្នំពេញ) ។ ប៉ុន្តែអាណាចក្រលាតសន្ធឹងហួសឆ្ងាយពីទីក្រុងបន្តិច ។ កសិករបង់ពន្ធមិនទៀងទាត់ទេ ជារឿយៗលុះត្រាតែមានការទារយក ឬការបង្ខិតបង្ខំ, ហើយកំរមានការទាក់ទងជាមួយប្រជាជនក្រៅភូមិណាស់ ។ ប្រជាជននៅតាមតំបន់ទីក្រុង ភាគច្រើនជាឈ្មួញ (សឹងតែទាំងអស់មានឫសគល់ជាជនបរទេស) ជាទាហាន និងជាអ្នកជាប់ពូជស្តេច ។ ក្នុងន័យនេះ យើងអាចសន្និដ្ឋានថា ពុំមានការឧបត្ថម្ភទ្រទ្រង់អ្វីគួរកត់សំគាល់ទេដល់សិល្បៈ វប្បធម៌ ឬស្ថាប័នសិក្សា ដែលអាចផ្តល់ការលើកទឹកចិត្តដ៏ចាំបាច់សំរាប់ឱ្យសកម្មភាពក្រៅកសិដ្ឋាន មានការវិវត្តន៍ ដូចនៅក្នុងប្រទេសអាស៊ីជាច្រើនទៀត ។

ភាគច្រើននៃវីរភាពបច្ចេកវិទ្យាសម័យអង្គរ បានរលុបបាត់អស់នៅក្នុងអ័ព្ទនៃពេលវេលាដែលកន្លងទៅ ។ មកដល់សតវត្សរ៍ទី១៩ ប្រហែលមានតែនៅតាមតំបន់កំពង់ប៉ុណ្ណោះ[៨] ដែលសហគមន៍នៅរក្សាបាននូវជំនាញធ្វើនាវាចរណ៍ទឹកសាប ធ្វើទូក កែច្នៃត្រី កែច្នៃម្ហូបអាហារខ្លះៗ ត្បាញរវៃ ជាបន្ថែមទៅលើការដាំដុះស្រូវ ។ ក្រៅពីនេះ ហាក់ដូចជាគ្មានអ្វីច្រើនទេ ។

## ២.៣ សម័យអាណានិគមនិយមបារាំង (ពាក់កណ្តាលសតវត្សរ៍ទី១៩ ដល់ពាក់កណ្តាលសតវត្សរ៍ទី២០)

មិនដូចប្រទេសអាណានិគមភាគច្រើនទេ បារាំងមិនបានកាន់កាប់រក្សាបញ្ជីកំណត់ត្រាលំអិតនៃព្រឹត្តិការណ៍សេដ្ឋកិច្ច និងសង្គមកិច្ចនៅក្នុងប្រទេសនេះទេ (Chandler 1993) ។ តាមការពិត ក្រៅតែពីប្រទេសវៀតណាមចេញ បារាំងបានកាន់កាប់រក្សាតិចតួចណាស់នូវបញ្ជីកំណត់ត្រាលើប្រទេសអាណានិគមនៅអាស៊ីអគ្នេយ៍នានា ។ អ្វីដែលមានគឺ កំណត់ត្រាខ្លះៗស្តីពី ការនាំចេញផលកសិកម្ម ពន្ធដារ ចំណូល និងថវិកា ។ លោក Chandler បានសរសេរដូច្នេះទៀតថា:

*"នៅក្នុងឱកាសដ៏កំរនានាដែលអ្នកនិពន្ធបារាំងយកចិត្តទុកដាក់ទៅលើបញ្ហាសេដ្ឋកិច្ចកម្ពុជា ពួកគេតែងភ្ជាប់ប្រទេសកម្ពុជា ជាមួយនឹងប្រទេសឯទៀតនៅឥណ្ឌូចិន ជាពិសេសទាក់ទិននឹងការនាំចេញផលដំណាំ និងគំនិតផ្តួចផ្តើមផ្សេងៗនៃរបបអាណានិគម ដូចជាការងារសាធារណៈជាដើម" (ទំព័រ ១៣៨) ។*

របាយការណ៍តាមសំណេររបស់អ្នកដំណើរជនជាតិបារាំងនៅទសវត្សរ៍១៨៥០, ១៨៦០ និង ១៨៧០ បានបង្ហាញថានៅតំបន់ដែលជាខេត្តកំពង់ចាមសព្វថ្ងៃ ដំណាំកប្បាសមានដាំដុះយ៉ាងទូលំទូលាយ (de Carne 2000; Mouhot 2000)[៩] ។ កំណត់ត្រាបានអះអាងទៀតថា ការងារកែច្នៃកប្បាស ដូចជា ការថ្ពេច (យកគ្រាប់ចេញ) រវៃ និងតម្បាញ គ្មានអ្វីប្លែកសំរាប់ប្រជាជនកម្ពុជាទេ ។ ដូចមានលើកនៅខាងក្រោម កប្បាសមានដាំដុះនៅកម្ពុជារហូតដល់ឆ្នាំ១៩៥០ ។ ដំណាំកប្បាសហាក់ដូចបានបញ្ឈប់

[៨] តំបន់កំពង់ ខុសប្លែកពីដែនដីខាងក្នុង ។ តំបន់កំពង់ស្ថិតនៅជាប់មាត់ទន្លេ ហើយប្រជាជនធ្វើការងារពាណិជ្ជកម្ម និងដឹកជញ្ជូន (Acharya and Chan 2001) ។

[៩] សៀវភៅទាំងនេះ ដើមឡើយបានបោះពុម្ពជាភាសាបារាំងនៅសតវត្សរ៍ទី១៩ ។ សេចក្តីយោងនានាដែលបានដកស្រង់មកនេះ បានពីឯកសារបកប្រែជាភាសាអង់គ្លេស ដែលសព្វថ្ងៃបានបោះពុម្ពចេញផ្សាយហើយ ។

អស់នៅចុងទសវត្សរ៍១៩៧០ ប៉ុន្តែកំណត់ត្រាផ្លូវការមិនបានបញ្ជាក់រឿងនេះច្បាស់ទេ ។ ថ្វីបើក្នុងរយៈពេលចុងក្រោយៗ កប្បាស ភាគច្រើនបានដាំដុះសំរាប់នាំចេញទៅប្រទេសជិតខាងក្តី ប៉ុន្តែជំនាញរបស់ប្រជាជនក្នុងការត្បាញវៃពិតជាមាននៅសេសសល់ ។ កេរ្តិ៍ដំណែលនៃការកែច្នៃកប្បាស អាចឃើញនៅសល់ដល់ពេលសព្វថ្ងៃ ដូចជា កីតំបាញដៃ និងកីតំបាញពាក់កណ្តាលស្វ័យប្រវត្តិ នៅតាមតំបន់មួយចំនួនដូចជា ខេត្តកំពង់ចាម តាកែវ និងព្រៃវែង ។ ប៉ុន្តែគួរឱ្យស្តាយ ប្រតិបត្តិការតម្បាញសព្វថ្ងៃប្រើអំបោះ នាំចូល ពីព្រោះការដាំដុះកប្បាសមិនបានរស់ឡើងវិញទេ ។

សកម្មភាពនេសាទត្រូវបានធ្វើជាលក្ខណៈពាណិជ្ជកម្ម អស់ជាងមួយសតវត្សរ៍មកហើយ ។ ព្រះរាជាបានជួលផ្ទៃទឹកធំៗ សំរាប់រយៈពេលពីមួយ-ពីរឆ្នាំ ទៅឱ្យអ្នកម៉ៅការដែលជួលកម្មករ ឬជួលបន្តតំបន់ចាប់ត្រីរបស់ខ្លួន ឱ្យទៅអ្នកស្រុក ដើម្បីធ្វើការ នេសាទ ។ បារាំងបានរៀបចំប្រព័ន្ធពន្ធដាររបស់គេ តាមគំរូដូចគ្នានឹងប្រព័ន្ធជួលតំបន់នេសាទដែរ ។ ត្រីចាប់បានមិនអាចលក់ ស្រស់ទាំងអស់ទៅទីផ្សារបានទេ គឺមានមួយចំនួនធំ បានយកធ្វើជាត្រីងៀត ត្រីប្រលាក់ ឬប្រហុកផ្អក ។ Petillot (1911) ប៉ាន់ស្មានថា នៅឆ្នាំ១៩០៩ ត្រីងៀត ឬត្រីប្រលាក់ប្រហែល ៥០.០០០តោន ត្រូវបាននាំចេញ ។ ការប៉ាន់ស្មានក្រោយៗ សំរាប់ ទសវត្សរ៍១៩២០ និង ១៩៣០ បង្ហាញថា ត្រីងៀតប្រហែល ២៥.០០០តោន បាននាំចេញពីកម្ពុជា ។ ដោយទំងន់ត្រីងៀត ស្មើនឹង ១/៣ នៃទំងន់ត្រីស្រស់ ដូច្នេះតួលេខខាងលើស្មើនឹង ៧៥.០០០តោនត្រីស្រស់ ។ ការប៉ាន់ស្មានសំរាប់ទសវត្សរ៍១៩៤០ បង្ហាញថា ផលិតផលប្រចាំឆ្នាំអាចដល់ទៅ ១២០.០០០តោន (van Zalinge, Nao, Touch and Deap 2000) ។ ទោះជាមានធនធានសំបូរ យ៉ាងនេះក្តី ក៏បារាំង ឬព្រះរាជា មិនបានកាន់កាប់រក្សាឱ្យបានជាប្រព័ន្ធទេទូវ បញ្ជីកំណត់ត្រាអំពីត្រីចាប់បាន ឬនាំចេញ ។ ម្យ៉ាង ទៀត ការពង្រឹង និងការធ្វើទំនើបកម្មលើសកម្មភាពនេះ ក៏មិនដែលមានដាក់បញ្ចូលទៅក្នុងរបៀបវារៈដែរ ។

ទោះយ៉ាងនេះក្តី ក្នុងសម័យអាណានិគមបារាំង មានការរីកចំរើនគួរកត់សំគាល់នៃតំបន់ទីក្រុង និងការកសាងប្រព័ន្ធ សារគមនាគមន៍ និងដឹកជញ្ជូន និងបណ្តាញផ្គត់ផ្គង់អគ្គិសនី ។ ប្រព័ន្ធផ្លូវដែក បានកកើតឡើង ហើយជនកម្ពុជាមួយចំនួនបានទៅ កាន់ប្រទេសបារាំងដើម្បីបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា ។ ទាំងអស់នេះបានក្លាយជាមូលដ្ឋានសំរាប់ការធ្វើទំនើបកម្ម ដែល យ៉ាងហោចណាស់ក៏នៅរាជធានីភ្នំពេញ និងក្រុងមួយចំនួន ពិសេសក្រុងព្រះសីហនុ ក្រុងបាត់ដំបង កំពង់ចាម និងសៀមរាប ។

នៅកម្ពុជា គេមិនអាចពន្យល់យ៉ាងងាយបានទេ ពីការវិវត្តន៍ទាបនៃសកម្មភាពក្រៅកសិដ្ឋាន ។ នៅក្នុងសង្គមភាគច្រើន សកម្មភាពមិនមែនកសិកម្មបានផុសឡើង ដោយសារផលិតភាពកសិកម្មឡើងខ្ពស់ ដែលអាចរំដោះកំលាំងពលកម្មមួយចំនួនចេញ ពីការងារកសិដ្ឋាន ព្រមទាំងជួយផ្តល់ទុនដល់សកម្មភាពទាំងនេះដែរ ។ នៅកម្ពុជា ផលិតភាពកសិកម្មមិនដែលបានខ្ពស់ខ្លាំងទេ ។ កសិកម្មយថាផល ពន្ធច្រើនហួសកំរិតលើផលិតផលកសិកម្ម និងស្ថានភាពនយោបាយមិនច្បាស់លាស់ មិនបានអនុញ្ញាតឱ្យដីធ្លី ឬ កំលាំងពលកម្ម អាចកើនផលិតភាពទេ ។ ផលិតភាពកសិកម្មទាប បានបង្ខំឱ្យសហគមន៍ទាំងមូលធ្វើការដាំដុះជាលក្ខណៈជីវភាព ដូច្នេះគឺគ្មានកំលាំង ឬធនធានអ្វី សំរាប់ជំរុញ ឬជួយទ្រទ្រង់ដល់សកម្មភាពមិនមែនកសិកម្មទេ ។ ម្យ៉ាងទៀត កង្វះបច្ចេកវិទ្យា ដោយសារគ្មានជំនួយឧបត្ថម្ភពីរដ្ឋ បានរួមចំណែករក្សាស្ថាពភាពឱ្យនៅដដែលបែបនេះ ។

## ២.៤ ពីឆ្នាំ១៩៥៣ ដល់ទសវត្សរ៍១៩៨០

មកដល់ទសវត្សរ៍១៩៤០ ប្រទេសកម្ពុជាទទួលបានមូលដ្ឋានឧស្សាហកម្មធុនតូច ។ របាយការណ៍រដ្ឋាភិបាលមួយដែល ផ្សព្វផ្សាយនៅឆ្នាំ១៩៥៨ បានលើកថា នៅមុនឆ្នាំ១៩៥៥ មាន ៣៦៩ឧស្សាហកម្មធុនតូចនិងមធ្យម ប្រតិបត្តិការនៅកម្ពុជា ។ នៅឆ្នាំ១៩៥៨ តួលេខនេះកើនដល់ជាងមួយពាន់: គ្រាន់តែពីឆ្នាំ១៩៥៥-៥៨ មានសហគ្រាសកើតថ្មីចំនួន ៩៨៥ ។ សហគ្រាស ទាំងនេះរួមមាន រោងចក្រមួយតំលើងរថយន្តម៉ាក Citroen កំលាំង២សេះ (ផលិតបាន ៧២០ឡាន/ឆ្នាំ), រោងចក្រមួយតំលើង ម៉ូតូ រោងចក្រពីរតំលើងវ៉ែស្តា រោងចក្រមួយតំលើងម៉ាស៊ីនដេរ, រោងចក្រផលិតទឹកសូដា៦ រោងចក្រធ្វើសាប៊ូ១១ រោងចក្រ តម្បាញប្រើគ្រឿងយន្ត៦ រោងចក្រក្រដាស២ រោងចក្រស្ករស១ រោងចក្រគីមី២ និងរោងចក្រមួយបកំប៉ុង១ (KOC 1958) ។

ទិន្នន័យបានពីផែនការ ៥ឆ្នាំ សំរាប់ឆ្នាំ១៩៦០-៦៤ បង្ហាញថា កម្ពុជានៅពេលនោះផលិតបានដូចជា ក្រណាត់ អំបោះ បាវក្រចៅ កៅស៊ូក្រែប ក្ដារបន្ទះ គ្រឿងសូត្រ និងថ្នាំលាប ហើយក៏មានគំរោងផលិតដែកទៀតនៅទសវត្សរ៍១៩៦០ (KOC 1960) ។ ក្នុងអំឡុងពេលពីឆ្នាំ១៩៥៣-៦៤ ជារយៈពេលវិនិយោគឯកជនបានចាក់ឫស ថ្វីបើការផលិតដែកមិនបានចេញ ជារូបរាងក្ដី (Sok and Acharya 2002) ។ បើនិយាយពីធនធានមនុស្ស មហាវិទ្យាល័យវេជ្ជសាស្ត្រមួយ និងស្ថាប័នបណ្ដុះ បណ្ដាលបច្ចេកទេសមួយចំនួនត្រូវបានបង្កើតឡើងក្រោមការឧបត្ថម្ភគាំពារអំពីរដ្ឋាភិបាល ។

បញ្ជីនេះហាក់ដូចធំធេងណាស់ ដោយនៅទសវត្សរ៍១៩៣០ និង១៩៤០ ហាក់ដូចមិនឃើញមានសមត្ថភាពផលិត ឬបណ្ដុះបណ្ដាលដូច្នេះទេ ។ ប៉ុន្តែស្ទើរគ្រប់សកម្មភាពទាំងនេះ មានទីតាំងនៅតំបន់ទីក្រុង ជាពិសេសនៅភ្នំពេញ និងមានខ្លះនៅក្រុងព្រះសីហនុ ។ ប៉ុន្តែជាការពិតដែរដែលថា ប្រជាជនភាគច្រើនបន្តរស់នៅក្នុងតំបន់ជនបទ និងរកចិញ្ចឹមជីវិតដោយធ្វើកសិកម្មជីវព្រឹត្តិ ។ ជំរឿនមានធ្វើនៅពេលនោះគឺ *ជំរឿនកម្ពុជាឆ្នាំ១៩៦២* មិនបានផ្ដល់ពត៌មានពីរបាយមុខរបរនៃកំលាំងពលកម្មទេ ។ ប៉ុន្តែទិន្នន័យជំរឿនស្ដីពី របាយប្រជាជនទីក្រុង-ជនបទ (ប្រជាជនជនបទមានច្រើនជាង ៨០%) និងការផលិតអគ្គិសនីនៅចុងទសវត្សរ៍១៩៥០ (តិចជាង ១០មេហ្គាវ៉ាត់ ភាគច្រើននៅភ្នំពេញ) (KOC 1960) បានបង្ហាញថា ឧស្សាហូបនីយកម្មជនបទ ឬ ចំរុះកម្មមុខរបរ មានតិចតួចបំផុត គឺមានតែការនេសាទ ការកែច្នៃត្រី ការកែច្នៃផលិតផលកសិកម្មខ្លះៗ តម្បាញគ្មានប្រើគ្រឿងយន្ត និងបណ្ដាសកម្មភាពប្រហាក់ប្រហែល ។

ចលាចលចាប់ផ្ដើមនៅចុងទសវត្សរ៍១៩៦០ ម៉្យាងដោយប្រទេសកម្ពុជាកាន់តែធ្លាក់ចូលជ្រៅទៅក្នុងស្រមោលសង្គ្រាមឥណ្ឌូចិន និងម៉្យាងទៀតដោយសារភាពស្ទៀមស្ទើកនៃសេដ្ឋកិច្ចដែលកើតចេញពីគោលនយោបាយផ្សេងៗនៅពេលនោះ ។ ចំពោះអំឡុងពេលពីឆ្នាំ១៩៧០-១៩៩០ គេតែងនិយាយថា ជាពេលមានចលាចល និងសង្គ្រាមស៊ីវិល ។ ពីឆ្នាំ១៩៧៥-៧៩ គឺជារយៈកាលខ្មែរក្រហម ដោយក្នុងនេះស្ទើរគ្រប់សកម្មភាពមិនមែនដាំដុះស្រូវ ត្រូវឈប់តាំងទាំងអស់ ។ ចំនួនប្រជាជនយ៉ាងច្រើនត្រូវបានកាត់ផ្ដាច់ពីការងារជំនាញរបស់ខ្លួន នៅពេលមានការជម្លៀសប្រជាជន និងការចាត់តាំងការងារឡើងវិញជាទ្រង់ទ្រាយធំ និងយ៉ាងរឹករាំ ។

ក្រោយឆ្នាំ១៩៨០ សកម្មភាពមួយចំនួនក្រោមរបបសហករណ៍ (ក្រុមសាមគ្គី ជាពិសេសរោងម៉ាស៊ីនកិនស្រូវ និងការកែច្នៃម្ហូបអាហារផ្សេងៗ) ចាប់ផ្ដើមផុសឡើងវិញ (Rozemuller1998) ជាបន្ថែមទៅលើវិស័យឯកជនដែលកំពុងចាប់កំណើត និងរីកលូតលាស់នៅតាមទីក្រុង និងពាក់កណ្ដាលទីក្រុង ។ សកម្មភាពកែច្នៃកប្បាសមួយចំនួន (ប្រហែលស្របគ្នានឹងការរស់ឡើងវិញនៃដំណាំកប្បាស) ដែលផ្ដើមឡើងនៅខេត្តកំពង់ចាមនៅទសវត្សរ៍១៩៨០ ដោយមានជំនួយពីសូវៀត តែស្ថានភាពអសន្តិសុខមិនអនុញ្ញាតឱ្យការប្រឹងប្រែងនេះចាក់ឫសបានទេ គឺមិនយូរប៉ុន្មានក៏ត្រូវផ្អាកវិញ ។ មកដល់ឆ្នាំ១៩៨៥ ឃើញមានកើតច្រើនជាទូទៅនូវការលក់ដូរតាមថ្នល់ ទីផ្សារតូចតាច ហើយផលិតកម្មទំនិញប្រើប្រាស់ធុនស្រាលដែលប្រមូលផ្ដុំនៅតាមតំបន់ទីក្រុង និងពាក់កណ្ដាលទីក្រុង ។ ឧស្សាហូបនីយកម្មខ្នាតធំ ចាប់ផ្ដើមនៅឆ្នាំ១៩៩០ (Sok and Acharya 2002) ។

## ២.៥ សង្ខេប

ពិនិត្យក្នុងប្រវត្តិសាស្ត្រ កម្ពុជាមិនបានទទួលមរតកអ្វីច្រើនទេក្នុងវិស័យចំរុះកម្មមុខរបរ ។ ទី១ សមិទ្ធិផលសំរេចបានក្នុងអារ្យធម៌មុនៗត្រូវបាត់បង់អស់ និងទី២ សមិទ្ធិផលតូចៗដែលសំរេចបាននៅពាក់កណ្ដាលខាងដើមនៃសតវត្សរ៍ទី២០ ក៏ត្រូវបាត់បង់ទៅក្នុងអំឡុងពេលមានចលាចលនាទសវត្សរ៍១៩៧០ និង ១៩៨០ ។

# ជំពូកទី ៣

# ចំរុះកម្មមុខរបរនៅទសវត្សរ៍១៩៩០

ពតិមានស្តីពីចំរុះកម្មសកម្មភាពពលកម្ម អាចបកស្រាយបានពីអង្កេតពីរ ក្នុងចំណោមអង្កេតទ្រង់ទ្រាយធំបួន ដែលបានធ្វើឡើងក្នុងទសវត្សរ៍១៩៩០។ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច (SES) ពីរដំបូងគឺនៅឆ្នាំ១៩៩៣ និងឆ្នាំ១៩៩៦ មិនអាចប្រើបានទេ ពីព្រោះទិន្នន័យស្តីពីរបាយសកម្មភាពពលកម្ម មិនបានកសាងជាតារាង ។ ទិន្នន័យលំអិតមានលេខពីរឬបីខ្ទង់ ស្តីពីរបាយកំលាំងពលករតាមមុខសកម្មភាព អាចទទួលបានពី SES១៩៩៧, ជំរឿនប្រទេសកម្ពុជាឆ្នាំ១៩៩៨, និង SES១៩៩៩។ បន្ទាប់មកគេអាចរកបាននូវចំណាត់ថ្នាក់ពលករតាមមុខសកម្មភាពក៏រិតពីរខ្ទង់ ដោយប្រើអង្កេតកំលាំងពលកម្ម (LFS) ឆ្នាំ២000 ។ ប៉ុន្តែដោយសារទំហំតូចនៃគំរូតាងក្នុង SES ១៩៩៧ និង ១៩៩៩ (ប្រហែល ៦.000គ្រួសារ) វាជាការប្រសើរបើសិនទិន្នន័យទទួលបានពីអង្កេតទាំងនេះ មិនត្រូវបានបំបែកលំអិតលើសពីចំណាត់ថ្នាក់មានលេខពីរខ្ទង់ ឬក៏ការបែងចែកតាមតំបន់ ។ ចំពោះការវិភាគមានលេខបីខ្ទង់ ឬក៏តាមតំបន់, ប្រភពតែមួយគត់ដែលយកជាការបានគឺ ជំរឿនប្រទេសកម្ពុជា ។

គួរបញ្ជាក់ផងដែរពីនិយមន័យនៃពាក្យ ទីក្រុង និង ជនបទ ។ ក្នុងការប្រើពាក្យជាអន្តរជាតិ តំបន់មួយ ត្រូវចាត់ទុកថាជា ទីក្រុង លុះត្រាតែបំពេញបាននូវលក្ខណៈវិនិច្ឆ័យមួយចំនួន ដូចជា ដង់ស៊ីតេប្រជាជន (ច្រើនជាង ៥00នាក់/គ.ម$^{២}$), ទំហំប្រជាជន (ច្រើនជាង ៥.000នាក់), និងមូលដ្ឋានការងារ (ការងារមិនមែនកសិកម្មខ្ពស់ជាង ៧៥%) ។ ឯតំបន់ផ្សេងទៀតត្រូវចាត់ជាតំបន់ជនបទ ។ នៅកម្ពុជា និយមន័យបែបរដ្ឋបាលមួយ ត្រូវបានប្រើជំនួស ក្នុងនេះស្រុកដែលមានទីចាត់ការខាងរដ្ឋបាលតាំងនៅគឺជាទីក្រុង ឯតំបន់ផ្សេងទៀតទទួលចំណាត់ថ្នាក់ជា ជនបទ ។ម្យ៉ាងទៀត មាន "ក្រុង" បួនគឺ ភ្នំពេញ ក្រុងព្រះសីហនុ កែប និងប៉ៃលិន បានទទួលចំណាត់ថ្នាក់ជា ទីក្រុង ថ្វីបើនៅក្រុងទាំងបីខាងក្រោយ គេឃើញមានតំបន់ធំៗជាច្រើនជា ជនបទ ។

ដោយបានចងចាំពីលក្ខណៈមិនប្រក្រតីនៃនិយមន័យនេះ និងការពិតជាក់ស្តែងដែលប្រទេសកម្ពុជាមានសេដ្ឋកិច្ចពឹងផ្អែកលើកសិកម្មជាសំខាន់, ការវិភាគក្នុងផ្នែកនេះ មិនផ្តោតត្រឹមតែលើតំបន់ស្របតាមនិយមន័យ "ជនបទ" នោះទេ ។ ការវិភាគមួយភាគធំ នឹងផ្អែកទៅលើទិន្នន័យប្រមូលផ្តុំ (ជនបទ និងទីក្រុង) ។

## ៣.១ ការវិភាគរបាយកំលាំងពលកម្ម ឆ្នាំ១៩៩៧-២000

តារាង៣.១ បង្ហាញទិន្នន័យស្តីពីការបែងចែកកំលាំងពលកម្មនៅកម្ពុជាសំរាប់បួនឆ្នាំគឺ ១៩៩៧ ១៩៩៨ ១៩៩៩ និង ២000 ។ តារាងនេះចងក្រងសំរាប់ទូទាំងប្រទេស ព្រមទាំងសំរាប់តំបន់ជនបទផងដែរ (តួលេខសំរាប់តំបន់ជនបទ បង្ហាញក្នុងផ្នែកខាងក្រោមនៃតារាង) ។ សមាមាត្រពលករយ៉ាងច្រើន (ជាង ៧0%) ប្រមូលផ្តុំក្នុងវិស័យកសិកម្ម ក្នុងទូទាំងប្រទេស ហើយតួលេខសំរាប់តំបន់ជនបទវិញ កាន់តែខ្ពស់ជាងទៀតគឺពី ៧៥-៨0% ។ ក្រុមពលករមួយចំនួនទៀត ដែលមានការប្រមូលផ្តុំគួរកត់សំគាល់ (ច្រើនជាង ១% នៃការងារសរុប) គឺការនេសាទ ការកែច្នៃម្ហូបអាហារ សំណង់ ការលក់ដូរ (ទំនិញ និងសេវា) សកម្មភាពដឹកជញ្ជូន (ផ្លូវគោក/ទឹក) អប់រំ និងរដ្ឋបាលសាធារណៈ ។ គ្រប់ក្រុមពលកម្ម ដែលមានចំណែកតិចជាង ១% ក្នុងកំលាំងពលកម្មសរុប ក្នុងរយៈ ៤ឆ្នាំនេះ បានចុះផ្តុំគ្នាក្នុងខ្ទង់ "ផ្សេងៗ" ។

បន្ទាប់មក ទិន្នន័យបង្ហាញពីការផ្តុំកម្មករតាមភេទ ក្នុងក្រុមពលកម្មជាច្រើនៈ មានពលករស្ត្រីច្រើនជាងធ្វើការក្នុងផ្នែកកែច្នៃម្ហូបអាហារ ឧស្សាហកម្មសំលៀកបំពាក់ និងការលក់ដូរ ចំណែកឯផ្នែកនេសាទ ដឹកជញ្ជូន និងរដ្ឋបាលសាធារណៈ មានពលករជាបុរសច្រើនជាង ។ ក្នុងការងារត្រូវប្រើកំលាំងធ្ងន់ ឬត្រូវធ្វើដំណើរច្រើន ដូចជា នេសាទ សំណង់ ដឹកជញ្ជូន មានពលករបុរសច្រើនជាង ។

រវាងតំបន់ទីក្រុង និងជនបទ ពុំមានការខុសប្លែកគ្នាច្រើនទេ នៅក្នុងរបាយពលករតាមមុខសកម្មភាពដែលធ្វើការបែងចែកនៅកំរិតតួលេខពីរខ្ទង់ (លើកលែងតែនៅតំបន់ជនបទណាដែលមានសមាមាត្រពលករយ៉ាងច្រើនប្រកបការងារកសិកម្ម និងសំរាប់ក្រុមពលកម្មដែលតូចពេកសឹងតែគ្មាន) ។ ដូច្នេះតាមទិន្នន័យទាំងនេះ ចំរុះកម្មមុខរបរនៅជនបទមានតិចតួចទេ និងមានការប្រមូលផ្តុំពលករស្ត្រីច្រើនជាងបុរស ក្នុងការងារកសិកម្ម ។ ដូចក្នុងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងៗទៀតដែរ មូលហេតុសំខាន់ក្នុងរឿងនេះគឺ ពលករស្ត្រីមានលទ្ធភាពចល័តមុខរបរ និងទីតាំងភូមិសាស្ត្រតិចជាង ។ ដូច្នេះពលករស្ត្រីតែងប្រមូលផ្តុំច្រើនៗនៅក្នុងជំរើសការងារផ្សេងៗដែលមានផលិតភាពទាប ។

ការប្រៀបធៀបនិន្នាការមុខរបរទៅតាមឆ្នាំខុសៗគ្នា មានចោទបញ្ហា ដោយសារទិន្នន័យមិនអាចប្រៀបធៀបគ្នាបាន ។ ពលករសរុបមាន ៤,២លាននាក់សំរាប់ SES ១៩៩៧, ៤,៨លាននាក់ សំរាប់ ជំរឿនប្រទេសកម្ពុជាឆ្នាំ១៩៩៨, ៥,៦លាននាក់សំរាប់ SES ១៩៩៩, និង ៥,២លាននាក់ សំរាប់ អង្កេតកំលាំងពលកម្មឆ្នាំ២000 ។ ទី១ ទិន្នន័យមិនអាចប្រៀបធៀបគ្នាបានទាំងស្រុងទេរវាងឆ្នាំទាំងនេះ ដោយមូលហេតុតំបន់គ្របដណ្តប់មិនដូចគ្នា (មានមូលហេតុច្រើនទៀត)[១០] ។ ទី២ អង្កេតនីមួយៗមាននិយមន័យ និងសៀវភៅណែនាំរបស់វាផ្ទាល់ ដែលមិនសុទ្ធតែស៊ីសង្វាក់គ្នាជាមួយអង្កេតឯទៀតនោះទេ ។ ទី៣ ចំពោះអង្កេតឆ្នាំ១៩៩៧, ១៩៩៩, និង ២000, ទិន្នន័យស្រង់បានពីអង្កេតលើគំរូតាង, ចំណែកឯទិន្នន័យសំរាប់ឆ្នាំ១៩៩៨ ផ្អែកលើការធ្វើជំរឿន ។ ទិន្នន័យបានពីអង្កេតគំរូតាង អាចមានលំអៀងតូចៗខ្លះនៅកំរិតតួលេខបំបែកលំអិត ដោយសារការជ្រើសគំរូតាង ។ ទី៤ ក្នុងអង្កេតគំរូតាង កម្មករធ្វើអង្កេតមានអាយុចាប់ពី ១០ឆ្នាំឡើងទៅ ចំណែកឯនៅក្នុងជំរឿនពលករទាំងអស់ចាប់ពីអាយុ៥ឆ្នាំឡើងទៅ ត្រូវបានធ្វើអង្កេត ដូច្នេះតួលេខកាន់តែខ្វះខាតលក្ខណៈអាចប្រៀបធៀបគ្នាបាន ។ ទី៥ ចំណាត់ថ្នាក់ពលករក្នុងអង្កេតកំលាំងពលកម្ម គឺមិនបានល្អិតល្អន់ដូចក្នុងអង្កេតឯទៀតៗទេ (ការងារធ្វើចំណាត់ថ្នាក់តាមវិស័យទី១, វិស័យទី២ ។ល។) ហើយនេះក៏ជាចំណុចមួយទៀតដែលមិនអាចប្រៀបធៀបគ្នាបាន ។

[១០] អង្កេត SES ១៩៩៧ បានរំលងចោលខេត្តបីធំៗនៅភាគពាយ័ព្យដោយសារហេតុផលខាងសន្តិសុខ ។ ជំរឿនបានអះអាងថា បានគ្របដណ្តប់ លើ ៩០% នៃប្រទេសកម្ពុជា ។ អង្កេត SES ១៩៩៩ ហាក់ដូចបានគ្របដណ្តប់លើ ៩៥% នៃផ្ទៃប្រទេស ។ ចំពោះអង្កេតកំលាំងពលកម្មឆ្នាំ២000 គេគ្មានពត៌មានលំអិតពីតំបន់គ្របដណ្តប់ទេ ។

## តារាង៣.១ ភាគរយរបាយកម្មករ, ចំណាត់ថ្នាក់មានលេខពីរខ្ទង់ នៃមុខសកម្មភាពសំរាប់ឆ្នាំ១៩៩៧ ១៩៩៨ ១៩៩៩ និង ២000

| មុខសកម្មភាព | SECS 1997 | | | Census 1998 | | | SECS 1999 | | | LF 2000 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ក្រុម | ពីរភេទ | ប្រុស | ស្ត្រី | ពីរភេទ | ប្រុស | ស្ត្រី | ពីរភេទ | ប្រុស | ស្ត្រី | ពីរភេទ | ប្រុស | ស្ត្រី |
| ០១. កសិកម្ម ប្រមាញ់ និងសកម្មភាពសេវាជាប់ទាក់ទង | 70.03 | 66.08 | 73.74 | 75.57 | 69.00 | 81.80 | 72.31 | 68.46 | 75.83 | 70.09 | 67.07 | 72.88 |
| ០២. រុក្ខា កាប់ឈើ និងសកម្មភាពសេវាជាប់ទាក់ទង | 0.70 | 0.85 | 0.56 | 0.14 | 0.20 | 0.08 | 1.63 | 1.99 | 1.30 | 0.85 | 0.93 | 0.76 |
| ០៥. នេសាទ ប្រតិបត្តិការភ្ញាស់ត្រី កសិដ្ឋាន | | | | 1.47 | 2.00 | 0.89 | 2.10 | 3.31 | 0.99 | 2.79 | 4.42 | 1.28 |
| ១៥. កម្មន្តសាលកម្ម ផលិតផលម្ហូបអាហារ និងភេសជ្ជៈ | 1.16 | 1.41 | 0.93 | 0.34 | 0.40 | 0.25 | 1.22 | 1.26 | 1.18 | 1.53 | 1.56 | 1.51 |
| ១៧. កម្មន្តសាលកម្មវាយនភ័ណ្ឌ | 1.07 | 0.43 | 1.67 | 0.27 | 0.00 | 0.46 | 1.15 | 0.48 | 1.77 | 0.88 | 0.49 | 1.25 |
| ១៨. កម្មន្តសាលកម្មសំលៀកបំពាក់ | 0.84 | 0.22 | 1.43 | 1.09 | 0.30 | 1.83 | 1.98 | 0.60 | 3.23 | 3.45 | 0.70 | 6.01 |
| ២០. កម្មន្តសាលកម្មឈើ និងផលិតផលឈើ | 1.39 | 1.81 | 1.00 | 0.35 | 0.50 | 0.13 | 0.27 | 0.53 | 0.03 | 0.05 | 0.10 | 0.01 |
| ៤៥. សំណង់ | 1.69 | 3.01 | 0.46 | 0.93 | 1.60 | 0.23 | 1.40 | 2.56 | 0.34 | 1.32 | 2.40 | 0.32 |
| ៥០. លក់ ថែទាំនិងជួសជុលយានយន្ត | 2.42 | 3.60 | 1.31 | 0.53 | 0.90 | 0.13 | 0.29 | 0.50 | 0.09 | 0.49 | 0.79 | 0.21 |
| ៥២. ពាណិជ្ជកម្មលក់រាយ លើកលែងតែយានយន្ត | 9.19 | 4.56 | 13.54 | 6.23 | 3.50 | 8.75 | 7.05 | 3.33 | 10.45 | 7.17 | 3.84 | 10.25 |
| ៦០. ដឹកជញ្ជូនតាមផ្លូវគោក និងតាមបំពង់បង្ហូរ | 1.59 | 3.17 | 0.11 | 2.22 | 4.10 | 0.42 | 1.59 | 3.30 | 0.04 | 1.85 | 3.73 | 0.11 |
| ៧៥. រដ្ឋបាលសាធារណៈ និងការពារជាតិ | 3.24 | 5.79 | 0.84 | 4.54 | 8.50 | 0.75 | 3.21 | 6.11 | 0.57 | 2.79 | 5.28 | 0.48 |
| ៨០. អប់រំ | 1.37 | 1.86 | 0.92 | 1.66 | 2.20 | 1.10 | 1.53 | 2.21 | 0.91 | 1.66 | 2.27 | 1.09 |
| ៩៥. គ្រួសារឯកជនដែលមានអ្នកធ្វើការ(ឱ្យគេ) | 1.19 | 1.24 | 1.15 | 0.21 | 0.20 | 0.25 | 0.63 | 0.66 | 0.60 | 0.64 | 0.68 | 0.60 |
| ផ្សេងៗ | 4.12 | 5.97 | 2.34 | 4.45 | 6.54 | 2.93 | 3.64 | 4.70 | 2.67 | 4.44 | 5.74 | 3.24 |
| សរុប | 100.00 | 100.00 | 100.00 | 100.00 | 100.00 | 100.00 | 100.00 | 100.00 | 100.00 | 100.00 | 100.00 | 100.00 |
| | | | | | | **ជនបទ** | | | | | | |
| ០១. កសិកម្ម ប្រមាញ់ និងសកម្មភាពសេវាជាប់ទាក់ទង | 79.96 | 76.70 | 82.91 | 82.76 | 77.30 | 87.63 | 77.74 | 74.53 | 80.63 | 75.85 | 73.29 | 78.17 |
| ០២. រុក្ខា កាប់ឈើ និងសកម្មភាពសេវាជាប់ទាក់ទង | 0.75 | 0.93 | 0.59 | 0.11 | 0.10 | 0.07 | 1.76 | 2.17 | 1.38 | 0.86 | 0.96 | 0.77 |
| ០៥. នេសាទ ប្រតិបត្តិការភ្ញាស់ត្រី កសិដ្ឋាន | | | | 1.47 | 2.00 | 0.89 | 2.10 | 3.31 | 0.99 | 2.79 | 4.42 | 1.28 |
| ១៥. កម្មន្តសាលកម្ម ផលិតផលម្ហូបអាហារ និងភេសជ្ជៈ | 1.03 | 1.37 | 0.72 | 0.26 | 0.30 | 0.19 | 1.34 | 1.24 | 1.03 | 1.53 | 1.57 | 1.49 |
| ១៧. កម្មន្តសាលកម្មវាយនភ័ណ្ឌ | 1.20 | 0.52 | 1.80 | 0.29 | 0.00 | 0.49 | 1.20 | 0.46 | 1.86 | 0.97 | 0.56 | 1.34 |
| ១៨. កម្មន្តសាលកម្មសំលៀកបំពាក់ | 0.47 | 0.10 | 0.79 | 0.83 | 0.20 | 1.80 | 1.73 | 0.51 | 2.82 | 3.36 | 0.64 | 5.82 |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០. កម្មន្តសាលកម្មឈើ និងផលិតផលឈើ | 1.50 | 1.87 | 1.16 | 0.31 | 0.50 | 0.12 | 0.24 | 0.48 | 0.02 | 0.05 | 0.09 | 0.01 |
| ៤៥. សំណង់ | 1.26 | 2.20 | 0.41 | 0.54 | 1.00 | 0.12 | 1.19 | 2.24 | 0.25 | 1.03 | 1.86 | 0.27 |
| ៥០. លក់ ថែទាំនិងជួសជុលយានយន្ត | 1.82 | 2.84 | 0.90 | 0.30 | 0.50 | 0.07 | 0.17 | 0.33 | 0.04 | 0.30 | 0.46 | 0.16 |
| ៥២. ពាណិជ្ជកម្មលក់រាយ លើកលែងតែយានយន្ត | 5.38 | 2.82 | 7.71 | 1.17 | 2.40 | 5.74 | 5.48 | 2.71 | 7.95 | 5.01 | 2.84 | 6.99 |
| ៦០. ដឹកជញ្ជូនតាមផ្លូវគោក និងតាមបំពង់បង្ហូរ | 0.87 | 1.75 | 0.06 | 0.57 | 2.90 | 0.36 | 1.17 | 2.43 | 0.03 | 1.31 | 2.66 | 0.08 |
| ៧៥. រដ្ឋបាលសាធារណៈ និងការពារជាតិ | 1.32 | 2.66 | 0.11 | 3.01 | 6.00 | 0.29 | 1.98 | 4.00 | 0.18 | 1.90 | 3.74 | 0.21 |
| ៨០. អប់រំ | 1.10 | 1.66 | 0.58 | 1.42 | 2.00 | 0.81 | 1.32 | 2.00 | 0.71 | 1.44 | 2.08 | 0.84 |
| ៩៥. គ្រួសារឯកជនដែលមានអ្នកធ្វើការ(ឱ្យគេ) | 0.94 | 0.90 | 0.97 | 0.09 | 0.00 | 0.10 | 0.44 | 0.43 | 0.45 | 0.61 | 0.71 | 0.52 |
| ផ្សេងៗ | 2.40 | 3.68 | 1.29 | 6.87 | 4.80 | 1.32 | 2.14 | 3.16 | 1.66 | 2.99 | 4.12 | 2.05 |
| សរុប | 100.00 | 100.00 | 100.00 | 100.00 | 100.00 | 100.00 | 100.00 | 100.00 | 100.00 | 100.00 | 100.00 | 100.00 |

## ៣.២ ការប្រៀបធៀបអង្កេត SES ១៩៩៧ និង SES ១៩៩៩

គេជឿថា អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចទាំងពីរនៅឆ្នាំ១៩៩៧ និង ១៩៩៩ អាចប្រៀបធៀបគ្នាបានប្រសើរជាងប្រភពទិន្នន័យផ្សេងៗទៀត ពីព្រោះគំរូតាងដកស្រង់ចេញពីគំរូតាងមេតែមួយដែលបានរៀបចំនៅឆ្នាំ១៩៩៣[១១] ។ ដូច្នេះគេត្រូវប្រឹងប្រែងប្រៀបធៀបបំរែបំរួលជាក់លាក់នៃចំនួនការងារនៅជនបទ តាមក្រុមសកម្មភាពធំៗ ដោយបំបែកចេញជាតួលេខ ២ខ្ទង់ រវាងឆ្នាំ១៩៩៧ និង ១៩៩៩ (តារាង៣.២) ។

**តារាង៣.២ ការងារ និងបំរែបំរួលការងារតាមក្រុមសកម្មភាពនៅតំបន់ជនបទ ឆ្នាំ១៩៩៧-៩៩**

| ក្រុមសកម្មភាព | កម្មករ ១៩៩៧ | កម្មករ ១៩៩៩ | បំរែបំរួលជាភាគរយ |
|---|---|---|---|
| ០១. កសិកម្ម ប្រមាញ់ និងសកម្មភាពសេវាជាប់ទាក់ទង | 2,770,703 | 3,815,151 | 38 |
| ០២. រុក្ខា កាប់ឈើ និងសកម្មភាពសេវាជាប់ទាក់ទង | 25,918 | 86,239 | 233 |
| ០៥. នេសាទ ប្រតិបត្តិការភ្ញាស់ត្រី កសិដ្ឋាន | | 102,994 | |
| ១០. ការជីកយកត្បូងថ្ម និង lignite | 201 | | |
| ១១. និស្សារណកម្មប្រេងកាត និងឧស្ម័នធម្មជាតិ | | 1,163 | |
| ១៣. ការយករ៉ែលោហៈ | 300 | | |
| ១៤. ការយករ៉ែ និងយកថ្មផ្សេងទៀត | 8,996 | 1,148 | -87 |
| ១៥. កម្មន្តសាលកម្ម ផលិតផលម្ហូបអាហារ និងភេសជ្ជៈ | 35,741 | 55,647 | 56 |
| ១៦. កម្មន្តសាលកម្មផលិតផលថ្នាំជក់ | 1,843 | 2,393 | 30 |
| ១៧. កម្មន្តសាលកម្មវាយនភ័ណ្ឌ | 41,443 | 58,888 | 42 |
| ១៨. កម្មន្តសាលកម្មសំលៀកបំពាក់ | 16,138 | 85,118 | 427 |
| ១៩. ការសំលាប់ស្បែក និងកែច្នៃស្បែក | | | |
| ២០. កម្មន្តសាលកម្មឈើ និងផលិតផលឈើ | 51,979 | 11,667 | -78 |
| ២២. ការផ្សព្វផ្សាយ បោះពុម្ព និងចំលងកំណត់ត្រានៃប្រព័ន្ធផ្សព្វផ្សាយ | 477 | 1,283 | 169 |
| ២៣. កម្មន្តសាលកម្មផលិតផលប្រេងកាតចំរាញ់ និងធ្យូងថ្ម | 411 | | - |
| ២៤. កម្មន្តសាលកម្មគីមី និងផលិតផលគីមី | | 845 | |
| ២៥. កម្មន្តសាលកម្មផលិតផលកៅស៊ូ និងប្លាស្ទិក | 201 | | |
| ២៦. កម្មន្តសាលកម្មផលិតផលរ៉ែមិនមែនដែក | 2,399 | 8,961 | 274 |
| ២៧. កម្មន្តសាលកម្មលោហៈជាមូលដ្ឋាន | 9,295 | | |
| ២៨. កម្មន្តសាលកម្មកែច្នៃផលិតផលលោហៈ មិនរាប់គ្រឿងម៉ាស៊ីនទេ | 1,150 | 6,332 | 451 |
| ២៩. កម្មន្តសាលកម្មគ្រឿងម៉ាស៊ីន និងបរិក្ខារ N.E.C | 859 | 1,603 | 87 |
| ៣២. កម្មន្តសាលកម្មបរិក្ខារ វិទ្យុ ទូរទស្សន៍ និងសារគមនាគមន៍ | 1,961 | | |
| ៣៥. កម្មន្តសាលកម្មសំភារៈដឹកជញ្ជូន | 874 | | |
| ៣៦. កម្មន្តសាលកម្មគ្រឿងសង្ហារឹម N.E.C | 913 | 3,201 | 251 |
| ៤០. អគ្គិសនី ឧស្ម័ន និងការផ្គត់ផ្គង់ទឹកក្តៅ និងចំហាយ | 350 | 1,130 | 223 |
| ៤១. ការប្រមូល បន្សុត និងចែកចាយទឹក | | 651 | |
| ៤៥. សំណង់ | 43,619 | 58,383 | 34 |
| ៥០. លក់ ថែទាំ និងជួសជុលយានយន្ត | 63,140 | 8,549 | -86 |
| ៥១. ពាណិជ្ជកម្មលក់ដុំ និងពាណិជ្ជកម្មយកកំរៃជើងសារ | 3,714 | 1,294 | -65 |
| ៥២. ពាណិជ្ជកម្មលក់រាយ លើកលែងតែយានយន្ត | 186,522 | 268,735 | 44 |

[១១] គំរូតាងមេថ្មីមួយ ត្រូវបានរៀបចំចេញពីជំរឿនឆ្នាំ១៩៩៨ ប៉ុន្តែមិនទាន់បានយកមកប្រើទេ ។

| | | | |
|---|---|---|---|
| ៥៥. សណ្ឋាគារ និងភោជនីយដ្ឋាន | 1,128 | 7,926 | 603 |
| ៦០. ដឹកជញ្ជូនតាមផ្លូវគោក និងតាមបំពង់បង្ហូរ | 30,052 | 57,279 | 91 |
| ៦១. ដឹកជញ្ជូនតាមផ្លូវទឹក | 5,195 | 1,881 | -64 |
| ៦២. ដឹកជញ្ជូនតាមផ្លូវអាកាស | | 6,260 | |
| ៦៣. សកម្មភាពទ្រទ្រង់ និងបន្ទាប់បន្សំឱ្យការដឹកជញ្ជូន | 13,298 | 14,559 | 9 |
| ៦៤. ប្រៃសណីយ៍ទូរគមនាគមន៍ | | 2,072 | |
| ៦៥. សេវាអន្តរការីហិរញ្ញវត្ថុ លើកលែងតែធានារ៉ាប់រង | 1,598 | 1,849 | 16 |
| ៦៦. ធានារ៉ាប់រង និងផ្តល់ទុនសោធននិវត្តន៍ | | 236 | |
| ៦៧. សកម្មភាពបន្ទាប់បន្សំឱ្យសេវាអន្តរការីហិរញ្ញវត្ថុ | 392 | 511 | 30 |
| ៧០. សកម្មភាពលក់ជួលអចលនទ្រព្យ | | 446 | |
| ៧១. ការជួលគ្រឿងម៉ាស៊ីន គ្មានប្រតិបត្តិករ | 1,215 | 719 | -41 |
| ៧២. កុំព្យូទ័រ និងសកម្មភាពទាក់ទិន | 453 | | |
| ៧៤. សកម្មភាពអាជីវកម្មផ្សេងទៀត | 1,394 | 3,234 | 132 |
| ៧៥. រដ្ឋបាលសាធារណៈ និងការពារជាតិ | 45,727 | 97,404 | 113 |
| ៨០. អប់រំ | 38,079 | 64,858 | 70 |
| ៨៥. សុខាភិបាល និងការងារសង្គមកិច្ច | 12,165 | 16,224 | 33 |
| ៩០. ទឹកសំអុយ និងការយកសំរាមទៅចោល និងអនាម័យ | 833 | 2,238 | 169 |
| ៩១. សកម្មភាពនៃអង្គការសមាជិក NEC | 2,273 | 2,477 | 9 |
| ៩២. ការកំសាន្ត ទំនិញវប្បធម៌ និងកីឡា | 3,737 | 5,592 | 50 |
| ៩៣. សកម្មភាពសេវាផ្សេងទៀត | 4,282 | 10,544 | 146 |
| ៩៥. គ្រួសារឯកជនដែលមានអ្នកធ្វើការ (ឱ្យគេ) | 32,438 | 21,625 | -33 |
| ៩៩. អង្គការ និងស្ថាប័ននៅក្រៅដែនដី | 1,702 | 7,960 | 368 |
| សរុប | 3,465,112 | 4,907,269 | 43 |

ទិន្នន័យក្នុងជួរក្រោមបំផុតនៃតារាង៣.២ បង្ហាញពីចំនួនពលករសរុបក្នុងរយៈ ២ឆ្នាំ ។ គេប៉ាន់ស្មានថា នៅឆ្នាំ១៩៩៧ ពលករជនបទមានប្រហែល ៣,៤លាននាក់, ឯនៅឆ្នាំ១៩៩៩ មានប្រហែល ៤,៩លាននាក់ ។ កំណើន ១,៥លាននាក់នេះ ដែលស្មើនឹងប្រហែល ៤៣% នៃចំនួនប្រជាជនធ្វើការងារនៅជនបទសរុប ដូចជាមិនគួរឱ្យជឿបានទេសំរាប់រយៈពេលតែ ២ឆ្នាំ ពីព្រោះពុំមានលំហូរប្រជាជនចូលទ្រង់ទ្រាយធំទេ មកពីតំបន់ទីក្រុង ឬមកពីក្រៅប្រទេស ដើម្បីបញ្ជាក់ពីតួលេខខុសគ្នានេះ ។ ពិតហើយក៏វិតគ្របដណ្តប់នៃអង្កេតទាំងពីរ មានបញ្ហាច្រើនត្រូវពន្យល់ ។ អាចថាមេគុណ (ទំងន់) ដែលបានប្រើនៅក្នុងអង្កេតគំរូតាងណាមួយ ឬក៏ទាំងពីរ វាមិនត្រឹមត្រូវ ដោយសារអង្កេតទាំងនេះមិនប្រើគំរូតាងមេដែលដកស្រង់ចេញពីជំរឿនទេ ប៉ុន្តែគេបានពឹងផ្អែកលើបញ្ជីធ្វើឡើងដោយអ៊ុនតាក់ (UNTAC) នៅឆ្នាំ១៩៩៣ ។

លំអៀងក្នុងការរាប់ចំនួនប្រជាជន បើសិនវាមានលក្ខណៈជាប្រព័ន្ធតាមមុខសកម្មភាពនានា (systematic across iindustries) នៅតែអនុញ្ញាតឱ្យធ្វើការប្រៀបធៀបខ្លះៗបាន ។ គេមិនអាចកំណត់បានទេថាលំអៀងនេះមានលក្ខណៈជាប្រព័ន្ធ ឬក៏អត់ ដូច្នេះការប្រៀបធៀបមួយចំនួនត្រូវបានធ្វើឡើងក្រោមការសន្មតថា លំអៀងមានលក្ខណៈជាប្រព័ន្ធ ។

ក្នុងវិស័យផលិតកម្ម ការងារបានកើនឡើងគួរកត់សំគាល់ (ជាង ១00%) ក្នុងផ្នែកនេសាទ ឧស្សាហកម្មសំលៀកបំពាក់ ផលិតផលរ៉ែមិនមែនដែក ការកែច្នៃវត្ថុពីលោហៈ ផលិតកម្មសង្ហារឹម ផលិតកម្មថាមពលអគ្គិសនី និងសកម្មភាពបោះពុម្ព ។ ក្នុងវិស័យសេវាកម្ម សណ្ឋាគារ ភោជនីយដ្ឋាន សកម្មភាពទាក់ទិននឹងអនាម័យ និងសេវាសាធារណៈ មានការរីកលូតលាស់ប្រហាក់ប្រហែលគ្នា ។ ផ្ទុយទៅវិញ វិស័យដែលបានរួមតូច (ដូចពិនិត្យឃើញតាមទិន្នន័យការងារ) គឺមានការជីកយករ៉ែ និងថ្ម

ឈើនិងផលិតផលឈើ លក់និងជួសជុលយានយន្ត ពាណិជ្ជកម្មលក់ដុំ ដឹកជញ្ជូនផ្លូវទឹក ជួលម៉ាស៊ីន និងការងារបំរើក្នុងផ្ទះ ។ ក្នុងវិស័យដែលរីកលូតលាស់ ឧស្សាហកម្មកាត់ដេរ ឈានមុខគេក្នុងបរិបទកម្ពុជា (វាបានរីកដុះដាលយ៉ាងលឿនក្នុងរយៈពេលនោះរួមទាំងនៅតំបន់ជនបទផង) ។ ផលិតផលរ៉ែមិនមែនដែក (ឧ. ថ្មកំបោរ) នៅតែមានតំរូវការ ដោយសារការរីកចំរើនក្នុងឧស្សាហកម្មសំណង់, ហើយអគ្គីសនី សណ្ឋាគារ ការបោះពុម្ព គ្រឿងសង្ហារឹម និងបណ្តាសកម្មភាពប្រហាក់ប្រហែល បានរីកលូតលាស់ស្របតាមដំណើរការធ្វើទំនើបកម្ម ។ ដោយសារមានកំណើនសេដ្ឋកិច្ច ៥-៦% នៅចុងទសវត្សរ៍១៩៩០ ដូច្នេះកំណើនបែបនេះក្នុងតំរូវការ វាគ្មានអ្វីមិនប្រាកដនិយមនោះទេ ។ សកម្មភាពខាងឈើនិងផលិតផលឈើ មានការរួមចុះ ប្រហែលដោយសារការត្រួតពិនិត្យតឹងរឹងរបស់រដ្ឋាភិបាលលើការកាប់ឈើ ។ ការដឹកជញ្ជូនតាមផ្លូវគោក ហាក់ដូចបានជំនួសឱ្យការដឹកជញ្ជូនតាមផ្លូវទឹក (កំណើនការនាំចូលយានយន្ត ជាភស្តុតាងបង្ហាញថា ការដឹកជញ្ជូនតាមផ្លូវគោកកំពុងរីកលូតលាស់យ៉ាងលឿន) ។ ចំណុចចុងក្រោយគឺ ដោយសារដំណើរការអភិវឌ្ឍន៍បានរីកចំរើន ចំនួនពលករបំរើការតាមផ្ទះនឹងត្រូវថយចុះ ។

សរុបមក ការរៀបរាប់ខាងលើ មានប្រយោជន៍សំរាប់បំផុសឱ្យឃើញនូវសកម្មភាពនានា ដែលមាន ឬដែលគ្មានសក្តានុពលក្នុងការរីកលូតលាស់ ។ ប៉ុន្តែគេមិនអាចស្រាវជ្រាវអ្វីបានច្រើនទៀតទេ អំពីទិន្នន័យទាំងនេះ ។

## ៣.៣ របាយសកម្មភាព ផ្អែកតាមជំរឿនឆ្នាំ១៩៩៨

តាមនិយមន័យរបស់វា ជំរឿនត្រូវផ្តល់ចំណាត់ថ្នាក់សកម្មភាពផ្សេងៗ បានលំអិតជាងអង្កេតគំរូតាង ។ តួលេខ (មាន ៣ខ្ទង់) នៃការបែងចែកពលករ ដែលបានពីជំរឿនប្រទេសកម្ពុជាឆ្នាំ១៩៩៨ មានចុះក្នុងតារាង៣.៣ ។ តារាងនេះបង្ហាញពីរបាយពលករនៅក្នុងក្រុមសកម្មភាពជ្រើសរើស (frequency distribution of workers in select industry groups) ដោយផ្អែកទំហំប្រៀបធៀបនៃសកម្មភាពនីមួយៗ (ដូចមានចុះក្នុងតារាង៣.១ និង ៣.២) និងដោយផ្អែកលើសកម្មភាពនានាដែលអាចរីកលូតលាស់នៅក្នុងបរិស្ថានជនបទកម្ពុជា ។ ទិន្នន័យត្រូវបានបង្ហាញដោយឡែកពីគ្នា សំរាប់ទូទាំងប្រទេសកម្ពុជា និងសំរាប់តំបន់ជនបទជាពិសេស[១២] ។

នៅឆ្នាំ១៩៩៨ ចំនួនការងារសរុបក្នុងប្រទេសមានប្រហែល ៤,៨លាន ហើយនៅតំបន់ជនបទមានប្រហែល ៤,១លាន ។ ក្រុមសកម្មភាពដែលចុះក្នុងតារាង៣.៣ តំណាងឱ្យប្រហែលតែ ១៤% នៃការងារសរុបក្នុងទូទាំងប្រទេស និងប្រហែលតែ ១០% ក្នុងតំបន់ជនបទ ។ តួលេខទាំងនេះមានកំរិតទាប ដែលបង្ហាញពីការទើបចាប់កកើតសកម្មភាពមិនមែនកសិកម្មនៅកម្ពុជា ។

**តារាង៣.៣ ការងារនៅក្នុងក្រុមសកម្មភាពជាក់លាក់មួយចំនួននៅឆ្នាំ១៩៩៨**

| | | ទូទាំងប្រទេសកម្ពុជា | | ជនបទកម្ពុជា | |
|---|---|---|---|---|---|
| សកម្មភាព | ពិពណ៌នា | ការងារ | ភាគរយ | ការងារ | ភាគរយ |
| 050 | នេសាទ ការភ្ញាស់ត្រី និងកសិដ្ឋានចិញ្ចឹមត្រី សកម្មភាពផ្តល់សេវាបន្ទាប់បន្សំដល់ការនេសាទ | 71,079 | 10.39 | 56,857 | 13.42 |
| 141,142 | ការយករ៉ែ និងថ្មផ្សេងៗ | 5,535 | 0.81 | 3,648 | 0.86 |
| 151 | ផលិតកម្ម ការកែច្នៃ សាច់ ត្រី ផ្លែឈើ បន្លែ ប្រេង ខ្លាញ់ | 4,750 | 0.69 | 2,797 | 0.66 |
| 152 | កម្មន្តសាលកម្មផលិតផលទឹកដោះគោ | 35 | 0.01 | 24 | 0.01 |
| 153 | ផលិតផលគ្រាប់ធញ្ញជាតិ ម្សៅ ផលិតផលម្សៅ និងផលិតផលចំណីសត្វ | 4,565 | 0.67 | 3,769 | 0.90 |
| 154 | កម្មន្តសាលកម្មផលិតផលអាហារផ្សេងទៀត | 2,672 | 0.39 | 1,579 | 0.37 |
| 155 | កម្មន្តសាលកម្មភេសជ្ជៈ | 4,291 | 0.63 | 2,785 | 0.66 |

[១២] សូមអាន Acharya and Mitra (2000) ដើម្បីបញ្ជាក់ពីសកម្មភាពជនបទសំខាន់ៗ ។

| | | | | | |
|---|---|---|---|---|---|
| 160 | កម្មន្តសាលកម្មផលិតផលថ្នាំជក់ | 1,501 | 0.22 | 1,044 | 0.25 |
| 171 | ការត្បាញ រវៃ និងវាយណភ័ណ្ឌសំរេច | 11,583 | 1.69 | 10,808 | 2.55 |
| 172 | កម្មន្តសាលកម្មវាយណភ័ណ្ឌផ្សេងទៀត | 1,457 | 0.21 | 1,192 | 0.28 |
| 173 | កម្មន្តសាលកម្មក្រណាត់ និងរបស់ធ្វើពីអំបោះចាក់ផ្សេងៗ | 67 | 0.01 | 34 | 0.01 |
| 181 | កម្មន្តសាលកម្មសំលៀកបំពាក់ លើកលែងតែសំលៀកបំពាក់រោមសត្វ | 52,818 | 7.72 | 34,766 | 8.21 |
| 182 | ការកែច្នៃ និងជ្រលក់រោមសត្វ កម្មន្តសាលកម្មសំភារៈរោមសត្វ | 14 | 0.00 | 11 | 0.00 |
| 191 | ការសំលាប់និងកែច្នៃស្បែក, ហិប កាបូបដៃ ស្បែកជើង កែបសេះនិងគ្រឿងបំពាក់សេះ | 358 | 0.05 | 165 | 0.04 |
| 192 | កម្មន្តសាលកម្មស្បែកជើង | 752 | 0.11 | 352 | 0.08 |
| 201 | អារឈើ និងផលិតផលឈើ | 9,454 | 1.38 | 7,026 | 1.66 |
| 202 | អារឈើផលិតផលឈើ ស្មោរ ចំបើង សំភារៈត្បាញ | 7,415 | 1.08 | 5,727 | 1.35 |
| 210 | កម្មន្តសាលកម្មក្រដាស និងផលិតផលក្រដាស | 440 | 0.06 | 285 | 0.07 |
| 251 | កម្មន្តសាលកម្មផលិតផលកៅស៊ូ | 2,009 | 0.29 | 1,663 | 0.39 |
| 269 | កម្មន្តសាលកម្មផលិតផលរ៉ែមិនមែនដែក ដែលមិនបានចាត់ថ្នាក់ចូលខ្ទង់ផ្សេង | 7,143 | 1.04 | 5,482 | 1.29 |
| 361 | កម្មន្តសាលកម្មគ្រឿងសង្ហារឹម | 8,981 | 1.31 | 5,436 | 1.28 |
| 371 | ការច្នៃប្រើវិញនូវកាកសំណល់ និងកំទេចលោហៈ | 180 | 0.03 | 125 | 0.03 |
| 401 | ផលិតកម្ម ការប្រមូល និងការចែកចាយអគ្គិសនី | 2,651 | 0.39 | 1,229 | 0.29 |
| 451 | ការរៀបចំទីកន្លែង | 1,303 | 0.19 | 514 | 0.12 |
| 452 | ការសាងសង់សំណង់ទាំងមូល ឬមួយចំណែក វិស្វកម្មស៊ីវិល | 31,197 | 4.56 | 16,530 | 3.90 |
| 453 | ការរៀបចំអាគារ | 7,906 | 1.16 | 3,535 | 0.83 |
| 454 | ការបង្ហើយអគារ | 620 | 0.09 | 214 | 0.05 |
| 455 | ការជួលសំភារៈសំណង់ ឬសំភារៈរុះរើសំណង់ជាមួយប្រតិបត្តិករ | 4,255 | 0.62 | 1,930 | 0.46 |
| 502 | ថែទាំ និងជួសជុលយានយន្ត | 10,719 | 1.57 | 5,271 | 1.24 |
| 504 | លក់ ថែទាំ និងជួសជុលម៉ូតូ និងគ្រឿងបន្លាស់ទាក់ទិន និងគ្រឿងបន្ទាប់បន្សំ | 9,206 | 1.35 | 4,920 | 1.16 |
| 505 | លក់រាយឥន្ធនៈគ្រឿងចក្រ | 3,030 | 0.44 | 1,499 | 0.35 |
| 512 | លក់វត្ថុធាតុដើមកសិកម្ម សត្វរស់ អាហារ ភេសជ្ជៈ និងថ្នាំជក់ | 2,820 | 0.41 | 1,585 | 0.37 |
| 514 | លក់ដុំផលិតផលអន្តរការីមិនមែនកសិកម្ម កាកសំណល់ និងកំទេចកំទី | 2,267 | 0.33 | 1,009 | 0.24 |
| 521 | ពាណិជ្ជកម្មលក់រាយមិនឯកទេស | 2,296 | 0.34 | 1,226 | 0.29 |
| 522 | លក់រាយ អាហារ ភេសជ្ជៈ និងថ្នាំជក់ ក្នុងហាងឯកទេស | 2,144 | 0.31 | 955 | 0.25 |
| 525 | ពាណិជ្ជកម្មលក់រាយ មិនមែននៅក្នុងហាង | 280,840 | 41.06 | 165,240 | 39.01 |
| 526 | ជួសជុលអីវ៉ាន់ក្នុងផ្ទះ និងអីវ៉ាន់ផ្ទាល់ខ្លួន | 1,974 | 0.29 | 1,021 | 0.24 |
| 551 | សណ្ឋាគារ កន្លែងបោះជំរំ និងការផ្តល់កន្លែងស្នាក់នៅរយៈពេលខ្លីផ្សេងទៀត | 4,172 | 0.61 | 931 | 0.22 |
| 552 | ភោជនីយដ្ឋាន រង្គសាល និងអាហារដ្ឋាន | 10,388 | 1.52 | 3,863 | 0.91 |
| 602 | ដឹកជញ្ជូនតាមផ្លូវគោកផ្សេងទៀត | 106,774 | 15.61 | 65,068 | 15.36 |
| 612 | ដឹកជញ្ជូនតាមផ្លូវទឹកសាប | 2,336 | 0.34 | 1,455 | 0.34 |
| | សរុប | 683,997 | 100 | 423,570 | 100 |

ដោយសារកសិកម្មមិនបានបញ្ចូលនៅក្នុងតារាងនេះ ដូច្នេះចំនួនភាគរយនៃសកម្មភាពផ្សេងទៀត មានកំរិតខ្ពស់ជាងក្នុងតារាង៣.១ និង៣.២ ។ ម្យ៉ាងទៀត ដោយសារវាជាចំណាត់ថ្នាក់មានលេខបីខ្ទង់ ដូច្នេះមានសកម្មភាពច្រើនថែមទៀតបានផុសឡើងក្នុងតារាងនេះ បើធៀបនឹងតារាងមុនៗ ។ តួលេខក្នុងតារាងនេះបង្ហាញថា ទោះបីដកកសិកម្មចេញហើយក្តី ក៏រហូតដល់ ២/៣ នៅតែស្ថិតនៅតំបន់ជនបទ ។ គេសង្កេតឃើញទៀតថា ហាក់ដូចមានទំនាក់ទំនងយ៉ាងខ្លាំងរវាងការពង្រាយការងារ (spread of employment) តាមមុខសកម្មភាពនៅក្នុងតំបន់ជនបទ និងនៅគ្រប់តំបន់ (correlation coefficient: 0.90) គឺបានន័យថា ការពង្រាយសកម្មភាពមិនមែនកសិកម្ម មានលក្ខណៈស្រដៀងគ្នាសំរាប់តំបន់ជនបទ និងសំរាប់គ្រប់តំបន់ (យ៉ាងហោចណាស់នៅក្នុងបញ្ជីសកម្មភាពនេះ) ។

ក្រុមសកម្មភាពលេចធ្លោ (គិតតាមសមាមាត្រការងារ) គឺមានការនេសាទនិងកែច្នៃត្រី ការយករ៉ែ ការកែច្នៃម្ហូបអាហារ រ៉ែមិនមែនលោហៈ ការត្បាញរវៃ សំលៀកបំពាក់ ផលិតកម្មគ្រឿងសង្ហារឹម ការអារឈើនិងកែច្នៃឈើ ការកិនគ្រាប់ធញ្ញជាតិ អគារនិងសំណង់ ពាណិជ្ជកម្មលក់រាយ ថែទាំជួសជុលយានយន្ត ថែទាំជួសជុលទោចក្រយានយន្ត និងការដឹកជញ្ជូនផ្លូវគោក ។ សកម្មភាពនីមួយៗ (ប្រហែលក្រៅពីការអារឈើចេញ) មានលក្ខណៈសំខាន់ និងអាចមានសក្តានុពលផ្តល់កំណើនការងារក្នុងពេលអនាគត ។ ចំណុចគួរប្រយ័ត្នៈ នៅក្នុងជំរឿន គេហាក់ដូចរាប់ចំនួនការងារមិនអស់ ទាំងនៅក្នុងការដឹកជញ្ជូនផ្លូវទឹក និង សកម្មភាពនេសាទនិងកែច្នៃត្រី ។ ការងារទាំងនេះឃើញមានច្រើនក្នុងការពិតជាក់ស្តែង ជាជាងអ្វីដែលនិន្នន័យបានបង្ហាញឱ្យឃើញ។ ដោយសារជំរឿន ក៏ដូចជាអង្កេតធំៗផ្សេងទៀត បានប្រើប្រាស់ "សកម្មភាពជាគោលដើម" ជាលក្ខណៈវិនិច្ឆ័យដើម្បីធ្វើចំណាត់ថ្នាក់ពលករទៅតាមស្ថានភាពការងាររបស់គេ ដូច្នេះសកម្មភាពមួយចំនួនដែលមានលក្ខណៈរដូវកាល ឬកន្លះពេល គឺមិនត្រូវបានគេទទួលស្គាល់ពេញលេញទេ ។

## ៣.៤ របាយតាមតំបន់នៃការងារមិនមែនកសិកម្ម

ដើម្បីពិនិត្យពីការប្រែប្រួលតាមតំបន់, ចំនួនការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្ម គិតជាភាគរយនៃការងារសរុប សំរាប់ស្រុកនីមួយៗក្នុងចំណោមស្រុកទាំង ១៨៦ នៅទូទាំងប្រទេស ត្រូវបានគណនា និងស្រង់ដាក់ផែនទី ដូចបង្ហាញក្នុងក្រាហ្វិក៣.១ និង ៣.២ ។ ផែនទីទាំងពីរនេះ បានកសាងឡើងដោយគ្មានការបែងចែករវាងតំបន់ជនបទ និង តំបន់មិនមែនជនបទទេ ដោយសារនិយមន័យ (រដ្ឋបាល)បច្ចុប្បន្ន បានកំណត់ស្រុកទាំងមូលៗតែម្តងថាជា តំបន់ជនបទ ឬ តំបន់ទីក្រុង[១៣] ។ ការប្រែប្រួលអត្រាការងារមិនមែនកសិកម្ម រវាងស្រុកនានា មានកំរិតតូចទេ ។ ប៉ុន្តែទោះមានកំរិតតូចដូច្នេះក្តី ក៏ការប្រែប្រួលនៅតែមានលក្ខណៈគួរកត់សំគាល់ ។ ស្រុកនានានៅក្រុងភ្នំពេញ និងនៅតាមខេត្តនៅភាគខាងលិចនិងខាងជើង គឺមានការងារមិនមែនកសិកម្មមានច្រើនគួរសម ឯនៅកន្លែងឯទៀតមានតិចជាង ។ ម្យ៉ាងទៀត មានស្រុកមួយចំនួននៅជុំវិញក្រុងភ្នំពេញ នៅតំបន់បឹងទន្លេសាប និងស្រុកខ្លះៗក្នុងភាគកណ្តាលនៃតំបន់ឦសាន និងតំបន់ខាងជើង, ដែលមានការងារមិនមែនកសិកម្មមួយចំនួនដែរ ។ ក្នុងមួយភាគធំនៃតំបន់ឦសាន និងកន្លែងជាច្រើននៃតំបន់វាលទំនាបមេគង្គ, ការងារមិនមែនកសិកម្មមានតិចជាង ៥% នៃការងារសរុប ។ មូលហេតុមួយគឺ នៅតាមតំបន់ដែលមានដីដាំដុះច្រើនៗ ប្រជាជនមិនបានងាកចេញពីការងារកសិកម្មទេ ។

នៅស្ទើរគ្រប់កន្លែង ពលករបុរស មានច្រើនជាង ពលករស្ត្រី នៅក្នុងការងារមិនមែនកសិកម្ម។ ដូចបានលើកពីខាងដើម ហេតុផលសមរម្យជាងគេដើម្បីពន្យល់រឿងនេះគឺ ពលករស្ត្រីមានលទ្ធភាពតូចជាងក្នុងការផ្លាស់ប្តូរទីកន្លែង និងមុខរបរ ។

---

[១៣] ដោយសារ (ក្រៅពីក្រុងមួយចំនួនដូចជា ភ្នំពេញ ក្រុងព្រះសីហនុ និងសៀមរាប) ស្ទើរតែទូទាំងប្រទេសបង្ហាញនូវលក្ខណៈជាជនបទ ដូច្នេះការកសាងផែនទីសរុបនេះ គឺហាក់ដូចតំណាងបានល្អនូវតំបន់ជនបទនានា ។

ដើម្បីបានស្ថិតិប៉ាន់ស្មានពីការប្រែប្រួលក្នុងការងារមិនមែនកសិកម្ម, មានការគណនា មធ្យមភាគ និង គំលាតស្តង់ដា (mean and standard deviation) នៃការងារមិនមែនកសិកម្មសំរាប់ ពលករស្ត្រី និង បុរស ដោយផ្អែកលើទិន្នន័យកំរិតស្រុក ។ តំលៃមធ្យមនៃកំរិតភាគរយនៃការងារមិនមែនកសិកម្មគឺ ២៧,៣៣%សំរាប់បុរស និង ១៧,៦០% សំរាប់ស្ត្រី ។ ប៉ុន្តែតំលៃគំលាតស្តង់ដា ដែលជាប់ទាក់ទិនគឺ ២២,៦៤ និង ២៣,៥០ ដែលជាតួលេខខ្ពស់ណាស់ បើធៀបនឹងតំលៃមធ្យមភាគ, ដូច្នេះពុំមាននិន្នាការកណ្ដាលណាមួយដែលធំគួរសមទេ ។ ការប្រែប្រួលយ៉ាងធំតាមតំបន់នៅក្នុងចំរុះកម្មការងារនេះ បានផ្ដល់គំនិតថា មានរូបភាពខុសប្លែកគ្នាច្រើននៅក្នុងប្រទេសកម្ពុជា គឺខុសពីការយល់ឃើញជាទូទៅថា នៅតាមតំបន់ឆ្ងាយៗ (ពីក្រុង, ទន្លេ, សមុទ្រ) ក្នុងប្រទេសកម្ពុជា ពុំមានសកម្មភាពអ្វីច្រើនទេក្រៅតែពីការធ្វើស្រែ ។

**ក្រាហ្វិក៣.១ សមាមាត្រពលករបុរស ក្នុងវិស័យមិនមែនបឋមនៅកំរិតស្រុក នៅឆ្នាំ១៩៩៨**




**ក្រាហ្វិក៣.២ សមាមាត្រពលករស្ត្រី ក្នុងវិស័យមិនមែនបឋមនៅកំរិតស្រុកនៅឆ្នាំ១៩៩៨**




ដើម្បីសិក្សាលំអិតថែមទៀតពីការប្រែប្រួលតាមតំបន់, ទិន្នន័យការងារនៅកំរិតខេត្តត្រូវបានបំបែកចេញជា ១៧វិស័យ (តារាង៣.៤ និង ៣.៥)[១៤] ។ មូលហេតុនៃការបង្កើតតារាងទាំងនេះ គឺដើម្បីស្រាវជ្រាវពីការប្រែប្រួលខុសគ្នារវាងតំបន់នានា នៅក្នុងសកម្មភាពមិនមែនកសិកម្ម គិតតាមមុខនិមួយៗនៃក្រុមសកម្មភាពចំបងៗ ទាំង ១៧វិស័យ ។ ដូចបានបញ្ជាក់ពីខាងដើម

[១៤] វិស័យទាំង១៧នេះ បានធ្វើចំណាត់ថ្នាក់ក្នុង ជំរឿនប្រទេសកម្ពុជា ដោយអនុលោមតាមចំណាត់ថ្នាក់អន្តរជាតិនៃមុខសកម្មភាព ។

ទិន្នន័យទាំងនេះទាក់ទិននឹងទូទាំងប្រទេស មិនមែនត្រឹមតែតំបន់ជនបទនោះទេ ។ មធ្យមភាគ និង គំលាតស្តង់ដារ (mean and standard deviation) ក្នុងកំរិតភាគរយនៃការងារនៅក្នុងវិស័យនីមួយៗ មានបង្ហាញក្នុង តារាង៣.៤ ។ ទិន្នន័យលំអិតតាមខេត្ត មានបង្ហាញនៅក្នុង តារាង៣.៥ ។

**តារាង៣.៤ មធ្យមភាគការងារជាភាគរយ នៅក្នុងវិស័យទាំង ១៧ : មធ្យមភាគ និងមេគុណបំរែបំរួល**

| | វិស័យ | មធ្យមភាគ | គំលាតស្តង់ដា | មេគុណបំរែបំរួល (%) |
|---|---|---|---|---|
| 1. | កសិកម្ម និងសកម្មភាពជាប់ទាក់ទិន | 73.64 | 19.51 | 26.49 |
| 2. | នេសាទ និងសកម្មភាពជាប់ទាក់ទិន | 2.11 | 3.51 | 166.35 |
| 3. | ការយករ៉ែ | 0.39 | 0.95 | 243.59 |
| 4. | កមន្តសាលកម្ម | 2.13 | 1.74 | 81.89 |
| 5. | អគ្គិសនី ទឹក និងឧស្ម័ន | 0.05 | 0.12 | 240.00 |
| 6. | សំណង់ | 0.90 | 1.15 | 127.78 |
| 7. | ពាណិជ្ជកម្មលក់ដុំ | 6.82 | 5.32 | 78.01 |
| 8. | សណ្ឋាគារ និងភោជនីយដ្ឋាន | 0.27 | 0.51 | 188.89 |
| 9. | ដឹកជញ្ជូន | 2.49 | 2.53 | 101.61 |
| 10. | សេវាហិរញ្ញវត្ថុ | 0.02 | 0.05 | 250.00 |
| 11. | ប្រតិបត្តិការលើអចលនទ្រព្យ | 0.05 | 0.07 | 140.00 |
| 12. | រដ្ឋបាលសាធារណៈ និងការពារជាតិ | 6.42 | 5.16 | 80.37 |
| 13. | អប់រំ | 1.45 | 0.53 | 36.55 |
| 14. | សុខាភិបាល | 0.52 | 0.38 | 90.48 |
| 15. | សេវាសហគមន៍ | 1.29 | 0.97 | 75.19 |
| 16. | ការងារឯកជន | 0.18 | 0.33 | 183.33 |
| 17. | ការងារក្នុងអង្គការនៅក្រៅប្រទេស | 0.17 | 0.23 | 135.29 |

ក្នុងចំណោមវិស័យទាំង១៧ មានតែ ៧វិស័យទេ ដែលមេគុណបំរែបំរួល (coefficient of variation: of the proportion employment in differents sectors) មានកំរិតទាបជាង ១០០% (មានមួយដែលតិចជាង ៣០%) ។ ដូច្នេះមានបំរែបំរួលយ៉ាងធំរវាងតំបន់នានា ហើយរឿងនេះផ្តល់គំនិតថា តំបន់នីមួយៗអាចមានឧត្តមភាពប្រៀបធៀបខ្លះៗនៅក្នុងសកម្មភាពណាមួយ ។

## ៣.៥ សង្ខេប

ការវិភាគក្នុងជំពូកនេះ បានគាំទ្រដល់គំហើញក្នុងជំពូកទី២ ដែលថា ចំរុះកម្មមុខរបរក្រៅពីកសិកម្ម មានតិចតួចណាស់នៅក្នុងប្រទេសកម្ពុជា ។ ម្យ៉ាងទៀត ភាគច្រើននៃចំរុះកម្មមុខរបរ កើតមានក្នុងវិស័យនានាដែលពឹងផ្អែកលើធនធានធម្មជាតិ ហើយទំនាក់ទំនងបែបក្លាសិក រវាង *"ផលិតភាពកសិកម្មខ្ពស់"* និង *"កំណើនវិស័យមិនមែនកសិកម្ម"* គឺមិនទាន់បង្កើតបានទេនៅកម្ពុជា ។ នៅទសវត្សរ៍១៩៩០ ការផ្លាស់ប្តូរឃើញកើតមានខ្លះដែរ ប៉ុន្តែក្នុងកំរិតតិចតួច ។ គេមិនអាចប៉ាន់ស្មានកើតទេពីទំហំនៃការផ្លាស់ប្តូរពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារគ្មានមូលដ្ឋានទិន្នន័យកំរិតម៉ាក្រូណាមួយសោះដែលអាចប្រៀបធៀបគ្នាបាន ។ បន្ទាប់មក មានការប្រែប្រួលខុសគ្នាយ៉ាងច្រើនរវាងតំបន់នានា (ទាំងរវាងស្រុក និង រវាងខេត្ត) នៅក្នុងទំហំ និងមុខការងារដែលប្រជាជនរកបាន ក្រៅពីការងារកសិកម្ម ។ ស្ថិតិទាំងនេះបានផ្តល់គំនិតថា ទោះបីសកម្មភាពក្រៅកសិដ្ឋាន និង សកម្មភាពមិនមែនកសិកម្ម មានតិចតួចក្តី ក៏ប៉ុន្តែវាមានច្រើនមុខណាស់ ។

## តារាង៣.៥ សមាមាត្រការងារ គិតតាម ១៥វិស័យសកម្មភាពចំបងៗ និង គិតតាមខេត្តនិមួយៗ

| ខេត្ត | C1 | C2 | C3 | C4 | C5 | C6 | C7 | C8 | C9 | C10 | C11 | C12 | C13 | C14 | C15 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| បន្ទាយមានជ័យ | 75 | 0.39 | 0.39 | 2.04 | 0.02 | 0.66 | 7.73 | 0.16 | 5.60 | 0.00 | 0.03 | 4.17 | 1.44 | 0.56 | 1.78 |
| បាត់ដំបង | 69 | 1.62 | 0.12 | 2.73 | 0.04 | 1.15 | 9.58 | 0.18 | 3.41 | 0.01 | 0.07 | 7.11 | 1.93 | 0.71 | 1.76 |
| កំពង់ចាម | 84 | 0.98 | 0.04 | 2.18 | 0.03 | 0.50 | 5.20 | 0.07 | 1.38 | 0.01 | 0.03 | 2.03 | 1.55 | 0.36 | 1.12 |
| កំពង់ឆ្នាំង | 81 | 4.40 | 0.03 | 1.34 | 0.01 | 0.30 | 5.38 | 0.06 | 1.28 | 0.01 | 0.03 | 3.13 | 1.35 | 0.37 | 1.19 |
| កំពង់ស្ពឺ | 89 | 0.03 | 0.06 | 0.80 | 0.01 | 0.21 | 2.81 | 0.06 | 0.81 | 0.00 | 0.02 | 3.05 | 1.35 | 0.29 | 0.96 |
| កំពង់ធំ | 84 | 1.70 | 0.06 | 1.37 | 0.01 | 0.32 | 4.28 | 0.10 | 1.09 | 0.01 | 0.03 | 3.10 | 1.61 | 0.37 | 1.19 |
| កំពត | 86 | 1.31 | 0.35 | 1.01 | 0.01 | 0.30 | 3.54 | 0.06 | 1.08 | 0.01 | 0.03 | 2.87 | 1.69 | 0.36 | 1.02 |
| កណ្តាល | 74 | 2.12 | 0.08 | 5.03 | 0.06 | 1.02 | 6.93 | 0.22 | 2.42 | 0.01 | 0.04 | 3.40 | 1.79 | 0.44 | 1.69 |
| កោះកុង | 36 | 16.00 | 0.08 | 5.40 | 0.06 | 1.74 | 14.81 | 0.57 | 8.83 | 0.03 | 0.08 | 10.04 | 0.80 | 0.63 | 2.95 |
| ក្រចេះ | 77 | 1.60 | 0.07 | 3.17 | 0.01 | 0.94 | 6.72 | 0.16 | 3.69 | 0.00 | 0.03 | 3.28 | 1.79 | 0.49 | 1.27 |
| មណ្ឌលគិរី | 75 | 0.12 | 3.25 | 0.85 | 0.01 | 0.80 | 4.61 | 0.12 | 0.93 | - | 0.10 | 9.93 | 0.85 | 0.76 | 1.93 |
| ភ្នំពេញ | 9 | 0.87 | 0.14 | - | 0.54 | 5.24 | 26.12 | 2.35 | 8.56 | 0.24 | 0.38 | 16.08 | 3.22 | 2.21 | 8.03 |
| ព្រះវិហារ | 83 | 0.16 | 0.09 | 0.77 | - | 0.15 | 2.29 | 0.06 | 0.42 | 0.00 | 0.02 | 10.06 | 1.23 | 0.31 | 0.85 |
| ព្រៃវែង | 90 | 0.55 | 0.08 | 0.93 | 0.01 | 0.21 | 3.56 | 0.02 | 0.80 | 0.01 | 0.02 | 1.64 | 1.41 | 0.27 | 0.66 |
| ពោធិសាត់ | 79 | 3.45 | 0.07 | 1.71 | 0.04 | 0.23 | 6.32 | 0.09 | 1.39 | 0.03 | 0.02 | 4.01 | 1.59 | 0.49 | 1.33 |
| រតនគិរី | 88 | 0.07 | 0.12 | 0.92 | 0.01 | 0.30 | 3.01 | 0.06 | 0.66 | 0.01 | 0.05 | 4.53 | 0.59 | 0.43 | 0.64 |
| សៀមរាប | 80 | 2.21 | 0.10 | 1.27 | 0.04 | 1.01 | 5.05 | 0.30 | 1.37 | 0.01 | 0.05 | 5.25 | 1.18 | 0.34 | 1.51 |
| កំពង់សោម | 42 | 8.68 | 0.16 | 7.41 | 0.26 | 3.47 | 14.86 | 1.32 | 7.76 | 0.06 | 0.10 | 7.75 | 1.84 | 0.74 | 3.25 |
| ស្ទឹងត្រែង | 79 | 0.33 | 0.01 | 1.66 | 0.01 | 0.74 | 5.56 | 0.14 | 2.08 | 0.02 | 0.02 | 7.41 | 1.23 | 0.62 | 1.03 |
| ស្វាយរៀង | 90 | 0.03 | 0.01 | 0.62 | 0.01 | 0.20 | 3.27 | 0.05 | 0.62 | 0.03 | 0.02 | 1.98 | 1.51 | 0.30 | 0.89 |
| តាកែវ | 90 | 0.12 | 0.01 | 1.50 | 0.01 | 0.21 | 2.51 | 0.04 | 0.67 | 0.01 | 0.02 | 1.86 | 1.72 | 0.28 | 1.03 |
| ឧត្តរមានជ័យ | 79 | 0.04 | 0.01 | 0.95 | 0.02 | 0.09 | 2.39 | 0.05 | 0.61 | - | 0.01 | 14.18 | 1.14 | 0.32 | 1.07 |
| កែប | 77 | 4.54 | 0.48 | 0.80 | 0.01 | 0.87 | 5.37 | 0.07 | 1.41 | 0.02 | 0.02 | 5.98 | 1.20 | 0.31 | 1.21 |
| ប៉ៃលិន | 49 | 0.03 | 3.77 | 3.67 | 0.01 | 0.87 | 11.76 | 0.25 | 3.00 | 0.01 | 0.04 | 23.02 | 0.48 | 0.58 | 0.73 |
| សរុប | 76 | 1.47 | 0.12 | 3.10 | 0.07 | 0.93 | 6.90 | 0.30 | 2.34 | 0.03 | 0.06 | 4.54 | 1.66 | 0.54 | 1.78 |

*សំគាល់: C1 និង C2 សំដៅដល់ ក្រុមសកម្មភាពផ្សេងៗ ដូចមានចុះក្នុងតារាង៣.៥*
*នៅក្នុងតារាងនេះ មានតែ ១៥ ក្រុមទេ ដោយសារក្រុម១៦ និង ១៧ បានបូកបញ្ចូលគ្នាជាមួយ ក្រុម១៥ ។*

# ជំពូកទី ៤

# ការពិពណ៌នាពីមុខសកម្មភាពការងារ នៅជនបទកម្ពុជា[១៥]

អាជ្ញាធរកម្ពុជាបានធ្វើ ជំរឿនគ្រឹះស្ថានទូទាំងប្រទេស លើកក្រោយបំផុតនៅឆ្នាំ១៩៩៥[១៦] យោងតាមជំរឿន នៅពេលនោះមានតែ ៨២៩គ្រឹះស្ថានអាជីវកម្មប៉ុណ្ណោះ ក្នុងនេះមាន ៩៤%ជាគ្រឹះស្ថានកម្មន្តសាលកម្ម ។ ប៉ុន្តែជំរឿនបានធ្វើអង្កេតតែលើគ្រឹះស្ថានណាដែលមានកម្មករចាប់ពី ១០នាក់ ឡើងទៅ ។ ម្យ៉ាងទៀត អង្កេតមានលំអៀងយ៉ាងខ្លាំងទៅខាងសកម្មភាពកម្មន្តសាលកម្មដែលតាំងនៅតំបន់ទីក្រុង ។ ដោយសារមានការផ្លាស់ប្តូរយ៉ាងច្រើនក្នុងរយៈពេល ៧ឆ្នាំ តាំងពីឆ្នាំ១៩៩៥ មក ការទាញយកសេចក្តីសន្និដ្ឋានផ្សេងៗនៅពេលនេះដោយប្រើអង្កេតខាងលើ អាចមិនសូវលក្ខណៈជាប់ទាក់ទិនល្អទេ ។ ដោយមើលឃើញចំណុចខ្វះខាតទាំងនេះ របកគំហើញក្នុងអង្កេតខាងលើមិនត្រូវបានប្រើប្រាស់ក្នុងការសិក្សានេះដើម្បីពិពណ៌នាពីការងារនៅជនបទ ឬ សកម្មភាពមិនមែនកសិកម្មនោះទេ ។

ការវិភាគក្នុងជំពូកមុនៗ បានផ្តល់គំនិតពីវិស័យមួយចំនួនដែលមានលក្ខណៈលេចធ្លោដោយសារទំហំ ឬកំណើន ។ ជំពូកនេះ នឹងប្រឹងប្រែងធ្វើការសិក្សានូវសកម្មភាពជ្រើសរើសមួយចំនួន នៅក្នុងក្រុមសកម្មភាពនានា ព្រមទាំងពិពណ៌នាពីសកម្មភាពមិនមែនកសិកម្មទាំងឡាយដែលមានទិន្នន័យស្រាប់ ឬដែលប្រមូលទិន្នន័យបាន ។

## ៤.១ ម៉ាស៊ីនកិនស្រូវ

ការកែច្នៃស្រូវជាសកម្មភាពមួយមានយូរយារណាស់មកហើយក្នុងប្រទេសកម្ពុជា ទោះបីវាមិនមែនជាសកម្មភាពលេចធ្លោក្តី ពីព្រោះតាំងពីដើមរៀងមក ស្រូវភាគច្រើនត្រូវបានកែច្នៃនៅក្នុងស្រុក សំរាប់ការប្រើប្រាស់ក្នុងស្រុក ។ ឬសគល់ថ្មីរបស់វាអាចចាប់ផ្តើមពីត្រឹមការរស់ឡើងវិញនៃ*ក្រុមសាមគ្គី* ក្នុងទសវត្សរ៍១៩៨០ ។ នៅពេលសេដ្ឋកិច្ចទីផ្សារបានចាក់ឬសនៅឆ្នាំ១៩៩៣ សកម្មភាពកិនស្រូវ ក៏កាន់តែលេចធ្លោឡើង ។ ចំនួនរោងម៉ាស៊ីនកិនស្រូវក៏បានកើនឡើងដែរ តាមពិតទៅគេគិតថា កំណើននៃឧស្សាហកម្មនេះនៅឆ្នាំ១៩៩៣-២០០១ វាខ្ពស់ជាងកំណើនក្នុងផលិតកម្មស្រូវ ។ នៅដើមទសវត្សរ៍២០០០ គេប៉ាន់ស្មានថាមាន ៤០០រោងម៉ាស៊ីនកិនស្រូវ កំពុងប្រតិបត្តិការនៅក្នុងប្រទេស ជាបន្ថែមទៅលើប្រហែល ១.០០០រោងម៉ាស៊ីនតូចៗផ្សេងទៀតដែលមានលក្ខណៈជាអង្គភាពពាណិជ្ជកម្មកំរិតភូមិ ។ ក្រៅពីនេះ នៅមានសំភារៈកិនស្រូវជាច្រើនទៀតធ្វើប្រតិបត្តិការដោយគ្រួសារ ប៉ុន្តែគេមិនបានយកមករាប់បញ្ចូលក្នុងការសិក្សានេះទេ ពីព្រោះវាស្ថិតនៅក្នុងក្របខ័ណ្ឌគ្រួសារ ។

---

[១៥] ក្រៅតែពីសកម្មភាពកិនស្រូវ និងការផលិតអគ្គីសនីនៅជនបទ, គំហើញក្នុងជំពូកនេះផ្អែកលើអង្កេតបឋមនានាដែលធ្វើឡើងសំរាប់ការសិក្សានេះ ។ ពត៌មានបានពីការសិក្សានានាដែលមានស្រាប់ បានយកមកបំពេញបន្ថែមលើទិន្នន័យបឋម ក្នុងគ្រប់ករណីទាំងអស់ ។

[១៦] ជំរឿនគ្រឹះស្ថានទូទាំងប្រទេសមួយបានធ្វើឡើងនៅឆ្នាំ២០០១-០២ ប៉ុន្តែលទ្ធផលមិនរំពឹងថាអាចទទួលបានមុនឆ្នាំ២០០៣ទេ ។ គេក៏មិនទាន់ដឹងដែរពីតំបន់គ្របដណ្តប់របស់វា ។

មានតំបន់ចំបងៗពីរដែលអង្គភាពកិនស្រូវពាណិជ្ជកម្មតាំងនៅ គឺ ភាគខាងលិច (ជាពិសេសខេត្តបាត់ដំបង និងបន្ទាយមានជ័យ) និង ភាគអគ្នេយ៍ (ជាពិសេសខេត្តព្រៃវែង តាកែវ ស្វាយរៀង និងកណ្តាល) ដែលជាតំបន់ផលិតស្រូវដ៏ចំបងផងដែរ ។ ម៉ាស៊ីនកិនស្រូវភាគច្រើនផលិតនៅ ចិន រុស្ស៊ី ឬវៀតណាម អូសទាញដោយម៉ាស៊ីនម៉ាស៊ូតចាស់ៗមានប្រសិទ្ធិភាពទាប ដែលធ្វើ ឱ្យរោងកិនស្រូវមានផលិតភាពទាបដែរ ។ ការចាញ់ប្រៀបមួយដែលម្ចាស់រោងម៉ាស៊ីនកិនស្រូវកម្ពុជាត្រូវជួបប្រទះគឺ គេទិញ ប្រេងម៉ាស៊ូតជាលុយដុល្លារ ហើយលក់ផលិតផលជាលុយ រៀល បាត ឬ ដុង ។ គេត្រូវខាតបង់ដោយសារការប្រែប្រួលចុះថ្លៃនៃ លុយ បាត និង ដុង ។ ស្រូវមួយចំនួននៅតែបន្តនាំចេញទៅប្រទេសជិតខាងដើម្បីកែច្នៃ ដោយសាររោងម៉ាស៊ីនបរទេសមានបច្ចេកវិទ្យាល្អជាងរោងម៉ាស៊ីនក្នុងស្រុក ហើយនេះជាការបាត់បង់តំលៃបន្ថែម និងការងារចំពោះកម្ពុជា ។

សំរាប់រោងម៉ាស៊ីនកិនស្រូវនៅកម្ពុជា មានរបៀបធ្វើប្រតិបត្តិការពីរបែបគឺ ការកិនឱ្យអតិថិជនផ្ទាល់ និងការកិនសំរាប់ទីផ្សារ ។ ក្នុងរបៀបទី១ ម្ចាស់ម៉ាស៊ីនធ្វើប្រតិបត្តិការតាមសំណើឱ្យកិនពីអតិថិជន ហើយទទួលផលកំរៃជាកន្ទក់ និងអង្កាមជាជាងការយកថ្លៃឈ្នួលជាប្រាក់ ។ រោងម៉ាស៊ីនតូចៗ (ដែលមានសមត្ថភាពផលិតបានជាង ៥០០គ.ក/ម៉ោង ហើយមានទុនអចល័តលើសពី ៥.០០០ដុល្លារ) អនុវត្តប្រតិបត្តិការកិនឱ្យអតិថិជនផ្ទាល់ជាសំខាន់ និងធ្វើសកម្មភាពតាមរដូវបានយ៉ាងច្រើន ៦ខែ ក្នុងមួយឆ្នាំ ។ រោងម៉ាស៊ីនធំៗ (សមត្ថភាពផលិតលើសពី ៥០០គ.ក/ម៉ោង ហើយរោងម៉ាស៊ីនខ្លះមានទុនអចល័តលើសពី ៣០.០០០ដុល្លារ) ជាទូទៅមានដំណើរការពេញៗមួយឆ្នាំ ។ ពួកគេទិញស្រូវពីភូមិខ្លួនផ្ទាល់ និងពីភូមិជិតខាង នៅពេលថ្លៃស្រូវអំណោយផលល្អ ធ្វើការកិនស្រូវ ហើយលក់ទៅទីផ្សារក្នុងមូលដ្ឋាន និងនៅតាមទីក្រុងនានា ។ ជួនកាលមានលក់ចេញទៅទីផ្សារអន្តរជាតិដែរ តែដោយកំរណាស់ ។ ដោយសារកំណើនពាណិជ្ជភាវូបនីយកម្មក្នុងវិស័យស្រូវអង្ករ ប្រតិបត្តិការកិនឱ្យអតិថិជនផ្ទាល់មិនសូវរីកចំរើនទៅមុខទេ ឯការកិនបំរើទីផ្សារកាន់តែមានច្រើនឡើង ។

រោងម៉ាស៊ីនកិនស្រូវស្ទើរតែទាំងអស់ ជាកម្មសិទ្ធិ និងធ្វើប្រតិបត្តិការដោយគ្រួសារឯកជន និងដោយគ្មានបុគ្គលិកជំនាញទេ ។ ប្តីប្រពន្ធ និងសាច់ញាតិ គឺជាកំលាំងពលកម្មសំខាន់ ហើយចំនួនបុគ្គលិកសរុបនៅសហគ្រាសនិមួយៗមានពី ៥-១០នាក់ ។ រោងម៉ាស៊ីនជាច្រើនគ្មានកាន់បញ្ជីគណនេយ្យ និងគ្មានកត់ពតិមានលំអិតដូចជា ទិន្នន័យ សារពើភ័ណ្ឌ ធាតុចូល និងធាតុចេញទេ ។ វិស័យទាំងមូលប្រឈមមុខនឹងកង្វះខាតទុនបង្វិល ដែលជាបញ្ហាមួយដ៏ចំបង ។ រោងម៉ាស៊ីនកិនស្រូវធំៗមានទទួលប្រាក់ខ្ចីខ្លះៗពីប្រភពស្ថាប័ន ប៉ុន្តែរោងម៉ាស៊ីនកិនតូចៗមិនបានទទួលទេ ហើយជាង ៦០%នៃរោងម៉ាស៊ីន មិនដែលខ្ចីបុលគេសោះ ។ ការលំបាកផ្សេងៗទៀតគឺមាន ការប្រើប្រាស់សមត្ថភាព និងទីផ្សារ (EDC 2001a)[១៧] ។ អត្រាទាញចំណូលប្រចាំឆ្នាំលើមូលធនបានប្រហែល ៥-២០% ហើយរោងម៉ាស៊ីនធំៗនិងថ្មីៗ មានទិន្នផលខ្ពស់ជាងរោងម៉ាស៊ីនតូចៗនិងចាស់ៗ (EDC 2001a) ។ រោងម៉ាស៊ីនកិនស្រូវ គឺជាទំនាក់ទំនងទៅមុខ (ទៅជិតអ្នកប្រើប្រាស់) មួយយ៉ាងសំខាន់សំរាប់ផលិតកម្មស្រូវ ដែលជាផលដំណាំកសិកម្មសំខាន់ជាងគេ ។ ប៉ុន្តែសក្តានុពលរបស់វាក្នុងការផ្តល់ការងារដោយផ្ទាល់ គឺមានលក្ខណៈរដូវកាលជាសំខាន់ និងមិនបានច្រើនប៉ុន្មានទេ ប៉ុន្តែផលចំណេញបន្ទាប់បន្សំបានពីការដឹកជញ្ជូន និងការស្តុកទុកដាក់អាចមានទំហំធំ ។

## ៤.២ ការផ្គត់ផ្គង់អគ្គីសនីនៅជនបទ

ក្នុងពេលបច្ចុប្បន្ននៅកម្ពុជា មានគ្រួសារប្រជាជនមិនលើសពី ១៥% ទេដែលតភ្ជាប់នឹងបណ្តាញអគ្គីសនី (២៦០.០០០គ្រួសារតាម ទិន្នន័យឆ្នាំ១៩៩៨) ។ បណ្តាញដាច់ៗពីគ្នាតភ្ជាប់បានប្រហែល ១៨០.០០០គ្រួសារ ឯ ៨០.០០០គ្រួសារទៀតទទួលថាមពលអគ្គីសនីពីម៉ាស៊ីនភ្លើងនៅតាមមូលដ្ឋាន និងអាគុយត្រូវបញ្ចូលអគ្គីសនីវិញ (សាកអាគុយ), ហើយសេវាទាំងនេះផ្តល់ដោយសហគ្រាស អគ្គីសនីជនបទខ្នាតតូច (REE) ដែលធ្វើប្រតិបត្តិការជាលក្ខណៈពាណិជ្ជកម្ម ។ សកម្មភាពនេះមួយភាគធំ

[១៧] សំភាសន៍ជាមួយបុគ្គលិក EDC មានសារៈសំខាន់ណាស់នៅក្នុងការប្រមូលយកពតិមាន ។

ស្ថិតនៅតាមបណ្តាខេត្តខាងភាគពាយព្យ ។

សព្វថ្ងៃមានសហគ្រាសពីរប្រភេទកំពុងធ្វើប្រតិបត្តិការៈ សហគ្រាសដែលផលិតនិងចែកចាយថាមពល និងសហគ្រាសសាកអាគុយ ។ សហគ្រាសប្រតិបត្តិការទាំងពីរប្រភេទ ក៏មានមួយចំនួនដែរ ។ អាជីវកម្មមួយភាគធំប្រើម៉ាស៊ីនភ្លើងម៉ាស៊ូតចាស់ៗ ផលិតនៅ ចិន ឬ រុស្ស៊ី ដែលមានប្រសិទ្ធិភាពទាប និងខូចជាញឹកញយ។ ការថែទាំក៏អនុវត្តបានតិចជាងតំរូវការនៃសំភារៈដែរៈ តំរូវការរើម៉ាស៊ីនក្រោយប្រើបាន ៤.០០០-៥.០០០ម៉ោង កំរបានអនុវត្តណាស់ ។

សហគ្រាសនីមួយៗមានទ្រព្យសកម្មជាមធ្យមតំលៃប្រហែល ១៧.៦៣៣ដុល្លារ និងជួលបុគ្គលិក ៥នាក់ (៣នាក់ធ្វើការពេញម៉ោង, ២នាក់ទៀតធ្វើកន្លះពេល) ។ ថ្លៃដើមថាមពលជាមធ្យម គឺប្រហែល ០,៣០-០,៤៥ដុល្លារក្នុងមួយគីឡូវ៉ាត់ម៉ោង ដែលខ្ពស់ខ្លាំងណាស់ ជាពិសេសបើធៀបនឹងថ្លៃដើមប្រហែលតែ ០,១០ដុល្លារ ក្នុងប្រព័ន្ធខ្នាតធំនៅប្រទេសឯទៀត។ ថាមពលបញ្ជូនតាមខ្សែភ្លើងគ្មានខ្នាត ចងលើបង្គោលឈើ ។ ការបញ្ជូនចរន្តមានការខាតបង់យ៉ាងច្រើន (ច្រើនជាង ៣០%) ពីព្រោះបង្គោលច្រើនតែគ្មានការជួសជុលទេ រហូតដល់វាដួល ។ អតិថិជនបង់ថ្លៃតាមអត្រាកំណត់មួយដែលកំរលើសពី ១-២ដុល្លារ/ខែ សំរាប់ថាមពល ១-២គីឡូវ៉ាត់ម៉ោង ហើយពិនិត្យតាមគុណភាពសេវា អតិថិជនគេមិនបង់ច្រើនជាងនេះទេ ។ ការប្រមូលថ្លៃអគ្គិសនីអនុវត្តមិនធ្វើបាន ១០០% ទេ។ ដូច្នេះមូលដ្ឋានចំណូលគឺទាប ហើយនេះជាមូលហេតុចំបងនៃការមិនបានផ្លាស់ប្តូរសំភារៈចាស់ៗចេញ ។ អត្រាទាញចំណូលប្រចាំឆ្នាំលើមូលធន បានប្រហែលតែ ៥% ប៉ុណ្ណោះ (EDC 2001b; EDC 2001c) ។

ចំនួនមធ្យមនៃអតិថិជនក្នុងមួយសហគ្រាសគឺ ១៩២គ្រួសារ ។ សេវាផ្គត់ផ្គង់តាមមួយកន្លែងៗដាច់ពីគ្នា និងសំរាប់តែការបំភ្លឺក្នុងផ្ទះ ។ គ្រួសារនានាទទួលអគ្គិសនីបានប្រហែល ៤ម៉ោង/ថ្ងៃ ។ មានតែ ៧% នៃ REEs ទេ ដែលផ្តល់អគ្គិសនីលើសពីតំរូវការនៃចង្កៀងបំភ្លឺតាមផ្ទះ ។

សហគ្រិនជាទូទៅច្រើនមានសញ្ញាប័ត្រថ្នាក់មធ្យមសិក្សា ប៉ុន្តែមានតិចនាក់ណាស់បានទទួលការបណ្តុះបណ្តាលបច្ចេកទេស ។ មានមួយចំនួនតូចបានទទួលការបណ្តុះបណ្តាលរយៈពេលខ្លី ។ ម្ចាស់សហគ្រាសភាគច្រើន ទទួលពតិមានបច្ចេកទេសលំអិតលើសំភារៈបរិក្ខារ និងការបញ្ជូនថាមពល តាមរយៈអ្នកផ្គត់ផ្គង់សំភារៈឱ្យ ។ និយោជិត ច្រើនជ្រើសរើសនៅនឹងមូលដ្ឋាន ហើយទទួលការបណ្តុះបណ្តាលភ្ជាប់នឹងការងារតែម្តង ។

ថ្វីបើរដ្ឋាភិបាលបានទទួលស្គាល់អាជីវកម្មនេះ (ទោះពុំមានចងក្រងច្បាប់គ្រប់គ្រងក្តី) ហើយអ្នកផ្គត់ផ្គង់ប្រហែលពាក់កណ្តាលមានអាជ្ញាប័ណ្ណធ្វើអាជីវកម្មក្តី ក៏ពួកគេបានរាយការណ៍ថា មិនដែលបានទទួលការជួយទ្រទ្រង់ពីរដ្ឋទេ ដោយសារលក្ខណៈទន់ខ្សោយក្នុងការផ្តល់អាជ្ញាប័ណ្ណ ។ មានតែ ១០% នៃ REEs ប៉ុណ្ណោះដែលរាយការណ៍ថាបានទទួលឥណទានពីស្ថាប័នហិរញ្ញវត្ថុនានា, ចំណែកឯ ៤០% ផ្សេងទៀតខ្ចីបុលពីប្រភពឯកជន ។ គ្មានសហគ្រិនណាណាមួយ បានទទួលជំនួយទ្រទ្រង់បច្ចេកទេសពីប្រភពស្ថាប័នទេ ។

អគ្គិសនីជនបទ មានសារៈសំខាន់ណាស់សំរាប់ការធ្វើទំនើបកម្មប្រទេសកម្ពុជា។ ប៉ុន្តែឧស្សាហូបនីយកម្មខ្នាតតូចដូចខាងលើនេះ ប្រហែលមិនអាចក្លាយជាជំរើសរយៈពេលវែងមួយសំរាប់ប្រទេសកម្ពុជាទេ យោងតាម អត្រាផលិតថាមពល *ក្នុងមនុស្សម្នាក់* គឺនៅតែទាប, បច្ចេកវិទ្យាចាស់គំរិល និងបន្ទុកចំណាយខ្ពស់ ។ ម្យ៉ាងទៀតសក្តានុពលផ្តល់ការងារក៏ទាបដែរ ។ ប៉ុន្តែទោះមានចំណុចខ្សោយដូច្នេះក្តី ឧស្សាហកម្មនេះទំនងអាចរស់បានច្រើនឆ្នាំតទៅទៀត ពីព្រោះមធ្យោបាយប្រមូលផ្តុំនៃការផ្គត់ផ្គង់អគ្គិសនីមិនទាន់មាននៅឡើយទេ ។

## ៤.៣ នេសាទ និងការកែច្នៃត្រី

ការនេសាទ និងការកែច្នៃត្រី ស្ថិតក្នុងចំណោមសកម្មភាពក្រៅកសិដ្ឋានដ៏ចំណាស់ជាងគេនៅកម្ពុជា។ តាមធម្មតាគេតែង

ចាត់ទុកសកម្មភាពនេះនៅក្នុងប្រភេទកសិកម្មនិងសកម្មភាពជាប់ទាក់ទិន ប៉ុន្តែនៅកម្ពុជាគេបែងចែកវាដាច់ដោយឡែក ដោយសារសារៈសំខាន់របស់វាក្នុងសេដ្ឋកិច្ចជាតិ ។ ថ្វីបើមនុស្សជាច្រើនជឿថា ការចាប់ត្រីសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន (ដែលមិនអាចរាប់កើត) មានច្រើនណាស់ក៏ដោយ ក៏គេនៅតែប៉ាន់ស្មានថា ផលិតកម្មផលនេសាទ មានពី ២៩០.០០០-៤៣០.០០០តោន មានតំលៃ ១០០-២០០លានដុល្លារ (McKenney and Prom 2002)[១៨] គឺប្រហែល ៧% នៃ ផសស ។

សេដ្ឋកិច្ចផលនេសាទកម្ពុជា មានការនេសាទទឹកសាបជាសំខាន់ ទោះកម្ពុជាមានឆ្នេរសមុទ្រដែរក៏ដោយ ។ ប្រភពត្រីចំបងៗគឺជាផ្ទៃទឹកសាប ដូចជា បឹងទន្លេសាប ទន្លេសាប ទន្លេមេគង្គនិងដៃជាច្រើនរបស់វា ។ ការនេសាទអនុវត្តជាសំខាន់នៅតំបន់អាង ឯការនេសាទនៅតំបន់ខ្ពង់រាបភាគកណ្តាលមានតិចតួចទេ (Chan and Acharya 2002) ។ ការនេសាទមានលក្ខណៈរដូវកាលជាសំខាន់ ដែលតែងធ្វើឡើងក្រោយការប្រមូលផលដំណាំនៅរដូវវស្សា ថ្វីបើនៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ មានប្រជាជនជាច្រើននាក់ធ្វើនេសាទពេញៗមួយឆ្នាំតែម្តង ។

បច្ចេកទេសនេសាទជាទូទៅមានលក្ខណៈសាមញ្ញ ដោយអ្នកនេសាទគ្រាន់ចេញទូកទៅចាប់ត្រីដោយប្រើសំនាញ់ ឬអួន ។ ទូកអាចតូចឬធំ ប្រើម៉ាស៊ីននិង/ឬច្រវ៉ា ។ ទូកសមុទ្រទំនើប ដូចរបស់ពួកតៃវ៉ាន់ ឬកូរ៉េ មិនទាន់មានប្រើនៅទឹកសាបកម្ពុជាទេ ។ ដោយត្រីភាគច្រើនគេលក់ស្រស់ទៅទីផ្សារ ប្រព័ន្ធទីផ្សារ និងដឹកជញ្ជូនមានសរៈសំខាន់ស្ទួលចំពោះកំរិតចំណេញ ។ សព្វថ្ងៃនេះ ការនេសាទនៅតែជាសកម្មភាពមានផលិតភាពពលកម្មទាប ហើយអ្នកនេសាទត្រីមួយភាគធំ រកចំណូលមិនបានច្រើនលើសកំរិត ជីវព្រឹត្តទេ ។

នៅកម្ពុជា ការកែច្នៃត្រីគឺជារបៀបអនុវត្តមានតាំងពីបុរាណ ដោយប្រជាជនត្រូវកែច្នៃត្រីទុកហូបពេលផុតរដូវត្រី ។ គេយកត្រីទៅហាល ប្រឡាក់អំបិល ឆ្អើរ និងធ្វើប្រហុកផ្អក[១៩] ។ ដំណើរការនីមួយៗខាងលើ អនុវត្តជាលក្ខណៈសិប្បកម្ម ឬតាមគ្រួសារ ប៉ុន្តែមិនមែនសុទ្ធតែជាគ្រួសារអ្នកចាប់ត្រីខ្លួនឯងទាំងអស់នោះទេ ។ បច្ចេកវិទ្យាដែលប្រើសំរាប់កែច្នៃត្រីនៅតាមភូមិគឺជាបច្ចេកវិទ្យាបុរាណសុទ្ធសាធ ប៉ុន្តែមានរោងចក្រទំនើបៗសំរាប់កែច្នៃត្រីមួយចំនួនដែរ បានកកើតឡើងនៅតាមទីក្រុងខ្លះ ។ ត្រីកែច្នៃហើយ គេលក់ចេញនៅនឹងមូលដ្ឋាន និងនៅតាមទីក្រុងនានា ហើយមួយចំនួនបាននាំចេញទៅបរទេស ។

ការនេសាទច្រើនតែមិនមែនជាសកម្មភាពតែមួយមុខគត់របស់ប្រជាជននោះទេ ។ កសិករដែលធ្វើស្រែនៅរដូវវស្សា គេធ្វើនេសាទនៅរដូវប្រាំង ។ ពួកកសិករដែលមានដីលិចទឹកនៅរដូវវស្សា គេធ្វើស្រែនៅរដូវប្រាំង និងធ្វើនេសាទនៅរដូវវស្សា ។ ដោយគណនាចេញពី ទិន្នន័យផលិតកម្មខាងលើ និង តួលេខការងារក្នុងតារាង៣.៣, ផលិតភាពពលកម្មបានប្រហែល ២.៥០០-៣.០០០ដុល្លារក្នុងកម្មករម្នាក់ ។ តួលេខនេះមិនប្រាកដនិយមទេ ហើយគេអាចពន្យល់បានតែម្យ៉ាងថា ចំនួនប្រជាជនធ្វើនេសាទមានច្រើនយ៉ាងខ្លាំងជាង ចំនួនពិនិត្យឃើញតាមទិន្នន័យម៉ាក្រូ ។ តាមពិត ទិន្នន័យម៉ាក្រូ ប្រហែលបង្ហាញតែពួកពលករដែលចំណាយពេលវេលាភាគច្រើនរបស់ខ្លួនលើការនេសាទ គឺមិនមែនអ្នកដែលធ្វើនេសាទជាបន្ថែមលើការងារកសិកម្មនោះទេ ។ ម្យ៉ាងទៀត ខ្សែរយៈទីផ្សារប្រហែលស្រូបយកតំលៃបន្ថែមអស់មួយភាគធំ ដែលរារាំងផលិតករមិនឱ្យទទួលបាននូវតំលៃពេញលេញនៃត្រីដែលខ្លួនចាប់បាន ។ ទិដ្ឋភាពនេះ នឹងពិភាក្សាក្នុង ជំពូកទី៦ ។

ឡូត៍នេសាទ (ផ្ទៃទឹកធំៗ) ត្រូវបានជួលទៅឱ្យអ្នកម៉ៅការឯកជន ។ អ្នកម៉ៅការមានកិច្ចសន្យាសំរាប់ពី ១ឆ្នាំ ទៅ ៣ឆ្នាំ ឬមួយធ្វើនេសាទផ្ទាល់មុខដោយខ្លួនឯងនៅកន្លែងនោះ ឬមួយជួលបន្តចំណែកខ្លះៗនៃផ្ទៃទឹករបស់ខ្លួនទៅឱ្យអ្នកនេសាទតូចៗ ។ ថ្វីបើប្រព័ន្ធនេះបានផ្តល់ចំណូលមួយចំនួនជូនរដ្ឋក្តី ប៉ុន្តែកន្លងមកមានការប្រើងប្រែងតាមរបៀបវិទ្យាសាស្ត្រតិចតួចណាស់ ដើម្បីប្រើ

[១៨] ការប្រែប្រួលយ៉ាងធំក្នុងតួលេខប៉ាន់ស្មាន បង្ហាញពីគុណភាពអន់នៃមូលដ្ឋានទិន្នន័យ ។

[១៩] លើសពីនេះ ការធ្វើទឹកត្រីបានក្លាយជាសកម្មភាពមួយយ៉ាងសំខាន់ក្នុងពេលសព្វថ្ងៃ ។

ប្រាស់ឱ្យបានពេញលេញនូវសក្តានុពលខាងនេសាទ ហើយការប្រឹងប្រែងរបស់រដ្ឋាភិបាលមជ្ឈឹមដើម្បីគ្រប់គ្រងធនធានធម្មជាតិ គឺហាក់ដូចមានត្រឹមការស្វែងរកចំណូលថ្លៃឈ្នួលឡូត៍ប៉ុណ្ណោះ ។ ប៉ុន្តែដោយទទួលស្គាល់តំរូវការផ្តល់សន្តិសុខស្បៀងឱ្យបានប្រសើរឡើងដល់សហគមន៍ក្នុងស្រុក, ក្នុងឡូត៍នេសាទប្រហែលមួយលានហិកតា គេបានលុបចោលអស់ ៥៦% ហើយតាំងពីឆ្នាំ២០០១ ដើម្បីដាក់ជាតំបន់នេសាទបើកចំហវិញ ។

## ៤.៤ ការផលិតក្អមឆ្នាំង

ការស្រាវស្រាវផ្នែកបុរាណវិទ្យា ជារឿយៗបានបកស្រាយពីកិរិតអារ្យធមិតាមរយៈសំណល់ក្អមឆ្នាំងដែលផលិតពីអតីតកាល ។ តាមពិតក្អមឆ្នាំងខ្មែរ មានចំណាស់ដូចវប្បធមិខ្មែរដែរ ។ នៅកម្ពុជា ផលិតកម្មក្អមឆ្នាំងនៅមានច្រើនតាមតំបន់ដែលមានអារ្យធមិបុព្វកាលៈ នៅច្រាំងទន្លេសាប និងនៅខេត្តកំពង់ឆ្នាំង និងកំពង់ធំ[២០] ។ ឈ្មោះខេត្តកំពង់ឆ្នាំង កើតចេញពីពាក្យ *ឆ្នាំង* ដែលជាឧបករណ៍ធ្វើពីដីសំរាប់ចំអិនអាហារ (Tin 2001) ។ នៅកម្ពុជាមានផលិតទាំងក្អមឆ្នាំងធ្វើពីដីដុតធម្មតា និងមានលាបថ្នាំ ជាតិកែវឱ្យភ្លឺ ។

ប្រព័ន្ធផលិតកម្មរួមមាន ការជីកនិងដឹកជញ្ជូនដីឥដ្ឋទៅតាមគ្រួសារ ការបំបែកដុំដីឱ្យម៉ដ្ឋ និងធ្វើវាឱ្យស្ងួតល្អ ច្របល់ទឹកនិងដីឱ្យត្រូវខ្នាតជាមួយដីឥដ្ឋ និងយកដីលាយហើយទៅសូនជារបស់ផ្សេងៗដោយប្រើសំភារៈមួយធ្វើពីឈើនិងក្រណាត់ ។ នៅចុងបញ្ចប់ គេយកភាជន៍ឬរបស់ផ្សេងៗដែលសូនបានទៅដុត ដោយប្រើអុស ។ ផលិតកម្មក្អមឆ្នាំងទាំងអស់ធ្វើជាលក្ខណៈគ្រួសារ (គ្មានរោងចក្រធ្វើក្អមឆ្នាំងទេ) ។ ទាំងស្ត្រី និងបុរស ជីកយកដីឥដ្ឋ រកអុស និងដឹកដីឥដ្ឋទៅផ្ទះដែលជាកន្លែងគេលាយដី ។ បន្ទាប់មកស្ត្រីសូនដីជាក្អមឆ្នាំង ហើយគ្រួសារ/សហគមន៍ដុតវាជាសំរេច ។ សិល្បៈសូនក្អមឆ្នាំង ត្រូវបានបន្តវេនពីម្តាយទៅកូន ។

ចំណុចគួរចាប់អារម្មណ៍ គឺការផលិតក្អមឆ្នាំងតាមរបៀបប្រពៃណីនេះ មិនប្រើកង់បង្វិលទេ (ឧបករណ៍នេះឃើញមានជាទូទៅក្នុងតំបន់អាស៊ីភាគច្រើន) ។ ផ្ទុយទៅវិញ ស្ត្រីចំណាយពេលអស់ច្រើន លើការធ្វើគែម និងជ្រុងភាជន៍ ។ វិធីនេះមិនសូវបានស្មើត្រឹមល្អទេ និងចំណាយពេលយូរ ។ តាមការបញ្ចូលបច្ចេកវិទ្យាទំនើប និងតាមគំរោងជំនួយដែលNGO អាល្លឺម៉ង់មួយបានចាប់ផ្តើមនៅឆ្នាំ១៩៩៩ គេបានដាក់បញ្ចូលនិងណែនាំឱ្យប្រើនូវឧបករណ៍ធាក់បង្វិលដោយជើង និងចង្ក្រានមានកំដៅខ្ពស់ នៅតាមតំបន់នានាក្នុងខេត្តកំពង់ឆ្នាំង ដែលបានធ្វើការសិក្សានេះ ។ បច្ចេកទេសនេះបានជួយបង្កើនផលិតភាពពលកម្ម និងធ្វើឱ្យអ្នកផលិតក្អមឆ្នាំងក្នុងស្រុកមានការពេញចិត្តច្រើន ។

ក្អមឆ្នាំង មិនមែនជាសកម្មភាពការងារពេញម៉ោងពេលទេ ហើយអ្នកផលិតក្អមឆ្នាំងស្ទើរគ្រប់គ្នា គេផលិតក្អមឆ្នាំងតែនៅក្រៅរដូវដាំដុះប៉ុណ្ណោះ ។ ចំណូលជាទូទៅមិនបានច្រើនលើសពីកិរិតជីវព្រឹត្តទេ ហើយមួយក្រុមមានគ្នាពីរនាក់ ជាទូទៅរកចំណូលបានប្រហែល ៧០.០០០រៀល ឬ ១៨ដុល្លារ ក្នុងមួយខែ (Tin 2000)[២១] ។ ដោយសារវាជាសកម្មភាពមិនពេញម៉ោងពេល ដូច្នេះអ្នកភូមិអះអាងថាបានចំណូលបន្ថែមប៉ុណ្ណោះក៏ត្រេកអរដែរ ។ ជាទូទៅអ្នកផលិតក្អមឆ្នាំងមានកិរិតអប់រំតិចតួច ជួនកាលមិនចេះអក្សរផង ។ ម្យ៉ាងទៀត គ្មាននរណាម្នាក់បានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីការផលិតក្អមឆ្នាំងទេ ក្រៅតែពីការបណ្តុះបណ្តាលផ្តល់ដោយ NGO ។

គេលក់ផលិតផលនៅតាមខេត្តជិតៗនោះ និងនៅភ្នំពេញផងដែរ ។ ថ្វីបើការប្រកួតប្រជែងពីគ្រឿងប្លាស្ទិកកំពុងផុសឡើង ក្តី ប៉ុន្តែផលិតផលដីដុតជាច្រើនចាប់ពីភាជន៍សំរាប់តាំងលំអរហូតដល់ក្អមដាក់ទឹក និងរបស់ប្រើប្រាស់ក្នុងផ្ទះបាយ នៅតែមាន តំរូវការខ្ពស់ពីសំណាក់សហគមន៍តាមភូមិនានា ។ ប៉ុន្តែ

---

[២០] ក្អមឆ្នាំង ក៏មានផលិតដែរនៅខេត្តកំពង់ស្ពឺ និងតាកែវ ដែលមានដីឥដ្ឋមានគុណភាពល្អ ។

[២១] អង្កេតធ្វើឆ្នាំ២០០២ សំរាប់ការសិក្សានេះបង្ហាញថា ចំនូលហាក់មានកិរិតខ្ពស់ជាងអង្កេតធ្វើដោយ Tin នៅពាក់កណ្តាលទសវត្សរ៍១៩៩០ ។

ចរិតក្នុងស្រុកនៃទីផ្សារ និងការបែកបាក់ក្នុងពេលដឹកជញ្ជូន ធ្វើឱ្យប្រាក់ ចំណូលក្នុងវិស័យនេះមានកំរិតទាប ។

## ៤.៥ ផលិតកម្មឥដ្ឋ

ផលិតកម្មឥដ្ឋ ជាឧស្សាហកម្មថ្មីមួយនៅកម្ពុជា ។ នៅក្នុងទសវត្សរ៍១៩៥០ ឡឥដ្ឋមានចំនួនមិនលើសពីជាងដប់ទេ ។ ប៉ុន្តែនៅចុងទសវត្សរ៍១៩៩០ អង្គភាពផលិតឥដ្ឋមានដល់ប្រហែល ៦០០ ក្នុងទូទាំងប្រទេស (RGC 1997)[២២] ។ រោងចក្រផលិតឥដ្ឋភាគច្រើន ស្ថិតក្នុងខេត្តកំពង់ចាម កណ្តាល កំពង់ធំ ហើយជាង ៦០% មានទីតាំងនៅក្រុងភ្នំពេញ ។ ទំហំរោងចក្រប្រែប្រួលខ្លាំងណាស់: រោងចក្រតូចៗមានសមត្ថភាពផលិត ២០០.០០០ដុំ/ឆ្នាំ, រីឯរោងចក្រធំៗអាចផលិតបានច្រើនជាងនេះ ៣០ដង ។ រោងចក្រនានាធ្វើផលិតផលច្រើនមុខ: ឥដ្ឋប្រហោង ឥដ្ឋតាន់ និងក្បឿង ក្នុងនេះផលិតផលលក់បានច្រើនជាងគេគឺឥដ្ឋប្រហោង ។ រោងចក្រភាគច្រើនមានទំហំតូច និងប្រើម៉ាស៊ីនវាយឥដ្ឋតែមួយគ្រឿងទេ[២៣] (Rozermuller 1999) ។

រោងចក្រជាច្រើន ជាឡឥដ្ឋគ្រួសារ ដែលតាមធម្មតាមានទំហំតូច ប្រើពលកម្មនៅក្នុងគ្រួសារជាសំខាន់ និងផ្គត់ផ្គង់ឥដ្ឋទៅភូមិជិតខាង ។ រោងចក្រធំៗ ឬឡឥដ្ឋក្រុមហ៊ុន គឺជាសហគ្រាសរៀបរយមានតំបន់ចែកចាយទូលាយ ។ អាជីវកម្មខ្នាតតូចគ្រប់គ្រងដោយគ្រួសារធ្វើជំនួញមិនរីកចំរើនទេ រីឯសហគ្រាសធំៗមានការរីកលូតលាស់ ។ ឥដ្ឋតាមធម្មតាលក់ទៅឱ្យការដ្ឋានសំណង់ធំៗ ឈ្មួញកណ្តាល/អ្នកលក់រាយដែលលក់ផលិតផលនៅតាមទីក្រុង ឬតំបន់ផ្សេងទៀត ឬលក់ផ្ទាល់ទៅឱ្យអតិថិជនតែម្តង ។ ក្នុងគ្រប់ករណី កំរិតថ្លៃដែលផលិតករទទួលបាន មិនខុសគ្នាច្រើនទេ យោងតាមឥទ្ធិពលទីផ្សាររបស់គេដែលសំខាន់ ។

រោងចក្រផលិតឥដ្ឋកម្ពុជាគំរូមួយ មានទុនជាទ្រព្យសកម្មជាប់លាប់ ៨.៥០០ដុល្លារ ហើយតាមធម្មតាប្រើបុគ្គលិកពី១៥-២០នាក់ (Rozermuller 1999)[២៤] ។ ការងារដែលបង្កើតឡើង ភាគច្រើនជាប្រភេទការងារគ្មានជំនាញ និងពាក់កណ្តាលជំនាញ ។ ចំណាយពលកម្ម តំណាងឱ្យប្រហែល ១/៣ នៃបន្ទុកចំណាយសរុប គឺតិចជាងចំណាយលើម៉ាស៊ូតដែលមានប្រហែល ៤០% នៃបន្ទុកចំណាយសរុប ។ ការផលិតឥដ្ឋមានដំណើរការពេញៗមួយឆ្នាំ ទោះបីតំរូវការមានលក្ខណៈរដូវកាលមួយកំរិតក្តី ពីព្រោះប្រជាជនមួយភាគធំសាងសង់ផ្ទះនៅរដូវប្រាំង ។ កម្មករគឺច្រើនទទួលបានការងារតាមរដូវកាល មិនមែនសុទ្ធតែបានពេញៗមួយឆ្នាំទេ ។

ផលិតករឥដ្ឋកម្ពុជា ប្រឈមមុខនឹងការប្រកួតប្រជែងយ៉ាងតឹងតែងពីបណ្តារោងចក្រនៅប្រទេសជិតខាង ។ ទី១ នៅប្រទេសជិតខាងគេលាយដីឥដ្ឋតាមរបៀបទំនើបជាង ធ្វើឱ្យផលិតផលគេមានគុណភាពល្អជាងដែរ ។ ទី២ ម៉ាស៊ីនវាយឥដ្ឋរបស់គេមានទំហំធំជាង ហើយម៉ាស៊ីនអូសក៏មានប្រសិទ្ធភាពខ្ពស់ជាងដែរ[២៥] ។ ទី៣ នៅប្រទេសជិតខាងគេដុតឥដ្ឋបានល្អជាងដោយសារគេប្រើធ្យូងថ្ម ឯនៅកម្ពុជាគេប្រើអុស និងអង្កាម ដែលមិនផ្តល់កំដៅបានច្រើនទេ ។ គេទទួលស្គាល់ជាទូទៅថា ឥដ្ឋកម្ពុជាមានតំលៃថោក គុណភាពល្អ អាចប្រើមានប្រសិទ្ធភាពល្អសំរាប់សង់អគារត្រឹមមួយជាន់ឬពីរជាន់ ប៉ុន្តែចំពោះសំណង់ខ្ពស់ជាងនេះ ឥដ្ឋកម្ពុជាមិនមាំគ្រប់គ្រាន់ទេ ។

## ៤.៦ តម្បាញសូត្រ

ការត្បាញសូត្រ គឺជាបច្ចេកវិទ្យាបុរាណមួយនៅកម្ពុជា ។ កាលពីជំនាន់ដើម ការចិញ្ចឹមដង្កូវនាង ការស្រាវសូត្រ និងការ

---

[២២] តួលេខផ្លូវការបង្ហាញថា មាន ៤៤៦រោងចក្រផលិតឥដ្ឋមានអាជ្ញាប័ណ្ណនៅឆ្នាំ១៩៩៧, ក្រៅពីនេះគឺជាអង្គភាពផលិតគ្មានអាជ្ញាប័ណ្ណ ។

[២៣] ម៉ាស៊ីនវាយឥដ្ឋ គឺជាម៉ាស៊ីនដែលចាក់ពុម្ពឥដ្ឋ ចេញពីដីឥដ្ឋ ។ ក្រៅពីម៉ាស៊ីនវាយឥដ្ឋចេញ រោងចក្រកម្ពុជាមានម៉ាស៊ីនផ្សេងតិចតួចទេ ។

[២៤] ការពិភាក្សាជាមួយបុគ្គលិក EDA និងការសិក្សាមុនៗរបស់ វិបសអ អាចជួយផ្តល់ការយល់ដឹងមួយចំនួនថែមទៀត (See Sok and Acharya 2002) ។

[២៥] រោងចក្រកម្ពុជាប្រើម៉ាស៊ីនម៉ាស៊ូតចាស់ៗ ចំណែកឯនៅប្រទេសផ្សេងគេប្រើម៉ូទ័រអគ្គិសនីមានប្រសិទ្ធភាពខ្ពស់ជាង ។

ផលិតសរសៃសូត្រ មានអនុវត្តទាំងអស់ក្នុងប្រទេសកម្ពុជា និងផ្សារភ្ជាប់ជាមួយតម្បាញ ។ ប៉ុន្តែបច្ចុប្បន្ននេះ មានតែការត្បាញ និងការជ្រលក់ពណ៌ទេ ដែលមានធ្វើនៅកម្ពុជា។ ៩៨%នៃសរសៃសូត្រនាំចូលមកពីវៀតណាម គឺមានតែ ២%ប៉ុណ្ណោះដែលផលិតបាននៅខេត្តបន្ទាយមានជ័យ ។ តម្បាញសូត្រជាសកម្មភាពកិច្ចគ្រួសារជាសំខាន់ មានស្ត្រីជាអ្នកអនុវត្ត ហើយចំណេះដឹងនេះត្រូវបានផ្ទេរបន្តពីម្តាយទៅកូន ។ មានការងារបីដែលពលករកម្ពុជាអនុវត្តគឺ រៀបចំសូត្រ ជ្រលក់ពណ៌ និងត្បាញ ។ កីត្បាញធ្វើពីឈើជាឧបករណ៍ដំណើរការដោយដៃ និងផលិតដោយជាងឈើក្នុងស្រុកតាមលក្ខណៈជាប្រពៃណី. ចំពោះល័ក្ខវិញត្រូវនាំចូលពីថៃ ។

គេផលិតបានទំនិញ ៥មុខ គឺ សារុង ផាមួងនិងក្រណាត់ ចរបាប់ ហូល និង ក្រមា ។ ផលិតផលទាំងអស់នេះលក់នៅក្នុងប្រទេស ជាពិសេសនៅភ្នំពេញ និងនៅខេត្តសៀមរាបមួយចំនួន ។ កាលពីមុនផលិតផលមួយចំណែកលក់ចេញទៅទៅប្រទេសថៃ ប៉ុន្តែលែងមានទៀតហើយតាំងពីកើតវិបត្តិហិរញ្ញវត្ថុនៅថៃក្នុងឆ្នាំ១៩៩៧ មក ។ តាមពិត ឥលូវនេះ ទំនិញថោកៗត្រូវបាននាំចូលពីថៃមកវិញ ហើយវាបានដាក់សំពាធខ្លាំងដល់ផលិតកម្មក្នុងស្រុក ។ សភាពការណ៍កាន់តែយ៉ាប់យឺនថែមទៀត ដោយសារមានក្រណាត់សាំងតេទិកនាំចូលមកពីប្រទេសចិត បានដណ្តើមទីផ្សារផលិតផលធ្វើពីសូត្រ ។

គេប៉ាន់ស្មានថា មានអ្នកត្បាញប្រហែល ១០.០០០គ្រួសារ ភាគច្រើននៅ ខេត្តតាកែវ (៥៥%), កណ្តាល (៣១%), ព្រៃវែងនិងកំពង់ចាម (១១%) ។ ក្នុងមួយឆ្នាំៗ ចំនួនអ្នកត្បាញកើនប្រហែល ៤-៥% (Victor-Pujebet and Peyre 2001) ។ សកម្មភាពត្បាញ ធ្វើឱ្យពលករជាប់រវល់ប្រហែល ១០ខែក្នុងមួយឆ្នាំៗ ហើយអ្នកត្បាញបានចំណូលប្រហែល ៤.០០០-៦.០០០៛ក្នុងមួយថ្ងៃ(មាន៩ម៉ោងធ្វើការ) ។

សរសៃសូត្រនាំចូលមកពីវៀតណាមតាមរយៈឈ្មួញកណ្តាល ដែលជាអ្នកបញ្ជូនសំភារៈទៅឱ្យអ្នកត្បាញ ។ ពាណិជ្ជករត្រួតត្រាជាសំខាន់លើទីផ្សារផលិតផល ហើយគេផ្តល់ឥណទានឱ្យអ្នកត្បាញក្នុងអត្រាការប្រាក់ ៣-៤%/ខែ ។ ការក្តោបក្តាប់យ៉ាងណែនរបស់ពួកពាណិជ្ជករនេះ បានបន្ទុចបង្អាក់ដល់ការដាក់អនុវត្តន៍គំនិតច្នៃប្រឌិតថ្មីៗនៅក្នុងផលិតកម្ម ។

សូត្រកម្ពុជាដែលផលិតតាមរបៀបសិប្បកម្មជាប្រពៃណី មិនត្រូវបានគេឱ្យតំលៃខ្ពស់ប៉ុន្មានទេ ។ គុណភាពផលិតផលមិនស្មើគ្នាទេពីមួយកីទៅមួយកី ហើយគុណភាពអន់នៃថ្នាំជ្រលក់ពណ៌ និងសរសៃសូត្រ ធ្វើឱ្យផលិតផលកាន់តែអន់គុណភាព ។ គួបផ្សំនឹង ផលិតភាពពលកម្មទាបដោយសារកីត្បាញមានបច្ចេកវិទ្យាអន់ និង ពលករមានការបណ្តុះបណ្តាលទាបផង សកម្មភាពនេះមិនអាចរីកចំរើនទេ ។ ម្យ៉ាងទៀត តំលៃបន្ថែមសំរាប់សកម្មភាពនេះ (និងប្រទេសកម្ពុជា) ត្រូវបានកាត់បន្ថយមួយកំរិតទៀត ដោយសារសរសៃសូត្រសឹងតែទាំងអស់ត្រូវនាំចូល ។

## ៤.៧ ក្រណាត់អំបោះត្បាញដោយកីសិប្បកម្ម

សកម្មភាពរវៃកប្បាស និងតម្បាញអំបោះ មានធ្វើនៅកម្ពុជាតាំងពីមុនទសវត្សរ៍១៩៧០ ប៉ុន្តែក្រោយមកបានបាត់អស់ទៅវិញ ។ សកម្មភាពរវៃ និងថ្លោចកប្បាស សឹងតែបាត់អស់ទាំងស្រុងក្រោយពេលកសិករបានឈប់ដាំដុះកប្បាស ។ ឥឡូវនេះសរសៃអំបោះបាននាំចូលមកពីវៀតណាម ហើយត្បាញជាក្រណាត់នៅកម្ពុជា ។ អ្នកភូមិនៅខេត្ត កំពង់ចាម កណ្តាល ព្រៃវែង ធ្វើតំបាញដោយប្រើ កីតំបាញដៃ និង កីតំបាញម៉ាស៊ីន ។ គេចាប់ប្រើកីតំបាញម៉ាស៊ីននៅតាមភូមិក្នុងខេត្តកណ្តាល ដោយសារនៅទីនោះសហគ្រិនមានលទ្ធភាពប្រើថាមពលអគ្គិសនីក្នុងរយៈ ៥-៧ឆ្នាំចុងក្រោយនេះ ។

ជាងឈើក្នុងភូមិ ផលិតទាំងកីតំបាញដៃ និងកីតំបាញម៉ាស៊ីន ។ មុនដំបូងជាងឈើរៀនពីរបៀបដាក់ភ្ជាប់ម៉ូទ័រអគ្គិសនីដើម្បីអូសកីតំបាញម៉ាស៊ីន តាមរយៈការបណ្តុះបណ្តាលទទួលបានមកពីវៀតណាម ។ កីតំបាញដៃមានផលិតភាពទាបៈ ពលករម្នាក់ផលិតបានមិនលើសពី ១០-១២ក្រម៉ាទេក្នុង១ថ្ងៃ, ប៉ុន្តែបើប្រើកីតំបាញម៉ាស៊ីនវិញគេអាចផលិតបាន ៣៥-៤០ក្រម៉ា/ថ្ងៃ ។ អ្នកត្បាញសឹងតែទាំងអស់ជាស្ត្រីវ័យក្មេង អាយុពី ១៨-២៨ឆ្នាំ ។ នៅខេត្តកំពង់ចាម ពលករមួយចំនួនធំ ជាអ្នកមូលដ្ឋាននៅក្នុង

សហគមន៍ចាម ហើយពលករនៅកន្លែងដទៃទៀតរួមមាន ជនចំណាកស្រុកមួយចំនួនមកពីខេត្តព្រៃវែង និងស្វាយរៀង ។ មធ្យមភាគប្រាក់ចំណូលសំរាប់ពលករស៊ីប្រាក់ឈ្នួលម្នាក់ គឺប្រហែល ២.៧០០-៣.០០០រៀលសំរាប់ការងារមួយថ្ងៃពេញ ។ លើសពីនេះ គេផ្តល់អាហារឱ្យបីពេល និងកន្លែងស្នាក់នៅទៀតផង ។

ទីផ្សារសំរាប់ផលិតផលសំខាន់ៗ កំពុងរីកចំរើនយ៉ាងទៀងទាត់ៈ ឧទាហរណ៍ក្រម៉ា ដែលមានផលិតតែនៅក្នុងវិស័យមិនប្រមូលផ្តុំនេះ គឺសព្វថ្ងៃគ្មានការប្រកួតប្រជែងពីរោងចក្រធំៗរបស់ប្រទេសជិតខាងទេ ។ ដោយក្រម៉ាមួយអាចប្រើបានតែ ៣-៤ខែ ដូច្នេះតំរូវការផ្លាស់ក្រម៉ាថ្មីគឺមានច្រើន ។ ទីផ្សារមានការប្រកួតប្រជែងល្អ និងគ្មានអ្នកទិញផ្តាច់មុខទេ ។ ឈ្មួញភាគច្រើនចុះទៅពីភ្នំពេញដើម្បីទទួលទិញផលិតផល ។ ទីផ្សារគ្មានលក្ខណៈរដូវកាលទេ ហើយផលិតកម្មធ្វើបានពេញៗមួយឆ្នាំ ។

តំបាញអំបោះទាមទារពលកម្មច្រើន ដូច្នេះវាអាចផ្តល់ការងារបានច្រើន ។ ប៉ុន្តែការធ្វើចំរុះកម្ម ឬការកែលំអផលិតផលឃើញមានតិចតួចណាស់ ដូច្នេះតំលៃបន្ថែមនៅតែទាប ហើយសកម្មភាពមានតាមកន្លែងដាច់ៗពីគ្នា ។ កីតំបាញម៉ាស៊ីនមានអនាគតល្អក្នុងការរីកលូតលាស់ ប៉ុន្តែកីតំបាញបុរាណប្រហែលជាមិនអាចរស់បានទេ ។

## ៤.៨ វត្ថុសិល្បៈសិប្បកម្ម

នៅកម្ពុជា មានការផលិតវត្ថុសិល្បៈសិប្បកម្មជាច្រើនប្រភេទ ។ ក្បាច់រចនាភាគច្រើនធ្វើតាមទំរង់ស្ថាបត្យកម្មអង្គរដែលកំលាំងទាក់ទាញខ្ពស់ក្នុងទីផ្សារទេសចរ ។ មុខទំនិញមួយចំនួនតូចផលិតពីចំបើង ឬផ្តៅ មួយចំនួនធ្វើដីឥដ្ឋ ខ្លះធ្វើពី ថ្មម៉ាប ថ្មភក់ និងចំនួនទៀតធ្វើពីលោហៈ(គ្រឿងស្ពិត និងចំលាក់លោហៈ) ។ សិល្បៈនេះ ដែលបានរស់រានជីវិតឆ្លងកាត់រយៈពេលមានចលាចលជាច្រើនឆ្នាំក្នុងពេលកន្លងមក បានរីកលូតលាស់ ដោយសារសិប្បករមានជំនាញ និងការប្តូរផ្តាច់កំរិតខ្ពស់ ។ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ឥលូវបានចាប់ផ្តើមធ្វើសកម្មភាពនានា ដើម្បីធ្វើឱ្យរស់ឡើងវិញនិងកែលំអសិល្បៈបុរាណនេះ លើផលិតផលមួយចំនួន ប៉ុន្តែគេមិនទាន់ដឹងច្បាស់លាស់ទេពីឥទ្ធិពលនៃការស្រាវជ្រាវនេះក្នុងការផ្ទេរចំណេះដឹងដល់កម្មករ ។

ផលិតកម្មវត្ថុសិល្បៈ ថ្មម៉ាប បានប្រមូលផ្តុំនៅខេត្តពោធិសាត់ កណ្តាល សៀមរាប និងក្រុងភ្នំពេញ[២៦] ។ សៀមរាប និងភ្នំពេញ ជាទីផ្សារសំខាន់ជាងគេ ឯខេត្តពោធិសាត់ជាប្រភពថ្មម៉ាប ។ សកម្មភាពភាគច្រើនអនុវត្តនៅកំរិតគ្រួសារជារឿយៗជាបន្ថែមទៅលើការងារកសិកម្ម ។ ពលកររៀនជំនាញសិល្បៈពីឪពុកម្តាយ និងពីអ្នកជួយណែនាំផ្សេងទៀត ។ ការផលិតវត្ថុសិល្បៈសិប្បកម្ម ជាសកម្មភាពតាមគ្រួសារ ធ្វើនៅតាមផ្ទះ ប៉ុន្តែក្នុងប៉ុន្មានឆ្នាំថ្មីៗ មានគ្រួសារអ្នកធូរធារខ្លះ បានបង្កើតកន្លែងផលិតកម្មទ្រង់ទ្រាយធំជាងមុន ។ គេជួលពលករមកបំរើការ ដែលជួនកាលជាក្រុមគ្រួសាររបស់គេផ្ទាល់ ។ បច្ចេកទេសជាប្រពៃណី គ្មានប្រើអ្វីច្រើនក្រៅពីញញួរ ពន្លាក និងឧបករណ៍ប្រហាក់ប្រហែលមួយចំនួនទៀត ។ វិធីសាស្ត្រទំនើបដែលមាន ប្រើពន្លាកម៉ាស៊ីន រណារម៉ាស៊ីន និងម៉ាស៊ីនខាត់ ឥលូវនេះកំពុងរីកលូតលាស់ឡើងហើយ ។ ក្នុងបច្ចេកវិទ្យាថ្មីនេះ ទុនវិនិយោគ និងផលិតភាពពលកម្ម មានកំរិតខ្ពស់ជាង ។ ក្នុងការងារនេះ គ្មានការបែងចែកជំនាញតាមភេទទេ ។ អង្កេតនេះបានបង្ហាញថា មានពលករទាំងបុរសនិងស្ត្រី បានចូលបំរើក្នុងសកម្មភាពនេះ ។ ពលករស៊ីឈ្នួលទទួលចំណូលបានខ្ពស់ជាងកំរិតជីវព្រឹត្តតែបន្តិចទេ ។

សព្វថ្ងៃគេកំពុងអភិវឌ្ឍវិធីសាស្ត្រទំនើបក្នុងការកាត់ថ្ម និងដាប់ថ្ម ប៉ុន្តែកម្មករក្នុងកន្លែងយកថ្មម៉ាបបន្តប្រើមធ្យោបាយសាមញ្ញគំរាំងក្នុងការគាស់យកថ្ម ។ ផ្ទាំងថ្មម៉ាបធំៗ ត្រូវបានដឹកយកចេញពីភ្នំ យកមកបំបែកជាដុំតូចៗ ហើយឆ្លាក់ចេញជារូបចំលាក់កាន់តែតូចៗឡើង ដូច្នេះមានថ្មខាតចោលច្រើនណាស់ ។ ដំណើរការទាំងមូលមានការប៉ះពាល់ដល់ប្រសិទ្ធភាពសេដ្ឋកិច្ចនៃ

[២៦] ក្នុងផ្នែកនេះ មានពិភាក្សាតែពីសិប្បកម្មថ្មម៉ាបទេ ដោយសារការចុះអង្កេតដល់កន្លែងបានកំណត់ការសិក្សាតែលើសិប្បកម្មនេះ ។ គេមិនឃើញមានទិន្នន័យទី២ ឬឯកសារអ្វីច្រើនគ្រប់គ្រាន់ទេ ដើម្បីអាចសរសេរបានពីគ្រប់ទ្រង់ទ្រាយទាំងអស់នៃសិប្បកម្ម ។

ផលិតកម្ម[២៧] និងមានការខ្វះខ្នាយថ្នម៉ាបដ៏មានតំលៃ (ដែលជាធនធានមិនកើតមកវិញទេ) ។

ពាណិជ្ជករត្រួតត្រាទីផ្សារផលិតផល ។ គេប្រមូលទិញផលិតផល ហើយលក់ចេញទៅទីផ្សារតាមរយៈបណ្តាញរបស់គេជាមួយអ្នកលក់រាយនៅតាមទីក្រុង ។ មានការខុសគ្នាច្រើនណាស់ រវាងថ្លៃលក់ឱ្យអតិថិជន និង ថ្លៃដែលសិប្បករទទួលបាន ។

## ៤.៩ សង្ខេប

ការពិពណ៌នាពីមុខសកម្មភាពក្នុងផ្នែកនេះ មិនបានដូចគ្នាបេះបិទទេ ពីព្រោះមិនអាចប្រមូលបានទិន្នន័យដែលឯកភាពគ្នាល្អ ស្តីពីសកម្មភាពទាំងនេះ ។ ទោះជាយ៉ាងនេះក្តី ពតិមានផ្តល់គំនិតថា សកម្មភាពមិនមែនកសិកម្មនៅជនបទកម្ពុជា ទាំងក្នុងវិស័យបុរាណ និងទំនើប គឺមានជាក់ស្តែង និងកំពុងរីកចំរើន ហើយការពិតនេះទិន្នន័យប្រភពទី២ មិនបានបង្ហាញពេញលេញទេ ។ បើសិនជាមានគោលនយោបាយសកម្មមួយ សកម្មភាពទាំងនេះអាចជាប្រភពការងារអាចរស់បាន សំរាប់កំលាំងពលកម្មនៅជនបទ ។ ចំណុចត្រូវប្រុងប្រយ័ត្នគឺ សកម្មភាពដូចជា ម៉ាស៊ីនភ្លើងខ្នាតតូច ឬកីតំបាញដៃ ប្រហែលមិនអាចចីរភាពក្នុងរយៈពេលវែងទេ ពីព្រោះការផ្គត់ផ្គង់អគ្គីសនីជាឧស្សាហកម្មមានលក្ខណៈប្រមូលផ្តុំ ហើយកីតំបាញម៉ាស៊ីននឹងជំនួសកីតំបាញដៃ ។ ម្យ៉ាងទៀត បច្ចេកវិទ្យាបច្ចុប្បន្នមានលក្ខណៈចាស់គំរិលក្នុងករណីភាគច្រើន ហើយក្នុងករណីជាច្រើនប្រាក់ចំណូលរបស់ពលករមានកំរិតទាប ។

[២៧] គួរលើកពីការនាំចូលវត្ថុសិល្បៈថោកៗពីថៃបង្ហាញពីស្ថាបត្យកម្មខ្មែរដែលជាក់សំពាធលើថ្លៃផលិតផល (Sok and Acharya 2002) ។

# ជំពូកទី ៥

# លក្ខណៈសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃសកម្មភាពជនបទមួយចំនួននៅកម្ពុជា

មានការសិក្សាមិនច្រើនទេដែលឱ្យនិយមន័យពី សេដ្ឋកិច្ចនៃសហគ្រាសជនបទតូចៗនៅកម្ពុជា[២៨] ។ ក្នុងជំពូកនេះ គំហើញនៃអង្កេតលើ ២៧៦សហគ្រាសស្ថិតក្នុងក្រុមសកម្មភាពនានា ព្រមទាំងអថេរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់វា មានលើកមក បង្ហាញ (រួមទាំងសហគ្រាសដែលផ្អែកលើមូលដ្ឋានគ្រួសារ និងគ្រួសារនានា ដែលអនុវត្តសកម្មភាពមិនមែនកសិកម្មក្នុងលក្ខណៈ ជាពលករផ្តល់អាជីពដោយខ្លួនឯង)។ នៅពេលប្រមូលទិន្នន័យ មានការប្រឹងប្រែងចាត់ទុកអង្គភាពផលិតកម្មនីមួយៗ ដូចជា សហគ្រាសមួយ និងគណនាអនុបាតហិរញ្ញវត្ថុនិងសេដ្ឋកិច្ចផ្សេងៗ ដូចតែងធ្លាប់ធ្វើសំរាប់សហគ្រាសអាជីវកម្ម ។ ទិន្នន័យមិនអាច ប្រមូលបាន ឯកភាពគ្នាល្អទេសំរាប់គ្រប់មុខសកម្មភាព ហើយតារាងនានាត្រូវកសាងឡើងដោយផ្អែកលើទិន្នន័យដែលមាន[២៩] ។

## ៥.១ គំរូតាង

គំរូតាងរួមមាន ៦០សហគ្រាសនិងបុគ្គលផ្តល់អាជីពដោយខ្លួនឯងដែលធ្វើនេសាទ, ៦០ផ្សេងទៀតខាងកែច្នៃត្រី, ៣០ ខាងតំបាញសូត្រ, ៣០ខាងតំបាញអំបោះ (ក្រមា), ៤០ខាងក្អមឆ្នាំង, ៣៤ខាងសិប្បកម្មថ្មម៉ាប និង ២២ខាងផលិតឥដ្ឋ/ក្បឿង។ ទាំងអស់នេះជាគំរូតាងតូចៗ និងមិនសុទ្ធតែអាចតំណាងបាននូវសកម្មភាពប្រភេទនេះនៅកម្ពុជាទេ ។ ដោយសារគ្មានអង្កេត សហគ្រាសឬគ្រឹះស្ថាន ដែលអាចប្រើជាមូលដ្ឋានសំរាប់ធ្វើការជ្រើសរើសគំរូតាង ដូច្នេះការសិក្សាទាំងនេះបានអនុវត្តនៅតាម ទីតាំងដែលគេមានការយល់ដឹងខ្លះហើយតាមរយៈ ការសិក្សាដែលមានស្រាប់ ឯកសារនានារបស់រដ្ឋាភិបាល ពត៌មានទីផ្សារ និងកំណត់ត្រាប្រវត្តិសាស្ត្រផ្សេងៗ ។ ម្យ៉ាងទៀត ទិដ្ឋភាពនានានៃ "លក្ខណៈអាចតំណាងបានគ្រប់គ្រាន់" និងលទ្ធភាពធនធាន ខាងក្រុមស្រាវជ្រាវ គឺជាគោលការណ៍ណែនាំសំរាប់ការកំណត់ទំហំគំរូតាងនានា[៣០] ។

---

២៨ ប៉ុន្តែមានការប្រឹងប្រែងជាពិសេសៗខ្លះដែរ ដើម្បីស្វែងយល់ពីដំណើរការផ្ទៃក្នុងនៃអង្គភាពអាជីវកម្មជនបទតូចៗ និងដើម្បីផ្តល់មតិពី វិធីសាស្ត្រសំដៅពង្រីកសកម្មភាពរបស់វា ។ ឧទាហរណ៍ យ៉ាងហោចណាស់មានការសិក្សាមួយៗដោយឡែកពីគ្នាស្តីពី សូត្រ ផលិតកម្មឥដ្ឋ និង រោងម៉ាស៊ីនកិនស្រូវ ។

២៩ ទិន្នន័យខ្លះក្នុងជំពូកនេះ មិនស៊ីគ្នាទាំងស្រុងជាមួយនឹងទិន្នន័យក្នុងជំពូកមុនទេ ។ ជំពូកមុនបានផ្អែកផងដែរលើការសិក្សាផ្សេងៗធ្វើដោយ ស្ថាប័នឯទៀត ដែលអាចប្រើគំរូតាងខុសគ្នា ។

៣០ គំរូតាង ៦០គ្រួសារ ជាទូទៅគេចាត់ទុកថាធំគ្រប់គ្រាន់សំរាប់តំណាងឱ្យសកម្មភាព ឬបាតុភូតអ្វីមួយ ។ ក្នុងសកម្មភាពមួយចំនួន គេបាន ឯកភាពលើគំរូតាងតូចៗជាងនេះ ព្រោះគេពិនិត្យឃើញថា ពត៌មានវាដូចគ្នាដដែលៗ ឬក៏ដូចក្នុងករណីផលិតកម្មឥដ្ឋ គេរកសហគ្រាសមិន បានច្រើនគ្រប់គ្រាន់ទេ ទោះបីរកដល់ទៅពីរកន្លែងក៏ដោយ ។

តារាង៥.១ បង្ហាញពតិមានលំអិតលើគំរូតាង ។ ដើម្បីសិក្សាលើ ២៧៦សហគ្រាសនេះ អង្កេតដល់កន្លែងបានធ្វើក្នុង ១៦ភូមិ និង តំបន់ជាយៗនៃទីប្រជុំជនខេត្តពីរ (បាត់ដំបង និង កំពង់ចាម) ។ អង្កេតបានធ្វើឡើងជាពីរផ្នែក : ក្នុងផ្នែកទី១ បានធ្វើសំភាសន៍ដោយប្រើបញ្ជីសំនួរជាក់លាក់ និងក្នុងផ្នែកទី២ បានធ្វើសំភាសន៍ជាចំហ ដើម្បីស្រង់យកមតិស្តីពីទំនាក់ទំនងទីផ្សារ ។

**តារាង៥.១ ពតិមានលំអិតលើគំរូតាង**

| សកម្មភាព | ខេត្ត | ភូមិ | គំរូតាង | សរុបគំរូតាង |
|---|---|---|---|---|
| នេសាទ | កំពង់ឆ្នាំង<br>ពោធិសាត់ | ឆ្នុកទ្រូ<br>កំពង់ហ្លួង | 30<br>30 | 60 |
| កែច្នៃត្រី | កំពង់ឆ្នាំង<br>ពោធិសាត់ | ឆ្នុកទ្រូ<br>កំពង់ហ្លួង | 30<br>30 | 60 |
| តំបាញសូត្រ | តាកែវ | ពៃ និងព្រៃជុប | 30 | 30 |
| តំបាញអំបោះ | កណ្តាល | ក្បាលកោះ | 30 | 30 |
| ក្អមឆ្នាំង | កំពង់ឆ្នាំង | ឧដុង្គ, ត្រពាំង, ក្រាំងដីមាស | 40 | 40 |
| សិប្បកម្មចម្លាក់ថ្មម៉ាប | ពោធិសាត់ | បន្ទាយដី, កែវសុណាន់លើ, បណ្តុះសណ្តែក, អូបាក្រងកណ្តាល, កញ្ជើបាយដាក់, និង ក្បាលហុង | 32 | 34 |
| ផលិតកម្មឥដ្ឋក្បឿង | បាត់ដំបង<br>កំពង់ចាម | | 9<br>13 | 22 |
| សរុប | | | | 276 |

ជំពូកទី៤ បង្ហាញថា មានកម្មករជាច្រើនបានធ្វើសកម្មភាពផ្សេងៗទៀត ក្រៅពីសកម្មភាពជនបទទាំងឡាយដែលបានលើកមកសិក្សា ។ តារាង៥.២ បង្ហាញថា ក្រៅតែពីគ្រួសារដែលធ្វើរបរនេសាទ និងការកែច្នៃត្រី, គ្រួសារក្នុងគំរូតាងភាគច្រើនមានដីកសិកម្មមួយចំនួន ហើយសកម្មភាពមិនមែនកសិកម្មគឺច្បាស់ជាសកម្មភាពបំពេញបន្ថែមប៉ុណ្ណោះទេសំរាប់គ្រួសារទាំងនេះ ។ ដោយហេតុថា ការនេសាទជាសកម្មភាពធំជាងគេឆ្ងាយណាស់ក្នុងវិស័យមិនមែនកសិកម្មនៅជនបទ ដូច្នេះគេអាចអះអាងដោយទុកចិត្តបានថា សកម្មភាពមិនមែនកសិកម្ម វាមិនមែនសុទ្ធតែជាការបំពេញបន្ថែមលើការងារកសិកម្មរាល់ៗលើកនោះទេ ។

**តារាង៥.២ របាយគ្រួសារតាមការកាន់កាប់ដី**

| ការកាន់កាប់ដី | នេសាទ | កែច្នៃត្រី | តំបាញសូត្រ | តំបាញកប្បាស | ក្អមឆ្នាំង | សិប្បកម្មថ្មម៉ាប | ផលិតឥដ្ឋក្បឿង |
|---|---|---|---|---|---|---|---|
| មាន | 3 | 5 | 30 | 29 | 36 | 23 | 14 |
| គ្មាន | 57 | 55 | 0 | 1 | 4 | 9 | 8 |
| សរុប | 60 | 60 | 30 | 30 | 40 | 32 | 22 |

លើកលែងតែអ្នកធ្វើសកម្មភាពខាងក្អមឆ្នាំង និងចម្លាក់ថ្មម៉ាប, តារាង៥.៣ បង្ហាញថា ជាមធ្យម សហគ្រាសទាំងអស់រកចំណូលបានយ៉ាងច្រើនពីសកម្មភាពក្រៅកសិកម្មនៅជនបទរបស់គេ គឺបានលើសពី ៥០% នៃចំណូលសរុបទៅទៀត ។ តាមពិតម្ចាស់ឡឥដ្ឋ អ្នកនេសាទ អ្នកតំបាញអំបោះ ទទួលបានចំណូលសឹងតែទាំងអស់ដោយមវិធីនេះ ។ ការកែច្នៃត្រីដែលជាសកម្មភាពតាមរដូវកាល ផ្តល់ចំណូលមិនលើសពី ២/៣ នៃចំណូលសរុបទេ ។ អ្នកផលិតក្អមឆ្នាំង និងអ្នកផលិតចំលាក់ថ្មម៉ាប ធ្វើសកម្មភាពទាំងនេះក្នុងលក្ខណៈជាការងារកន្លះពេលដូចគ្នា ហើយបានចំណូលមិលើសពី ១/៣ នៃចំណូលសរុបទេ ។ ដូច្នេះស្ថានភាពជាក់ស្តែង វាប្រែប្រួលទៅតាមប្រភេទសហគ្រាស ។

**តារាង៥.៣ ទំហំចំណូលទទួលបានពីសកម្មភាពមិនមែនកសិកម្ម (របាយសហគ្រាសតាមមុខសកម្មភាព)**

| សកម្មភាព | %ចំណូលបានពីសកម្មភាពនេះ (មធ្យម) | គំលាតស្តង់ដារ |
|---|---|---|
| នេសាទ | 89.24 | 21.01 |
| កែច្នៃត្រី | 66.49 | 21.46 |
| តំបាញសូត្រ | 61.85 | 21.69 |
| តំបាញអំបោះ | 75.23 | 21.96 |
| ក្អមឆ្នាំង | 33.00 | - |
| សិប្បកម្មចំលាក់ថ្មម៉ាប | 36.00 | - |
| ផលិតកម្មឥដ្ឋ | 93.00 | - |

ទិន្នន័យនៅក្នុងតារាង៥.៤ បង្ហាញថា ក្រៅពីខាងនេសាទចេញ សហគ្រាសភាគច្រើនក្នុងគំរូតាងមានដើមកំណើតក្នុងពេលថ្មីៗនេះទេ ។ មួយចំណែក ដើមកំណើតថ្មីៗនេះវាបង្ហាញពីរបាយអាយុនៃប្រជាជន និងមួយចំណែកទៀត វាឆ្លុះបញ្ចាំងពីការកសាងសេដ្ឋកិច្ចកម្ពុជាឡើងវិញចាប់តាំងពីទសវត្សរ៍១៩៨០ មក ។ គេជឿថា ការនេសាទមិនបានរលុះរលាយទេក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ ដូច្នេះវាក៏មិនចាំបាច់ត្រូវបង្កើតឡើងវិញដែរ ។

**តារាង៥.៤ ចំនួនឆ្នាំ តាំងពីសហគ្រាសចាប់ផ្តើមប្រតិបត្តិការ (របាយសហគ្រាសតាមមុខសកម្មភាព)**

| សកម្មភាព | ចំនួនឆ្នាំប្រតិបត្តិការ | | | |
|---|---|---|---|---|
| | មុនឆ្នាំ១៩៨០ | ១៩៨០-១៩៩០ | ១៩៩១ ដល់បច្ចុប្បន្ន | សរុប |
| នេសាទ | 21 | 15 | 24 | 60 |
| កែច្នៃត្រី | 6 | 16 | 38 | 60 |
| តំបាញសូត្រ | 1 | 24 | 5 | 30 |
| តំបាញអំបោះ | 4 | 13 | 13 | 30 |
| ក្អមឆ្នាំង | 6 | 9 | 25 | 40 |
| សិប្បកម្មចំលាក់ថ្មម៉ាប | 5 | 7 | 20 | 32 |
| ផលិតកម្មឥដ្ឋ | - | 4 | 18 | 22 |

## *៥.២ ការងារ និងប្រាក់ចំណូល*

សកម្មភាពក្រៅកសិកម្មនៅជនបទ មានលក្ខណៈរដូវកាលក្នុងកំរិតណាមួយ ជាពិសេសបើសិនវាពឹងផ្អែលលើធាតុចូលមានលក្ខណៈរដូវកាល ដូចជា ពលកម្ម ឬបើសិនតំរូវការធាតុចេញមានលក្ខណៈរដូវកាលដែរ ។ ការងារនៅក្នុងរដូវមួយ មិនអាចមានន័យថា ពលករចំនួនប៉ុនគ្នាមានការងារនេះធ្វើពេញមួយឆ្នាំនោះទេ ។ ដូច្នេះតួលេខដែលបង្ហាញជូនក្នុងផ្នែកនេះ ត្រូវធ្វើការបកស្រាយឱ្យបានស្របគ្នា ។

### *៥.២.១ ទំហំការងារ*

តារាង៥.៥ បង្ហាញថា ជាមធ្យមសហគ្រាសនេសាទជួលបុគ្គលិកប្រហែល ៣,៦៥នាក់ ។ ក្នុងរដូវពីខែ មករា-មីនា និង មេសា-មិថុនា ចំនួនមធ្យមនៃពលករក្នុងមួយសហគ្រាស គឺឡើងដល់កំរិតពេញ, ប៉ុន្តែក្នុងរដូវពីខែកក្កដា-កញ្ញា វាធ្លាក់ចុះដល់ក្រោមកណ្តាលនៃចំនួននេះ ។ ចំនួនកម្មករ ឡើងវិញដល់ ៨០% នៃកំរិតពេញក្នុងរដូវខែតុលា-ធ្នូ ។ គិតតាមចំនួនការងារ សហគ្រាសនេសាទភាគច្រើន (ជិត ៦០%) ទំហំតូចទេ និងមានពលករពី ២-៥នាក់ (រួមទាំងពលករស៊ីឈ្នួល) ។ វិធីឃើញមានច្រើនបំផុត គឺ ក្រុមមួយដែលមានឪពុកម្នាក់ចេញទៅនេសាទជាមួយកូនប្រុសគាត់ ។ បន្ទាប់មកគឺមានសហគ្រាសមាន

ពលករម្នាក់ និងបន្ទាប់មកទៀតសហគ្រាសមានប្រើពលករ ៦-១០នាក់ ។ ក្នុង ៦០សហគ្រាស មានតែ ៣សហគ្រាសទេ ដែលប្រើពលករដល់ ១១-២០នាក់ក្នុងសហគ្រាសមួយៗ ។ នៅពេលធ្វើសម្ភាសន៍ បានរកឃើញប្រតិបត្តិករមួយចំនួនតូចដែលមានទូកម៉ាស៊ីនធំៗ ប្រើកម្មករប្រហែល ១០-១៥នាក់ក្នុងទូកមួយៗ ។ គំលាតស្តង់ដាយ៉ាងធំ ធៀបនឹងមធ្យមភាគ វាផ្តល់គំនិតថា សកម្មភាពទាំងឡាយក្នុងសហគ្រាសគំរូតាង មានទំហំផ្សេងៗពីគ្នា ។

ការកែច្នៃត្រី គឺជាសកម្មភាពគ្រួសារ/សិប្បកម្ម ដែលប្រើពលករតាមរដូវកាល (មិនច្រើនជាង ២-៣ខែទេ នៅពេលសំបូរត្រី) និងដែលបន្ទាប់ក៏ទៅធ្វើសកម្មភាពផ្សេងៗទៀត ។ ចំនួនការងារមធ្យមបង្ហាញក្នុងតារាង៥.៥ ហាក់ដូចមានតិច (ពលករ ២,២៣នាក់ ពីព្រោះវាជាមធ្យមភាគរវាងក្នុងរដូវ និងក្រៅរដូវ) ។ ដូចក្នុងការនេសាទដែរ ពលករកែច្នៃត្រីច្រើននាក់បំផុតចូលបំរើក្នុងសហគ្រាសនានាដែលមានប្រើពលករ ២-៥នាក់ ។ ពលករច្រើនគួរសមដែរធ្វើការងារក្នុងសហគ្រាសមានពលករតែម្នាក់ ។ មានសហគ្រាសតែពីរទេ ដែលមួយៗមានពលករពី ៦-១០នាក់ ។

**តារាង៥.៥ ចំនួនកម្មករសរុប (របាយសហគ្រាសតាមមុខសកម្មភាព)**

| សកម្មភាព | កម្មករម្នាក់ | កម្មករ ២-៥នាក់ | កម្មករ ៦-១០ នាក់ | កម្មករ ១១-២០នាក់ | កម្មករច្រើនជាង ២០នាក់ | សរុប | កម្មករមធ្យម | គំលាតស្តង់ដា | ភាគរយ កម្មករស្រី |
|---|---|---|---|---|---|---|---|---|---|
| នេសាទ | 7 | 35 | 5 | 3 | - | 60 | 3.65 | 3.13 | 28.51 |
| កែច្នៃត្រី | 23 | 35 | 2 | - | - | 60 | 2.23 | 2.45 | 54.85 |
| តំបាញសូត្រ | 16 | 14 | - | - | - | 30 | 1.51 | 0.27 | 97.59 |
| តំបាញអំបោះ | 2 | 23 | 5 | - | - | 30 | 4.00 | 1.87 | 86.66 |
| ក្អមឆ្នាំង | 27 | 11 | - | - | - | 38 | 1.35 | 0.68 | - |
| សិប្បកម្មថ្មម៉ាប | 8 | 16 | 8 | - | - | 32 | 2.26 | 1.85 | - |
| ផលិតកម្មឥដ្ឋ | - | - | - | 4 | 18 | 22 | 32.86 | 19.36 | - |

ទោះបីមានគីតំបាញសូត្រច្រើនប្រមូលផ្តុំនៅកន្លែងតែមួយក្តី ក៏គីតំបាញជាកម្មសិទ្ធិរបស់គ្រួសារខុសៗគ្នា ហើយគ្រួសារនីមួយៗអាចជាត់ទុកជាសហគ្រិនបាន ។ គ្មានអ្វីគួរភ្ញាក់ផ្អើលទេ ដែលក្នុងចំណោម ៣០អង្គភាពផលិត មាន ១៦អង្គភាពជាអង្គភាពមានពលករតែម្នាក់ ហើយ ១៤អង្គភាពទៀតមានប្រើពលករ ២-៥នាក់ ។ ផ្ទុយមកវិញ អង្គភាពតំបាញអំបោះមានទំហំធំជាង ហើយទោះបីចំនួនពលករមធ្យមនៅក្នុងសកម្មភាពនេះ គឺ ២-៥នាក់ដូចគ្នា ប៉ុន្តែសហគ្រាសមានពលករតែម្នាក់ មានចំនួនតិចជាង (តែ ២អង្គភាព) ។ ក្នុងករណីតម្បាញសូត្រ ចំនួនប្រើពលករមធ្យមគឺ ៤នាក់ គឺខ្ពស់ជាងកិរិតមធ្យមភាគត្រឹម ១,៥១ ។ គំលាតស្តង់ដាក្នុងទាំងពីរករណី មានកិរិតតូច ធៀបនឹងមធ្យមភាគ គឺបានន័យថា គ្មានការប្រែប្រួលច្រើនទេក្នុងទំហំអង្គភាព ។ ម្យ៉ាងទៀតក៏គ្មានការប្រែប្រួលតាមរដូវកាលច្រើនដែរៈ សកម្មភាពទាំងពីរនេះ ដំណើរការពេញៗមួយឆ្នាំ ។

ក្អមឆ្នាំង ក៏ដូចជាការកែច្នៃត្រីដែរ គឺជាសហគ្រាសតាមគ្រួសារ តែខុសគ្នាត្រង់ថា វាជាការងារមិនពេញពេល និងធ្វើជាហូរហែពេញៗមួយឆ្នាំ ។ សហគ្រាសភាគច្រើន (២៧សហគ្រាសក្នុងចំណោម ៣៨សហគ្រាស) គឺជា អង្គភាពផលិតមានពលករតែម្នាក់ ហើយចំនួនពលករមធ្យមក្នុងមួយអង្គភាពគឺ ១,៣៥នាក់ (តូចជាងគេក្នុងគំរូតាង) ។ សិប្បកម្មចម្លាក់ថ្មម៉ាប ជាសកម្មភាពគ្រួសារស្រដៀងនឹងសកម្មភាពក្អមឆ្នាំងដែរ ប៉ុន្តែទំហំសហគ្រាសមិនមែនតូចដូចគេតែងគិតនោះទេ ពាក់កណ្តាលនៃសហគ្រាសទាំងនេះ ប្រើពលករពី ២-៥នាក់ និង ២៥%ប្រើពលករពី ៦-១០នាក់ ។ ក្នុងចំណោម ៣២សហគ្រាស មានតែ ៨សហគ្រាសទេ ដែលជា អង្គភាពមានពលករតែម្នាក់ ។ មធ្យមភាគការងារគឺ ២,២៦ ។

សហគ្រាសធ្វើអាជីវកម្មផលិតកម្មឥដ្ឋ មានទំហំធំៗជាងគេក្នុងគំរូតាង: ជាមធ្យមភាគសហគ្រាសផលិតឥដ្ឋមួយមានបុគ្គលិកប្រហែល ៣២នាក់ ។ តួលេខនេះ ធំជាងបណ្តាសហគ្រាសធ្វើអង្កេតដោយ Rozemuller ដែលជាមធ្យមសហគ្រាសមួយមានកម្មករ ១៥-២០នាក់ ។ ក្នុងចំណោម ២២សហគ្រាសក្នុងការសិក្សានេះ មានតែ ៤សហគ្រាសប៉ុណ្ណោះដែលមានបុគ្គលិកពី ១១-២០នាក់ ។ ប៉ុន្តែ Rozemuller បានធ្វើការសិក្សាក្នុងឆ្នាំ១៩៩៨ ហើយសិក្សានេះបានធ្វើក្រោយគ្នាដល់ទៅ ៤ឆ្នាំ ។ ប៉ុន្តែរឿងនេះក៏អាចបណ្តាលផងដែរមកពីបញ្ហាដែលថា គំរូតាងនេះមិនបានបង្ហាញពេញលេញល្អនូវអង្គភាពផលិតទំហំតូចៗ ។

ខ្ទង់បញ្ឈរចុងក្រោយនៃតារាង៥.៥ បង្ហាញថា ពលករស្ត្រីធ្វើសកម្មភាពនេសាទ មានតិចជាង ១/៣ នៃចំនួនសរុប ប៉ុន្តែមានច្រើនគួរសមក្នុងការកែច្នៃត្រី ។ ស្ត្រីបំរើការងារជាសំខាន់ក្នុងសកម្មភាពតំបាញទាំងពីរ ។ ទិន្នន័យអង្កេតបង្ហាញថា ការបែងចែកការងារតាមភេទមានលក្ខណៈមិនច្បាស់លាស់ទេក្នុងសកម្មភាពបីប្រភេទ ប៉ុន្តែវាមានលក្ខណៈច្បាស់លាស់ក្នុងយ៉ាងហោចណាស់ ៤ប្រភេទ ទៀត ។

### *៥.២.២ ការជួលពលកម្ម និងផលកំរៃ*

តារាង៥.៦ បង្ហាញថា ១០០% នៃពលករផលិតឥដ្ឋត្រូវបានជួលមកបំរើការ ហើយនេះតួលេខមួយខ្ពស់ជាខ្លាំង ធៀបនឹងតួលេខសំរាប់សហគ្រាសឯទៀតៗដែលមានតាំងពី ២០%សំរាប់ខាងនេសាទ, ១៦%ខាងសិប្បកម្មចម្លាក់ថ្មម៉ាប, រហូតដល់តិចជាង ៣%សំរាប់ខាង កែច្នៃត្រី តំបាញសូត្រ និងក្អមឆ្នាំង ។ ដោយសារសកម្មភាពនានាក្រៅពីផលិតឥដ្ឋ ជាសិប្បកម្មខ្នាតតូច សមាមាត្រកម្មករជួលមកធ្វើការក៏មានទំហំតូចដែរ ។ ក្នុងករណីភាគច្រើន ពលករគឺជាម្ចាស់អាជីវកម្មខ្លួនឯង និងសមាជិកគ្រួសារគាត់ ។ ទំហំប្រតិបត្តិការកាន់តែតូចកាលណា ចំនួនពលករស៊ីឈ្នួលក៏កាន់តែតិចកាលណោះ ហើយបើទំហំប្រតិបត្តិការកាន់តែធំ ពលករស៊ីឈ្នួលក៏មានកាន់តែច្រើនដែរ ។

កំរៃជាមធ្យមសំរាប់ពលករបុរស បានខ្ពស់បំផុតនៅខាងនេសាទ និងទាបបំផុតនៅខាងតំបាញអំបោះ (ក្នុងចំណោម ៤ សកម្មភាពដែលមានទិន្នន័យ - ជាដោយឡែកគឺ គ្មានពលករស៊ីឈ្នួលទេក្នុងតំបាញសូត្រ) ។ ខាងផ្នែកនេសាទ កំរៃប្រចាំខែសំរាប់ ពលករបុរស គឺ ១៥៣.២៨៣រៀល (មួយខែពេញ) ដែលត្រូវជាជាង ៥.០០០រៀលបន្តិចក្នុងមួយថ្ងៃ ។ ប៉ុន្តែការងារមានពេញៗ មួយខែសំរាប់តែមួយរយៈពេលខ្លីប៉ុណ្ណោះ ។ មធ្យមភាគចំនួនថ្ងៃធ្វើការក្នុងមួយខែ គឺប្រហែល ១៣ថ្ងៃ ដោយសារក្នុងខែខ្លះ (កក្កដា-កញ្ញា) គ្មានការងារធ្វើទេ ។ ប្រាក់កំរៃសំរាប់ពលករស្ត្រីនៅក្នុងសកម្មភាពនេះ មានកំរិតទាបជាង គឺប្រហែលតែ ៨៣% នៃកំរិតប្រាក់កំរៃសំរាប់ពលករបុរស ។ ក្នុងផ្នែកកែច្នៃត្រីវិញ ប្រាក់កំរៃសំរាប់ពលករបុរសបានប្រហែល ៤.៥០០រៀល/ថ្ងៃ ឯ ពលករស្ត្រីបានប្រហែល ៦៣% នៃកំរិតនេះ ។ ក្នុងផ្នែកតំបាញអំបោះ ប្រាក់កំរៃបានកាន់តែតិច ប្រហែល ២.៧០០រៀល/ថ្ងៃ ប៉ុន្តែគំលាតប្រាក់កំរៃតាមយេនឌ័រ វាទាបសឹងស្មើសូន្យ ។ សរុបមក ពលករទទួលបានប្រាក់កំរៃមិនលើសពីកំរិត ១ដុល្លារ/ថ្ងៃ ច្រើនប៉ុន្មានទេ ហើយថែមទាំងមានគំលាតតាមភេទទៀត ។

**តារាង៥.៦ ចំនួនភាគរយជាមធ្យមនៃកម្មករស៊ីឈ្នួល និង ប្រាក់កំរៃជាមធ្យម (តាមមុខសកម្មភាព)**

| សកម្មភាព | ភាគរយកម្មករស៊ីឈ្នួល | ប្រាក់កំរៃមធ្យមបុរស/ខែ | ប្រាក់កំរៃមធ្យមស្ត្រី/ខែ | ការងារបុរស (ចំនួនថ្ងៃ/ខែ) | ការងារស្ត្រី (ចំនួនថ្ងៃ/ខែ) |
|---|---|---|---|---|---|
| នេសាទ | 21.71 | 153,283 | 127,500 | 12.9 | 12.9 |
| កែច្នៃត្រី | 1.80 | 137,500 | 86,980 | 23.7 | 23.7 |
| តំបាញសូត្រ | - | - | - | 9.2 | 27.1 |
| តំបាញអំបោះ | 9.07 | 80,900 | 81,928 | 10.0 | 28.7 |
| ក្អមឆ្នាំង | 2.50 | - | - | - | - |
| សិប្បកម្មថ្មម៉ាប | 16.00 | - | - | - | - |
| ផលិតឥដ្ឋ | 100 | - | - | - | - |

### ៥.២.៣ ការទទួលបានជំនាញ

តារាង៥.៧ បង្ហាញថា តើជំនាញផ្សេងៗវាមានឬទេ និង តើពលករ (រួមទាំងអ្នកផ្តល់អាជីពដោយខ្លួនឯង) ទទួលបានជំនាញដោយវិធីណា។ តារាងបង្ហាញថា ក្នុងគ្រប់មុខសកម្មភាព ពលករភាគច្រើនលើសលុបរៀនជំនាញពីក្រុមគ្រួសាររបស់ខ្លួន ។ ក្នុងការនេសាទ និងកែច្នៃត្រី ប្រហែល ១/៤ នៃពលករ រៀនជំនាញភ្ជាប់នឹងការអនុវត្តន៍ការងារតែម្តង ។ ផ្នែកខាងក្អមផ្អាំង NGOs បំពេញតួនាទីសំខាន់ក្នុងការផ្តល់ជំនាញឱ្យ ប៉ុន្តែក្នុងសិប្បកម្មចម្លាក់ថ្មម៉ាប NGOs បំពេញតួនាទីតិចទេ ។ សរុបមក ក្នុងសកម្មភាពភាគច្រើន ជំនាញនានាត្រូវបានផ្ទេរពីមួយជំនាន់ទៅមួយជំនាន់ ហើយក្នុងករណីខ្លះៗ NGOs ក៏បានចូលមកជួយដែរ ប៉ុន្តែគេមិនដឹងច្បាស់ទេថា តើតួនាទីរបស់ NGOs នេះវាសំខាន់ប៉ុណ្ណាក្នុងការជួយឱ្យពលករបានទទួលការងារបច្ចុប្បន្នរបស់ខ្លួន ។

**តារាង៥.៧ ប្រភពនៃការទទួលបានជំនាញសំរាប់កម្មករ (របាយសហគ្រាសតាមមុខសកម្មភាព)**

| សកម្មភាព | ឳពុកម្តាយ/អ្នកផ្ទៃទាំ | NGO | ភ្ជាប់នឹងការងារ | បណ្តុះបណ្តាលផ្លូវការ | សរុប |
|---|---|---|---|---|---|
| នេសាទ | 43 | 1 | 16 | - | 60 |
| កែច្នៃត្រី | 47 | - | 13 | - | 60 |
| តំបាញសូត្រ | 30 | - | - | - | 60 |
| តំបាញអំបោះ | 29 | - | 1 | - | 30 |
| ក្អមផ្អាំង | 11 | 25 | - | 2 | 38 |
| សិប្បកម្មថ្មម៉ាប | 26 | 2 | 3 | 1 | 32 |
| ផលិតឥដ្ឋ | 17 | 2 | 3 | - | 22 |

មុខសកម្មភាពដែលបានធ្វើអង្កេតសំរាប់ការសិក្សានេះ មិនមែនជាប្រភេទសកម្មភាពដែលតាមធម្មតាត្រូវមានការបណ្តុះបណ្តាលក្នុងប្រព័ន្ធនោះទេ ជាពិសេសបើសិនបច្ចេកវិទ្យា និងវិធីសាស្ត្រប្រតិបត្តិការ មានលក្ខណៈប្រពៃណី ។ ប៉ុន្តែក៏មិនមែនបានន័យថា ក្នុងវិស័យទាំងនេះគ្មានលទ្ធភាព ឬតំរូវការ កែលំអបច្ចេកវិទ្យានោះដែរ ។ អន្តរាគមន៍របស់នាយកដ្ឋានវិចិត្រសិល្បៈនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈក្នុងផ្នែកក្អមផ្អាំង និងសិប្បកម្ម, សកម្មភាព NGO អាល្លឺម៉ង់មួយក្នុងការផ្ទេរបច្ចេកវិទ្យាខាងក្អមផ្អាំង, ការណែនាំឱ្យប្រើកីតំបាញម៉ាស៊ីន, បានបង្ហាញពីទំហំលទ្ធភាពក្នុងការជួយកែលំអគុណភាពផលិតផល និងផលិតភាព ។

## ៥.៣ ចំណាយជាមូលធន

### ៥.៣.១ ទំហំមូលធន

តារាង៥.៨ បង្ហាញទិន្នន័យពីរបាយសហគ្រាសតាមទំហំចំណាយជាមូលធន (តំលៃទ្រព្យសកម្មជាប់លាប់ក្រៅពីដីធ្លី, គិតជារៀល) និងតំលៃមធ្យមនៃចំណាយជាមូលធនរបស់សហគ្រាសតាមមុខសកម្មភាពនិមួយៗ ។

ទំហំសហគ្រាសដែលអាចពិនិត្យឃើញតាមតួលេខចំណាយជាមូលធន មានការខុសប្លែកគ្នាច្រើនជាង ទំហំសហគ្រាសដែលអាចពិនិត្យឃើញតាមទិន្នន័យចំនួនពលករ ។ ឧទាហរណ៍ នៅក្នុងផ្នែកនេសាទ សហគ្រាសតូចជាងគេមានចំណាយជាមូលធនតិចជាង ២៥០.០០០រៀល (ប្រហែល ៦៣ដុល្លារ) រីឯសហគ្រាសធំជាងគេ អាចមានច្រើនជាងនេះ ២០ដង ។ រូបភាពក៏ស្រដៀង គ្នានេះដែរសំរាប់សហគ្រាសកែច្នៃត្រី គឺសហគ្រាសតូចបំផុតមានចំណាយជាមូលធនធំជាង ៥០.០០០រៀល បន្តិច (ប្រហែល ១៣ដុល្លារ) ចំណែកសហគ្រាសធំៗបំផុត អាចធំជាងនេះ ៤០ដង ។ គំលាតចំណាយជាមូលធនរវាងសហគ្រាស មានកំរិតតូច បំផុតនៅផ្នែកក្អមផ្អាំង (ជារឿងសមហេតុផលយោងតាមវិធីផលិតប្រើពលកម្មច្រើន), បន្ទាប់មកគឺតំបាញសូត្រដែលប្រើ បច្ចេកវិទ្យាចាស់គំរិលដូចគ្នា, តមកទៀតគឺតំបាញអំបោះ, ហើយបន្ទាប់មកទៀតគឺសិប្បកម្មចម្លាក់ថ្មម៉ាប ។ ក្នុងសិប្បកម្មចម្លាក់ ថ្មម៉ាប

ការបញ្ចូលប្រើប្រាស់នូវរណារម៉ាស៊ីន និងពន្លាកម៉ាស៊ីន ដោយសហគ្រិនខ្លះៗ បានបង្កើនគំរូវការប្រើប្រាស់ទុន និងបានពង្រីកគំលាតចំណាយជាមូលធនរវាងសហគ្រាស ។ ផលិតកម្មឥដ្ឋ មានចំណាយជាមូលធនច្រើនដូចៗគ្នា ហើយគំលាតក្នុងទំហំចំណាយនេះមិនធំណាស់ណាទេ (ខុសគ្នាប្រហែល ៣ដង ពីទំហំតូចបំផុត ដល់ទំហំធំបំផុត) ។ ប៉ុន្តែនៅខាងនេសាទ និងកែច្នៃត្រី គំលាតមានកំរិតធំណាស់រហូតដល់ជាង ២០ដង រវាងសហគ្រាសតូចបំផុត និង ធំបំផុត ។ គំលាតដ៏តូចរវាងចំណាយជាមូលធននៅក្នុងផលិតកម្មឥដ្ឋ អាចកើតចេញពីគំរូតាងដែលមានលំអៀងទៅខាងសហគ្រាសធំៗ ។

**តារាង៥.៨ ទំហំទ្រព្យសកម្មជាប់លាប់ (របាយសហគ្រាសតាមមុខសកម្មភាព)**

| សកម្មភាព | ចំណាត់ថ្នាក់ទំហំ (រៀល) | ចំនួនសហគ្រាស | ទ្រព្យសកម្មជាប់លាប់ (មធ្យមជារៀល) |
|---|---|---|---|
| នេសាទ | <250,000 | 9 | 3.9 លាន |
| | 250,000-500,000 | 10 | |
| | 500,000-1 លាន | 14 | |
| | 1-1.5 លាន | 9 | |
| | 1.5-5 លាន | 8 | |
| | >5 លាន | 10 | |
| កែច្នៃត្រី | <50,000 | 13 | 1.49 លាន |
| | 50,000-200,000 | 8 | |
| | 200,000-500,000 | 16 | |
| | 500,000-1 លាន | 7 | |
| | 1-2 លាន | 7 | |
| | >2 លាន | 6 | |
| តំបាញសូត្រ | <50,000 | 6 | 130,557 |
| | 50,000-100,000 | 8 | |
| | 100,000-200,000 | 11 | |
| | >200,000 | 5 | |
| តំបាញកប្បាស | <1 លាន | 4 | 3.76 លាន |
| | 1-2 លាន | 3 | |
| | 2-3 លាន | 7 | |
| | 3-5 លាន | 5 | |
| | >5 លាន | 11 | |
| ក្អមឆ្នាំង | <200,000 | 7 | 283,560 |
| | 200,000-300,000 | 12 | |
| | >300,000 | 6 | |
| ថ្មម៉ាប | <500,000 | 17 | 1.47 លាន |
| | 500,000-3 លាន | 7 | |
| | >3 លាន | 8 | |
| ផលិតកម្មឥដ្ឋ | <70 លាន | 5 | 126 លាន |
| | 70-100 លាន | 8 | |
| | 100-200 លាន | 6 | |
| | >200 លាន | 3 | |

ជាមធ្យម ចំណាយជាមូលធនក្នុងផ្នែកនេសាទ គឺ ៣,៩លានរៀល ( ប្រហែល ៩៧៥ដុល្លារ),ក្នុងផ្នែកកែច្នៃត្រីគឺ ១,៤៩ លានរៀល ( ប្រហែល ៣៧៣ដុល្លារ), ផ្នែកតំបាញសូត្រ ១៣០.៥៥៧រៀល ( ប្រហែល ៣៤ដុល្លារ), តំបាញកប្បាស ៣,៧៦ លានរៀល ( ប្រហែល ៩៤០ដុល្លារ), ក្អមឆ្នាំង ២៨៣.៥៦០រៀល ( ប្រហែល ៧២ដុល្លារ) និងសិប្បកម្មចម្លាក់ថ្មម៉ាប ១,៤៧លានរៀល ( ប្រហែល ៣៧០ដុល្លារ) ។ មានតែផ្នែកផលិតកម្មឥដ្ឋទេ ដែលមានមធ្យមភាគចំណាយជាមូលធនច្រើនដល់ទៅ ១២៦ លានរៀល ( ប្រហែល ៣១.៥០០ដុល្លារ)[៣១] ។ តួលេខនេះបង្ហាញថា ក្រៅពីផលិតកម្មឥដ្ឋចេញ (និងនៅក្នុងបរិបទនៃប្រទេសមានចំណូលទាបក្តី) ក៏គេអាចផ្តួចផ្តើមកសាងសហគ្រាសអាជីវកម្មនៅតំបន់ជនបទបានដោយប្រើមូលធនតែមួយចំនួនតូច ដែលអាចផ្តល់ការងារមានប្រាក់កំរៃ បានមួយចំនួន ។

*៥.៣.២ លទ្ធកម្ម និងការថែទាំសំភារៈ*

តើបរិក្ខារប្រើប្រាស់មានចោទបញ្ហាទេ? តារាង៥.៩ បង្ហាញពីរបាយសហគ្រាស បែងចែកតាមរបៀបធ្វើលទ្ធកម្មទ្រព្យសកម្មជាប់លាប់ ។ មុននឹងពណ៌នាទិន្នន័យ សំខាន់ណាស់ត្រូវកំណត់និយមន័យនៃចំណងជើងខ្ទង់បញ្ឈរ ២ និង ៣ នៃតារាង ។ "អ្នកផ្គត់ផ្គង់ធាតុចូលក្នុងស្រុក" គឺជាម្ចាស់ហាងក្នុងស្រុកជាប់លាប់ដែលលក់សំភារៈ( ប្រាក់ដល់ដៃ ឬជឿ), ជាងឈើឬអ្នកផលិតបរិក្ខារក្នុងស្រុក ។ ផ្ទុយទៅវិញ "អន្តរការី" អាចជា អ្នកតំណាងក្រុមហ៊ុនផលិតគ្រឿងសំភារៈ ឬពាណិជ្ជករលក់ផលិតផលសំរេចដែលជាអ្នកផ្គត់ផ្គង់ធាតុចូល (ជាចំណែកមួយនៃទំនាក់ទំនងពាណិជ្ជកម្មដ៏ធំមួយ) ។ អន្តរការីអាចជាអ្នកមិននៅក្នុងស្រុកភូមិ និងមកពីកន្លែងផ្សេងដើម្បីផ្គត់ផ្គង់ធាតុចូលតាមការបញ្ជាទិញ ។ ចំពោះផលិតករក្នុងស្រុក អ្នកផ្គត់ផ្គង់ក្នុងស្រុកមានលក្ខណៈគួរទុកចិត្តនិងអាចពឹងផ្អែកបានប្រសើរជាងអន្តរការី ។

**តារាង៥.៩ របៀបធ្វើលទ្ធកម្មទ្រព្យសកម្មជាប់លាប់ ( របាយសហគ្រាសតាមមុខសកម្មភាព)**

| សកម្មភាព | អ្នកផ្គត់ផ្គង់ ធាតុចូលក្នុងស្រុក | អន្តរការី | ភ្នំពេញ | ផ្គត់ផ្គង់ ដោយខ្លួនឯង | សរុប |
|---|---|---|---|---|---|
| នេសាទ | 21 | 36 | 3 | - | 60 |
| កែច្នៃត្រី | 27 | 20 | 2 | 1 | 60 |
| តំបាញសូត្រ | 14 | 15 | 1 | - | 30 |
| តំបាញកប្បាស | 19 | 9 | 2 | - | 30 |

របាយសហគ្រាសក្នុងតារាងនេះបង្ហាញថា អ្នកផ្គត់ផ្គង់ក្នុងស្រុក និងអន្តរការី ផ្គត់ផ្គង់សំភារៈក្នុងចំនួនប្រហែល១គ្នា ។ ក្នុងការនេសាទ មានអន្តរការីច្រើនជាងដែលធ្វើការផ្គត់ផ្គង់សំភារៈ, រីឯក្នុងការកែច្នៃត្រី មានសហគ្រាសច្រើនជាងដែលទទួលសំភារៈពីអ្នកផ្គត់ផ្គង់ធាតុចូលក្នុងស្រុក ។ ក្នុងផ្នែកតំបាញសូត្រ អ្នកផ្គត់ផ្គង់ក្នុងស្រុក និងអន្តរការីមានចំនួនស្មើគ្នា, ចំណែកឯក្នុងផ្នែកតំបាញអំបោះ មានសហគ្រិនច្រើនណាស់ទិញសំភារៈពីអ្នកផ្គត់ផ្គង់ក្នុងស្រុក ។

ប្រភពផ្គត់ផ្គង់សំភារៈ ជាប់ទាក់ទងនឹងប្រភេទសំភារៈ ។ អ្នកធ្វើទូក ផលិតទូកនៅក្នុងស្រុក ឯអន្តរការីទិញម៉ាស៊ីនម៉ាស៊ូត (របស់ប្រើហើយ) ពីថៃ (ឬទិញក្នុងស្រុក បើវាផលិតនៅរុស្ស៊ី ឬចិន) ។ ម៉ាស៊ីនយកមកចាប់លើទូកដោយម្ចាស់ទូកខ្លួនឯង ឬដោយជាងម៉ាស៊ីនក្នុងស្រុក ។ ចំពោះការកែច្នៃត្រី សំភារៈចំបង១គឺ ឆ្នាំង ខ្ទះ ធុង ប្រដាប់កូរ កាំបិត និងរបស់ផ្ទះបាយផ្សេង១ ដែលអាចទិញបានដោយងាយពីហាងក្នុងស្រុកនានា ។ មានតែប្រតិបត្តិការធំ១ទេ ដែលត្រូវការរបស់ ដូចជាទូរទឹកកកជាដើម ។ ជាងឈើក្នុងស្រុក ផលិតទាំងសំភារៈតំបាញសូត្រ និងតំបាញអំបោះ ប៉ុន្តែអាចមានអ្នកផ្សេងនៅក្នុងខ្សែរយៈផ្គត់ផ្គង់ ដែលទទួលកីតំបាញ យកមកលក់ឱ្យអ្នកត្បាញ ។ ចំណុចល្អមួយទៀតនៃការប្រើសំភារៈក្នុងស្រុក គឺលទ្ធភាពជួសជុលម៉ាស៊ីននៅក្នុងស្រុក

[៣១] Rozemuller បានគណនាមធ្យមភាគនៃចំណាយជាមូលធនសំរាប់រោងចក្រផលិតឥដ្ឋនិមួយ១ ឃើញប្រហែល ៨.000ដុល្លារ ។ តួលេខខុសគ្នានេះ អាចដោយសារគំលាតពេលធ្វើមុនក្រោយរវាងការសិក្សាទាំងពីរ និងការលំអៀងទៅខាងសហគ្រាសធំ១នៅក្នុងគំរូតាងនេះ ។

ដែលអស់សោហ៊ុយតិច ។ ជារឿយៗណាស់ ម្ចាស់ម៉ាស៊ីនជួសជុលវាដោយខ្លួនឯង ។ នេះជាហេតុផលមួយដែលសហគ្រិនជ្រើសយកបច្ចេកវិទ្យាសាមញ្ញៗ ទោះបីផលិតភាពវាទាបក្តី ។

ផលិតករភាគច្រើនទទួលបានទ្រព្យសកម្មជាប់លាប់ និងទុនបង្វិល តាមរយៈ កេរ្តិ៍មរតក និងធនធានផ្ទាល់របស់គ្រួសារ បន្ទាប់មកគឺការខ្ចីបុលពីសាច់ញាតិ និងមិត្តភក្តិ ។ មានតិចនាក់ណាស់ទៅខ្ចីបុលពីប្រភពស្ថាប័ន (យ៉ាងហោចណាស់ក៏នៅក្នុងផ្នែកនេសាទ កែច្នៃត្រី តំបាញសូត្រនិងអំបោះ ដែលអង្កេតបានខឹតខំសាកសួរពីរឿងឥណទាន) ។ គំហើញនេះមិនមែនជារឿងថ្មីទេ ពីព្រោះការសិក្សាផ្សេងៗទៀតបានរកឃើញដូច្នេះដែរ ។ មូលហេតុចំបងនៃកង្វះការផ្គត់ផ្គង់ឥណទាន គឺ ហេដ្ឋារចនាសម្ព័ន្ធសង្គមមិនសមស្របសំរាប់ការគ្រប់គ្រង និងប្រមូលទារប្រាក់កំចី ។ ផលវិបាកគឺ អត្រាការប្រាក់ខ្ពស់ បានរារាំងការខ្ចីបុលរបស់អ្នកត្រូវការទុន ហើយក្នុងដំណើរការនេះ សហគ្រាសអាជីវកម្មមិនអាចរីកលូតលាស់ទេ[៣២] ។

### *៥.៣.៣ អនុបាតមូលធន-ពលកម្ម*

អនុបាតមូលធន-ពលកម្ម កំណត់ទំហំមូលធនដែលត្រូវការដើម្បីបង្កើនការងារមួយ (ឬតំរូវការមូលធននៃសកម្មភាព: capital intensity of activities) ។ តារាង៥.១០ បង្ហាញពីអនុបាតសំរាប់ ៦សកម្មភាព ក្នុងចំណោមសកម្មភាពទាំង ៧មុខ ។

សំរាប់ការនេសាទ និងការកែច្នៃត្រី គេត្រូវការពី ៧០០.០០០-៨០០.០០០រៀល (ប្រហែល ២០០ដុល្លារ) ដើម្បីបង្កើតការងារមួយ ដែលជាតួលេខមួយតូចទេ ពិនិត្យតាមទំរង់បច្ចេកវិទ្យា និងរបៀបរៀបចំក្នុងពេលសព្វថ្ងៃ ។ តំរូវការមូលធនសំរាប់ការងារមួយ រឹតតែតូចថែមទៀតសំរាប់តំបាញសូត្រគឺពី ៩០.០០០-១០០.០០០រៀល (២៥-៣០ដុល្លារ) ប៉ុន្តែតំបាញសូត្រត្រូវការជំនាញខ្ពស់ជាង ។ តំបាញអំបោះត្រូវការកាន់តែច្រើននូវមូលធនក្នុងពលករម្នាក់ (ប្រហែល ៩០០.០០០រៀល) ដោយសារកីត្បាញមានដាក់ម៉ូទ័រអគ្គិសនី ។ ក្អមឆ្នាំង ត្រូវការពី ២៥០.០០០-២៦០.០០០រៀល (៦៥-៧០ដុល្លារ) សំរាប់ពលករម្នាក់ ប៉ុន្តែវាទាមទារជំនាញច្រើនជាង ។ មានតែក្នុងករណីផលិតកម្មឥដ្ឋទេ ដែលតំរូវការមូលធនសំរាប់បង្កើតការងារមួយឡើងដល់ ៤,៩៤លានរៀល (១.២៥០ដុល្លារ) ។ តួលេខនេះខ្ពស់ជាងគេខ្លាំងណាស់នៅក្នុងគំរូតាង ប៉ុន្តែវាមិនធំពេកទេ បើពិនិត្យក្នុងបរិបទនៃសហគ្រាសធំៗ ។

**តារាង៥.១០ អនុបាតមូលធន-ពលកម្ម (តាមមុខសកម្មភាព)**

| សកម្មភាព | អនុបាតមូលធន-ពលកម្ម (មធ្យម, រៀល) | គំលាតស្តង់ដារ |
|---|---|---|
| នេសាទ | 753,722 | 1,427,683 |
| កែច្នៃត្រី | 789,301 | 2,356,941 |
| តំបាញសូត្រ | 96,850 | 65,547 |
| តំបាញកប្បាស | 943,517 | 476,845 |
| ក្អមឆ្នាំង | 253,290 | 219,809 |
| ផលិតកម្មឥដ្ឋ | 4.94 លាន | 6.44 លាន |

តួលេខគំលាតស្តង់ដារ គឺធំបន្តិច ។ សំរាប់ ៣សកម្មភាព ក្នុងចំណោមសកម្មភាពទាំង ៦មុខ គំលាតស្តង់ដាវាធំជាងតំលៃមធ្យមភាគ ហើយក្នុង ៣សកម្មភាពផ្សេងទៀត វាមិនតូចជាងតួលេខមធ្យមភាគច្រើនទេ ។ គំលាតយ៉ាងធំរវាងតួលេខអនុបាតមូលធន-ពលកម្មនានា មានន័យថា មានការខុសគ្នាច្រើនណាស់នៅក្នុងបច្ចេកវិទ្យាដែលដាក់ប្រើប្រាស់ជាក់ស្តែង ។ គំលាតធំនេះអាចកើតចេញពីការវាយតំលៃទ្រព្យសកម្មរបស់អ្នកឆ្លើយសំភាសន៍ ប៉ុន្តែនៅក្នុងសកម្មភាពមួយចំនួន ដូចជាការនេសាទជាដើម បច្ចេកវិទ្យាដែលដាក់ប្រើប្រាស់មានច្រើនមុខច្រើនបែបណាស់ ។

[៣២] បំណុលជាមូលធន អាចបង្កើនមូលដ្ឋានមូលធនសរុបរបស់បណ្តុំសហគ្រាសជនបទ ។ នៅក៏រិតសហគ្រាសនិមួយៗ ការខ្ចីនៅទីផ្សារអាចបង្កើនកំលាំងសហគ្រាស ហើយតាមនេះនឹងបង្កើនផលរបរ ។ ប៉ុន្តែនាបច្ចុប្បន្នរឿងទាំងនេះមិនបានកើតមានទេ ។

សរុបមក ទិន្នន័យខាងលើបង្ហាញថា មានការប្រើប្រាស់ពលកម្មច្រើននៅក្នុងសកម្មភាពភាគច្រើន ហើយនេះអាំងឌីកាទ័រ បង្ហាញពីសក្តានុពលធំក្នុងការបង្កើតការងារដោយប្រើមូលធនតូច ។

## ៥.៤ ផលិតកម្ម និងផលិតភាព

### *៥.៤.១ ផលិតកម្ម និងតំលៃបន្ថែម*

ទិន្នន័យស្តីពីផលិតកម្មប្រចាំឆ្នាំបានពីសហគ្រាសទាំងនេះ (ផ្តិតាមទំហំ) មានចុះក្នុងតារាង៥.១១ ។ តំលៃបន្ថែមនៅក្នុងផ្នែកនេះ គណនាឡើងដោយយកតំលៃ ផលិតកម្ម ដកនឹង ធាតុចូលសំភារៈ ។ ខ្ទង់បញ្ឈរចុងក្រោយទាំងពីរ បង្ហាញទិន្នន័យអំពីតំលៃបន្ថែមមធ្យម និងអនុបាតនៃតំលៃបន្ថែមធៀបនឹងផលិតកម្ម (ជាភាគរយ) ។ ដោយសារទំហំខុស១គ្នានៃផលិតកម្មក្នុងមុខសកម្មភាពនីមួយ១, ចំណាត់ថ្នាក់ទំហំក្នុងតារាង៥.១១ ត្រូវបានរៀបចំឡើងតាមនោះ ។ ក្នុងប្រតិបត្តិការនេសាទ ទំហំផលិតកម្មមានតាំងពីតិចជាង ២លានរៀលក្នុងមួយឆ្នាំ (ប្រហែល ៥០០ដុល្លារ), រហូតដល់ធំជាង ៥០លានរៀល (ប្រហែល ១២.៥០០ដុល្លារ) ។ ការកែច្នៃត្រី មានលំនាំស្រដៀងគ្នា ប៉ុន្តែសហគ្រាសក្នុងក្រុមទំហំធំ១ មានចំនួនច្រើនជាង ។ ខាងតំបាញសូត្រ សហគ្រាសមានទំហំពី ១,៧លានរៀល ដល់ជាង ៥លានរៀល (មានគំលាតតូចជាង), ហើយខាងតំបាញអំបោះវិញ ទំហំមានពី តិចជាង ១៥លានរៀល ដល់ធំជាង ៤០លានរៀល ។ ក្នុងគំរូតាងនេះ ប្រតិបត្តិការតំបាញសូត្រ មានទំហំតូចជាងតំបាញអំបោះដោយសារកីត្បាញអំបោះប្រើម៉ាស៊ីន និងមានសមត្ថភាពផលិតធំជាង ។

សហគ្រាសនេសាទនីមួយ១មានតំលៃមធ្យមនៃផលិតកម្ម ១៩លានរៀល (៤.៨៩០ដុល្លារ) និងតំលៃបន្ថែម ១២,៧លាន រៀល ដូច្នេះ អនុបាតតំលៃបន្ថែមធៀបនឹងផលិតកម្មគឺ ៦៦% ។ តំលៃនេះហាក់តូចយោងតាមចរិតនៃសកម្មភាពនេះ ប៉ុន្តែមច្ឆា វប្បកម្មមានចំណែកសំខាន់នៅកម្ពុជា ។ មច្ឆាវប្បកម្មតំរូវឱ្យអាជីវករទិញពូជកូនត្រី ទិញចំណីត្រី និងត្រូវជួលជុលទ្រុងត្រីជា ប្រចាំ ហើយចំណាយទាំងការបូកបន្ថែមលើតំលៃដើមសំភារៈ ។ តំលៃមធ្យមនៃផលិតកម្មខាងកែច្នៃត្រី ធំខាងការនេសាទដល់ ទៅ ៤ដងខ្ពស់ជាង ប៉ុន្តែតំលៃបន្ថែមតូចជាងត្រឹម ៣១% ។ រឿងនេះដោយក្នុងសកម្មភាពកែច្នៃត្រី ត្រីទាំងអស់ត្រូវទិញចូលៈ មិនមែនគ្រប់១គ្នា "នេសាទ-កែច្នៃត្រី" ជាមួយគ្នាតែម្តងទេ ហើយទោះជាធ្វើដូច្នេះក្តី ក៏ត្រីនៅតែជាវត្ថុធាតុដើមសំរាប់ពួកគេ ។

តំលៃផលិតកម្មខាងតំបាញសូត្រ មានកំរិតតូចគួរសមទេត្រឹមប្រហែល ៣,៥លានរៀល (៨៧៥ដុល្លារ) ក្នុងមួយឆ្នាំ, ប៉ុន្តែតំបាញអំបោះមានកំរិតខ្ពស់ជាង (មធ្យមភាគផលិតកម្មប្រចាំឆ្នាំក្នុងមួយសហគ្រាស ខ្ពស់ជាងខាងតំបាញសូត្រ ១០ដង) ។ តំលៃបន្ថែមខាងតំបាញសូត្រគឺ ៥៤%នៃតំលៃផលិតកម្ម, ឯខាងតំបាញអំបោះគឺ ២៣% ។ ដូច្នេះគំលាតរវាងតំបាញទាំងពីរ បានរួមតូចមកវិញ បើគិតតាមកំរិតតំលៃបន្ថែម ។ ទាំងតំបាញសូត្រ និងតំបាញអំបោះ អាចផ្តល់តំលៃបន្ថែមសរុបច្រើនថែមទៀត ដល់កម្ពុជា បើសិនសកម្មភាពទាំងនេះមិនត្រូវពឹងផ្អែកលើសរសៃសូត្រឬអំបោះនាំចូលទេនោះ[៣៣] ។

ទំហំផលិតកម្មក្នុងសកម្មភាពទាំងបីដែលប្រើ ដី/ដីឥដ្ឋ (ក្អមឆ្នាំង, សិប្បកម្មចម្លាក់ថ្មម៉ាប, ផលិតឥដ្ឋ) មានចំណងទាក់ទងជាមួយនឹងទំហំចំណាយជាមូលធន ។ ផលិតកម្មក្អមឆ្នាំង ផ្តល់ អនុបាតតំលៃបន្ថែមធៀបផលិតកម្ម មានកំរិតខ្ពស់ ដោយសារវាប្រើធាតុចូល (ដី/ដីឥដ្ឋ) ថោកខ្លាំងណាស់ (ដីឥដ្ឋពេញមួយរទេះគោ ថ្លៃតែ ៥.០០០រៀល) ឬក៏ជីកយកបានដោយខ្លួនឯង ។ ក្នុងករណីផលិតកម្មឥដ្ឋ តំលៃបន្ថែមធៀបផលិតកម្ម គឺប្រហែល ៦៨% ។ ដី/ដីឥដ្ឋ មិនថ្លៃទេ តែចំណាយលើម៉ាស៊ូតវាខ្ពស់

---

[៣៣] នៅប្រទេសដទៃ កសិករចិញ្ចឹមដង្កូវនាងនៅលើដើមមន ឬដើម tussore ។ បន្ទាប់មកគេយកសូត្រនោះមកផលិតសរសៃសូត្រ ។ ក្នុងតំបាញអំបោះ ការថ្លេចកប្បាស រវៃអំបោះ និងត្បាញ ត្រូវធ្វើជាមួយគ្នា ។ ដំណើរការនេះ គេបង្កើតបានតំលៃបន្ថែមច្រើនក្នុងប្រទេស ។

គួរសមដែរ ដូច្នេះអនុបាតតំលៃបន្ថែមធៀបផលិតកម្ម មិនបានខ្ពស់ដូចផលិតកម្មក្អមឆ្នាំងទេ[៣៤] ។

**តារាង៥.១១ របាយសហគ្រាសតាមទំហំផលិតកម្ម, មធ្យមភាគផលិតកម្ម, និង មធ្យមភាគតំលៃបន្ថែម**

| សកម្មភាព | ចំនួនសហគ្រាស តាមថ្នាក់នៃទំហំ | មធ្យម (រៀល) | តំលៃបន្ថែម (រៀល) | តំលៃបន្ថែម/ផលិតកម្ម x ១០០ |
|---|---|---|---|---|
| នៃសាទ (N=60) | | 19,252,755 | 12,721,252 | 66.07 |
| < 2 លានរៀល | 8 | | | |
| 2-3 លានរៀល | 10 | | | |
| 3-4 លានរៀល | 8 | | | |
| 4-5 លានរៀល | 6 | | | |
| 5-7 លានរៀល | 5 | | | |
| 7-10 លានរៀល | 6 | | | |
| 10-15 លានរៀល | 5 | | | |
| 15-50 លានរៀល | 6 | | | |
| > 50 លានរៀល | 6 | | | |
| កែច្នៃត្រី (N=60) | | 86,006,841 | 26,868,651 | 31.24 |
| < 1 លានរៀល | 8 | | | |
| 1-2.5 លានរៀល | 9 | | | |
| 2.5-4.5 លានរៀល | 8 | | | |
| 4.5-10 លានរៀល | 7 | | | |
| 10-50 លានរៀល | 10 | | | |
| > 50 លានរៀល | 18 | | | |
| តំបាញសូត្រ (N=30) | | 3,501,652 | 1,898,329 | 54.21 |
| < 1.7 លានរៀល | 6 | | | |
| 1.7-2.5 លានរៀល | 6 | | | |
| 2.5-3 លានរៀល | 7 | | | |
| 3-5 លានរៀល | 5 | | | |
| > 5 លានរៀល | 6 | | | |
| តំបាញអំបោះ (N=30) | | 32,634,017 | 7,421,425 | 22.74 |
| < 15 លានរៀល | 8 | | | |
| 15-30 លានរៀល | 8 | | | |
| 30-40 លានរៀល | 7 | | | |
| > 40 លានរៀល | 7 | | | |
| ក្អមឆ្នាំង (N=38) | | 3,147,782 | 3,061,739 | 97.26 |
| ផលិតកម្មឥដ្ឋ (N=22) | | 270,355,714 | 183,409,316 | 67.84 |

### *៥.៤.២ អនុបាត ធាតុចេញ-ពលកម្ម, តំលៃបន្ថែម-ពលកម្ម, និង មូលធន-ធាតុចេញ*

អនុបាត ធាតុចេញ-ពលកម្ម ឬ តំលៃបន្ថែម-ពលកម្ម ជាអាំងឌីកាទ័រនៃផលិតភាពពលកម្ម ។ អនុបាតទាំងនេះ បង្ហាញពីសមត្ថភាពនៃប្រព័ន្ធផលិតកម្ម ក្នុងការផ្តល់ចំណូល សំរាប់កត្តាធាតុចូលដែលបានប្រើការ ។ អនុបាតផលិតភាពពលកម្មខ្ពស់ បង្ហាញពី កំលាំងរស់ខ្លាំងខាងសេដ្ឋកិច្ចនៃសហគ្រាស ដោយសហគ្រិននិងកម្មករ អាចរកកំរៃបានសមរម្យ និងផ្ទុយមកវិញ ។

[៣៤] ក្អមឆ្នាំង ក៏ប្រើឥន្ធនៈដើម្បីដុតដែរ តែបរិមាណកំដៅដែលត្រូវការទាប ។ គេមានប្រើឡសហគមន៍ដែលមានលក្ខណៈសន្សំសំចៃខ្ពស់ ។

អនុបាតមូលធន-ធាតុចេញ កំណត់ពីតំរូវការធនធានជាប់លាប់ ដើម្បីបង្កើតផលិតកម្មមួយឯកតា ។ អនុបាតទាំងបីនេះ ព្រមទាំង អនុបាតមូលធន-ពលកម្មដែលបង្ហាញនៅក្នុងតារាង៥.១០ មានសារៈសំខាន់ណាស់សំរាប់ ការធ្វើផែនការវិនិយោគ ការជ្រើស រើសបច្ចេកវិទ្យា និងការបង្កើតការងារ ។

តារាង៥.១២ បានបង្ហាញអនុបាតទាំងនេះ សំរាប់ ៦សកម្មភាព ក្នុងចំណោមសកម្មភាពទាំង៧ ដែលកំពុងសិក្សា ។ អនុបាតពីរខាងដើម គិតជារៀលក្នុងពលករម្នាក់, ចំណែកឯអនុបាតទី៣ គឺជាតួលេខសុទ្ធ ។

**តារាង៥.១២ អនុបាត ធាតុចេញ-ពលកម្ម, តំលៃបន្ថែម-ពលកម្ម, និង មូលធន-ធាតុចេញ**

| សកម្មភាព | អនុបាត ធាតុចេញ/ពលកម្ម | អនុបាត តំលៃបន្ថែម/ពលកម្ម | អនុបាត មូលធន/ធាតុចេញ |
|---|---|---|---|
| នេសាទ | 3,712,397 | 2,361,044 | 0.22 |
| កែច្នៃត្រី | 25,827,014 | 10,154,218 | 0.19 |
| តំបាញសូត្រ | 2,474,698 | 1,261,600 | 0.05 |
| តំបាញអំបោះ | 8,018,212 | 1,795,832 | 0.12 |
| ក្អមឆ្នាំង | 2,819,086 | 2,744,000 | 0.08 |
| ផលិតកម្មឥដ្ឋ | 8,601,311 | 7,629,644 | 0.47 |

លំនាំនៅក្នុងផលិតភាពពលកម្ម ដូចពិនិត្យឃើញក្នុងតារាងខាងលើ មានលក្ខណៈចំលែកបន្តិចៈ ការកែច្នៃត្រី បង្ហាញនូវ តួលេខផលិតភាពខ្ពស់បំផុត, បន្ទាប់មកគឺ ផលិតកម្មឥដ្ឋ, តំបាញអំបោះកប្បាស និងការនេសាទ, ហើយចុងក្រោយគឺ ក្អមឆ្នាំង និង តំបាញសូត្រ ។ ទំហំផលិតកម្ម ការប្រើបច្ចេកវិទ្យា និង ផលិតភាពពលកម្ម ពុំបានដើរតាមលំដាប់ដូចគ្នាទាំងអស់ទេ ។ តំលៃ បន្ថែមក្នុងកម្មករម្នាក់ មានកំរិតខ្ពស់បំផុតនៅក្នុងផ្នែកកែច្នៃត្រី (២.៥៧១ដុល្លារ), និងមានកំរិតទាបបំផុតក្នុងផ្នែកតំបាញសូត្រ (៣២០ដុល្លារ), គឺវាធំតូចជាងគ្នា ១:៨ (ធំតូចជាងគ្នា ៨ដង) ។ សកម្មភាពប្រើមូលធនច្រើន ដូចជា ផលិតកម្មឥដ្ឋ មានអនុបាត តំលៃបន្ថែមក្នុងកម្មករម្នាក់ ទាបការកែច្នៃត្រី ។ តំបាញសូត្រផ្តល់តំលៃបន្ថែមក្នុងមនុស្សម្នាក់ មិនលើសពីកំរិតជីវព្រឹត្តប៉ុន្មានទេ គឺបើគណនាលើមូលដ្ឋានប្រចាំថ្ងៃ វាមានកំរិតប្រហែល ១ដុល្លារ/ថ្ងៃ ។ ទិន្នន័យទាំងនេះបង្ហាញថា ទំហំប្រតិបត្តិការ ឬកំរិតជឿន លឿននៃបច្ចេកវិទ្យា មិនមែនសុទ្ធតែផ្តល់ជោគជ័យបានទេ ហើយតំរូវការផលិតផល (គឺថ្លៃផលិតផល) មានតួនាទីយ៉ាងសំខាន់ ។

អនុបាតមូលធន/ធាតុចេញដែលមានតំលៃតិចជាងមួយ បញ្ជាក់ថា មូលធនវិលបានច្រើនជាងមួយដងក្នុងមួយឆ្នាំ គឺបាន ន័យថា មូលធនមួយឯកតាៗមានសមត្ថភាពបង្កើតធាតុចេញ បានច្រើនជាងតំលៃចារិករបស់វា ក្នុងមួយឆ្នាំៗ ។ ក្នុងឧស្សាហកម្ម ទំនើបធំៗបំផុត មូលធនវិលបានតែមួយដងទេក្នុងរយៈពី ៣-៥ឆ្នាំ (អនុបាតមូលធន/ធាតុចេញ គឺ ៣-៥) ។ អនុបាតមូលធន /ធាតុចេញ ក្នុងគំរូតាងនេះ មានតួលេខខ្ពស់បំផុតដល់ ០,៤៧ក្នុងផលិតកម្មឥដ្ឋ, និងតួលេខទាបបំផុតមិនដល់ ០,១០ ទេ ក្នុង តំបាញសូត្រ និងក្អមឆ្នាំង (តារាង៥.១២) ។ ក្នុងសកម្មភាពជនបទទាំងនេះមួយចំនួន មូលធនវិលបានច្រើនដងក្នុងមួយឆ្នាំ ដូច្នេះ ប្រសិទ្ធភាពប្រើមូលធនក្នុងសកម្មភាពបែបនេះ គឺខ្ពស់ច្រើនដងជាងឧស្សាហកម្មទំនើបធំៗ ។ ការណ៍នេះបញ្ជាក់ថា សកម្មភាព ទាំងនេះអាចរស់បានដោយសារធាតុចូលពលកម្មជាសំខាន់ ហើយមានសហគ្រាសជាច្រើនខ្វះខាតទុន ។

សង្ខេបមក សកម្មភាពទាំងអស់ផលិតបានតំលៃបន្ថែមច្រើនណាស់ បើធៀបនឹងចំណាយមូលធន និងផលិតកម្មរបស់វា ។ ដូច្នេះជាលក្ខណៈហិរញ្ញវត្ថុ សកម្មភាពទាំងនេះមានប្រសិទ្ធភាពខ្ពស់ ។ នៅក្នុងទីផ្សារ ការអាចរស់ជីវិតបានទាមទារលើសពី ប្រសិទ្ធភាពហិរញ្ញវត្ថុនេះទៀត ។ ទំហំប្រតិបត្តិការវាសំខាន់បំផុតដើម្បីធានាឱ្យមានចំណូលអប្បបរមាកំរិតណាមួយ, បច្ចេកវិទ្យា សំខាន់ខ្លាំងណាស់ចំពោះផលិតភាពពលកម្ម, ហើយតំរូវការវាសំខាន់បំផុតដែរក្នុងការរក្សាឱ្យធាតុចេញមានថ្លៃលក់ខ្ពស់សមរម្យ ។

## ៥.៥ ប្រាក់ចំណេញ និង ភាពមានចំណេញ

ប្រាក់ចំណេញ ដែលជាចំណូលអាចប្រើបានរបស់សហគ្រិន គឺជាកត្តាកំណត់ងាប់រស់របស់សហគ្រាស ។ ប្រាក់ចំណេញគណនាឡើង ដោយយក ផលិតកម្ម (ចំណូលលក់បាន) ដកនឹង ចំណាយត្រូវទូទាត់ និងរំលស់[៣៥] ។ អនុបាតប្រាក់ចំណេញផ្សេងៗដែលបានគណនាក្នុងពេលនេះ គឺមានប្រាក់ចំណេញក្នុងមួយឯកតាផលិតកម្ម, ប្រាក់ចំណេញក្នុងមួយឯកតាតំលៃបន្ថែម, ប្រាក់ចំណេញក្នុងមួយឯកតាចំណាយមូលធន, និងប្រាក់ចំណេញក្នុងកម្មករមិនស៊ីឈ្នួលម្នាក់ (គឺប្រាក់ចំណេញក្នុងពលករម្ចាស់អាជីវកម្មម្នាក់) ។ តារាង៥.១៣ មានអនុបាតទាំងនេះ សំរាប់ ៦សកម្មភាព ក្នុងចំណោម ៧សកម្មភាពដែលបានសិក្សា ។

តារាង៥.១៣ បង្ហាញថា ជាមធ្យមសហគ្រាសនេសាទមួយរកបានចំណូលដុលប្រចាំឆ្នាំ ១១.៣៥១.៤៧១រៀល (២.៨៣៩ដុល្លារ) សំរាប់យកមកចែកចាយគ្នារវាងសមាជិកគ្រួសាររបស់ម្ចាស់សហគ្រាស ។ អនុបាតប្រាក់ចំណេញធៀបសមាជិកគ្រួសារដែលធ្វើការ (ឬចំណូលក្នុងពលករម្ចាស់អាជីវកម្មម្នាក់) ត្រូវបានគណនានៅក្នុងខ្ទង់បញ្ឈរចុងក្រោយ ។ សំរាប់ប្រតិបត្តិការនេសាទ ប្រាក់ចំណេញនេះមានប្រហែល ១.៧៦៧ដុល្លារ/ឆ្នាំ ឬ ៤-៥ដុល្លារ ក្នុងសមាជិកជាម្ចាស់សហគ្រាសម្នាក់ក្នុងមួយថ្ងៃ ។ តាមពិតតួលេខអាចតិចជាងនេះទៀត នៅពេលគេកាត់កងចំណាយផ្សេងៗពីប្រាក់ចំណេញដុល ដើម្បីគណនាប្រាក់ចំណេញសុទ្ធ ។ តួលេខនេះក៏ជាមធ្យមភាគលើបណ្តាសហគ្រាសដែលខុសប្លែកគ្នាជាខ្លាំងៈ សហគ្រាសតូចៗអាចបានចំណេញទាបជាងនេះច្រើន គឺមិនលើសពីកំរិតជីវព្រឹត្តប៉ុន្មានទេ ។ សហគ្រាសកែច្នៃត្រីមួយ អាចរកបានចំណេញដុលប្រចាំឆ្នាំ ២៦.៥៦០.៤០៥ រៀល (ប្រហែល ៦.៦៤០ដុល្លារ) ។ ចំណេញដុលក្នុងពលករម្ចាស់អាជីវកម្មម្នាក់ (គិតជាដុល្លារអាមេរិក) គឺប្រហែល ៣.២៤៦ ដុល្លារ/ឆ្នាំ ឬប្រហែល ៩ដុល្លារ/ថ្ងៃ ។ សំរាប់សហគ្រាសតំបាញសូត្រ ប្រាក់ចំណេញដុល គឺ ១.៨៨៥.២៧៣រៀល (ប្រហែល ៤៧៥ដុល្លារ) ក្នុងនេះ ពលករជាម្ចាស់ម្នាក់ទទួលបាន ៣១៥ដុល្លារ/ឆ្នាំ ឬទាបបន្តិចជាងកំរិត ១ដុល្លារ/ថ្ងៃ ។ សំរាប់សហគ្រាសតំបាញអំបោះ ប្រាក់ចំណេញដុលក្នុងសហគ្រាសមួយគឺ ៦.៣០៩.៤២៥រៀល/ឆ្នាំ (ប្រហែល ១.៥៨០ដុល្លារ) ដែលគណនាឃើញប្រហែល ៣.៤០០រៀលក្នុងពលករជាម្ចាស់ម្នាក់ក្នុងមួយថ្ងៃ ។ ពលករជាម្ចាស់ និងពលករស៊ីឈ្នួល រកបានប្រហាក់ប្រហែលគ្នានៅក្នុងប្រតិបត្តិការតំបាញទាំងពីមុខនេះ ។ សំរាប់ក្អមឆ្នាំង ចំណេញដុលប្រចាំឆ្នាំគឺ ៣.០០៥.៧៤៨រៀល (ប្រហែល ៧៥១ដុល្លារ) និងសំរាប់ផលិតកម្មឥដ្ឋ ចំណេញដុលប្រចាំឆ្នាំគឺ ៤៤.០០០.០០០រៀល (ប្រហែល ១១.០០០ដុល្លារ) ។ តួលេខលំអិតបែបនេះ មិនអាចគណនាបានទេសំរាប់សកម្មភាពផ្សេងទៀត ។

**តារាង៥.១៣ អនុបាតភាពមានចំណេញ (គិតជារៀល)**

| សកម្មភាព | ចំណេញក្នុងសហគ្រាសមួយ | ចំណេញ/ធាតុចូល x ១០០ | ចំណេញ/តំលៃបន្ថែម x ១០០ | ចំណេញ/មូលធន | ចំណេញ/ពលករជាម្ចាស់ |
|---|---|---|---|---|---|
| នេសាទ | 11,351,471 | 48.18 | 87.83 | 7.33 | 7,068,367 |
| កែច្នៃត្រី | 26,560,405 | 34.54 | 88.38 | 17.88 | 12,985,366 |
| តំបាញសូត្រ | 1,885,273 | 52.23 | 98.85 | 14.44 | 1,251,915 |
| តំបាញអំបោះ | 6,309,425 | 19.05 | 82.87 | 2.72 | 1,208,319 |
| ក្អមឆ្នាំង | 3,005,748 | 94.00 | 98.17 | 10.60 | - |
| ផលិតកម្មឥដ្ឋ | 44,000,000 | 16.27 | 23.27 | 0.35 | - |

[៣៥] ក្នុងការសិក្សានេះ រំលស់ត្រូវបានគណនាយ៉ាងសាមញ្ញ គឺ ១០% នៃតំលៃទ្រព្យសកម្មជាប់លាប់ សំរាប់ធ្វើការកាត់កងជារៀងរាល់ឆ្នាំ ។

ចំណូលក្នុងពលករជាម្ចាស់ម្នាក់ បានខ្ពស់ជាងកំរិតជីវភាពក្នុងគ្រប់សកម្មភាពទាំងអស់លើកលែងតែខាងតំបាញចេញ ។ ប៉ុន្តែដូចបានបង្ហាញរួចហើយ ប្រាក់កំរៃពលករស៊ីឈ្នួលស្ថិតនៅកំរិតជីវភាពនៅគ្រប់ទីកន្លែងទាំងអស់ ។ ហេតុផលមួយអាចថា លក្ខខណ្ឌទីផ្សារពលកម្មវាជាកត្តាកំណត់ប្រាក់កំរៃរបស់ពលករ សំខាន់ជាងសមត្ថភាពក្នុងការបង់ប្រាក់កំរៃនេះ ។ ពលករស៊ីឈ្នួលនៅតាមសហគ្រាសមិនមែនកសិកម្មនៅជនបទ មានជំនាញទាប និងជារឿយៗមិនចេះអក្សរទេ ហើយលក្ខខណ្ឌទីផ្សារពលកម្មជាទូទៅវាទន់ខ្សោយ (គឺ ការផ្គត់ផ្គង់ធំជាងតំរូវការ) ។ កត្តាទាំងនេះញ៉ាំងឱ្យប្រាក់កំរៃមានកំរិតទាប ។

ប្រាក់ចំណេញក្នុងមួយឯកតាផលិតកម្ម (ចំណេញ/ធាតុចូល x ១០០) និង ប្រាក់ចំណេញក្នុងមួយឯកតាតំលៃបន្ថែម (ចំណេញ/តំលៃបន្ថែម x ១០០) មានគណនាក្នុង តារាង៥.១៣ ។ អត្រាចំណេញក្នុងគ្រប់សកម្មភាពមានកំរិតខ្ពស់ ។ វាខ្ពស់អស្ចារ្យក្នុង ៤សកម្មភាព (ក្នុងចំណោម ៦សកម្មភាព) និងខ្ពស់បង្គួរក្នុងផ្នែកតំបាញអំបោះ និងផលិតកម្មឥដ្ឋ ។ ប្រាក់ចំណេញក្នុងមួយឯកតានៃមូលធនវិនិយោគ មានកំរិតខ្ពស់ខ្លាំងណាស់ក្នុងគ្រប់សកម្មភាព លើកលែងតែផលិតកម្មឥដ្ឋមួយចេញ ហើយមូលធនវិនិយោគលើទ្រព្យសកម្មជាប់លាប់ទាំងអស់ អាចប្រមូលចូលវិញបានច្រើនដងក្នុងរយៈពេលតិចជាងមួយឆ្នាំ ។ ក្នុងផ្នែកតំបាញសូត្រ និងការកែច្នៃត្រី មូលធនជាប់លាប់អាចប្រមូលមកវិញបានក្នុងរយៈពេលតិចជាងមួយខែ[៣៦] ។

## ៥.៦ ភាពមានចំណេញ និងទំហំ

មកទល់ពេលនេះ ទិន្នន័យបង្ហាញថា ប្រសិទ្ធភាពផ្ទៃនៃសហគ្រាសតូចៗ និងសហគ្រាសមីក្រូ មានកំរិតខ្ពស់ ប៉ុន្តែប្រាក់កំរៃរបស់ពលករមិនបានខ្ពស់ទេ ។ ប្រតិបត្តិការខ្នាតតូច និងបច្ចេកវិទ្យាចាស់គំរិល ក៏មានចំណែកធ្វើឱ្យប្រាក់កំរៃបានតិចដែរ ។ ក្នុងអនុផ្នែកនេះ មានធ្វើការវាតតំលៃពីទំនាក់ទំនងរវាង ចំណូល និងបច្ចេកវិទ្យា ជាមួយនឹង ទំហំនៃប្រតិបត្តិការ ។

សមីកា regression ត្រូវបានប៉ាន់ស្មានដើម្បីផ្ទៀងផ្ទាត់ទំនាក់ទំនងដូចបានពណ៌នាខាងលើ ។ យោងតាមចរិតសាមញ្ញនៃទិន្នន័យ បច្ចេកវិទ្យាត្រូវបានវាស់វែងតាម អនុបាតមូលធន/ធាតុចេញ (capital/output ration), ហើយ ចំណូលត្រូវបានវាស់វែងតាម អនុបាតតំលៃបន្ថែម/ពលកម្ម (value added to labour ratio) ។ ទំហំប្រតិបត្តិការ ត្រូវបានវាស់វែងតាមទំហំធាតុចេញ ។ សមីកាដែលប៉ាន់ស្មាន (using logarithmic transformation) សំរាប់ ៤ សកម្មភាព មានដូចខាងក្រោម :

*ការនេសាទ*

$$\text{Ln (Value added/labour)} = 0.11 - \underset{(1.10)}{0.15}\ \text{Ln (Capital/output)} + \underset{(7.66)}{0.77}\ \text{Ln (Output)}$$

$R2=0.54$; $F = 31.80$

*ការកែច្នៃត្រី*

$$\text{Ln (Value added/labour)} = 1.23 - \underset{(0.37)}{4\text{x}10^{-2}}\ \text{Ln (Capital/output)} + \underset{(6.64)}{0.71}\ \text{Ln (Output)}$$

$R2=0.62$; $F = 42.41$

*តម្បាញសូត្រ*

$$\text{Ln (Value added/labour)}=1.91\text{x}10^{-2} - 2.24\text{x}10^{-2}\ \text{Ln (Capital/output)} + 0.83\ \text{Ln (Output)}$$

---

[៣៦] អត្រាទាញចំណូលខ្ពស់បែបនេះ មានលក្ខណៈធម្មតាទេក្នុងសហគ្រាសតូចៗ (សហគ្រាសមីក្រូ) នៅប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី ។ សូមអាន ADB (1998) ។ អត្រានេះមិនខ្ពស់ទេនៅក្នុងផលិតកម្មឥដ្ឋ ដោយសារផលិតកម្មឥដ្ឋ មិនមែនជាសហគ្រាសមីក្រូ ។

(0.68) (6.19)

$R^2$=0.62; F = 20.91

*តម្បាញកប្បាស*

Ln (Value added/labour) = 2.49 - 0.26 Ln (Capital/output) + 0.57 Ln (Output)

(1.44) (4.01)

$R^2$=0.40; F = 8.05

(Figures in brackets are the respective ‘t’ values; ‘Ln’ refers to natural logarithm)

នៅក្នុងសមីកាទាំង៤ មេគុណ Ln (Output) គឺវិជ្ជមាន ហើយមានតួលេខធំគួរសម (statistically significant at 0.01 percent confidence)[៣៧] ។ ប៉ុន្តែ មេគុណ Ln (Capital/output) មានតួលេខស្ថិតិមិនសំខាន់ទេ (ប្រហែលអថេរនេះមិនអាចតំណាងបានល្អគ្រប់គ្រាន់ទេនូវ បច្ចេកវិទ្យា)[៣៨] ។ ជាទូទៅ សមីការនានាបញ្ជាក់ថា ទំហំចំណូលក្នុងពលករម្នាក់ វាជាប់ទាក់ទងខ្លាំងណាស់នឹង ទំហំប្រតិបត្តិការ ។

## ៥.៧ សង្ខេប

ការវិភាគក្នុងជំពូកនេះបង្ហាញថា សកម្មភាពនៅជនបទមានការខុសប្លែកគ្នាជាខ្លាំងៈ មានការប្រែប្រួលខុសគ្នាច្រើនណាស់ រវាងមុខសកម្មភាពនានា និងក្នុងមុខសកម្មភាពនិមួយៗរវាងសហគ្រាសនានា ក្នុងការប្រើពលកម្ម ចំណាយជាមូលធន តំលៃបន្ថែម និង ភាពមានចំណេញ ។ ប៉ុន្តែ សឹងតែទាំងអស់ ប្រើពលកម្មច្រើន និងខ្វះខាតមូលធន ។ សឹងតែទាំងអស់ មានវដ្តបង្វិលទុនរយៈពេលខ្លី គឺក្នុងករណីខ្លះត្រឹមតែមួយខែប៉ុណ្ណោះ ។ ប្រភពមូលធនមួយភាគធំគឺជា ធនធានផ្ទាល់ខ្លួន ។ អ្នកផ្គត់ផ្គង់សំភារៈ គឺជាម្ចាស់ហាងក្នុងស្រុក ឬមួយអន្តរការី ហើយកត្តាចំបងក្នុងការជ្រើសរើសគ្រឿងម៉ាស៊ីន គឺភាពងាយស្រួលក្នុងការជួសជុលវា ។ លើកលែងតែក្នុងផលិតកម្មឥដ្ឋចេញ ពលករស៊ីឈ្នួលមានចំនួនតិចទេ បើធៀបនឹងពលករដែលបំរើការងារនៅក្នុងអាជីវកម្មរបស់ខ្លួនឯងផ្ទាល់ ។ ប្រាក់កំរៃបង់ទៅឱ្យពលករ តែងស្ថិតនៅត្រឹមកំរិតជីវព្រឹត្តជានិច្ច ទោះបីប្រាក់ចំណេញក្នុងមុខសកម្មភាពជាច្រើន (និងសហគ្រាសនានា) វាបានខ្ពស់ជាងកំរិតជីវព្រឹត្តក៏ដោយ ។ រឿងនេះគឺដោយសារទីផ្សារពលកម្មមានលក្ខណៈទន់ខ្សោយ ។ ទោះបីប្រតិបត្តិការមួយចំនួនមានប្រសិទ្ធភាពបច្ចេកទេសខ្ពស់ក៏ដោយ ក៏ចំណូលសុទ្ធនៅតែបានតិច ដោយសារ ប្រតិបត្តិការមានទំហំតូចពេក ធាតុចេញបានថ្លៃទាប និងបច្ចេកវិទ្យាចាស់គំរិល[៣៩] ។

---

[៣៧] ទំនាក់ទំនងវិជ្ជមាននេះ មិនផ្ទុយគ្នាទេនឹងគំហើញនៅក្នុងតារាង៥.១១ ។ សមីការទាំងនេះវាស់វែង ទំនាក់ទំនងក្នុងមុខសកម្មភាពនិមួយៗ រវាងសហគ្រាសនានា, ចំណែកឯទិន្នន័យក្នុងតារាង៥.១១ បង្ហាញនូវបំរែបំរួលរវាងមុខសកម្មភាពនានា ។

[៣៨] ការកំនត់មួយបែបទៀតដែលប្រើអនុបាតមូលធន/ពលកម្ម ដើម្បីតំនាងឱ្យបច្ចេកវិទ្យា ក៏មិនផ្តល់លទ្ធផលខុសគ្នាច្រើនគួរកត់សំគាល់ដែរ ។

[៣៩] ប្រសិទ្ធិភាពបច្ចេកទេស សំដៅដល់ប្រសិទ្ធភាពក្នុងការប្រើប្រាស់មធ្យោបាយផលិតកម្មដែលមានស្រាប់ ។ ចំណុចនេះ វាខុសគ្នាពីគុណភាពបច្ចេកវិទ្យា ដែលមានលក្ខណៈចាស់គំរិលខ្លាំងណាស់ក្នុងករណីភាគច្រើន ។

# ជំពូកទី ៦

# ម៉ាឃីទិង និងខ្សែរយៈទីផ្សារ

ម៉ាឃីទិង ជាដំណាក់កាលមួយយ៉ាងសំខាន់ក្នុងគ្រប់អាជីវកម្ម ប៉ុន្តែវាប្រហែលមានតួនាទីជាគន្លឹះតែម្តងនៅក្នុងអាជីវកម្មជនបទតូចៗនៅកម្ពុជា ពីព្រោះមានតំបន់ជនបទតិចតួចណាស់ដែលបានធ្វើសមាហរណកម្មយ៉ាងល្អទៅក្នុងទីផ្សារធំៗ ។ កង្វះការធ្វើសមាហរណកម្មទៅក្នុងទីផ្សារ បានប៉ះពាល់ទាំងការចែកចាយធាតុចេញ និងការផ្គត់ផ្គង់ធាតុចូល ។ ជារឿយៗ ស្ថានភាពផ្តាច់មុខក្នុងស្រុកបានផុសឡើង ហើយដោយមូលហេតុនេះ ផលិតករអាចមិនបានទទួលចំណូលគ្រប់គ្រាន់អំពីផលិតផលរបស់ខ្លួន ។ ផ្ទុយទៅវិញ អ្នកត្រួតត្រាទីផ្សារទទួលបានផលចំណេញយ៉ាងច្រើន ។ ជំពូកនេះ បង្ហាញនូវការវិភាគពីរផ្សេងគ្នាគឺ ការវិភាគទី១ ស្តីពីទិដ្ឋភាពផ្សេងៗនៃការធ្វើម៉ាឃីទិងផលិតផល ផ្អែកតាមពត៌មានប្រមូលបានតាមបញ្ជីសំនួរ និង ការវិភាគទី២ ស្តីពីរចនាសម្ព័ន្ធទីផ្សារ និងទំនាក់ទំនងរបស់វាទៅដល់ដំណើរការផលិតកម្ម ដូចមានបង្ហាញក្នុងការសិក្សានានាដែលបានធ្វើឡើងដោយប្រើវិធីសាស្ត្រគុណភាព ។

## ៦.១ ទីផ្សារ និង ការកំណត់ថ្លៃ

តារាង៦.១ បង្ហាញទិន្នន័យស្តីពី វិធីដែលមុខសកម្មភាពផ្សេងៗលក់ផលិតផលរបស់ខ្លួនទៅទីផ្សារ ។ ប្រភេទអ្នកទិញផ្សេងៗ មានដូចគ្នានឹងអ្វីដែលបានពិពណ៌នានៅក្នុង ជំពូកទី៥ ។

**តារាង៦.១ វិធីលក់ផលិតផលទៅទីផ្សារ**

| សកម្មភាព | លក់ឱ្យអ្នកទិញក្នុងស្រុក | លក់ឱ្យអន្តរការី/ពាណិជ្ជករ | លក់ឱ្យទីផ្សារនៅភ្នំពេញ | លក់ឱ្យអ្នកផ្សេង | សរុប |
|---|---|---|---|---|---|
| នេសាទ | 16 | 39 | - | 5 | 60 |
| កែច្នៃត្រី | 6 | 45 | - | 1 | 60 |
| តំបាញសូត្រ | 4 | 25 | - | 1 | 30 |
| តំបាញកប្បាស | - | 5 | 25 | - | 30 |

តារាងនេះបង្ហាញថា នៅក្នុងសកម្មភាពទាំង ៤មុខ ដែលមានទិន្នន័យ អ្នកទិញដែលមានចំនួនភាគរយសរុបធំជាងគេ គឺអន្តរការី និងពាណិជ្ជករ បន្ទាប់មកគឺ អ្នកទិញក្នុងស្រុក (ហាងក្នុងស្រុក) ។ មានតែផលិតផលតំបាញអំបោះ (ក្រម៉ា) មួយករណីគត់ ដែលគេលក់ដោយផ្ទាល់ទៅទីផ្សារនានានៅភ្នំពេញ ។ អន្តរការីធ្វើប្រតិបត្តិការនៅត្រង់ចន្លោះរវាងទីផ្សារធំៗ និងផលិតករ ។ អន្តរការីអាចនៅក្នុង ឬមិននៅក្នុងមូលដ្ឋាន និងអាចមានការរកស៊ីផ្តាច់មុខនៅក្នុងតំបន់ ។ ទិដ្ឋភាពនេះមានពិភាក្សានៅក្នុងអនុផ្នែកបន្ទាប់ ។

តារាង៦.២ បង្ហាញទិន្នន័យពីចំណាប់អារម្មណ៍របស់ផលិតករ អំពី អ្នកណាត្រួតត្រាលើថ្លៃធាតុចេញ ។

**តារាង៦.២ ចំណាប់អារម្មណ៍អំពី អ្នកណាត្រួតត្រាលើថ្លៃធាតុចេញ**

| សកម្មភាព | អ្នកទិញក្នុងស្រុក | អន្តរការី/ពាណិជ្ជករ | ទីផ្សារនៅភ្នំពេញ | ផ្សេងទៀត |
|---|---|---|---|---|
| នេសាទ | 7 | 47 | 1 | 5 |
| កែច្នៃត្រី | 15 | - | 5 | 40 |
| តំបាញសូត្រ | 4 | 25 | - | 1 |
| តំបាញអំបោះ | 16 | - | 14 | |

ចំណាប់អារម្មណ៍របស់ផលិតករស្តីពីអ្នកណាត្រួតត្រាលើថ្លៃធាតុចេញ មានលក្ខណៈចំរុះគ្នា. ភាគច្រើនវាទាក់ទិននឹងទីផ្សារដែលផលិតករម្នាក់ៗបានជួប ។ ខាងផ្នែកនេសាទ ក្នុងចំណោមផលិតករ ៦០នាក់ មាន ៤៧នាក់យល់ថា អន្តរការីជាអ្នកត្រួតត្រាលើថ្លៃ ។ រឿងនេះអាចមានការពិតខ្លះមែន ពីព្រោះទីផ្សារត្រីដែលធ្វើការទិញលក់ផលិតផលស្រស់ជាសំខាន់ វាមានទំហំធំ និងត្រួតត្រាដោយមនុស្សមកពីក្រៅតំបន់មូលដ្ឋាន ។ គេដឹងជាទូទៅថា ទីផ្សារភ្នំពេញ និងនៅឯនាយព្រំដែន (នៅថៃ) ជាអ្នកកំណត់ថ្លៃផលិតផលសំរេច ។ ក្នុងករណីនៃការកែច្នៃត្រី អន្តរការី និងពាណិជ្ជករ ហាក់ដូចមិនសំខាន់ទេ ។ ទី១ ផលិតផលមិនចាំបាច់ប្រញាប់លក់ជាបន្ទាន់ទេ ។ ទី២ ត្រីកែច្នៃភាគច្រើនបំរើការប្រើប្រាស់ក្នុងស្រុក ហើយមានតែមួយភាគតូចប៉ុណ្ណោះដែលនាំចេញទៅវៀតណាម តាមរយៈពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ។ ខ្ទង់ "ផ្សេងទៀត" ក្នុងតារាងនេះ សំដៅដល់ភ្នាក់ងារនានាដែលមិនបានលើកមកពិភាក្សាក្នុងអត្ថបទនេះ គឺបានន័យថា ត្រីកែច្នៃ មានលក់ចេញតាមច្រកជាច្រើនទៀតក្រៅពី ជំរើសទាំងបីដែលបានបង្ហាញខាងលើនេះ ។

អន្តរការីដែលផ្គត់ផ្គង់សរសៃសូត្រ និងប្រមូលផលិតផលសំរេចដើម្បីលក់ទៅទីផ្សារភ្នំពេញ គ្រប់គ្រងទីផ្សារផលិតផលសូត្រ ។ ផលិតផលអំបោះ (ក្រមា) ត្រូវបានលក់ចេញនៅក្នុងស្រុក និងនៅភ្នំពេញ ។ ដូច្នេះហើយ ចម្លើយពីរឿងអ្នកណាត្រួតត្រាថ្លៃផលិតផល វាឆ្លុះបញ្ចាំងម្តងទៀតពីស្ថានភាពទីផ្សារបច្ចុប្បន្ន ។

**តារាង៦.៣ តើអ្នកផ្គត់ផ្គង់ធាតុចូល ជាអ្នកទិញធាតុចេញដែរឬយ៉ាងណា និង តើការបង់តំលៃធាតុចេញ ត្រូវបានកាត់កងជាមួយការផ្គត់ផង់ធាតុចូលឬយ៉ាងណា**

| សកម្មភាព | អ្នកផ្គត់ផ្គង់ធាតុចូល ជាអ្នកទិញធាតុចេញ | អ្នកផ្គត់ផ្គង់ធាតុចូល មិនមែនជាអ្នកទិញធាតុចេញ | តំលៃធាតុចូល កាត់កងជាមួយការបង់ថ្លៃធាតុចេញ | តំលៃធាតុចូល មិនកាត់កងជាមួយការបង់ថ្លៃធាតុចេញ |
|---|---|---|---|---|
| នេសាទ | 7 | 53 | 6 | 54 |
| កែច្នៃត្រី | 8 | 52 | 8 | 52 |
| តំបាញសូត្រ | 22 | 8 | 11 | 19 |
| តំបាញអំបោះ | 6 | 24 | 16 | 14 |

ការស្រាវជ្រាវនេះ បានខិតខំកំណត់ដែរថា តើអ្នកផ្គត់ផ្គង់ធាតុចូល គេត្រួតត្រាទីផ្សារធាតុចេញដែរឬយ៉ាងណា ។ តារាង ៦.៣ បង្ហាញថា នៅក្នុងសកម្មភាពនេសាទ និងកែច្នៃត្រី មានសហគ្រិនប្រហែលតែ ១៥% ប៉ុណ្ណោះដែលរកឃើញថា ទីផ្សារធាតុចេញ និងទីផ្សារធាតុចូល គឺត្រួតត្រាដោយពាណិជ្ជករជាបុគ្គលតែមួយ។ រឿងនេះមិនពិបាកពន្យល់ទេ ពីព្រោះធាតុចូលសំរាប់ការនេសាទ (ក្រៅពីម៉ាស៊ូត សំណាញ់ និងអាចអំបិលផងដែរសំរាប់ការកែច្នៃ) សុទ្ធតែផលិតនៅក្នុងស្រុក ។ សហគ្រិនមួយចំនួនតូចដែលផ្គត់ផ្គង់ផលិតផលឱ្យអ្នកផ្គត់ផ្គង់ធាតុចូល ប្រហែលជាអ្នកដែលខ្ចីប្រាក់គេ ហើយសងវិញជាវត្ថុ ។ ករណីតំបាញសូត្រ អ្នកផ្គត់ផ្គង់សរសៃសូត្រ ក៏ជាអ្នកទិញក្រណាត់សូត្រដែរ ។ សកម្មភាពនេះ គឺហាក់ដូចជាផលិតកម្មជាប់ឃុំខ្លួនដូច្នោះ ពីព្រោះផលិតករសឹងធ្លាក់ខ្លួនជាពលករស៊ីឈ្នួលរបស់អ្នកទិញ (និងអ្នកលក់) ទៅហើយ ។ ក្នុងករណី *ក្រមាអំបោះត្បាញ* ផលិតកររកបានទីផ្សារនៅភ្នំពេញដោយផ្ទាល់តែម្តង ឬមួយតាមរយៈម្ចាស់ហាងលក់ដូរក្នុងស្រុក ។ គ្មានអន្តរការីធ្វើជាអ្នកត្រួតត្រាទីផ្សារធាតុចេញទេ (សូមពិនិត្យផងដែរនូវ តារាង៦.២) ។

ខ្ទង់បញ្ឈរពីរចុងក្រោយក្នុងតារាង៦.៣ បង្ហាញចម្លើយចំពោះសំនួរថា តើការបង់ថ្លៃលើធាតុចេញ ត្រូវបានកាត់កងជាមួយនឹង ឥណទានសំរាប់ទិញធាតុចូលឬទេ។ ផលិតករភាគច្រើនក្នុងសកម្មភាពជាប់ទាក់ទិននឹងនេសាទ មិនចងភ្ជាប់ប្រាក់ចំណូលលើធាតុចេញ ទៅនឹងការបង់ថ្លៃធាតុចូលទេ ។ ក្នុងសកម្មភាពទាក់ទិននឹងតំបាញទាំងពីរមុខ មានការកាត់កងមួយចំនួន ។ ដូចមានចង្អុលបង្ហាញនៅខាងក្រោម សហគ្រាសទាំងនេះទទួលបានឥណទានយ៉ាងច្រើនជាសរសៃសូត្រ/អំបោះ ដែលត្រូវសងវិញជាក្រណាត់ត្បាញហើយ។ លក្ខណៈដូច្នេះ វាផ្ទុយនឹងគោលការណ៏ទីផ្សារប្រកួតប្រជែង ហើយប្រហែលមិនអាចផ្តល់អត្ថប្រយោជន៏បានពេញលេញដល់ផលិតករទេ ។

តារាង៦.៤ ផ្តល់ទិន្នន័យពីរឿង តើផលិករទទួលបានការទូទាត់ទាន់ពេលឬទេសំរាប់ផលិតផលរបស់ខ្លួន និងផ្តល់គំនិតដូចជាថា មានពលករចំនួនច្រើនខ្លាំងណាស់ក្នុងសកម្មភាពទាក់ទិននឹងនេសាទ ដែលបានទទួលការទូទាត់នៅពេលប្រគល់ផលិតផល។ គេមិនអាចថាដូច្នេះបានទេសំរាប់តំបាញសូត្រ ដោយសារការពឹងផ្អែកយ៉ាងធ្ងន់ធ្ងររបស់ផលិតករទៅលើអន្តរការី គឺពួកគេទទួលបានប្រាក់ទូទាត់នៅក្រោយពេលដែលទំនិញបានលក់អស់នៅភ្នំពេញ ។ របៀបទូទាត់គ្រឿងអំបោះស្ថិតនៅចន្លោះសកម្មភាពទាំងពីរខាងលើ ។ ជាទូទៅ សកម្មភាពផ្អែកលើ ដី/ថ្ម ទទួលបានប្រាក់ទូទាត់ទាំងអស់នៅពេលប្រគល់ផលិតផល ។ ដូច្នេះគេអាចសន្និដ្ឋានថា ក្នុងមុខសកម្មភាព និងសហគ្រាសភាគច្រើន ផលិតករទទួលបានការទូទាត់ដោយមិនយឺតយ៉ាវច្រើនទេ ។

**តារាង៦.៤ ពេលវេលានៃការទូទាត់ គិតតាមរបាយគ្រួសារ**

| សកម្មភាព | ទូទាត់មុន | ពេលប្រគល់ផលិតផល | ក្រោយលក់ផលិតផលបាន | យឺតពេលហួសហេតុ |
|---|---|---|---|---|
| នេសាទ | 3 | 52 | 3 | 3 |
| កែច្នៃត្រី | 4 | 51 | 1 | 4 |
| តំបាញសូត្រ | 1 | 8 | 11 | 10 |
| តំបាញអំបោះ | - | 20 | - | 10 |
| ក្អមឆ្នាំង | - | 36 | 3 | 1 |
| សិប្បកម្មចម្លាក់ថ្មម៉ាប | - | 30 | 2 | - |
| ផលិតកម្មឥដ្ឋ | - | 20 | 2 | - |

ទិន្នន័យប្រមូលបានពីទិន្នាការផ្អែកលើពេលវេលាក្នុងលក់ដូរ បង្ហាញនូវលំនាំជាច្រើននៃការលូតលាស់នៅតាមក្រុមសកម្មភាពនានា ។ ក្នុងប្រហែល ៤ឆ្នាំចុងក្រោយ ការនេសាទបានធ្លាក់ចុះ ដោយអ្នកឆ្លើយសំភាសន៏បានត្អូញត្អែរថា ផលិតកម្មបានធ្លាក់ចុះពីកំរិតមូលដ្ឋាន ១០០ នៅឆ្នាំ១៩៩៨ មកត្រឹម ៦៥ នៅឆ្នាំ២០០២ ។ ការធ្លាក់ចុះនេះ ក៏បានរកឃើញក្នុងការសិក្សាផ្សេងៗទៀតផងដែរ ទោះបីទំហំនៃការធ្លាក់ចុះវាមិនស្មើគ្នាក្តី[៤០] ។ ផ្ទុយមកវិញ ការកែច្នៃត្រី បានរីកលូតលាស់ពីកំរិតមូលដ្ឋាន ១០០ ដល់ ១២៨ ក្នុងរយៈ ៤ឆ្នាំ ហើយនេះអាចជាកំណើនជំរុញឡើងដោយតំរូវការ ។

ផលិតកម្មសូត្រ មានកំណើនតិចតួចណាស់ពីកំរិត ១០០ ដល់ ១១១ ក្នុងរយៈ ៤ឆ្នាំ ។ តំរូវការផលិតផលសូត្រ ស្ថិតនៅស្ទើរមស្លឹក ដោយសារមានការប្រកួតប្រជែងដ៏តឹងតែងពីក្រណាត់សំយោគ (synthetics) នាំចូលពីប្រទេសជិតខាង ។ ប៉ុន្តែការលក់ផលិតផលតំបាញអំបោះ បានលូតលាស់យ៉ាងលឿនពីកំរិតមូលដ្ឋាន ១០០ ដល់ ៣៥៣ ។ ក្នុងដំណាក់កាលនេះ គេមិនទាន់ច្បាស់ទេថា ហេតុអ្វីបានជាសកម្មភាពនេះលូតលាស់លឿនដល់ម្លេះ ។ ការចុះសាកសួរដល់កន្លែងបានបង្ហាញថា ទី១ ផលិតផលនេះគ្មានការប្រកួតប្រជែងពីប្រទេសជិតខាងទេ ហើយក្រមាមួយមានអាយុប្រើប្រាស់តែ ៣-៤ខែប៉ុណ្ណោះ ដូច្នេះតំរូវការមានកំរិតថេរល្អ ។ ទី២ ទីផ្សារក្រមាអំបោះ មានដំណើរការពិបាកយល់បានៈ ខណៈដែលតំរូវការហាក់ដូចកើនឡើងយ៉ាងលឿន កំរិតថ្លៃនៅស្លឹកដដែល ហើយប្រាក់ចំនេញក៏បានទាប។ ការពន្យល់មួយដែលអាចត្រឹមត្រូវ គឺក្រម៉ាលក់ចេញបានល្អ ពីព្រោះវាថោក។

[៤០] គេរាយការណ៍ថា ក្នុងប៉ុន្មានឆ្នាំនេះ ផលិតកម្មត្រីត្រូវបានប៉ះពាល់ដោយសារទឹកជំនន់ជាញឹកញាប់ និងកត្តាខាងអេកូឡូស៊ីផ្សេងៗទៀត ។

ម្យ៉ាងទៀត ការចុះសាកសួរដល់កន្លែងបង្ហាញថា ការផ្គត់ផ្គង់ក៏បានកើនលឿនណាស់ដែរ ។ ក្នុងមួយឆ្នាំៗ យ៉ាងហោចណាស់មាន ៦០កីតំបាញម៉ាស៊ីនតំលើងថ្មី ហើយកំណើនការផ្គត់ផ្គង់បានរួមចំណែករក្សាថ្លៃលក់ឱ្យនៅទាប ។

កន្លងមកតំរូវការក្អមឆ្នាំងមានលំនឹង ចំណែកឯតំរូវការចម្លាក់ថ្មម៉ាបគ្មានលំនឹងទេ ។ ការប្រកួតប្រជែងហួសប្រមាណ រួមទាំងបន្ទុកចំណាយខ្ពស់ អាចជាមូលហេតុធ្វើឱ្យលក់បានតិច ។ សន្ទស្សន៍ផលិតកម្មឥដ្ឋ បានធ្លាក់ចុះពីកំរិតមូលដ្ឋាន ១០០ នៅឆ្នាំ១៩៩៨ ដល់កំរិត ៦៣ នៅឆ្នាំ២០០២ ដោយសារកង្វះតំរូវការ និងការប្រកួតប្រជែងតឹងតែងពីប្រទេសជិតខាងដែលធ្វើការផ្គត់ផ្គង់ផលិតផលគុណភាពខ្ពស់ ។

## ៦.២ ធនធានធម្មជាតិ និងការកែច្នៃផលិតផលកសិកម្ម

### *៦.២.១ នេសាទ និងការកែច្នៃត្រី*

ការនេសាទ គឺជាអាជីវកម្មដ៏ស្មុគស្មាញ និងមានពាក់ព័ន្ធដៃគូយ៉ាងច្រើននៅក្នុងដំណើរការផលិតកម្ម និងម៉ាឃីទីង ។ ទូកផលិតនៅក្នុងស្រុកតែម្តង ហើយនេះជាការងារឯកទេសមួយដែលជាទូទៅអនុវត្តដោយក្រុមជនជាតិភាគតិចមួយចំនួន ។ ទូកតូចៗងាយធ្វើជាង ប៉ុន្តែប្រើបានតែសំរាប់ទឹករាក់ទេ ។ ទូកធុនមធ្យម និងធំៗ មានរបៀបធ្វើស្មុគស្មាញជាង ហើយត្រូវដាក់ម៉ាស៊ីនម៉ាស៊ូត ។ ការផ្គត់ផ្គង់គ្មានលក្ខណៈផ្តាច់មុខទេ ហើយទូកសំបូរអាចរកបានក្នុងរយៈពេលខ្លី ។

សំណាញ់នេសាទ ធ្វើពីជាតិនីឡុង និងនាំចូលពីប្រទេសដទៃ ។ កាលពីមុន មានឧបករណ៍នេសាទធ្វើពីឫស្សីផលិតនៅក្នុងស្រុក ប៉ុន្តែសព្វថ្ងៃរបស់បែបនេះបានឈប់ធ្វើអស់ហើយ ។ សំណាញ់នេសាទមួយ ប្រើមិនបានយូរជាងមួយរដូវទេ ហើយត្រូវផ្លាស់វាចេញ ។ នេះគឺជាការខាតបង់មួយចំពោះធនធានរបស់ប្រទេស ពីព្រោះសំណាញ់នេសាទនីឡុងអាចផលិតបាននៅកម្ពុជា ។

ត្រីចាប់បានភាគច្រើនគេលក់ស្រស់ទៅទីផ្សារ ហើយមានតែត្រីមួយចំណែកតូចប៉ុណ្ណោះដែលគេយកទៅធ្វើផ្អក ឆ្អើរ ហាលស្ងួត ឬប្រលាក់ប្រៃ ។ ត្រីស្រស់បានដឹកជញ្ជូនជាសំខាន់មកភ្នំពេញ ឬទៅព្រំដែននៅប៉ោយប៉ែតដើម្បីនាំចេញទៅថៃ ។ ឈ្មួញមានមូលដ្ឋាននៅក្នុងស្រុក ឬប្រចាំតំបន់ គឺជាប្រតិបត្តិករសំខាន់នៅក្នុងជំនួញនេះ ។ ឈ្មួញមានពីរប្រភេទៈ អ្នកទទួលត្រីក្នុងចំនួនតូចៗពីបុគ្គលអ្នកនេសាទ ហើយលក់វាទៅទីផ្សារក្នុងតំបន់ ដែលនៅទីនោះមានឈ្មួញមួយក្រុមផ្សេងទៀតទទួលទិញបន្ត និង អ្នកជាម្ចាស់ឡូត៍នេសាទសម្បទានដែលមានធនធានដើម្បីលក់ផលិតផលខ្លួនទៅភ្នំពេញ ឬប៉ោយប៉ែត ។ ហើយនៅភ្នំពេញ និង ប៉ោយប៉ែត មានអ្នកទទួលត្រីបន្តដើម្បីចែកចាយទៅដល់អ្នកប្រើប្រាស់ចុងក្រោយ ។ ទីផ្សារនានាគ្មានភាពសុក្រិតល្អទេ ដោយសារឈ្មួញមានតិចនាក់ បើធៀបនឹងចំនួនផលិតករ[៤១] ។ ដោយសារទូរស័ព្ទដៃ ទីផ្សារមានតម្លាភាពល្អ ពីព្រោះគេអាចទាក់ទងផ្តល់ពតិមានពីថ្លៃត្រីទៅគ្រប់កន្លែងជារៀងរាល់ថ្ងៃបាន ។

ស្ថានភាពផ្តាច់មុខ អាចពិនិត្យឃើញតាមស្ថានភាពពិតដែល ថ្លៃត្រីស្រស់ដែលផលិតករ (និងឈ្មួញខ្លះៗ) ទទួលបាន វាមិនបានកើនឡើងទេក្នុងរយៈ២-៣ឆ្នាំចុងក្រោយ ទោះបីមានកំណើនតំរូវការកើនក៏ដោយ ។ ប៉ុន្តែ ថ្លៃធាតុចូលមួយចំនួនដូចជា អំបិល ទឹកកក និងម៉ាស៊ូត បានកើនយ៉ាងទៀងទាត់ ។ ក្នុងការធ្វើអាជីវកម្ម ពាណិជ្ជករកម្ពុជា ត្រូវចាញ់ប្រៀបពាណិជ្ជករថៃ ដែលគិតថ្លៃត្រីឱ្យជាប្រាក់បាត ចំណែកឯពាណិជ្ជករកម្ពុជាត្រូវទូទាត់ចំណាយរបស់ខ្លួនជាប្រាក់ដុល្លារ និងជាពិសេសទៅទៀត ដោយសារក្នុងពេលថ្មីៗ ប្រាក់បាតមាននិន្នាការប្រែប្រួលចុះថ្លៃធៀបនឹងដុល្លារ ។

[៤១] ខណៈដែលផលិតករអាចចាប់ត្រីបានទោះបីមានតែទូកចែវតូចមួយក្តី ប៉ុន្តែពាណិជ្ជករត្រូវមានទំហំទិញលក់កំរិតណាមួយ ដើម្បីអាចស្តុក និងដឹកជញ្ជូនត្រី ទៅកន្លែងឆ្ងាយៗអោយមានប្រសិទ្ធភាព ហើយស្ថានភាពរកស៊ីផ្តាច់មុខ នឹងកើតមានឡើងដោយចៀសមិនរួច (ពិសេស ដោយសារត្រីជាផលិតផលងាយខូចគុណភាព) ។

**ក្រាហ្វិក៦.១ ទំនាក់ទំនងដើមខ្សែ និងចុងខ្សែ នៅក្នុងប្រតិបត្តិការនេសាទ**




ក្រាហ្វិក៦.១ បង្ហាញពីទំនាក់ទំនងដើមខ្សែ និងចុងខ្សែ ក្នុងប្រតិបត្តិការនេសាទ ដូចបានពិនិត្យឃើញក្នុងការសិក្សាដល់ទីកន្លែង ។ ថ្លៃបង់ដោយ អន្តរការី/ឈ្មួញ ទៅឱ្យផលិតករ ត្រូវបានកំណត់ឡើងដោយថ្លៃជាក់ស្តែងនៅព្រំដែន ឬនៅភ្នំពេញ ហើយគេចរចាថ្លៃជារៀងរាល់ថ្ងៃ ។ ដើម្បីទូទាត់ចំណាយដឹកជញ្ជូន (ម៉ាស៊ូតសំរាប់កាមីញ៉ុង ៣០តោន) ប្រាក់កំរៃតាមផ្លូវ និងប្រាក់បង់ឱ្យកន្លែងត្រួតពិនិត្យ អន្តរការីបង់ ៥បាតក្នុងមួយគីឡូក្រាម ដើម្បីដឹកនាំត្រីទៅច្រកព្រំដែនប៉ោយប៉ែត[៤២] ។ ក្រៅពីនេះអន្តរការីត្រូវបង់កំរៃអាជ្ញាប័ណ្ណប្រហែល ១០០.០០០រៀលក្នុងដំណើរមួយជើង, ចំណាយទូរស័ព្ទប្រហែល ៨០.០០០រៀល និងចំណាយពលកម្មប្រហែល ៤០០.០០០រៀលក្នុងមួយខែ សំរាប់ការផ្ទុក និងរើត្រីចេញ ។ នៅឯព្រំដែន ចំណាយលើឃ្លាំងអស់ប្រហែល ៣០.០០០-៤០.០០០រៀល (ក្នុងមួយឡាន, ក្នុងមួយជើង) ប៉ុន្តែមានតែប្រតិបត្តិករធំៗដែលប្រើរថយន្ត៣០តោនទេ ដែលប្រើឃ្លាំង ព្រោះបើយកទំនិញតិចចូលឃ្លាំងវាមិនចំណេញទេ ។ ពាណិជ្ជករតូចៗឆ្លងកាត់ព្រំដែន និងចាត់ចែងលក់ផលិតផល តាមថ្លៃណាមួយដែលគេអាចចរចាបាន ។ បើសិនទំនិញទៅដល់ព្រំដែនយឺត, ក្រោយពេលបិទព្រំដែន, គេត្រូវអស់សោហ៊ុយថែមទៀតដើម្បីដឹកទំនិញឆ្លងព្រំដែន ។ នៅឯឃ្លាំង គេត្រូវចំណាយលើទឹកកកសំរាប់ស្តុកត្រី អស់ ៥០.០០០រៀលថែមទៀត ។ ក្រៅពីនេះនៅមានកំរៃព្រំដែន ១០០.០០០រៀល, គយថៃ ៥០០បាត/តោន, និងប្រាក់សំណូកដើម្បីបានឆ្លងព្រំដែន, ដែលត្រូវបូកបន្ថែមក្នុងបន្ទុកចំណាយ ។ ចំណាយអស់ទាំងនេះ មិនធ្លាក់លើអ្នកប្រើប្រាស់ទាំងអស់ទេ ។ តាមពិតអ្នកប្រើប្រាស់បានទទួលផលល្អពីទីផ្សារប្រកួតប្រជែង ដោយសារផលិតករ អន្តរការី និងឈ្មួញ ត្រូវទទួលរ៉ាប់រងចំណាយទាំងនេះ ។ ដូច្នេះគ្មានអ្វីគួរភ្ញាក់ផ្អើលទេ ថ្លៃលក់របស់ផលិតករ វានៅស្ពឹកគ្មានកំណើន ។

ការដឹកទំនិញទៅភ្នំពេញអស់សោហ៊ុយតិចជាង ដោយសារចំងាយផ្លូវជិត ប៉ុស្តិ៍ត្រួតពិនិត្យតិច ហើយប្រាក់បង់ក្រៅផ្លូវការតាមធម្មតាគេយកតិចជាង ។ ប៉ុន្តែ ថ្លៃចុងក្រោយនៃធាតុចេញក៏ទាបដែរនៅភ្នំពេញ បើធៀបនឹងប៉ោយប៉ែត ។ ឈ្មួញតូចតាចមួយចំនួនរើទំនិញរបស់ខ្លួននៅទីផ្សារក្នុងស្រុកដើម្បីបំរើការប្រើប្រាស់ផ្ទាល់ ឬធ្វើការកែច្នៃ ។ គេមានបញ្ហាខាងប្រតិបត្តិការតិចតួចជាងមែន ប៉ុន្តែប្រាក់ចំណូលក៏បានតិចជាងដែរ ។

ដោយមានពតិមានលំអិតដូចបានលើកខាងលើ គេអាចរកឃើញកត្តាជាច្រើនដែលអាចជួយដល់ផលិតករត្រីកម្ពុជា :

[៤២] អ្នកដឹកជញ្ជូនគ្រប់គ្រងដោយផ្ទាល់នូវចំណាយតាមផ្លូវទាំងអស់ ដូចជា ប្រាក់កំរៃផ្លូវការ និងមិនផ្លូវការ ឯអ្នកបញ្ជូនទំនិញគ្មានចូលពាក់ព័ន្ធនឹងការចាត់ចែងទាំងអស់នេះទេ ។

១) ប្រសិនបើការបង់ប្រាក់ក្រៅផ្លូវការនៅតាមផ្លូវត្រូវបានកាត់បន្ថយ

២) ប្រសិនបើពាណិជ្ជករក្នុងស្រុក ទទួលបានលក្ខខណ្ឌប្រសើរជាងនេះ នៅក្នុងដំណើរការពាណិជ្ជកម្ម ដែលអាចផ្តល់អត្ថប្រយោជន៍ដល់ទាំងពាណិជ្ជករ និងផលិតករ

៣) ប្រសិនបើកន្លែងឃ្លាំងស្តុកអាចដោះស្រាយបានដោយមានថ្លៃសមរម្យសំរាប់គ្រប់ៗគ្នា ដើម្បីជៀសវាងកុំអោយពាណិជ្ជករត្រូវលក់ដូរផលិតផលខ្លួនក្នុងស្ថានភាពបង្ខំបន្ទាន់ខ្លាំងពេក

៤) ប្រសិនបើផ្លូវពាណិជ្ជកម្ម (ផ្លូវថ្នល់) ត្រូវបានកែលំអជាលក្ខណៈរូបវ័ន្ត

៥) ប្រសិនបើបទប្បញ្ញត្តិធ្វើពាណិជ្ជកម្មជាមួយពាណិជ្ជករថៃ ត្រូវបានពង្រឹង ។

### *៦.២.២ ផលិតកម្មសូត្រ*

ថ្វីបើតំបាញសូត្រប្រើកីម៉ាស៊ីនផលិតក្នុងស្រុកក្តី, ប៉ុន្តែថ្នាំជ្រលក់ និងសរសៃសូត្រ ចូលមកពី "ក្រៅ" ដែលធ្វើឱ្យអ្នកក្នុងស្រុកគ្មានកំលាំងត្រួតត្រាពិតៗលើផលិតកម្មទេ ។ ម្យ៉ាងទៀត ដោយពុំមានការដាក់ចូលប្រើនូវបច្ចេកវិទ្យាទំនើប ទំនាក់ទំនងសេដ្ឋកិច្ចទៅខាងដើមខ្សែ វានៅទន់ខ្សោយ និងមានលក្ខណៈដោយដុំៗ[៤៣] ។

**ក្រាហ្វិក៦.២ ទំនាក់ទំនងដើមខ្សែ និងចុងខ្សែនៅក្នុងផលិតកម្មសូត្រ**




មានអន្តរការីដល់ទៅ ៣-៤នាក់ ដែលចេញចូលភូមិនិមួយៗ ដើម្បីផ្គត់ផ្គង់សរសៃសូត្រ ថ្នាំជ្រលក់ និងប្រមូលផលិតផលសំរេច ។ ក្នុងករណីមួយចំនួន អ្នកប្រមូលផលិតផលសំរេច និងអ្នកលក់សរសៃសូត្រ គឺជាមនុស្សតែម្នាក់ ។ ពួកគេក៏ជាអ្នកចាត់ចែងការដឹកជញ្ជូនទៅ-មកទីផ្សារនៅភ្នំពេញ ដើម្បីយកសរសៃសូត្រទៅឱ្យផលិតករ និងដឹកត្រឡប់ទៅវិញនូវក្រណាត់សូត្រ ។ ថ្លៃផលិតផលសំរេច កំណត់ឡើងដោយតំរូវការ និងគុណភាពផលិតផល ។ ក្នុងពេលបច្ចុប្បន្ន តំរូវការបានចុះខ្សោយ ដោយសារមានការប្រកួតប្រជែងខ្លាំងពីសូត្រ និង ក្រណាត់សំយោគពីប្រទេសជិតខាង ។ ក៏រឹតថ្លៃទទួលរងការគាបសង្កត់ ដោយសារគេមានគំនិតថា ក្រណាត់សូត្រកម្ពុជាមានគុណភាពអន់ ។ អត្រាខូចចោលក៏ខ្ពស់ដែរ ដោយសារចំណុចខ្វះផ្សេងៗក្នុងផលិតផល ហើយកត្តានេះបានគាបសង្កត់ថ្លៃមួយកំរិតទៀត ។

អន្តរការីផ្គត់ផ្គង់ដុំសរសៃសូត្រប្រហែល ៤-៥គីឡូក្រាម ទៅឱ្យផលិតករ ដែលថ្លៃ ១៦ដុល្លារ/គ.ក បើបង់ប្រាក់ដល់ដៃ ឬ ២០ដុល្លារ/គ.ក បើយកជឿ ។ បើយកសូត្រគេជឿ អាចមានលក្ខខណ្ឌថា ត្រូវលក់ផលិតផលឱ្យអ្នកផ្គត់ផ្គង់សូត្រនោះវិញ ។ វដ្តផលិតកម្មមួយដុំៗ មិនដែលលើសពីមួយខែទេ (ជាមធ្យម ២សប្តាហ៍) ។ ក្នុងករណីមួយចំនួនតូច អ្នកនាំចូលសូត្រឆៅ ដែល

---

[៤៣] មានសំណើមួយធ្វើឡើងដោយ PRASAC ដើម្បីបញ្ចូលបច្ចេកវិទ្យាទំនើបទៅក្នុងវិស័យតំបាញសូត្រ ប៉ុន្តែការងារនេះកំពុងស្ថិតក្នុងដំណាក់កាលគិតគូរពីដំបូងនៅឡើយទេ ។

មាននាំចូលថ្នាំជ្រលក់ផងដែរ គេព្យាយាមលក់វាដោយផ្ទាល់ទៅឱ្យផលិតករ តែការអនុវត្តន៍បែបនេះមិនឃើញរីកធំទេ[៤៤] ។ ផលិតករទទួលបានចំណូល ទៅតាមគុណភាពផលិតផលរបស់ខ្លួន ។ អន្តរការីលក់ផលិតផលនៅភ្នំពេញ ដែលមានឈ្មួញនៅផ្សារថ្មី ផ្សារអូឬស្សី ផ្សារទួលទំពូង ឬ ហាងលក់គ្រឿងសូត្របន្ទាយស្រី ត្រួតត្រាទីផ្សារ និងកំរិតតំលៃ ។ ចំណាយដឹកជញ្ជូនទំនិញ ២០-៤០គ.ក ទៅភ្នំពេញ គឺប្រហែល ២៥.០០០រៀល (ចេញដោយអន្តរការី) ។

អន្តរការីជារឿយៗទទួលបានឥណទានពីឈ្មួញ ហើយដោយសារអត្រាការប្រាក់មានកំរិតខ្ពស់ ដូច្នេះ នៅក្នុងខ្សែរយៈពាណិជ្ជកម្មនេះ អ្នកទទួលបានផលចំណេញពិតៗ គឺអាចជាពួកឈ្មួញនៅទីក្រុង មិនមែនអន្តរការីគ្រឿងសូត្រទេ ។ អន្តរការីក៏ត្រូវបង់ខាតដែរនៅពេលឈ្មួញពន្យាការបង់ប្រាក់ ។ នៅចុងបញ្ចប់ គេលក់ផលិតផលឱ្យអ្នកប្រើប្រាស់ក្នុងថ្លៃពី ២០-២៥ ដុល្លារក្នុងមួយដុំ, ក្នុងនេះ ឈ្មួញបានចំណេញប្រហែល ២-៤ដុល្លារ/ដុំ, អន្តរការីគ្រឿងសូត្របានចំណេញ ១-៣ដុល្លារ/ដុំ, ហើយផលិតករទទួលបានប្រហែល ១០-១៥ដុល្លារ/ដុំ[៤៥] ។

ដោយមូលហេតុដូចខាងលើ ផលិតករមានការចាញ់ប្រៀបនៅទីផ្សារ ដោយសារគ្មានការត្រួតត្រាលើថ្លៃធាតុចូល ឬថ្លៃធាតុចេញ ។ បច្ចេកវិទ្យាអន់ ធ្វើឱ្យផលិតភាពនៅតែទាប ដែលនាំឱ្យស្ថានភាពទីផ្សាររបស់ពួកគេកាន់តែចុះខ្សោយ ។ សរុបមកសកម្មភាពតំបាញសូត្រ ទាមទារនូវការកែតំរូវមួយយ៉ាងពេញលេញ ។

### *៦.២.៣ កីតំបាញអំបោះ*

ដូចបានលើករួចហើយ ម៉ាស៊ីនតំបាញអំបោះគេផលិតនៅក្នុងស្រុក ប៉ុន្តែសរសៃអំបោះទាំងអស់នាំចូលមកពីវៀតណាម ហើយថ្លៃរបស់វាត្រូវបានកំណត់ពីខាងក្រៅ ។

**ក្រាហ្វិក៦.៣ ទំនាក់ទំនងដើមខ្សែ និងចុងខ្សែ ក្នុងផលិតកម្មតំបាញអំបោះ**




តាំងពីដើមរៀងមក ផលិតករតែងមានទំនាក់ទំនងផ្ទាល់ជាមួយឈ្មួញក្រណាត់នៅភ្នំពេញ ។ ក្នុងរបរនេះគ្មានអន្តរការីទេ ហើយម្ចាស់អាជីវកម្មមួយចំនួនធ្វើដំណើរទៅភ្នំពេញ ដើម្បីយកផលិតផលទៅប្រគល់ឱ្យគេ និងយកសរសៃសូត្រមកត្បាញវិញ ។ ផលិតករចំណាយដល់ ៦.០០០រៀលសំរាប់មួយជើងៗ (សោហ៊ុយធ្វើដំណើរតាមម៉ូតូ) ដើម្បីដឹកអីវ៉ាន់ ៥០គីឡូក្រាម ជាវត្ថុធាតុដើម ឬផលិតផលសំរេច ។

មានកត្តាពីរយ៉ាងតិច ដែលកាត់បន្ថយចំណូលរបស់ពលករ និងផលិតករ ។ ទី១ ទីផ្សារធាតុចេញមានការប្រកួតប្រជែង ហើយបើសិនតំលៃផលិតកម្មកើនឡើងដោយសារកំណើនថ្លៃធាតុចូល កំណើននេះមិនមែនអាចផ្ទេរទៅទីផ្សារបានរហូតនោះទេ។ ទី២ ទោះបីកីតំបាញមានដាក់ម៉ូទ័រអគ្គីសនីហើយក្តី ប៉ុន្តែបច្ចេកវិទ្យានេះនៅតែចាស់គំរិលនៅឡើយ ។ ដូច្នេះផលិតភាពនៅតែទាប ហើយហេតុផលតែមួយដែលផលិតផលអាចនៅរស់បាន គឺមកពីគ្មានការប្រកួតប្រជែងពីកន្លែងផ្សេង និងផលិតផលមានថ្លៃទាប

[៤៤] ការលក់ផ្ទាល់ដោយអ្នកនាំចូល បានបំបាត់អន្តរការីអស់មួយជាន់ ដូច្នេះផលិតករទទួលបានសរសៃសូត្រក្នុងតំលៃថោកជាង (១៨ដុល្លារ/គ.ក) ។ បើសិនច្រកនេះក្លាយជាការពេញនិយមទៅអនាគត វាអាចផ្តល់ប្រយោជន៍ដល់ផលិតករ ។

[៤៥] ដោយផលិតករអាចត្បាញបានតែ ២ដុំក្នុងមួយខែ ដូច្នេះចំណូលរបស់គេបានត្រឹមកំរិតជីវភាព ។

(នេះជាស្ថានភាពចំលែកមួយ តែមានពិតជាក់ស្តែង) ។ សកម្មភាពនេះអាចទទួលកំលាំងជំរុញមួយ ប្រសិនបើទំនាក់ទំនងចុងខ្សែត្រូវបានពង្រឹង ។

### *៦.២.៤ ក្អមឆ្នាំង*

ដូចក្នុងភាគច្រើននៃសកម្មភាពឯទៀតៗដែលបានសិក្សា ទំនាក់ទំនងដើមខ្សែនៅក្នុងផ្នែកក្អមឆ្នាំង អាចសំខាន់ខ្លាំងជាងទំនាក់ទំនងចុងខ្សែ ។ ធាតុចូលសំខាន់ជា ដីឥដ្ឋ ដែលថោកទេគឺ ១រទេះ (ប្រហែល 0,៥ម$^{៣}$) ថ្លៃ ៥.000រៀល (ឬ ២0.000រៀល បើដឹកដល់ផ្ទះ ដោយប្រើរទេះរបស់អ្នកដឹក) ហើយដី ១រទេះនេះអាចផលិតបាន ២៥0-៣00ឆ្នាំងនិងភាជន៍ ។ ជារឿយៗផលិតករ ជីកយកដីឥដ្ឋ និងដឹកវាទៅផ្ទះដោយខ្លួនឯង ។

ដូចបានលើករួចហើយ ផលិតករសូនដីធ្វើឆ្នាំង ហើយដួលឡគេ ដើម្បីដុតចំអិនវា។ ថ្លៃឈ្នួលឡគឺ ២៥.000រៀលសំរាប់មួយវគ្គ និងត្រូវចំណាយ ៨.000រៀលផ្សេងទៀតលើថ្លៃអុស ។ ផលិតករជាអ្នកទទួលរ៉ាប់រងចំណាយអស់ទាំងនេះ ។ ក្នុងមួយវគ្គៗ អាចដុតបានប្រហែល ១00 ឆ្នាំង និងភាជន៍ ។ ដំណើរការទាំងមូលនៃការសូននិងដុត ឆ្នាំង និងភាជន៍ ១00 នេះ ចំណាយពេលអស់ប្រហែល ១១ថ្ងៃ ។

ពាណិជ្ជករ និងអន្តរការី លក់ចេញទៅទីផ្សាររហូតដល់ ៩៥% នៃផលិតផល ។ កន្លែងលក់ចេញភាគច្រើនរបស់ពាណិជ្ជករប្រមូលផ្តុំនៅតាមផ្លូវជាតិលេខ៥ ដែលតភ្ជាប់ខេត្តកំពង់ឆ្នាំង មកក្រុងភ្នំពេញ ។ គេធ្វើការលក់រាយ, ដឹកផលិតផលមកភ្នំពេញ និងខេត្តសៀមរាប, ហើយក៏មាននាំចេញមួយចំនួនតូចតាមរយៈទំនាក់ទំនងជាមួយនឹងឈ្មួញផ្សេងៗទៀត ។ ការបាក់បែកអាចមានរហូតដល់ ៣0% ដែលរ៉ាប់រងដោយពាណិជ្ជករ ប៉ុន្តែផលិតករអាចជួយរ៉ាប់រងមួយចំណែកតាមរយៈការកែតំរូវលើកំរិតថ្លៃ ។

**ក្រាហ្វិក៦.៤ ទំនាក់ទំនងដើមខ្សែ និងចុងខ្សែ ក្នុងផលិតកម្មក្អមឆ្នាំង**




ក្នុងពេលថ្មីៗនេះ ពាណិជ្ជករបានលក់កើនឡើងដល់ទៅ ១0ដង ។ គ្មានកំរិតថ្លៃស្តង់ដាទេសំរាប់ផលិតផលនីមួយៗ លើកលែងតែចំពោះរបស់មួយចំនួនដែលលក់ទៅឱ្យអ្នកក្នុងស្រុកសំរាប់ការប្រើប្រាស់ក្នុងគ្រួសារ ។ ផលចំណេញរបស់ផលិតករបានអធិប្បាយនៅក្នុង ជំពូកទី៥ រួចហើយ រីឯ ផលចំណេញរបស់ពាណិជ្ជករមិនអាចកំណត់បានទេដោយសារកត្តាថ្លៃលក់ ដូចបញ្ជាក់នៅខាងលើ ។ ប៉ុន្តែវាសឹងតែច្បាស់ហើយដែលថា ពាណិជ្ជករបានផលចំណេញខ្ពស់ជាងផលិតករ (អាចបានតិចជាងបើគិតក្នុងមួយឯកតាលក់) ពីព្រោះតាមធម្មតាពាណិជ្ជករមានទំហំប្រតិបត្តិការធំជាង ។

ជំនួយបច្ចេកទេសពី NGO បានជួយពង្រឹងដល់ទំនាក់ទំនងដើមខ្សែយ៉ាងពិតប្រាកដ ។ ម្យ៉ាងទៀត ទំនាក់ទំនងដើមខ្សែក៏មិនធ្វើអោយផលិតករចាញ់ប្រៀបណាស់ណាដែរ ។ ប៉ុន្តែដូចបានបញ្ជាក់ជូនពីខាងដើម ទំហំប្រតិបត្តិការរបស់ផលិតករម្នាក់ៗវាតូចពេក មិនអាចផ្តល់ចំណូលបានច្រើនទេ ។

### ៦.២.៥ សិប្បកម្មចម្លាក់ថ្មម៉ាប

ទំនាក់ទំនងដើមខ្សែចំបងនៅក្នុងសិប្បកម្មចម្លាក់ថ្មម៉ាប គឺជាការផ្គត់ផ្គង់ថ្មម៉ាប ។ អ្នកដឹកជញ្ជូន និងអន្តរការី គឺជាចំណងទាក់ទងមួយយ៉ាងសំខាន់មួយនៅក្នុងខ្សែរយៈពាណិជ្ជកម្ម ហើយដោយឡែកនៅក្នុងទំនាក់ទំនងចុងខ្សែគឺមាន អន្តរការីនិងអ្នកលក់ដុំ នៅភ្នំពេញ នៅតំបន់ផ្សេងទៀតនៃកម្ពុជា និងនៅបរទេស ។ អន្តរការីជាអ្នក ទិញ និងលក់ផលិតផលចេញវិញ ទៅអោយអ្នកប្រើប្រាស់ចុងក្រោយ ។

អ្នកដឹកយកថ្ម គឺជាប្រជាជនក្នុងស្រុកនៃ តំបន់ជួរភ្នំក្រវាញដែលនៅចំងាយប្រហែល ៧០-៨០គីឡូម៉ែត្រ ពីកន្លែងផលិតកម្មនៅក្នុងក្រុងពោធិ៍សាត់ ។ គេដឹកយក និងកាត់បំបែកផ្ទាំងថ្មម៉ាប ដឹកតាមរទេះគោទៅដាក់នៅក្នុងឃ្លាំងចំហមួយ (គឺកន្លែងចំហមួយដែលគេអាចដឹកដុំថ្ម បន្តទៅទៀតបាន) ។ ការងារដឹកយក និងដឹកថ្មម៉ាប ប្រើពេលពីមួយខែទៅពីរខែទើបចប់សព្វគ្រប់ ហើយអ្នកដឹកយកថ្មទទួលបានចំណូលត្រឹមតែការរស់រានមានជីវិត ហើយអ្នកដឹកយកថ្មទទួលបានចំណូលត្រឹមតែប៉ុណ្ណោះ ។

អន្តរការីទទួលទំនិញពីកន្លែងស្តុកថ្ម បន្ទាប់ពីបានបង់ប្រាក់ទៅឱ្យអ្នកដឹកយកថ្ម ទៅតាមគុណភាព និងទំងន់ថ្ម[៤៦] ។ ផលិតករ (អ្នកឆ្លាក់) ទិញថ្មពីអន្តរការី ក្នុងថ្លៃពី ៧០០-៤.០០០រៀល/គីឡូក្រាម ។ តាមធម្មតាអន្តរការីលក់ថ្មទៅឱ្យផលិតករបានថ្លៃ ២-៣ដងលើសពីថ្លៃដែលបង់ទៅឱ្យអ្នកដឹកយកថ្ម។ ប្រាក់ចំណេញមួយភាគ ត្រូវបានចែករំលែក (ក្រៅផ្លូវការ) ទៅឱ្យមន្ត្រីរដ្ឋាភិបាល ដើម្បីអាចទៅកាន់ខេត្តពោធិ៍សាត់បានដោយសុវត្ថិភាព ។

ផលិតករលក់វត្ថុសិល្បៈសិប្បកម្មទៅឱ្យពាណិជ្ជករមកពីភ្នំពេញ និងសៀមរាប ។ ពាណិជ្ជករទាំងនេះទទួលយកដល់ទៅ ៨០% នៃចំនួនផលិតផលសរុប ។ ពាណិជ្ជករផ្គត់ផ្គង់វត្ថុសិប្បកម្មទៅឱ្យអ្នកលក់ដុំដែលជាបណ្តាញរបស់ខ្លួន និងដែលធ្វើការចែកចាយបន្តទៅឱ្យហាងតូចៗ ហាងវត្ថុសិល្បៈធំៗ និងហាងលក់គ្រឿងអនុស្សាវរីយ៍ ។ អតិថិជនចុងក្រោយគឺ ពួកទេសចរ ក្រុមអ្នកមានចំណូលខ្ពស់នៅក្នុងស្រុក និងអ្នកនាំចេញ/អ្នកលក់ដុំបរទេស ។ ពាណិជ្ជករជាទូទៅមានមធ្យោបាយដឹកជញ្ជូនផ្ទាល់ខ្លួន ហើយតែងទទួលរ៉ាប់រងបន្ទុកចំណាយទាំងនេះ ។ តាមធម្មតាពាណិជ្ជករមានកំរិតចំណេញ ២-៣ដងខ្ពស់ជាងថ្លៃដើមរបស់គេ ហើយអ្នកលក់ដុំក៏មានកំរិតចំណេញ ២-៣ដងខ្ពស់ជាងថ្លៃដើមដូចគ្នាដែរ ។ គេអាចមើលឃើញថា ផលិតផលកើនតំលៃដល់ទៅ ៦ដង គិតពីពេលវាចេញពីដៃផលិតករ និងដល់ដៃអតិថិជន ។

**ក្រាហ្វិក៦.៥ ទំនាក់ទំនងដើមខ្សែ និងចុងខ្សែ ក្នុងសិប្បកម្មថ្មម៉ាប**




ជាថ្មីម្តងទៀត គឺ ពាណិជ្ជករ និងអ្នកលក់ដុំ មិនមែនផលិតករទេ ដែលត្រួតត្រាលើសកម្មភាពនេះ ។ ទាំងអ្នកដឹកយកថ្ម ទាំងអ្នកឆ្លាក់ ទទួលបានចំណូលតូចៗ និងមានកំលាំងត្រួតត្រាតិចតួចណាស់លើទីផ្សារ ។ ថ្វីបើសព្វថ្ងៃផលិតករជាច្រើនបានពង្រីក

[៤៦] ថ្មថ្លៃជាងគេគឺ ថ្មពណ៌បៃតងចាស់ ដោយសារឃើញដូចត្បូងមរកត ។

ផលិតភាពរបស់ខ្លួន ដោយប្រើម៉ាស៊ីនខួង និងម៉ាស៊ីនដាប់ ប៉ុន្តែមិនបានទទួលចំណូលច្រើនណាស់ណាទេ ដោយសារកង្វះការត្រួតត្រាលើទីផ្សារ ។

### *៦.២.៦ ផលិតកម្មឥដ្ឋ*

ក្នុងផលិតកម្មឥដ្ឋ ទំនាក់ទំនងដើមខ្សែ រួមមាន អ្នកផ្គត់ផ្គង់ដីឥដ្ឋ អ្នកផ្គត់ផ្គង់អង្កាម (គឺម្ចាស់រោងម៉ាស៊ីនកិនស្រូវ) និង អ្នកដឹកជញ្ជូន ។ ទំនាក់ទំនងចុងខ្សែ រួមមាន អន្តរការី ពាណិជ្ជករ និង អ្នកដឹកជញ្ជូន ។

គ្រឿងម៉ាស៊ីនសំរាប់ផលិតកម្មឥដ្ឋ គឺនាំចូលមកពីវៀតណាម ។ គ្រឿងម៉ាស៊ីនអាចថាមិនល្អជាងគេទេសំរាប់អាជីវកម្មនេះ ប៉ុន្តែគេចូលចិត្តប្រើវាដោយសារតំលៃថោក ។ អ្នកផ្គត់ផ្គង់ដីឥដ្ឋជារឿយៗជាម្ចាស់ដីឡូត៍ដែលគេជីកយកដីឥដ្ឋ ដើម្បីដឹកយកទៅកន្លែងផលិតឥដ្ឋ ។ ពលករត្រូវបានជួលនៅក្នុងស្រុក ដោយផ្តល់ប្រាក់កំរៃនៅកំរិតជីវព្រឹត្ត ដើម្បីឱ្យជីកយកដីឥដ្ឋទៅផ្ទុកលើរថយន្តដឹកដី ។ បន្ទាប់មកអ្នកដឹកជញ្ជូនដឹកដីឥដ្ឋទៅកន្លែងផលិតឥដ្ឋ ។ ក្នុងករណីឥដ្ឋក្បឿង គឺផលិតករ មិនមែន អ្នកលក់ដុំទេ ដែលត្រួតត្រាទីផ្សារនៅក្នុងដំណាក់កាលនេះ ។ គេលក់ឥដ្ឋតាមការបញ្ជាទិញ ព្រមទាំងផ្គត់ផ្គង់ឱ្យអ្នកលក់ដុំ និងអ្នកលក់រាយ ។ ក្រោយពេលទំនិញចេញផុតពីកន្លែងផលិតឥដ្ឋហើយ គឺពាណិជ្ជករជាអ្នកកំណត់ថ្លៃ ។ អត្រាចំណេញមានកំរិតតូចទេ ប្រហែល ១០រៀលក្នុងឥដ្ឋមួយដុំ ។

**ក្រាហ្វិក៦.៦ ទំនាក់ទំនងដើមខ្សែ និងចុងខ្សែ នៅក្នុងផលិតកម្មឥដ្ឋក្បឿង**




មិនដូចម្ចាស់អាជីវកម្មដទៃទេ ម្ចាស់ផលិតកម្មឥដ្ឋត្រួតត្រាទីផ្សាររបស់ខ្លួនឯងយ៉ាងគ្រប់ជ្រុងជ្រោយ ។ ដូច្នេះមិនទាន់មានការប្រឹងប្រែងដើម្បីគណនាអត្រាចំណេញនៅតាមកំរិតណាផ្សេងទេ ក្រៅតែពីនៅកំរិតផលិតកម្ម ដោយសារវាមានតំលៃចារិក ។ ប៉ុន្តែដូចក្នុងសកម្មភាពឯទៀតដែរ ផលិតភាពក្នុងផលិតកម្មឥដ្ឋអាចកើនឡើង បើសិនមានការកែលំអបច្ចេកវិទ្យា ។

## ៦.៣ សង្ខេប

ដូចផលិតករតូចតាចជាទូទៅនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នានា សកម្មភាពអាជីវកម្មជនបទតូចៗនៅកម្ពុជា ក៏ជួបឧបសគ្គនៃ កង្វះការត្រួតត្រាលើយន្តការទីផ្សារ និងថ្លៃ ។ ពាណិជ្ជករ និងអន្តរការី ដែលមានប្រាក់ និងមានស្ថានភាពផ្តាច់មុខ គឺបានចំណេញច្រើនណាស់ ។ ប៉ុន្តែគួររំលឹកដែរថា ពាណិជ្ជករមិនមែនដូចគ្នាទាំងអស់ទេ ។ ក្នុងចំណោមពាណិជ្ជករ គឺមាន "អ្នកត្រួត ត្រា" និង "អ្នកពឹងផ្អែក" ។ ជារឿយៗណាស់ ពាណិជ្ជករដែលមានទីតាំងនៅទីក្រុង និងដែលមានការប្រាស្រ័យទាក់ទងផ្ទាល់ជា មួយអ្នកទិញចុងក្រោយ គឺជាពាណិជ្ជករដែលធ្វើការត្រួតត្រាច្រើនជាអតិបរមា ។

ទំនាក់ទំនងដើមខ្សែ ជារឿយៗពុំមានច្រើនទេ ហើយទោះបីផលិតករពុំមានជួបឧបសគ្គនៃលក្ខខណ្ឌពាណិជ្ជកម្មមិនស្មើភាពគ្នាក្តី ប៉ុន្តែធាតុចូលគុណភាពអន់ធ្វើឱ្យផលិតភាពរបស់គេនៅទាបដដែល ។ ពាណិជ្ជករធំៗមានតួនាទីគ្របលើគេនៅក្នុងទំនាក់ទំនងចុងខ្សែ ហើយបញ្ហាកាន់តែធ្ងន់ធ្ងរឡើងនៅពេលពាណិជ្ជករទាំងនេះក៏ជាអ្នកផ្គត់ផ្គង់ធាតុចូលផងដែរ ។ ក្នុងករណីបែបនេះ ផលិតករមានស្ថានភាពដូចគ្នានឹង ពលករទទួលកំរៃតាមឯកតាផលិត ដូច្នោះដែរ ។ ប៉ុន្តែពុំមានករណីច្រើនប៉ុន្មានទេដែលផលិតករស្ថិតក្រោមការត្រួតត្រារបស់ពាណិជ្ជករទាំងពីរខាង ហើយកន្លងមករឿងនេះឃើញមានច្បាស់តែក្នុងផលិតកម្មសូត្រប៉ុណ្ណោះ ។

# ជំពូកទី ៧

# គំនិតផ្តួចផ្តើមខាងគោលនយោបាយ និងទីផ្សារ

នៅទសវត្សរ៍ចុងក្រោយនេះ គេឃើញមានគំរោងជាច្រើនសំដៅលើកកំពស់វិស័យកសិកម្ម និង សកម្មភាពផ្សេងទៀត នៅកម្ពុជា ក្នុងដំណើការនៃការអភិវឌ្ឍន៍ប្រទេស ។ រដ្ឋាភិបាល និងអង្គការអន្តរជាតិ ព្រមទាំង NGOs ផង គឺជាអ្នកដឹកនាំគំនិតផ្តួចផ្តើមទាំងនេះ ។ ប៉ុន្តែមិនទាន់មានគោលការណ៍អ្វីច្បាស់លាស់ទេ ដើម្បីជំរុញឧស្សាហកម្មកម្មតូចៗ, អាជីវកម្មនៅជនបទ ឬ សកម្មភាពក្រៅកសិដ្ឋាន ក្រៅតែពីគំនិតផ្តួចផ្តើមមួយចំនួនដែល NGOs និងភ្នាក់ងារអន្តរជាតិខ្លះៗបានអនុវត្ត ។ វិស័យមិនមែនកសិកម្មនៅជនបទ ពុំឃើញមានចុះនៅក្នុង ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកទី១ (SEDP, 1996-2000) ឬក៏មានចែងច្បាស់លាស់នៅក្នុង SEDP ទី២ ដែរ ។ សូម្បីតែ ឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (PRSP) ដែលរដ្ឋាភិបាលបានរៀបចំក្នុងពេលថ្មីៗ ក៏គ្រាន់តែបានធ្វើការកត់សំគាល់ខ្លះៗពីផ្នែកនេះប៉ុណ្ណោះ (លើកលែងតែការនេសាទ) ។

ជំពូកនេះមានគោលដៅ ពិនិត្យត្រួសៗពីគំនិតផ្តួចផ្តើមមួយចំនួនដែលអាចជាប់ទាក់ទិនដល់ សកម្មភាពមិនមែនកសិកម្ម និង ក្រៅកសិដ្ឋាន នៅជនបទ ។

## ៧.១ ការរៀបរាប់ពីគំនិតផ្តួចផ្តើមជ្រើសរើសមួយចំនួន

### *៧.១.១ សកម្មភាពនេសាទ*

នៅកម្ពុជា ការនេសាទគឺជាផ្នែកចំបងមួយ ហើយក្រៅពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមានទីភ្នាក់ងារឯកទេសមួយចំនួនទៀតដូចជា គណៈកម្មាធិការទន្លេមេគង្គ និងសមភាគីកិរិតរបស់ខ្លួន ដែលចូលរួមក្នុងការអភិវឌ្ឍវិស័យនេះ។ គំរោងផ្សេងៗសំរាប់លើកកំពស់ការនេសាទមានជាអាទិ ការអភិរក្សធនធាន ការបង្កើតលក្ខខណ្ឌសំរាប់ការបន្តពូជត្រីបានកាន់តែប្រសើរ ការបណ្តុះបណ្តាលមន្ត្រីរដ្ឋាភិបាល ការគ្រប់គ្រងឡូត៍នេសាទ បញ្ហាលទ្ធភាពសហគមន៍ក្នុងស្រុកក្នុងការប្រើប្រាស់តំបន់នេសាទ និងការរកទីផ្សារអន្តរជាតិ (EDC 2002; McKenney and Prom 2002)។ ការពិភាក្សាវែកញែកពីប្រសិទ្ធភាពសកម្មភាព អភិវឌ្ឍន៍ វាឋិតនៅក្រៅក្របខ័ណ្ឌឯកសារនេះ ប៉ុន្តែគេគួរបញ្ជាក់ដែរថា ជារឿយៗគោលការណ៍ដែលមានស្រាប់នានា បានទទួល ការរិះគន់ ពីព្រោះវាមិនបានជួយអ្វីសក្តិសិទ្ធិទេ ដើម្បីធ្វើឱ្យវិស័យនេះឃ្លាតចេញពី របបគ្រប់គ្រងមជ្ឈការលើធនធាន ឆ្ពោះទៅ កាន់របបសេដ្ឋកិច្ចដឹកនាំដោយទីផ្សារវិញ ។ម្យ៉ាងទៀតនៅក្នុងគោលនយោបាយ មានវិធានការតិចតួចណាស់ដែលសំដៅពង្រឹង មូលដ្ឋានផលិតកម្មនេសាទសមុទ្រ គឺខុសគ្នាទាំងស្រុងពីការនេសាទត្រីទឹកសាបដែលមានចែងយ៉ាងច្រើន ។ គួរបញ្ជាក់ដែរថា ការកែច្នៃត្រី ការវេចខ្ចប់ (រួមទាំងការបង្កក) និងការដាក់កំប៉ុង អាចបន្ថែមតំលៃបានច្រើនណាស់ បើសិនមានបរិស្ថានខាងគោលនយោបាយដែលអំណោយផលល្អ ។ ប៉ុន្តែគួរឱ្យស្តាយ ដោយសកម្មភាពជាក់ស្តែងផ្សេងៗនៅកំរិតគោលនយោបាយដើម្បីបំរើទិសដៅនេះ ឃើញមានតិចតួចពេក ។

### ៧.១.២ ការអភិវឌ្ឍន៍វិស័យឯកជនក្រោមគំរោងCARERE

កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ/គំរោងស្តារ និងបង្កើតតំបន់ឡើងវិញ (CARERE) បានផ្តួចផ្តើមធ្វើនៅឆ្នាំ១៩៩៥ ដើម្បីដកពិសោធន៍ពីការធ្វើ ផែនការអភិវឌ្ឍន៍នៅកំរិតមូលដ្ឋាន ។ CARERE ត្រូវបានដាក់អនុវត្តក្នុងខេត្តជ្រើសរើសមួយចំនួននៅភាគពាយ័ព្យ និងភាគឦសាន និងមានទិដ្ឋភាពផ្សេងៗដូចជា ការអភិវឌ្ឍន៍វិមជ្ឈការ, ការអភិវឌ្ឍន៍កសិកម្ម និង ការធ្វើវិមជ្ឈការប្រជាធិបតេយ្យ, ដោយមានការផ្តោតមួយកំរិតតូចទៅលើការអភិវឌ្ឍន៍វិស័យឯកជននេះផងដែរ ។

សកម្មភាពអភិវឌ្ឍន៍វិស័យឯកជនរបស់ CARERE បានផ្តោតជាចំបងលើការពង្រឹងសកម្មភាពអាជីវកម្មនៅជនបទ ។ ក្នុងនេះមានការប្រឹងប្រែងបង្កើតសមាគមអង្គភាពផលិតឯកជនតូចៗ ដូចជា រោងម៉ាស៊ីនកិនស្រូវ ផលិតកម្មឥដ្ឋ អង្គភាពនេសាទ និង ផលិតកម្មអគ្គីសនីខ្នាតតូច ។ គោលដៅជាមូលដ្ឋាននៃការបង្កើតសមាគម គឺដើម្បីផ្តល់ការបណ្តុះបណ្តាលជំណាញគ្រប់គ្រងអាជីវកម្ម ជួយបង្កើតក្រុមឥណទាន និងជួយដល់ការងារស្វែងរកទីផ្សារ ។ ការសិក្សាដល់ទីកន្លែងមួយចំនួនត្រូវបានធ្វើឡើង និងបានក្លាយជាមូលដ្ឋានសំរាប់ការកសាងគោលនយោបាយផ្សេងៗក្នុងវិស័យទាំងនេះ ។

ដោយកម្មវិធី CARERE បានចប់នៅឆ្នាំ២000, សាខាខាងអភិវឌ្ឍន៍វិស័យឯកជនរបស់វា សព្វថ្ងៃបានក្លាយជា NGO ឯករាជ្យមួយឈ្មោះថាអង្គការអភិវឌ្ឍន៍សហគ្រិនភាពនៃកម្ពុជា (Entrepreneurship Development of Cambodia: EDC) ។ EDCសព្វថ្ងៃផ្តោតការយកចិត្តទុកដាក់លើការជំរុញវិស័យឯកជន និងការកសាងទុនខាងសង្គមកិច្ចនៅជនបទកម្ពុជា ។ EDC គាំទ្រយ៉ាងសកម្មលើគំរោងនានាដែលជួយដល់ការកសាងក្រឹត្យក្រមសំរាប់វិស័យឯកជន, ការគ្រប់គ្រងសហគ្រាស, ការកែលំអសកម្មភាពកិនស្រូវ, ការនេសាទជាលក្ខណៈពាណិជ្ជកម្ម, ផលិតកម្មឥដ្ឋក្បឿង, និងប្រភពថាមពលដែលអាចកើតឡើងវិញ ។

### ៧.១.៣ ការបណ្តុះបណ្តាល

កម្ពុជាមានប្រព័ន្ធបណ្តុះបណ្តាលវិជ្ជាជីវៈមួយ ដែលមាន ៣៣ មជ្ឈមណ្ឌល និងសាលាបច្ចេកទេស បង្កើតឡើងដោយរដ្ឋ និង NGOs ។ មានសាលាច្រើនបែបយ៉ាងណាស់ដែលអាចទាក់ទងដល់ឧស្សាហូបនីយកម្មក្នុងតំបន់ជនបទ និងដែលមានជាអាទិ៍:

១) សាលារៀនសំរាប់ឧស្សាហកម្ម

២) មជ្ឈមណ្ឌលបណ្តុះបណ្តាល Don Bosco ភ្នំពេញ

៣) មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

៤) មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ Don Bosco, Telka

៥) មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ បាត់ដំបង

៦) មជ្ឈមណ្ឌលមិត្តភាពខ្មែរ-ជប៉ុន សំរាប់បណ្តុះបណ្តាលវិជ្ជាជីវៈ

៧) មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ សៀមរាប

៨) មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេសឧស្សាហកម្មកំពត

៩) មជ្ឈមណ្ឌលសហគ្រាសសំរាប់យុវជនជនបទ នៅខេត្តព្រៃវែង និង ស្វាយរៀង (PRASAC)

ភាគច្រើននៃមជ្ឈមណ្ឌលបណ្តុះបណ្តាលទាំងនេះ ផ្តល់ការបណ្តុះបណ្តាលមានមូលដ្ឋានធំទូលាយ ។ ក្នុងពេលបច្ចុប្បន្ន គេពុំមានពតិមានសំរាប់ធ្វើការវាយតំលៃពីការរួមចំណែករបស់ស្ថាប័នទាំងនេះដល់ការធ្វើចំរុះកម្មមុខរបរទេ ។ ក្នុងបទសំភាសន៍មួយ

ជំនាញការបណ្តុះបណ្តាលម្នាក់ធ្វើការក្នុង NGO អន្តរជាតិ បានប្រាប់យ៉ាងស្មោះត្រង់ថា តាមរយៈការបណ្តុះបណ្តាលបច្ចេកទេសមានរយៈ២-៣សប្តាហ៍ ឬ ២-៣ខែ គេពិបាកនឹងធ្វើឱ្យយុវជនជនបទដែលជារឿយៗគ្មានទ្រព្យអ្វីសោះ (ហើយរៀនមិនបានលើសពី ៥-៦ឆ្នាំនៅបឋមសិក្សាទេ) ប្រែក្លាយទៅជាសហគ្រិនមួយយ៉ាងពេញលេញបាន ។ ដោយហេតុថា មនុស្សម្នាក់ដែលមានប្រវត្តិជាកសិករ មានត្រូវការអ្វីច្រើនទៀតក្រៅពីការបណ្តុះបណ្តាលបច្ចេកទេស ដើម្បីក្លាយជាសហគ្រិនបាន ដូច្នេះអ្នកដែលបានទទួលបណ្តុះបណ្តាលហើយ ក្នុងករណីប្រសើរបំផុតគឺគ្រាន់តែអាចជួយបង្កើនផលិតភាពនៅតាមអង្គភាពដែលខ្លួនចូលបំរើការប៉ុណ្ណោះ (បើសិនអាចចូលបាន) ។ ប៉ុន្តែវាអាចជួយបង្កើនភាពងាយមានការងារធ្វើរបស់បុគ្គលនោះ[៤៧] ។

Don Bosco ស្ថិតក្នុងចំណោមមជ្ឈមណ្ឌលបណ្តុះបណ្តាលមានឥទ្ធិពលច្រើនៗ ដោយផ្តល់ការបណ្តុះបណ្តាល (ដល់កុមារកំព្រាជាសំខាន់) ក្នុងមុខជំនាញជាច្រើនខាង ការរក្សាទុកម្ហូបអាហារ, ការកាត់ដេរ និងដេរប៉ាក់, សកម្មភាពខាងអេឡិចត្រូនិច និងអគ្គិសនី, វិស្វកកម្មខាងគ្រឿងយន្ត និងបោះពុម្ព ។ សកម្មភាពបណ្តុះបណ្តាលបានពង្រាយនៅតាមតំបន់ផ្សេងៗក្នុងប្រទេស ដូចជា ប៉ោយប៉ែត ក្រុងកែប ក្រុងព្រះសីហនុ ខេត្តកណ្តាល កំពង់ចាម កំពង់ធំ បាត់ដំបង និងតាកែវ ។ កន្លងមកមានបេក្ខជនជាង ២.០០០នាក់បានទទួលការបណ្តុះបណ្តាលក្នុងជំនាញផ្សេងៗ ហើយតាមធម្មតាពួកគេទទួលបានប្រាក់ឧបត្ថម្ភ ក្នុងរយៈពេលរៀន។

នេះអាចជាការវាយតំលៃដោយស្មានៗមួយ ប៉ុន្តែមនុស្សជាច្រើនដែលបានទទួលបណ្តុះបណ្តាលហើយតែងស្វែងរកការងារនៅតាមក្រុងធំៗ គឺហាក់ដូចមិនឃើញមានសញ្ញាអ្វីបង្ហាញថា សិក្ខាកាមបានក្លាយជាសហគ្រិនខ្នាតតូច ឬត្រលប់ទៅតំបន់ជនបទវិញទេ[៤៨] ។

### *៧.១.៤ ការអភិវឌ្ឍន៍សហគ្រិនភាព*

កម្មវិធីអភិឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ (MPDF) ជាគំរោងមួយដែលឧបត្ថម្ភ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារពិភពលោក និងរដ្ឋាភិបាលអ្នកផ្តល់ជំនួយទ្វេភាគីជាច្រើន, និងដែលបានចាប់ផ្តើមដំណើរការតាំងពីឆ្នាំ១៩៩៧ ។ កម្មវិធីមានគោលដៅ ជំរុញវិស័យឯកជនក្នុងស្រុកក្នុងប្រទេសទាំងបីដែលមានសេដ្ឋកិច្ចអន្តរកាលនៅអាស៊ីអគ្នេយ៍ ។ MPDF បានធ្វើ ១២៨វគ្គសិក្សា និងបានបណ្តុះបណ្តាល ១.៦០៤សហគ្រិននៃសហគ្រាសធុនតូច និងមធ្យម (SMEs) នៅក្នុងតំបន់។ កម្មវិធីក៏មានធ្វើផងដែរនូវវគ្គបណ្តុះបណ្តាលខ្លីៗមានលក្ខណៈទន់ភ្លន់អាចបត់បែនបានមួយចំនួន ដែលអ្នកប្រើប្រាស់មានការពេញចិត្តច្រើន ។ នៅវៀតណាម MPDF បានផ្តួចផ្តើមសកម្មភាពនានានៅតាមតំបន់ជនបទ, ប៉ុន្តែនៅកម្ពុជា សកម្មភាព MPDF មិនបានប្រមូលផ្តុំនៅតាមជនបទទាំងអស់ទេ ។ ម្យ៉ាងទៀតក្នុងចំណោម ៨៧គំរោងស្តីពីជំនួយទីប្រឹក្សាក្រុមហ៊ុន ដែលបានធ្វើចប់ហើយនៅក្នុងតំបន់ គឺមានតែ ៧គំរោងទេដែលទាក់ទងដល់ប្រទេសកម្ពុជា ។

ក្រៅពីគំរោងដែលបានបញ្ចប់ហើយដូចបានបញ្ជាក់នៅខាងលើ, ប្រតិបត្តិការរបស់ MPDF នៅកម្ពុជា នៅឆ្នាំ២០០១ បានផ្តោតលើ ការសិក្សាពីចម្ងាយ ការបណ្តុះបណ្តាលនាយកធនាគារ និងការផ្តល់ហិរញ្ញប្បទានអោយកម្មវិធីទូរទស្សន៍មួយ ។ ក្នុងក្របខ័ណ្ឌនៃតំបន់ជនបទ MPDFបានជួយឧបត្ថម្ភដល់ សហព័ន្ធនៃសមាគមអ្នកកិនស្រូវ ។ MPDF ក៏បានជួយបង្កើត RICENET គឺជាអាសយដ្ឋានអ៊ិនធឺណិតមួយស្តីពីស្រូវ ។ ម្យ៉ាងទៀត MPDF មានសកម្មភាពមួយជួយដល់ផលិតកម្មទឹកសណ្តែក, ដែលជាឧស្សាហកម្មផ្នែកលើកសិផល ប៉ុន្តែគំរោងនេះមិនស្ថិតនៅក្នុងតំបន់ជនបទទេ (MPDF2002) ។

### *៧.១.៥ មីក្រូឥណទាន*

ផ្អែកតាមឯកសារមានស្រាប់នានា និងករណីសិក្សាបានបង្ហាញជូនក្នុងអត្ថបទនេះ គេឃើញច្បាស់ថា ឥណទានគឺជាឧប

---

[៤៧] សំភាសន៍ជាមួយជំនាញការបណ្តុះបណ្តាលរបស់ PRASAC កាលពីថ្ងៃ ០៤ កញ្ញា ២០០២ ។

[៤៨] សំភាសន៍ជាមួយជំនាញការនៃមជ្ឈមណ្ឌលសំរាប់បណ្តុះបណ្តាល Don Bosco កាលពីថ្ងៃ ០៦ កញ្ញា ២០០២ ។

សក្តិបងចំពោះគ្រប់សកម្មភាពអភិវឌ្ឍន៍នៅកម្ពុជា។ ឥណទានឯកជនមានថ្លៃខ្ពស់និងលក្ខណៈតឹងតែង រីឯឥណទានស្ថាប័នមានតិចតួចណាស់ ។ ម្យ៉ាងទៀត អ្នកខ្ចីជាច្រើននាក់ពុំមានលក្ខណៈសម្បត្តិខាងផ្លូវច្បាប់ដើម្បីទទួលបានឥណទានពីប្រភពស្ថាប័នទេ ។

ធនាគារពាណិជ្ជយល់ថា ប្រតិបត្តិការធនាគារមិនអាចធ្វើកើតទេក្នុងតំបន់ជនបទ[៤៩] ។ ប៉ុន្តែមានការទទួលស្គាល់ជាទូទៅថា មីក្រូឥណទានហាក់ដូចអាចបំពេញបាននូវតំរូវការរបស់កសិករជនបទតូចៗ និងផលិតករដទៃទៀត ។ កិច្ចប្រឹងប្រែងពង្រីកមីក្រូហិរញ្ញវត្ថុបានទទួលកំលាំងជំរុញចំបងមួយ នៅពេល ACELEDA បានកសាងខ្លួនឯងទៅជាអ្នកផ្តល់ឥណទានដ៏សំខាន់មួយ (ក្តាប់ ៥៨%នៃទីផ្សារ), និងបន្ទាប់មកនៅពេលបង្កើតបាន ធនាគារអភិវឌ្ឍន៍ជនបទជាតិ ដើម្បីផ្តល់ហិរញ្ញប្បទានឡើងវិញ ដល់ទីភ្នាក់ងារមីក្រូហិរញ្ញវត្ថុនានា ។ នៅឆ្នាំ២០០១ មានសរុប ៧៥ស្ថាប័នមីក្រូឥណទានដែលបំរើសេវាដល់ ២១%នៃគ្រួសារនៅជនបទកម្ពុជា (EMT 2001) ។ ប៉ុន្តែគិតជាទំហំហិរញ្ញវត្ថុវិញ សព្វថ្ងៃវាអាចដោះស្រាយបានប្រហែលតែ ២៣%នៃតំរូវការប៉ុណ្ណោះ ហើយគេប៉ាន់ស្មានថា កង្វះឥណទានមានប្រហែល ១២០លានដុល្លារ/ឆ្នាំ (Kang 2002) ។ ការគណនាផ្សេងៗបានបង្ហាញថា ស្ថាប័នមីក្រូឥណទានជនបទអាចរស់រានបានខាងហិរញ្ញវត្ថុ បើសិនអត្រាការប្រាក់បានខ្ពស់ជាង ៤៨% ដូច្នេះអត្រាទាញចំណូលរបស់សហគ្រាសអ្នកខ្ចីឥណទានត្រូវតែបានខ្ពស់ជាងនេះទៀត ។ ការវិភាគពីខាងដើមបានបង្ហាញថា មានករណីជាក់ស្តែងជាច្រើនដែលអត្រាចំណូលលើវិនិយោគអាចបានលើសពី ៤៨% ប៉ុន្តែប្រាក់ទុននៅតែមិនហូរចូលទៅក្នុងតំបន់ជនបទទៀត ដោយសារមូលហេតុជាច្រើន:

ក) ប្រាក់ចំណេញត្រូវបានពង្រាយស្តើងពេកទៅលើអ្នកពាក់ព័ន្ធផ្សេងៗគ្នា ដូច្នេះ គេពិបាកនឹងផ្តល់កំចីដល់អ្នកប្រើប្រាស់ជាក់លាក់ណាមួយ

ខ) ហានិភ័យមានកំរិតខ្ពស់ពេក ដោយសារអវត្តមាននៃក្របខ័ណ្ឌច្បាប់

គ) ការផ្គត់ផ្គង់ត្រូវបានរឹតបន្តឹង

ជាលទ្ធផល ក្នុងប្រាក់ ២០លានដុល្លារបានពី ADB ដើម្បីជំរុញមីក្រូឥណទាន គឺមានតែមួយភាគតូចប៉ុណ្ណោះ ដែលបានប្រើប្រាស់ក្នុងពេលសព្វថ្ងៃ ។

### *៧.១.៦ គំនិតផ្តួចផ្តើមនៃវិស័យឯកជន*

វិស័យឯកជន និង NGOs បានផ្តួចផ្តើមគំរោងមួយចំនួនដើម្បីឱ្យមានការវិវត្តន៍ ឬការរស់ឡើងវិញ នៃសកម្មភាពមួយចំនួនក្នុងតំបន់ជនបទ ។ ការកែច្នៃកសិផលគឺជាគំរូល្អមួយ ក្នុងនេះមានអាជីវកម្មកែច្នៃដំឡូងឈើដែលគ្រឹះស្ថានឧស្សាហកម្មចំបងមួយបានផ្តួចផ្តើមធ្វើ ។ រោងចក្រកែច្នៃដំឡូងឈើត្រូវបានកសាងនៅជិតកសិដ្ឋាន ហើយបើសិនកសិករដាំដំណាំនេះ គឺមានការធានាទិញផលិតផលតាមចំនួន និងតំលៃកំណត់មួយ (Sok and Acharya 2002) ។ ការធ្វើសមាហរណកម្មកសិ-ឧស្សាហកម្មប្រភេទនេះ គឺជាទំរង់មួយទៀតនៃឧស្សាហូបនីយកម្មជនបទ ដែលកំពុងតែរីកធំ នៅក្នុងប្រទេសកម្ពុជា ។

គំនិតផ្តួចផ្តើមរបស់វិស័យឯកជន ក៏បានចាប់ផ្តើមក្នុងផ្នែកកែច្នៃម្ហូបអាហារដែរ ។ ឧទាហរណ៍ផ្សេងៗនៃផលិតកម្មទឹកត្រីមានកត់សំគាល់នៅក្នុងឯកសារ Acharya (2002) ហើយសកម្មភាពផ្សេងទៀតរួមមាន ការខ្ចប់សាច់ ការខ្ចប់ផ្លែឈើ និងការកែច្នៃបន្លែ ។ ប៉ុន្តែសព្វថ្ងៃ សកម្មភាពទាំងនេះកំពុងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍន៍ពីដំបូងដៃនៅឡើយទេ ។

ការជំរុញផលិតកម្មសូត្រ គឺជាគំនិតផ្តួចផ្តើមមួយទៀត ដែលអាចបង្កើនការអភិវឌ្ឍន៍ឧស្សាហកម្មជនបទ ។ ក្នុងនេះមាន

---

[៤៩] ធនាគារកាណាឌីយ៉ា បានដកពិសោធន៍ផ្តល់កំចីឱ្យកសិករនៅចុងទសវត្សរ៍១៩៩០ ហើយបានពិនិត្យឃើញថា ការងារនេះមិនផ្តល់ចំណេញទេ ។ សកម្មភាពនេះក្រោយមកក៏ត្រូវបញ្ឈប់វិញ ។

គំរោងពីរដែលអំណោយផលល្អ ពីព្រោះមានទីតាំងក្នុងតំបន់ជនបទ និងមានពាក់ព័ន្ធផ្ទាល់ជាមួយកសិករ និងពលករជនបទ ។ ឧទាហរណ៍មួយជាប់ពាក់ព័ន្ធនឹង គំរោង PRASAC នៅឆ្នាំ២០០១-០២ ដោយមានទិសដៅធ្វើការអភិវឌ្ឍន៍បច្ចេកវិទ្យា ការកែលំអការរៀបចំនិងគុណភាពផលិតផល និង ការធ្វើម៉ាឃីទិងផលិតផលបានកាន់តែប្រសើរ (Victor-Pujebet and Peyre 2001) ។ ការសិក្សាលើបច្ចេកទេសធ្វើដោយ PRASAC បង្ហាញថា គេអាចបង្កើនផលិតកម្ម និងការលក់គ្រឿងសូត្រ ឱ្យវាធំជាងនេះដល់ទៅបីដងបានក្នុងរយៈ១០ឆ្នាំខាងមុខ។ UNESCO ក៏បានជួយទ្រទ្រង់ផងដែរដល់សមាគមនារីតំបាញសូត្រ នៅភ្នំជីសូរ ខេត្តតាកែវ ដោយផ្តល់ការបណ្តុះបណ្តាលមានគុណភាពខ្ពស់ខាងតំបាញ និងការជ្រលក់ពណ៌ ។

## ៧.២ សង្ខេប

គំនិតផ្តួចផ្តើមខ្លះៗដែលបង្ហាញជូនក្នុងការសិក្សានេះ មិនបានគ្របដណ្តប់អស់ទេនូវសកម្មភាពគ្រប់បែបយ៉ាងដែលកំពុងមានអនុវត្តនៅកម្ពុជា ប៉ុន្តែវាអាចឆ្លុះបញ្ចាំងបានល្អគួរសមពីស្ថានភាពខាងគោលនយោបាយសាធារណៈ និងសកម្មភាពផ្សេងៗរបស់រដ្ឋាភិបាល និងរបស់ទីភ្នាក់ងារផ្សេងទៀត ។ គេឃើញច្បាស់ថា ក្នុងករណីល្អបំផុតកិច្ចប្រឹងប្រែងទាំងនេះបានត្រឹមកំរិតសាមញ្ញប៉ុណ្ណោះ ហើយលើកលែងតែចំពោះការនេសាទ និងមីក្រូឥណទានទេ ដែលមានអន្តរាគមន៍កំរិត *ម៉ាក្រូ* , អន្តរាគមន៍ឯទៀតទាំងអស់ហាក់ដូចធ្វើឡើងនៅកំរិត *មីក្រូ* និងកំរិតបុគ្គល ។ សកម្មភាពនេះបានទាក់ទាញការយកចិត្តទុកដាក់ ពីព្រោះវាបានជោគជ័យ ប៉ុន្តែគេមិនអាចចាត់ទុកវាជាចំណែកមួយនៃ "គោលនយោបាយសាធារណៈ" បានទេ ។ សរុបមក នៅកម្ពុជាក្នុងពេលបច្ចុប្បន្ន គេឃើញមានតិចតួចទេនូវកិច្ចប្រឹងប្រែងដើម្បីលើកកំពស់សហគ្រាស និងសកម្មភាពមិនមែនកសិកម្មនៅជនបទ ។

# ជំពូកទី ៨

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ដោយសារហេតុផលដែលជាប់ទាក់ទងនឹងប្រវត្តិសាស្រ្តជាសំខាន់ នៅជនបទកម្ពុជាមានរបរចិញ្ចឹមជីវិតតិចតួចណាស់ក្រៅពីការធ្វើកសិកម្មជីវព្រឹត្ត ។ កិច្ចប្រឹងប្រែងដើម្បីធ្វើទំនើបកម្មសេដ្ឋកិច្ចនៅអំឡុងទសវត្សរ៍១៩៥០ និង ១៩៦០ បានផ្តល់ផ្លែផ្កាមួយចំនួន ប៉ុន្តែផលប៉ះពាល់ពិតៗកើតមានតែចំពោះទីក្រុងមួយចំនួនតូចប៉ុណ្ណោះ ។ នៅទសវត្សរ៍១៩៨០ និង ១៩៩០ សកម្មភាពមួយចំនួនបានរីកទៅដល់តំបន់ជនបទ ហើយសកម្មភាពដែលមានស្រាប់មួយចំនួន ដូចជាការនេសាទ ក៏កាន់តែមានក្រិត្យក្រមច្បាស់ឡើង ។ ប៉ុន្តែមកទល់ពេលនេះ សេដ្ឋកិច្ចមិនមែនកសិកម្មនៅជនបទមិនទាន់លូតលាស់ដល់ទំហំមួយដែលអាចមានផលប៉ះពាល់ទៅលើវចនាសម្ព័ន្ធការងារនៅជនបទបានទេ ។

បន្ថែមទៅលើការងារវិភាគទិន្នន័យទី២ ការសិក្សានេះបង្ហាញលទ្ធផលបានពីការចុះសាកសួរដល់កន្លែងដែលធ្វើឡើងលើ ៧ មុខសកម្មភាពអាជីវកម្មនៅជនបទ គឺមាន ការនេសាទ ការកែច្នៃត្រី តំបាញសូត្រ តំបាញអំបោះ ក្ដមឆ្នាំង សិប្បកម្មចម្លាក់ថ្មម៉ាប និងផលិតកម្មឥដ្ឋ ។ ក្នុងស្ទើរគ្រប់ករណីទាំងអស់ ដំណើរការផ្ទៃក្នុងសហគ្រាសមានប្រសិទ្ធភាពល្អ ។ ប៉ុន្តែសហគ្រាសទាំងនេះជួបការលំបាកបណ្តាលពី បច្ចេកវិទ្យាអន់ថយចាស់ហួសសម័យ, បុគ្គលិកពុំមានការបណ្តុះបណ្តាលគ្រប់គ្រាន់និងមិនសូវបានជួបពាក់ព័ន្ធនឹងបច្ចេកវិទ្យាទំនើប, កង្វះហិរញ្ញវត្ថុ, ខ្សែរយៈទីផ្សារមានតិចតួច, និង ទំហំប្រតិបត្តិការតូចដែលផ្តល់ចំណូលមិនបានគ្រប់គ្រាន់ ។ ខ្សែរយៈទីផ្សារវាមិនត្រឹមតែមិនគ្រប់គ្រាន់នោះ និងមានតំលៃខ្ពស់ប៉ុណ្ណោះទេ ប៉ុន្តែជារឿយៗវាបានធ្វើឱ្យផលិតករ *ចាញ់ប្រៀបគេ* ។ លើសពីនេះទៀត បែបបទប្រតិបត្តិការអាជីវកម្មជាលក្ខណៈជីវព្រឹត្ត និងដឹកនាំដោយគ្រួសារ ធ្វើឱ្យផលិតភាពនៅតែមានកំរិតទាប ។ ឧបសគ្គពីរទៀតដែលគេតែងលើកញឹកញាប់បំផុតថា បានរារាំងដល់ការជំរុញអាជីវកម្មក្នុងស្រុកនៅកម្ពុជា (គឺ ហេដ្ឋារចនាសម្ព័ន្ធអន់ខ្សោយ និងដុល្លារូបនីយកម្មនៃរូបិយវត្ថុ) ក៏ហាក់ដូចឃើញមានផងដែរក្នុងករណីទាំងនេះ ។

មកទល់សព្វថ្ងៃ គោលនយោបាយសាធារណៈដែលផ្តោតលើប្រតិបត្តិការមិនមែនកសិកម្មគឺមានតិចតួច និងដោយដុំៗ ។ ទោះបីការប្រឹងប្រែងដោយចោះៗក្នុងពេលកន្លងមកវាមានប្រយោជន៍ក្តី ប៉ុន្តែវាមិនមែនជាគ្រឿងលើកទឹកចិត្តគ្រប់គ្រាន់ទេសំរាប់ការអភិវឌ្ឍន៍ជនបទ ។

ការជំរុញសកម្មភាពមិនមែនកសិកម្មនៅជនបទ ទាមទារនូវការប្រឹងប្រែងកំរិតជាតិមួយដើម្បីធ្វើឧស្សាហូបនីយកម្មជនបទ ដោយផ្តោតលើការកែប្រែប្រតិបត្តិការអាជីវកម្មនៅជនបទចេញពីលក្ខណៈជីវព្រឹត្តិ ទៅបំរើសេដ្ឋកិច្ចទីផ្សារវិញ និងដោយមានការចូលរួមយ៉ាងពេញលេញពីវិស័យឯកជន ។ ទិដ្ឋភាព ដូចជា ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចអំណោយផល ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និង អភិបាលកិច្ចល្អ, គឺជាលក្ខខណ្ឌត្រូវមានជាមុនសំរាប់គោលនយោបាយបែបនេះ ។ អ្នកខ្លះបានជជែកវែកញែកថា កំណើនសេដ្ឋកិច្ចមិនមែនកសិកម្ម (ដែលជួយសំរួលដោយតំរូវការពីវិស័យកសិកម្ម) គួរតែចងភ្ជាប់យ៉ាងជិតស្និទ្ធជាមួយនឹងការធ្វើទំនើបកម្មវិស័យកសិកម្ម បើពុំនោះទេការប្រឹងប្រែងនេះនឹងបានជោគជ័យតែតិចតួច ។ ទស្សនៈ *បែបប្រកាន់តឹង* ដូច្នេះ មិនបានទទួលការគាំទ្រច្រើនក្នុងអត្ថបទនេះទេ ។

ឯកសារនេះគ្មានគោលដៅផ្តល់នូវ គំរូប្លង់មួយសំរាប់ការលូតលាស់វិស័យមិនមែនកសិកម្ម នៅក្នុងក្របខ័ណ្ឌនៃការធ្វើផែនការអភិវឌ្ឍន៍នោះទេ ។ ដូច្នេះហើយ អនុសាសន៍នានាត្រូវបានធ្វើឡើង ដោយផ្អែកទៅតាមការពិភាក្សាវែកញែកលើ បញ្ហាមួយចំនួនតូចដែលផុសចេញពីការចុះសិក្សាដល់ទីកន្លែង ។

## ៨.១ ការអភិវឌ្ឍន៍តាមវិស័យ

ក្នុងអាជីវកម្មមិនមែនកសិកម្មនៅជនបទ សកម្មភាពសំខាន់ៗមួយចំនួនជាប់ទាក់ទិននឹងវិស័យធនធានធម្មជាតិ ដូចជាការនេសាទ ព្រៃឈើ និងធនធានទឹក។ វិស័យនិមួយៗទោះដោយផ្ទាល់ឬដោយប្រយោលក្តី វាមានផលប៉ះពាល់ចំពោះសកម្មភាពមិនមែនកសិកម្ម និង/ឬ ការងារ ។ ជារឿយៗមានការលើកឡើងពីតំរូវការគោលនយោបាយគ្រប់ជ្រុងជ្រោយមួយ ហើយទោះបីរដ្ឋាភិបាលបានបង្កើតក្របខ័ណ្ឌគោលនយោបាយសំរាប់ធនធាននិមួយៗហើយក្តី (ដោយមានជំនួយពីទីភ្នាក់ងារបរទេសនានា) ប៉ុន្តែនៅមានការងារច្រើនទៀតដែលត្រូវធ្វើ ។ ក្របខ័ណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយសំរាប់ធនធានធម្មជាតិ ព្រមទាំងយន្តការសំរាប់អនុវត្ត (គឺមានទិដ្ឋភាពខាង បច្ចេកទេស ច្បាប់ រដ្ឋបាល និង តុលាការ) ត្រូវតែដាក់អនុវត្តឱ្យបានឆាប់។ ចំណុចនេះពុំមានពន្យល់លំអិតក្នុងឯកសារនេះទេ ពីព្រោះក្នុងឯកសារផ្សេងទៀតមានការពិភាក្សាវែកញែកយ៉ាងច្រើនហើយ[៥០] ។

## ៨.២ ម៉ាឃីទិង

ការធ្វើម៉ាឃីទិងផលិតផលនានា ត្រូវបានសំរួលដោយហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសង្គមកិច្ចដែលមានស្រាប់ ព្រមទាំងប្រព័ន្ធច្បាប់ និងរដ្ឋបាល ដ៏សក្តិសិទ្ធិមួយ ។ នេះអាចជាសេចក្តីថែងជាទូទៅមួយសំរាប់គ្រប់ផលិតផល និងសេវាទាំងអស់ ។

ដោយមានសេចក្តីថែងដូចខាងលើ បរិបទនៃសកម្មភាព និងឧស្សាហកម្មជនបទនានា មិនគួរពិនិត្យក្នុងក្របខ័ណ្ឌជាទូទៅពេកទេ។ ផលិតផល និងសេវាមួយចំនួន ត្រូវបានប្រើប្រាស់ក្នុងស្រុក នៅក្នុងវិស័យជនបទដោយផ្ទាល់ ហើយមួយចំនួនទៀតអាចរកទីផ្សារបាននៅខាងក្រៅ ។ ទាំងសំរាប់ផលិតផលលក់ក្នុងស្រុក ឬលក់ទៅក្រៅ គេត្រូវបង្កើតច្រកមួយដែលមានប្រសិទ្ធភាព និងមានតំលៃទាប ដើម្បីជួយឱ្យផលិតផលមានប្រសិទ្ធភាពតំលៃ និងអាចលក់ចេញទាន់ពេល។ ត្រីនិងផលិតផលត្រី, ឧស្សាហកម្ម ផ្អែកលើធនធានដទៃទៀត, សេវាដឹកជញ្ជូនផ្លូវទឹកនៅជនបទ, និងផលិតផលពឹងផ្អែកលើកសិកម្ម, គឺមានលក្ខណៈលេចធ្លោជាង គេ ។ ផលិតផលជាច្រើនត្រូវបានប្រើប្រាស់នៅក្នុងស្រុក តែជារឿយៗវាជាប្រភេទទំនិញដែលមានការប្រកួតប្រជែងពីផលិតផល ធ្វើនៅទីក្រុង ឬមកពីបរទេស ។ ឧទាហរណ៍ជាតួយ៉ាងមួយគឺ របស់ធ្វើពីដីដុតសំរាប់ប្រើប្រាស់ក្នុងផ្ទះ និងកីតំបាញអំបោះ ។ ផលិតផលក្នុងស្រុកទាំងនេះមួយចំនួនអាចប្រឈមនឹងការប្រកួតប្រជែងយ៉ាងខ្លាំងពីផលិតផលធ្វើពីប្លាស្ទិក/លោហធាតុ និងក្រណាត់នាំចូល, ហើយនៅចុងបញ្ចប់អាចនឹងចាញ់គេ ។ ចំពោះផលិតផលបែបនេះ គេត្រូវធ្វើផែនការដើម្បីធ្វើអន្តរកាលយ៉ាងរលូនល្អទៅធ្វើផលិតផល ឬដំណើរការមួយផ្សេងទៀត (ឬក៏កែលំអដំណើរការ) ។

នៅក្នុងប្រទេសមួយចំនួន គេបង្កើតក្រុមហ៊ុនម៉ាឃីទិងសំរាប់សកម្មភាពអាជីវកម្មជនបទ ដើម្បីលក់ចេញទៅទីផ្សារនូវផលិតផលនានាដូចជា របស់សិប្បកម្ម គ្រឿងសូត្រធ្វើតាមការបញ្ជាទិញ និងវត្ថុសិល្បៈផ្សេងៗ ។ ដូច្នេះត្រូវមានការស្រាវជ្រាវពីលក្ខណៈអាចធ្វើបានខាងសេដ្ឋកិច្ចនៃវិធីសាស្ត្របែបនេះនៅកម្ពុជា ។ ប៉ុន្តែវិធីសាស្ត្រនេះត្រូវតែអាចរស់ដោយខ្លួនឯងបានក្នុងរយៈពេលមួយដ៏សមគួរ បើមិនដូច្នោះទេវាច្បាស់ជាគ្មានអនាគតទេ ។

ការធ្វើស្តង់ដាផលិតផល ការត្រួតពិនិត្យគុណភាព និងការវេចខ្ចប់ គឺជាសមាសភាគមួយយ៉ាងសំខាន់នៃម៉ាឃីទិង ។

---

[៥០] ឯកសារយោងដ៏មានប្រយោជន៍គឺមាន កំណត់ហេតុនៃកិច្ចប្រជុំអ្នកផ្តល់ជំនួយស្តីពីធនធានធម្មជាតិ និងរបាយការណ៍នានារៀបចំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, គណៈកម្មាធិការទន្លេមេគង្គ, និងទីភ្នាក់ងារផ្តល់ជំនួយពហុភាគី និងទ្វេភាគីជាច្រើនទៀត ។

ប្រទេសមួយចំនួនបានបង្កើតស្ថាប័នផ្សេងៗដើម្បីជួយធ្វើស្តង់ដាផលិតផល និងដើម្បីជួយបញ្ជាក់គុណភាពផលិតផលដោយយកកំរៃ ។ ដូចគ្នាដែរ ការវេចខ្ចប់បានក្លាយជាឧស្សាហកម្មមួយដោយឡែក ហើយស្ថាប័នឯកទេសត្រូវបានបង្កើតឡើងដើម្បីច្នៃបង្កើតវិធីសាស្ត្រវេចខ្ចប់ថ្មីៗទៀត ។ បញ្ហាថា តើវិធីសាស្ត្របែបនេះអាចសមស្របសំរាប់កម្ពុជាបានប៉ុណ្ណា វាទាមទារនូវការស្រាវជ្រាវជាអាទិភាពមួយផ្សេងទៀត[៥១] ។

## ៨.៣ បច្ចេកវិទ្យា និងធនធានមនុស្ស

ហេតុការណ៍ និងអនុសាសន៍មួយចំនួន ទាក់ទិននឹងការបង្កើនគុណភាពធនមនុស្ស និងការផ្ទេរបច្ចេកវិទ្យាទៅឱ្យសហគ្រាសជនបទ មានបង្ហាញជូនដូចខាងក្រោម៖

១) សព្វថ្ងៃមានកង្វះខាតបុគ្គលិកដែលមានការអប់រំកំរិតមូលដ្ឋានយ៉ាងល្អ ។ ដូច្នេះមានបុគ្គលិកតិចនាក់ណាស់ដែលអាចយកទៅបណ្តុះបណ្តាលដោយផ្ទាល់នៅក្នុង សកម្មភាពនានាដែលស៊ីគ្នានឹងការទាមទារផ្សេងៗ ខាងបច្ចេកទេស និងសំរាប់មុខអាជីវកម្មដ៏ជាក់លាក់ ។

២) បច្ចុប្បន្ននេះ មានកង្វះបុគ្គលិកអ្នកមានជំនាញបច្ចេកទេសវិជ្ជាជីវៈកំរិតមធ្យម ។ សាលាបច្ចេកវិទ្យានានា (ជាពិសេសបើសិនគេដាក់ពង្រាយវាពាសពេញប្រទេស) ដែលអាចជួយផ្តល់ជំនាញទាំងនេះ (ក្រោយពេលសិក្ខាកាមបានសិក្សាចំណេះទូទៅអស់រយៈ ៨ឆ្នាំ ឬច្រើនជាងនេះ) នឹងអាចជួយបំពេញកង្វះខាតនេះបានយ៉ាងច្រើន ។

៣) គំនិតវៃឆ្លាតខាងជំនួញមានតិចនាក់ណាស់ ហើយជួនកាលមានតែក្នុងក្រុមជនជាតិខ្លះៗដោយសារហេតុផលខាងប្រវត្តិសាស្ត្រ ។ បញ្ហានេះក៏មានជាធម្មតាដែរនៅក្នុងប្រទេសដទៃ ប៉ុន្តែគេត្រូវតែខិតខំដោះស្រាយ ។ ទាំងនៅសាលាជំនួញពេញម៉ោង និងពាក់កណ្តាលអាជីព ដែលបង្រៀននូវគន្លឹះពី សហគ្រិនភាព ហិរញ្ញវត្ថុ និង ទិដ្ឋភាពពិសេសៗនៃការគ្រប់គ្រងបច្ចេកវិទ្យា អាចមានប្រយោជន៍ក្នុងការបំពេញកង្វះខាតនៃចំណេះដឹងផ្នែកជំនួញ ។ ចំពោះអ្នកមិនសូវធូរធារនៅជនបទ NGOs មួយចំនួនបានបញ្ចូលទស្សនៈថ្មីមួយហៅថា "ក្រុមសហគ្រិន" (Bogart and Das 1989) ។ វិធីសាស្ត្របែបនេះ គួរពិនិត្យឱ្យបានល្អិតល្អន់នៅក្នុងបរិបទប្រទេសកម្ពុជា ។

៤) បណ្តុះបណ្តាលមានតំលៃខ្ពស់នៅកម្ពុជា ជាចំណុចមួយគួរព្រួយបារម្ភ ។ លើកលែងតែមានការផ្តល់ឧបត្ថម្ភធនសំរាប់ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ប្រព័ន្ធនេះនឹងច្រានចេញនូវប្រជាជនភាគច្រើនលើសលុបដែលពុំមានលទ្ធភាពបង់ប្រាក់ ។ ក្នុងនេះការជួយទ្រទ្រង់របស់រដ្ឋមានសារៈសំខាន់ជាសារវន្ត គឺ ឬមួយដោយផ្តល់ការបណ្តុះបណ្តាលមានតំលៃថោក ឬមួយដោយផ្តល់អាហារូបករណ៍យ៉ាងធូរទូលាយ ហើយជារឿយៗគេត្រូវធ្វើទាំងពីរមុខនេះ ។ មេរៀនបានពីបណ្តាប្រទេសមានចំណូលទាប ប៉ុន្តែមានកំរិតអក្ខរកម្មខ្ពស់ ដូចជា ស៊ីរីលង្កា ចិន និង វៀតណាម ក៏អាចមានប្រយោជន៍ដែរ ។ ការបណ្តុះបណ្តាលមានតំលៃទាប ក្នុងនេះមានទាំងការបណ្តុះបណ្តាលផ្អែកលើសហគមន៍ផង ក៏អាចផ្តល់ចំណេះដឹងល្អដែរ (World Bank 1994; ILO 1994) ។

៥) ការផ្ទេរបច្ចេកវិទ្យា មានសារៈសំខាន់បំផុតដើម្បីបង្កើតមូលដ្ឋានបច្ចេកវិទ្យាដ៏ល្អមួយ ។ សព្វថ្ងៃពុំទាន់មានរូបមន្ត

[៥១] ឧទាហរណ៍ដ៏ល្បីមួយនៃការធ្វើស្តង់ដាផលិតផល ការត្រួតពិនិត្យគុណភាព និងការពង្រីកម៉ាកយីហោ គឺករណី ក្រុមផ្កាំង Delft ។ ក្នុងសតវត្សរ៍ទី១៩ នៅពេលមានការប្រកួតប្រជែងខ្លាំងពីផលិតផលព័រស៊ីឡែនចិន, សិប្បករជាតិហូឡង់ បានធ្វើការខ្លាំងណាស់ដើម្បីឈានដល់កំរិតស្តង់ដាមួយខ្ពស់ជាង និងពង្រីកម៉ាកយីហោរបស់ខ្លួនផ្ទាល់ ។ ពួកគេបានជោគជ័យក្នុងការធ្វើឱ្យអ្នកផងមើលឃើញថា ផលិតផលរបស់ពួកគេមានគុណភាពល្អជាងផលិតផលចិន ។ សព្វថ្ងៃនេះ ក្រុមផ្កាំង Delft គឺជាឧស្សាហកម្មមួយ ដែលផលិតព័រស៊ីឡែនដ៏ល្អៗបំផុតក្នុងពិភពលោក ។

ឯកភាពគ្នាតែមួយដើម្បីសំរេចរឿងនេះទេ ប៉ុន្តែវិធីសាស្ត្រនមួយដែលអាចប្រើបានគឺ ការបង្កើតឡើងនូវអង្គការបីភាគី (និយោជក ពលករ និងរដ្ឋាភិបាល) ក្រោមការគ្រប់គ្រងរួមពីសំណាក់ អង្គការផលិតភាពអាស៊ី (Asian Productivity Organisation: APO) ដែលមានទីតាំងនៅក្រុងតូក្យូ ។ ប្រទេសជាច្រើននៅអាស៊ី គេមាន ក្រុមប្រឹក្សាផលិតភាពជាតិ ដែលចែករំលែក និងផ្សព្វផ្សាយបច្ចេកវិទ្យានៅកំរិតជាតិ ក៏ដូចជានៅកំរិតអន្តរជាតិតាមរយៈពិធីសារផ្ទេរ ។ ប្រទេសមួយចំនួនក៏មានផងដែរនូវ សាខាផ្សេងៗដែលមានជំនាញឯកទេសក្នុងការដោះស្រាយបញ្ហាជនបទ ។ គេគួរពិចារណាពីការបង្កើតក្រុមប្រឹក្សាជាតិមួយនៅកម្ពុជាដែរ ។

## ៨.៤ សេវាអភិវឌ្ឍន៍អាជីវកម្ម និងការពង្រឹងផ្នែកផ្គត់ផ្គង់

គ្រប់អាជីវកម្មទាមទារនូវសេវាគាំទ្រដែលអាចជាប់ទាក់ទិននឹង ហិរញ្ញវត្ថុ ទីផ្សារ ធាតុចូល បច្ចេកវិទ្យា តំលៃ និង បញ្ហាផ្សេងៗជាច្រើនទៀត ។ នៅក្នុងបណ្តាប្រទេសឧស្សាហកម្មទំនើប សេវាបែបនេះអាចរកបាន នៅក្នុងមហាវិទ្យាល័យ ទស្សនាវដ្តីវិជ្ជាជីវៈ និង អ៊ិនធឺណិត, និងតាមរយៈទីភ្នាក់ងារប្រឹក្សាយោបល់មួយចំនួន ។ សេវាខ្លះត្រូវបង់ថ្លៃ ប៉ុន្តែសេវាជាច្រើនផ្តល់ឱ្យដោយមិនគិតថ្លៃ ។ សំរាប់ប្រទេសជាច្រើនដែលមិនសូវអភិវឌ្ឍន៍ខ្លាំង គេត្រូវបង្កើតបរិយាកាសអាជីវកម្មមួយក្នុងដំណាក់កាលដំបូង (ដោយមានជំនួយពីក្រៅបើសិនមានការចាំបាច់) ទើបទីផ្សារអាចចាប់ផ្តើមផ្តល់សេវាអាជីវកម្មបាន ។ ដូច្នេះ ការពង្រឹងផ្នែកផ្គត់ផ្គង់ គឺជាវិធានការដ៏សំខាន់មួយខាងគោលនយោបាយ[៥២] ។ ក្នុងនេះមានវិធីសាស្ត្រមួយ គឺការបង្កើត សេវាអភិវឌ្ឍន៍អាជីវកម្ម (Business Development Services: BDS) ។

BDS រួមមាន ការបណ្តុះបណ្តាល, សេវាកម្មទីប្រឹក្សានិងផ្តល់យោបល់, ជំនួយម៉ាឃីទិង, ពត៌មាន, ការផ្ទេរនិងអភិវឌ្ឍន៍បច្ចេកវិទ្យា, ការលើកកំពស់ទំនាក់ទំនងអាជីវកម្ម ។ BDS អាចជួយទាំងក្នុងកិច្ចប្រតិបត្តិការ និងក្នុងយុទ្ធសាស្ត្រ ។ សេវាកម្មជួយដល់ប្រតិបត្តិការត្រូវបានផ្តល់លើមូលដ្ឋានប្រចាំថ្ងៃ, រីឯសេវាកម្មជាយុទ្ធសាស្ត្រ គេត្រូវការសំរាប់សំរាប់ការពង្រីក និងការធ្វើផែនការអាជីវកម្មជំនួញរយៈពេលមធ្យម និងវែង ។ BDS អាចជាសេវាកម្មមួយដ៏ជាក់លាក់ ឬក៏ជា សេវាកម្មមួយក្រុម, ហើយការសំរេចថាធ្វើត្រូវយ៉ាងណាៗវាជាប់ទាក់ទងនឹងទីផ្សារដែលគេត្រូវបំរើ (ILO 2001) ។

តួអង្គផ្សេងៗនៅក្នុង BDS គឺ សហគ្រាសឯកជន (អតិថិជន), អ្នកជួយសំរួល (អ្នកពិគ្រោះយោបល់, ទីប្រឹក្សាខាងគោលនយោបាយ), អ្នកផ្តល់ (អ្នកបញ្ជោក់ផលិតផល, អ្នកផ្គត់ផ្គង់បច្ចេកវិទ្យា, អ្នកដោះស្រាយបញ្ហា, អ្នកបណ្តុះបណ្តាល), អ្នកផ្តល់ជំនួយ និងរដ្ឋាភិបាល ។ ទំនាក់ទំនងរវាងទីភ្នាក់ងារផ្សេងៗ មានលំនាំដូចខាងក្រោមៈ




[៥២] ការពង្រឹងផ្នែកផ្គត់ផ្គង់ មិនមែនជាគោលនយោបាយប្រឆាំងនឹងទីផ្សារទេ ។ រដ្ឋាភិបាលសហរដ្ឋអាមេរិក ក៏បានអនុវត្តគោលនយោបាយនេះដែរ ក្នុងទំរង់ប្លែកគ្នាមួយកាលពីទសវត្សរ៍១៩៨០ ។

អតិថិជនរកសេវាកម្មតាមតំរូវការ និងកំរិតថ្លៃ, អ្នកផ្តល់គឺជាទីភ្នាក់ងារឯកជនដែលដើរតាមតំរូវការសំរាប់ការងារ និងដែលធ្វើការដើម្បីរកចំណេញ, ចំណែកឯអ្នកផ្តល់ជំនួយ NGOs ឬរដ្ឋាភិបាល ជួយទ្រទ្រង់ដល់អ្នកជួយសំរួលនៅក្នុងដំណាក់កាលអភិវឌ្ឍន៍ដំបូង ប៉ុន្តែនៅទីបំផុតអ្នកជួយសំរួលក៏ដើរតាមទីផ្សារដែរ ។ ជួនកាល ធនាគារបានបំពេញតួនាទីជាអ្នកជួយសំរួល ។ នៅប្រទេសមួយចំនួន ធនាគារពិសេស១ហៅថា "ធនាគារអភិវឌ្ឍន៍" បានទទួលរ៉ាប់រងការងារផ្តល់សេវាទាំងនេះ។ ឯកសាររបស់ធនាគារពិភពលោក (២០០១) និង ILO (២០០១) បានផ្តល់ឧទាហរណ៍ជាច្រើននៃ បែបផែនខុស១គ្នានៃ BDS ។

មានសេវាកម្មមួយចំនួនផ្សេងទៀត ដែលរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយអាចផ្តល់អោយ និងដែលមិនមែនជាការផ្តល់ដោយផ្ទាល់នូវឧបត្ថម្ភធន ឬសម្បទានជាសាច់ប្រាក់ ។ សេវាទាំងនេះមានជាអាទិ ការបណ្តុះបណ្តាល (នៅក្នុងប្រទេស ឬនៅបរទេស) ការបង្កើតឧទ្យានឧស្សាហកម្ម ឬឧទ្យានបច្ចេកទេសវិទ្យា, និងការកសាងសំភារៈផ្តល់ការងាយស្រួល (គ្រឿងបង្អកធំ១ សំរាប់អ្នកនេសាទតូច១) ឬក៏ មជ្ឈមណ្ឌលច្នៃម៉ូដរួម (សំរាប់ឧស្សាហកម្មកាត់ដេរតូច១) ។ ជំនួយក៏អាចផ្តល់ដើម្បីជួយរៀបចំសមាគមអាជីវកម្មផ្សេង១ផងដែរ ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ការផ្តល់សេវាក្រោម "ហេតុផលជួយឧស្សាហកម្មក្មេងខ្ចី" គឺជាសកម្មភាពពេញច្បាប់បំផុត ។ ប៉ុន្តែគេត្រូវចៀសវាងកុំឱ្យ BDS ក្លាយទៅស្ថាប័នដើរតាមការផ្គត់ផ្គង់ ។

## ៨.៥ ហិរញ្ញវត្ថុ

ឯកសារផ្សេង១ ព្រមទាំងការចុះសិក្សាដល់កន្លែងក្នុងការសិក្សានេះ បានផ្តល់គំនិតថា ប្រជាជនកម្ពុជាធ្វើអាជីវកម្មដោយប្រើប្រាក់សន្សំរបស់ខ្លួនផ្ទាល់ និងខ្ចីបុលពីសាច់ញាតិ និងមិត្តភ័ក្តិ ហើយរបៀបរបបនេះត្រូវតែផ្លាស់ប្តូរចេញ ។ ប៉ុន្តែដើម្បីពង្រឹងស្ថាប័នផ្តល់កំចី លក្ខខណ្ឌមួយចំនួនត្រូវបំពេញឱ្យបានជាមុន ។

១) តម្លាភាព និងពត៌មានទីផ្សារ ទាមទារឱ្យមានស្ថាប័នគាំទ្រអាជីវកម្ម (គឺ អាជ្ញាធរធានារ៉ាប់រងឯករាជ្យ, សវនកម្មកំណត់ដោយច្បាប់, សហគ្រាសពិគ្រោះច្បាប់អាជីវកម្ម, និងទីភ្នាក់ងារវាយតំលៃលទ្ធភាពសងបំណុលរបស់សហគ្រាស) ដែលមជ្ឈដ្ឋានអន្តរជាតិគេគោរព និងទទួលស្គាល់ ។ កម្ពុជាមានការខ្វះខាតលើចំណុចទាំងនេះមួយភាគធំ ហើយតាមឯកសារដែលមានស្រាប់គេមិនដឹងច្បាស់ទេថា តើចំណុចនិមួយ១បានទទួលការយកចិត្តទុកដាក់ហើយឬនៅ ។ ស្ថាប័នទាំងនេះមិនមែនសុទ្ធតែកើតឡើងតាមគំនិតផ្តួចផ្តើមរបស់វិស័យឯកជនទាំងអស់ទេ ។ តាមពិត ការឧបត្ថម្ភគាំទ្រយ៉ាងច្រើនពីរដ្ឋ និងភាពជាដៃគូជាមួយរដ្ឋាភិបាល វាមានសារៈសំខាន់បំផុតសំរាប់ការបង្កើតស្ថាប័នទាំងនេះ ។

២) ធនាគារនៅកម្ពុជា មានលក្ខណៈប្រហាក់ប្រហែលគ្នានឹងធនាគារទូទៅក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ដែរ គឺមានការិយាល័យកណ្តាលមួយ (ជារឿយ១មានតែការិយាល័យនេះមួយគត់) នៅក្នុងរដ្ឋធានី, ធ្វើប្រតិបត្តិការលើទឹកប្រាក់ធំ១, និងធ្វើអាជីវកម្មក្នុងបរិស្ថានមានហានិភ័យទាប ។ តាមពិត និយមន័យនៃហានិភ័យ មិនដែលបានកំណត់ជាផ្លូវការទេនៅកម្ពុជា ហើយចំណុចនេះត្រូវមានការស្រាវជ្រាវថែមទៀត ។ ឯសំនួរផ្សេង១ទៀតដូចជា តើតំរូវការឥណទានមានទំហំប៉ុណ្ណា សំរាប់ សហគ្រាសជនបទ, ប្រពន្ធទីផ្សាររាលក់រាយនៅជនបទ, សហគ្រាសអាជីវកម្មវិមជ្ឈការ និងពាណិជ្ជកម្ម, តើតំរូវការឥណទានមានលក្ខណៈរដូវកាលយ៉ាងដូចម្តេច, តើអ្នកខ្ចីបុលមានសមត្ថភាពសងវិញប៉ុណ្ណា, គឺនៅមិនទាន់មានចម្លើយច្បាស់លាស់ទេ ។ ពិតហើយ ផ្នែកផ្គត់ផ្គង់នៃប្រព័ន្ធហិរញ្ញវត្ថុ ត្រូវមានការគាំទ្រយ៉ាងច្រើនខាងគោលនយោបាយ ។

៣) ថ្វីបើករណីសិក្សានានាក្នុងការសិក្សានេះ មិនបានឆ្លុះបញ្ចាំងច្បាស់ក៏ដោយ ប៉ុន្តែគេដឹងថា សកម្មភាពសេដ្ឋកិច្ចមួយ

ចំនួនធំបានទទួលឥណទាន ដោយបង់អត្រាការប្រាក់ ៦០-១២០%/ឆ្នាំ ។ នេះជាភស្តុតាងបញ្ជាក់ថា ស្ថាប័នឥណទានអាចរកស៊ីបានចំណេញជាមួយប្រជាជនក្នុងចំនួនច្រើនជាងក្នុងពេលសព្វថ្ងៃទៅទៀត ។ សព្វថ្ងៃនេះធនាគារមិនទាន់មានជំនាញ ឬបទពិសោធន៍ ដើម្បីធ្វើការចរចាឱ្យបានសក្តិសិទ្ធិជាមួយសហគ្រាសប្រភេទ "តូច" ឬវិមជ្ឈការទេ ។ ធនាគារមានពិសោធន៍ដើម្បីចាត់ចែងកំចីធំៗ ជាមួយអតិថិជនមួយចំនួនតូច ប៉ុន្តែមិនមែនជាមួយអតិថិជនមួយចំនួនធំ ដែលចង់បានកំចីតូចៗនោះទេ ។ ក្នុងការចាត់ចែងជាមួយអតិថិជនតូចៗ បន្ទុកចំណាយប្រតិបត្តិការរបស់ធនាគារតែងតែកើនឡើង ដូច្នេះហើយធនាគារក៏បានចៀសវាងប្រតិបត្តិការបែបនេះ ។ ដើម្បីធ្វើប្រតិបត្តិការធនាគារជាមួយអ្នកខ្ចីធុនតូច និងវិមជ្ឈការ គេត្រូវប្រើវិធីសាស្ត្រមួយផ្សេងទៀត ហើយរបៀបគ្រប់គ្រងបែបនេះមិនទាន់មានប្រជាប្រិយភាពទេ ប៉ុន្តែគេត្រូវការវានៅកម្ពុជា ។

៤) ចំពោះអាជីវកម្មតូចៗខ្លាំងពេក បទពិសោធថ្មីៗក្នុងប្រទេសកំពុងអភិវឌ្ឍន៏ឯទៀតៗបង្ហាញថា ប្រតិបត្តិករតែងៗដែលតូចខ្លាំងណាស់អាចបំពេញលក្ខខណ្ឌខ្ចីឥណទានមិនបានមែន ប៉ុន្តែបើសិនគេរួមគ្នាជាក្រុម កិត្តនាម (លក្ខណៈគួរទុកចិត្តបាន) របស់ពួកគេនឹងកើនឡើង (Hulme and Mosley 1996; Tilakaratna 1996) ។ ក្រុមឥណទាន (ឬសមាគម) ដែលប្រមូលផ្តុំអ្នកខ្ចីតូចៗ ជារឿយៗតែងចាប់ផ្តើមដំណើរការជាក្រុមសន្សំប្រាក់ ហើយនៅពេលកិត្តិនាមជាអ្នកសន្សំប្រាក់របស់ពួកគេបានរឹងប៉ឹងហើយ គេក៏អាចដាក់ពាក្យសុំខ្ចីប្រាក់ជាក្រុមបាន (គឺខ្ចីក្នុងចំនួនទឹកប្រាក់ដែលធនាគារអាចគ្រប់គ្រងបានដោយមានបន្ទុកចំណាយទាប) ហើយបែងចែកប្រាក់នោះនៅក្នុងក្រុមទៅតាមតំរូវការរបស់សមាជិកម្នាក់ៗ (ADB 1998) ។ កំចីនេះពុំមានសម្បទានលើអត្រាការប្រាក់ ឬរយៈពេលសងទេៈ អត្រាការប្រាក់ អាចស្មើគ្នានឹងអត្រាការប្រាក់លើអតិថិជនល្អបំផុត ឬក៏អាចខ្ពស់ជាងផង ។ ក្នុងប្រទេសជាច្រើនវិធីសាស្ត្រនេះកាន់តែពេញនិយមហើយ ដោយសារអត្រាសងប្រាក់វិញជាទូទៅ មានកំរិត ៩០% ឬខ្ពស់ជាងទៀត ។ ដើម្បីធ្វើឱ្យប្រព័ន្ធបែបនេះអាចដំណើរការក្នុងទូទាំងប្រទេស គេត្រូវមានការរៀបចំ និងបទប្បញ្ញត្តិ ។ ការពង្រឹង រដ្ឋបាលមូលដ្ឋាន (ក្នុងករណីនេះគឺ ក្រុមប្រឹក្សាឃុំ ដែលអាចដើរតួជាអាជ្ញាធររៀបចំបទប្បញ្ញត្តិ) ក៏ដូចជាសមាគម អាជីវកម្មផ្សេងៗ អាចជាជំហានមួយនៅក្នុងទិសដៅនេះ ។ លក្ខខណ្ឌដែលត្រូវបំពេញឱ្យបានជាមុនមួយទៀត គឺ ការបណ្តុះបណ្តាល និង គំនិតផ្តួចផ្តើមថ្មីយ៉ាងច្រើននៅក្នុងគោលដៅនេះ ។ ហើយបញ្ហាប្រឈមដ៏ចំបងមួយគឺ ការផ្ទេរមូលនិធិពីវិស័យធនាគាររៀបរយទៅខាងស្ថាប័នមីក្រូហិរញ្ញវត្ថុ គ្រឹះស្ថានធនាគារវិមជ្ឈការប្រហាក់ ប្រហែល ។ ការកសាងធនាគារអភិវឌ្ឍន៏ជនបទ គឺជាជំហានមួយនៅក្នុងទិដៅនេះ ប៉ុន្តែនៅមានការងារច្រើន ទៀតដែលត្រូវធ្វើ[៥៣] ។

[៥៣] មានការពិភាក្សាមួយចំនួនលើបញ្ហានេះជាមួយនឹងការអភិវឌ្ឍន៏ធនាគារ ដោយសារពួកគេបានប្រមូលផ្តុំជាក្រុមធំដែលមិនមាន ទ្រព្យនៅក្នុងប្រទេសមួយចំនួន ។ ទោះជាយ៉ាងណាក៏ដោយ បញ្ញត្តិមិនគួរបដិសេធទេ ។

# ឯកសារយោង


Acharya, Sarthi (2001), Poverty Reduction in Cambodia — Some Reflections *Cambodia Development Review*, Vol. 5, Issue 2 (Phnom Penh: Cambodia Development Resource Institute)

Acharya, Sarthi (2001), Private Sector in Cambodia — Glimpses from Case Studies, *Cambodia Development Review*, Volume 6, Issue 3 (Phnom Penh: Cambodia Development Resource Institute)

Acharya, Sarthi & Chan Sophal (2001), “Water and Other Natural Resources in Cambodia — An Explanation of the Present State of Development” Paper presented at the International Water History Association Conference, Bergen, Norway, 10–12 August 2001

Acharya, Sarthi & A. Mitra (2000), *The Potential of Rural Industries and Trade to Provide Decent Work Conditions* (New Delhi: ILO-SAAT, 2000) Working Paper

ADB (1998), *Report on Micro Credit* (Manila: Asian Development Bank)

Bogart, M.V.D. & S.P. Das (1989), *Group Entrepreneurship within the Rural Poor* (New Delhi: Indian Social Institute)

Chan Sophal & Sarthi Acharya (2002), *Facing the Challenge of Rural Livelihoods: A Perspective from Nine Villages in Cambodia* (Phnom Penh: Cambodia Development Resource Institute) Working Paper 25

Chandler, David (1983), *A History of Cambodia* (Boulder: Westview Press)

Corts, Louise & Leedom Lefferts (2000), "Khmer earthenware in Mainland Southeast Asia: An approach through production" *Udaya, Journal of Khmer Studies.* Issue no. 1 (The APSARA Autority, Cambodia)

De Carne, L. (2000), *Travels on the Mekong – Cambodia, Laos and Vietnam* (Bangkok: White Lotus, first published in 1872)

Entrepreneurship Development of Cambodia (2001), Rice Milling Enterprise Survey and Credit Study — Kandal, Takeo, Prey Veng and Svay Rieng (Phnom Penh)

Entrepreneurship Development of Cambodia (2001b), Survey of 45 Cambodian Rural Electrification Enterprises (Phnom Penh)

Entrepreneurship Development of Cambodia (2001c), Cambodia Rural Electricity Enterprise – Final Report (Phnom Penh)

Entrepreneurship Development of Cambodia (2002), Cambodia Fisheries Sector Information Design Initiative, Final Report Prepared for UN-ESCAP (Phnom Penh)

EMT (Ennatier Moulethan Tchonnebat) (2001), Annual Report (Phnom Penh)

Hulme, D. & P. Mosley (eds.) (1996), *Finance Against Poverty* (London: Routledge)

ILO, “Community Based Training for Employment and Income Generation” (Geneva: from H. C. Haan, 1994, International Labour Organisation Vocational Training Systems Management Branch)

ILO (1999), Decent Work — Report of the Director General (Geneva: International Labour Organisation)

ILO (2000), A Report on the National Workshop on the Strategic Approaches to Job Creation in the Urban Informal Sector (International Labour Organisation, Surajkund, Haryana, 17–19 February 2000)

Site: http://www.ilo.org/public/english/region/asro/newdelhi/

ILO (2001a), Report of the Expert Group Seminar on Rural Industrialisation (New Delhi: International Labour Organisation, SAAT)

ILO (2001b), Business Development Services for Small Enterprises, Site: http://oracle02.ilo.org/dyn/empent.Portal

Islam, R. (1983), "Off-farm Employment in the Development of Rural Asia: Issues and Evidence," Paper presented at the Workshop on Off-Farm Employment in the Development of Rural Asia (Bangkok: ILO-ARTEP)

Kang Chandararot (2002), The Development of Micro Finance in Cambodia, *Cambodia Development Review*, Vol. 6, Issue 3 (Phnom Penh: Cambodia Development Resource Institute)

Kingdom of Cambodia (1958), *Progress Made in Cambodia* (Phnom Penh)

Kingdom of Cambodia (1960), *Premier Plan Quinquennal Preah Norodom Sihanouk (1960–64),* (Phnom Penh)

McKenney, Bruce & Prom Tola (2002), *Natural Resources and Rural Livelihoods in Cambodia: A Baseline Assessment* (Phnom Penh: Cambodia Development Resource Institute) Working Paper No. 23

Mekong Project Development Facility (2001), *Annual Report* (Phnom Penh)

Mekong Project Development Facility (2002), *Cambodia Country Report – Report of Operations 2001 and Action Plan 2002* (Phnom Penh)

Mouhot, H. (2000), *Travels in Siam, Cambodia, Laos and Annam* (Bangkok: White Lotus, first published in 1865)

Murshid, K.A.S. (1998), *Food Security in an Asian Transitional Economy – The Cambodian Experience* (Phnom Penh: Cambodia Development Resource Institute) Working Paper 6

Pelillot, L. (1911), *Le Pêche et Les Poissons, Une Richesse du Cambodge*, (Paris: Librairie Maritime et Coloniale)

Rooney, D.F. (2000), *Angkor – An Introduction to the Temples* (Hong Kong: Odyssey Publications)

Royal Government of Cambodia (1999), *Census of Cambodia 1998* (Phnom Penh: National Institute of Statistics, Ministry of Planning)

Royal Government of Cambodia (1997), *Brick Factories in Cambodia* (Phnom Penh: Ministry of Industry, Mining and Energy)

Rozemuller, H.B. (1998), *Overview of Rice Millers' Associations in Northwest Cambodia* (Phnom Penh: Centre for Advanced Studies) Occasional Paper Series, No. 4

Rozemuller, H.B. (1998), *An Overview of Brick and Tile Manufacturing Industry in Western Cambodia* (Phnom Penh: Centre for Advanced Study) Occasional Paper Series, No. 5

Saith, A. (1992), *The Rural Non-Farm Economy: Processes and Policies* (Geneva: World Employment Programme, ILO)

Sok Hach & Sarthi Acharya (2002), *Cambodia's Annual Economic Review — 2002* (Phnom Penh: Cambodia Development Resource Institute)

Sok Hach, Chea Huot & Sik Boreak (2001), *Cambodia's Annual Economic Review — 2001* (Phnom Penh: Cambodia Development Resource Institute)

Tarling, N. (1999) (ed.), *Cambridge History of Southeast Asia*, Vol. 2, Part 1 (Cambridge: The University Press)

Tilakaratna, S. (1996), *Credit Schemes for the Poor: Some Conclusions and Lessons from Practice* (Geneva: Development and Technical Co-operation Department, ILO) Issues and Development Discussion Paper 9

Tin, T. (2000), Methods of Making Ka-Am and Chhnang by the Residents of Andong Russey, *Bulletin of the Students of the Department of Archaeology* (Phnom Penh: Royal University of Phnom Penh) No. 2, November

Van Zalinge, N., T. Nao, S. T. Touch, & L. Deap (2000), 'Where There is Water, There is Fish? Cambodian Fisheries Issues in a Mekong River Basin Perspective', in M. Ahmed and P. Hircsh (eds.), *Common Property in the Mekong: Issues of Sustainability and Sustenance* (Manila: ICLARM Study Review 26)

Victor-Pujebet, B. & A. Peyre, (2001), *Options for Establishing a Full Production and Marketing Chain for Silk Products in Southern Cambodia, Phase-II* (Phnom Penh: PRASAC)

Willmott, W. E. (1977), History and Sociology of the Chinese in Cambodia Prior to the French Protectorate (*Journal of Southeast Asian Studies*) Vol. 7, No. 1

World Bank (1994), Vocational Training — A Sector Policy Paper (Washington DC: World Bank)

World Bank (2001), Private Sector Development: Entrepreneurship, Markets and Development — A Discussion Paper — SecM2001-0303, May 2001 (Washington DC: World Bank)

# បញ្ជីឯកសារពិភាក្សារបស់ វបសអ

១. Kannan, K. P. (វិច្ឆិកា ១៩៩៥) *ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សំរាប់ប្រទេសកម្ពុជា: ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលំអ* (ឯកសារពិភាក្សាលេខ ១) ច្បាប់ដែលបានបោះពុម្ពផ្សាយ ហើយផ្សព្វផ្សាយអស់ ។

២. McAndrew, John P. (មករា ១៩៩៦) *ជំនួយហូរចូលជំនួយស្រពិចស្រពិល: ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ទ្វេ និង ពហុភាគី ១៩៩២-៩៥* (ឯកសារពិភាក្សាលេខ ២) ច្បាប់ដែលបានបោះពុម្ព ហើយផ្សព្វផ្សាយអស់ ។

៣. Kannan, K. P. (មករា ១៩៩៧) *ការកែទំរង់សេដ្ឋកិច្ច ការកែតម្រូវរចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៣) ច្បាប់ដែលបានបោះពុម្ពផ្សាយ ហើយផ្សព្វផ្សាយអស់ ។

៤. ជីម-ចរិយា ស្រ៊ុន-ពិធូ សូ-សុវណ្ណារិទ្ធ ចន-ម៉ាកឃិនឌ្រូ ងួន-សុគន្ធា ប៊ុន-ដូរីណា និងរ៉ូប៊ីន-ប៊ិដឹលវី (មិថុនា ១៩៩៨) *ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៤) ជាភាសាខ្មែរតំលៃ ៩.000រៀល ។

៥. Toshiyasu-Kato ច័ន្ទ-សុផល និងឡុង-វ៉ូ-ពិសិដ្ឋ (កញ្ញា ១៩៩៨) *សមាហរណកម្មសេដ្ឋកិច្ចតំបន់សំរាប់ការអភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តំលៃ ៩.000រៀល ។

៦. Murshid, K. A. S. (ធ្នូ ១៩៩៨), *សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរៈអាស៊ី: បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៦) ជាភាសាខ្មែរតំលៃ ៧.៥00រៀល ។

៧. McAndrew, John P. (ធ្នូ ១៩៩៨) *ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិតគ្រួសារនៅក្នុងភូមិខ្មែរពីរ* (ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរតំលៃ ៧.៥00រៀល ។

៨. ច័ន្ទ-សុផល Martin-Godfrey, Toshiyasu-Kato ឡុង-វ៉ូ-ពិសិដ្ឋ Nina-Orlova, Per-Ronnås ទា-សាវ៉ា (មករា ១៩៩៩) *ប្រទេសកម្ពុជា: បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមានផលិតភាព* (ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរ តំលៃ ៦.000រៀល ។

៩. តេង-យូគី ប៊ុន-ដូរីណា សូ-សុវណ្ណារិទ្ធ និង ចន-ម៉ាកឃិនឌ្រូ (មេសា ១៩៩៩) *បទពិសោធន៍របស់សកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ* (ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរតំលៃ ៤.៥00រៀល ។

១0. Gorman, Siobhan, ជាមួយ ប៊ុន-ដូរីណា និង សុខ-ខេង (មិថុនា ១៩៩៩) *បញ្ហាតួនាទីបុរស-ស្ត្រី និងការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា: ការពិនិត្យមើលជាទូទៅ* (ឯកសារពិភាក្សាលេខ ១0) ជាភាសាខ្មែរតំលៃ ៤.៥00រៀល ។

១១. ច័ន្ទ-សុផល និង សូ-សុវណ្ណារិទ្ធ (មិថុនា ១៩៩៩) *ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃ ការប៉ាន់ស្មានជំហានដំបូង* (ឯកសារពិគ្រោះលេខ ១១) ជាភាសាខ្មែរ តំលៃ ៣.000រៀល ។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វ៉ូពិសិដ្ឋ ទា-សាវ៉ា សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គឹមហួន និងជា-វុធណា (តុលា ១៩៩៩) *ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្តាប្រទេសអាស៊ីអគ្នេយ៍: ទស្សនៈកម្ពុជា*

(ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១៣. អ៊ុង-ប៊ុនឡេង (សីហា ២០០០) *ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ១៣) ជាភាសាខ្មែរតំលៃ ៣.០០០រៀល ។

១៤. Toshiyasu-Kato Jeffrey A. Kaplan, ច័ន្ទ-សុផល និង រៀល-សុភាព (សីហា ២០០០) *ប្រទេសកម្ពុជា: លើកកំពស់អភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍មាននិរន្តរភាព*(ឯកសារពិភាក្សាលេខ ១៤) ជាភាសាខ្មែរ តំលៃ ៣.០០០រៀល ។

១៥. Toshiyasu Kato, ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២០០០) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយ: បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ១៥) ជាភាសាខ្មែរ តំលៃ ១០.០០០រៀល ។

១៦. ស៊ិក បូរ៉ាក្ស (ធ្នូ ២០០០) *កម្មសិទ្ធិ ការលក់ដូរ និងការប្រមូលផ្តុំដីធ្លីនៅកម្ពុជា: ការពិនិត្យវិភាគដោយត្រួសៗនូវទិន្នន័យទីពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន*(ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរតំលៃ ៨.០០០រៀល ។

១៧. ច័ន្ទ-សុផល សូ-សុវណ្ណារិទ្ធ និងប៊ុន-ដូរីណា (មិថុនា ២០០១) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅសាលាកសិកម្មព្រែកលៀប*(ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរ តំលៃ ៧.០០០រៀល ។

១៨. Martin Godfrey សូ-សុវណ្ណារិទ្ធ ទេព-សារ៉ាវី ប៊ុន-ដូរីណា Claude-Katz Sarthi-Acharya ស៊ីសុវត្ថិ-ឌួង-ចាន់តូ និង ហ៊ីង ថូរ៉ាក់ស៊ី (តុលា ២០០១) *ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជា: ការកាត់បន្ថយភាព ក្រីក្រ ការលូតលាស់ និងការកែតំរូវចំពោះវិបត្តិ*(ឯកសារពិភាក្សាលេខ ១៨) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

១៩. ច័ន្ទ-សុផល ទេព-សារ៉ាវី និង *Sarthi Acharya* (ខែធ្នូ ឆ្នាំ២០០១) *ការកាន់កាប់ដីនៅកម្ពុជា: ការវិភាគលើទិន្នន័យចុងក្រោយ* (ឯកសារពិភាក្សាលេខ ១៩) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២០. សូ សុវណ្ណារិទ្ធ រៀល សុភាព អ៊ុច ឧទេយ្យ ស៊ី វត្ថមុនី Brett Ballard និង Sarthi Acharya (ខែមីនា ឆ្នាំ២០០២) *ការវាយតំលៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២០) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២១. Bhargavi Ramamurthy ស៊ិក-បូរ៉ាក្ស Per Ronnås និង សុក-ហាច (ខែមីនា ឆ្នាំ២០០២) *ប្រទេសកម្ពុជា ឆ្នាំ១៩៩៩-២០០០: ការផ្តោតលើបញ្ហាដីធ្លី កំលាំងពលកម្ម និងការចិញ្ចឹមជីវិតនៅជនបទ* (ឯកសារ ពិភាក្សាលេខ ២១) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២២. ច័ន្ទ-សុផល និង Sarthi Acharya (ខែកក្កដា ឆ្នាំ២០០២) *ការលក់ដូរដីធ្លីនៅកម្ពុជា: ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូរដីធ្លី* (ឯកសារពិភាក្សាលេខ ២២) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២៣. Bruce McKenney និង ព្រុំ-តុលា (ខែកញ្ញា ឆ្នាំ២០០២) *ធនធានធម្មជាតិ និងជីវភាពនៅតាមជនបទក្នុងប្រទេសកម្ពុជា:* ការវាយតំលៃជាមូលដ្ឋាន (ឯកសារពិភាក្សាលេខ ២៣) ជាភាសាខ្មែរ តំលៃ ១០.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៤. ច័ន្ទ-សុផល គីម-សេតារា និង Sarthi Acharya (ខែធ្នូ ឆ្នាំ២០០២) *ដីធ្លី ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជា: ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៤) ជាភាសាខ្មែរតំលៃ ៦.០០០រៀល ជាអង់គ្លេស៧ដុល្លារ ។

២៥. ច័ន្ទ-សុផល និង Sarthi Acharya (ខែធ្នូ ឆ្នាំ២០០២) *បញ្ហាប្រឈមចំពោះការចិញ្ចឹមជីវិតនៅជនបទ* (ឯកសារពិភាក្សាលេខ២៥) ជាភាសាខ្មែរតំលៃ ៨.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

## ការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្ម: ទស្សនៈស្ដីពីការបង្កើតការងារ នៅកម្ពុជា

ឥលូវនេះ គេបានព្រមព្រៀងថាមានការរីកចំរើនមិនថា នៅក្នុងឧស្សាហកម្មទំនើបធំៗ ឬក៏វិស័យក្នុងវិស័យកសិកម្មតែឯងទេ វាអាច ឬនឹងអាចបំរើគោលបំណងនៃការបង្កើតការងារជនបទនៅក្នុងល្បឿនមួយដូចគ្នាដោយសារមានកំណើនតំរូវការការងារ ។ ទាក់ទងនឹងបញ្ហានេះ កំណើនដ៏គួរឱ្យចាប់អារម្មណ៏នៃឧស្សាហកម្មជនបទធុនតូច និងមធ្យមនៅជប៉ុន កូរ៉េខាងត្បូង និងតៃវ៉ាន់នាពេលកន្លងទៅ ហើយថ្មីៗនេះ នៅចិន បានបង្កើតនូវចំណាប់មួយដ៏ធំនៅក្នុងការលើកតំកើងសកម្មភាពក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្មនៅប្រទេសអាស៊ីជាច្រើនដទៃទៀត ។

ការសិក្សានេះកើតឡើងពីភាពចាំបាច់នៃការបង្កើតការងារផ្សេងៗឱ្យបានច្រើន និងចំរុះមុខ នៅក្នុងសេដ្ឋកិច្ចអន្តរកាលរបស់កម្ពុជា ដើម្បីកាត់បន្ថយ ភាពក្រីក្រ ភាពគ្មានការងារធ្វើ និង ភាពមានការងារមិនពេញលទ្ធភាព ។ នៅខែមីនា ២០០៣ បណ្ដាញវិភាគអភិវឌ្ឍន៏បានបោះពុម្ពឯកសារមួយស្ដីពីការសិក្សាតាមប្រទេសដែលមានចំណងជើងថា "ការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្មក្នុងសេដ្ឋកិច្ចអន្តរកាលនានានៅអាស៊ីអគ្នេយ៏ និងនៅប្រទេសថៃ" និងដែលមាន ជំពូកមួយស្ដីពីកម្ពុជា ហើយជំពូកនេះបានដកស្រង់យកមកចងក្រងជាឯកសារពិភាក្សានេះ ។

---

Sarthi Acharya ជាអតីតនាយកស្រាវជ្រាវនៅ វបសអ ហើយលោក គឹម សេតារា និងលោក ច័ន្ទ សុផល ជាអ្នកស្រាវជ្រាវនៅ វបសអ, ចាប សុថារិទ្ធ ជានាយករងនៅ CICP និងមាច យ៉ាឌី ជាទីប្រឹក្សានៅ CICP ។

បណ្ដាញវិភាគអភិវឌ្ឍន៏ រួមមាន វិទ្យាស្ថានបណ្ដុះបណ្ដាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា វិទ្យាស្ថានខ្មែរសំរាប់ប្រតិបត្តិការនិងសន្តិភាព នៅភ្នំពេញ វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចជាតិ និងមជ្ឈមណ្ឌលស្ថិតិជាតិនៅវៀងច័ន្ទ និងវិទ្យាស្ថានកណ្ដាលគ្រប់គ្រងសេដ្ឋកិច្ច និងវិទ្យាស្ថានសេដ្ឋកិច្ចនៅហាណូយ និងវិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៏ថៃ ។ ការងាររបស់បណ្ដាញវិភាគអភិវឌ្ឍន៏បានប្រព្រឹត្តទៅដោយមានការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពី IDRC, CANADA និងពីមូលនិធិ Rockefeller ។

៧.០០០រៀល

ផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា
អាសយដ្ឋានប្រៃសណីយ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥-២៣) ៨៨១-៧០១/៨៨១-៩១៦/៨៨៣-៦០៣ ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល: cdri@camnet.com.kh website: http://www.cdri.org.kh